ទស្សនាវដ្តីមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិង អ.ស.ប
- ប្រវត្តិសង្ខេបការសេចក្តីក្នុងកាវិច្ឆ

លេខ ៥៨ ខែតុលា ឆ្នាំ២០០៤

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៥៨ ខែតុលា ឆ្នាំ២០០៤

## មាតិកា

◆ សំបុត្រៈ កម្មវិធីមួយនៃ "គម្រោងឯកសាររស់" ..........................១

**ផ្ទៃព័ត៌ពិសេស**

◆ បទអន្តរាគមន៍របស់ឯកឧត្តម សុខ អាន ..................................៥

◆ ការពិភាក្សានិងអនុម័តកិច្ចព្រមព្រៀង ....................................១១

◆ ធ្វើនីតិកម្មនេះឲ្យទៅជាការពិត .............................................៦០

◆ ប្រជាជនកម្ពុជាត្រូវការសេចក្តីទុកចិត្ត ..............................ក្របក្នុង



**សាលបតុម្មុខៈ ទីតាំងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកាលពីឆ្នាំ១៩៧៩**



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

បន្ទាប់ពីអង្គសភាបិទសម័យប្រជុំនៅព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តល់បទសម្ភាសន៍ដល់អ្នកកាសែតនៅខាងមុខសាលប្រជុំសភា ។ ឆ្លើយតបទៅនឹងសំណួររបស់អ្នកកាសែតម្នាក់អំពីទិវាជាតិដើម្បីការចងចាំនិងយុត្តិធម៌ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា សម្តេចនឹងអនុញ្ញាតឲ្យមន្ត្រីរាជការនិងប្រជាពលរដ្ឋឈប់សម្រាកមួយថ្ងៃ នៅពេលដែលតុលាការបើកសវនាការកាត់ទោសនាថ្ងៃដំបូង ។ នៅថ្ងៃដែលតុលាការបើកសវនាការដំបូង អាចមានការផ្សាយបន្តផ្ទាល់តាមកញ្ចក់ទូរទស្សន៍ ដូច្នេះគួរឲ្យមន្ត្រីរាជការប្រជាពលរដ្ឋឈប់សម្រាកមួយថ្ងៃ ដើម្បីមានឱកាសរៀនសូត្រអំពីនីតិវិធីនៅក្នុងតុលាការ និងមើលដំណើរការកាត់ទោសផង ។

នេះជាការឆ្លើយតបទៅនឹងសំណើរបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានស្នើរាជរដ្ឋាភិបាលកម្ពុជាកាលពីខែកក្កដា ឆ្នាំ២០០៤ ឲ្យបង្កើតទិវាជាតិដើម្បីការចងចាំនិងយុត្តិធម៌ដែលនឹងប្រារព្ធឡើងនៅថ្ងៃទីមួយនៃដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោក ឆាំង យុ រំពឹងថា ទិវានេះនឹងអនុញ្ញាតឲ្យប្រជាពលរដ្ឋកម្ពុជាគោរពវិញ្ញាណក្ខន្ធសាច់ញាតិជាទីស្រលាញ់ទាំងឡាយដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម និងអនុញ្ញាតឲ្យអ្នកដែលនៅរស់ពីរបបខ្មែរក្រហមរំឭកអំពីជីវិតរបស់ខ្លួននៅក្នុងរបបនេះ ព្រមទាំងផ្លាស់ប្តូរបទពិសោធន៍ជាមួយអ្នកដទៃ ។ ព្រមជាមួយនេះ ប្រជាពលរដ្ឋអាចចូលរួមតាមដានដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមកញ្ចក់ទូរទស្សន៍ឬតាមវិទ្យុថែមទៀត ។ **ឆេព ម៉េងឃាន**

**អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា **អ្នកបកប្រែៈ** ដាត រចនា, ជី ទេវិទ្ធិ **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# កម្មវិធីមួយនៃ "គម្រោងឯកសាររស់" ដំណើរការមុនពេលមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

រដ្ឋសភាជាតិកម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និងសេចក្តីព្រាងច្បាប់ស្តីអំពីវិសោធនកម្មច្បាប់ច្បាប់ខ្មែរក្រហម នៅថ្ងៃទី៤-៥ ខែតុលា ឆ្នាំ២០០៤នេះ ។ បន្ទាប់ពីផ្តល់សច្ចាប័នលើច្បាប់នេះហើយ អាចមានរយៈពេលមួយតទៅមុខទៀតមុននឹងការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចចាប់ផ្តើមទៅបាន ។ នៅក្នុងអំឡុងពេលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែដំណើរការកម្មវិធីមួយដែលប្រតិបត្តិដោយមនុស្សបីក្រុមដែលមានសមាសភាពផ្សេងៗគ្នាក្នុងសង្គមគឺ ១) សហគមន៍ជនជាតិចាម ២) សមាគមដូនជី និង ៣) សមាគមនិស្សិត ។ គោលបំណងរបស់មជ្ឈមណ្ឌលក្នុងការបង្កើតកម្មវិធីនេះឡើងគឺជួយដល់ក្រុមទាំងបីក្នុងការផ្តល់ពត៌មានអំពីប្រវត្តិសាស្ត្រខ្មែរក្រហម អំពីដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងអំពីធនធានដែលមាន ដល់គ្រប់សហគមន៍ ហើយក្រុមទាំងបីនេះនឹងជួយនាំសាធារណជនមកកន្លែងជំនុំជម្រះក្តីនៅពេលសាលាក្តីចាប់ផ្តើមដំណើរការ ។ ជាងនេះទៅទៀត យើងនឹងធ្វើការជាមួយសហគមន៍ជនជាតិចាមនិងសមាគមដូនជី ដើម្បីចងក្រងឯកសារស្តីអំពីប្រវត្តិសាស្ត្រផ្ទាល់ខ្លួននៅក្នុងរបបខ្មែរក្រហម ។

កម្មវិធីនេះគឺជាផ្នែកមួយនៃ "គម្រោងឯកសាររស់" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលនឹងអនុវត្តពេញលេញនៅក្នុងពេលមានដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

## ១) សហគមន៍ជនជាតិចាម

ជនជាតិចាមគឺជាជនជាតិភាគតិចមួយនៅក្នុងប្រទេសកម្ពុជាដែលមានចំនួនច្រើនជាងជនជាតិភាគតិចដទៃទៀត ហើយជាសហគមន៍មួយដែលមានភាពសាមគ្គីគ្នាយ៉ាងស្អិតល្មួត ។ ដោយសារមានភ័ស្តុតាងមួយចំនួនបង្ហាញថា សហគមន៍នេះគឺជាមុខសញ្ញាដែលខ្មែរក្រហមធ្វើទារុណកម្ម ហើយអត្រាស្លាប់មានចំនួនខ្ពស់ជាងជនជាតិភាគតិចឯទៀតៗ ដូច្នេះសហគមន៍នេះអាចផ្តល់នូវភ័ស្តុតាងចាំបាច់នៅក្នុងសាលាក្តីខាងមុខនេះ ។

នៅក្នុងខែសីហាកន្លងមកនេះ យើងបានជួបជាមួយតំណាងសហគមន៍ជនជាតិចាមមកពីវិហារអ៊ីស្លាមចំនួន៣៦៩ទូទាំងប្រទេស ។ ហាកិម-តួនទាំងអស់ដែលបានសហការនៅក្នុងការប្រជុំ បានឯកភាពគ្នាចូលរួមនៅក្នុងគម្រោងការនេះ ។ យើងបានរៀបចំកម្រងសំណួរដែលមានពីរផ្នែកសម្រាប់សហគមន៍របស់គាត់ ។ ផ្នែកទី១សួរអំពីពត៌មានជាប្រវត្តិសាស្ត្ររបស់បុគ្គលនីមួយៗ និងអំពីប្រវត្តិសាស្ត្រភូមិឋានរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ ផ្នែកទី២នឹងប្រមូលពត៌មាននានាអំពីតម្រូវការបច្ចុប្បន្នរបស់សហគមន៍ដើម្បីជួយផ្តល់លទ្ធភាពដល់សមាជិកសហគមន៍នេះវិវត្តទៅមុខបានបន្ទាប់ពីសាលាក្តីបញ្ចប់ (ដូចជានៅពេលបច្ចុប្បន្ននេះ យើងកំពុងតែពិចារណាទៅលើការបង្កើតគេហទំព័រសម្រាប់សហគមន៍ជនជាតិចាម ដែលអាចផ្តល់ឱកាសឲ្យគាត់ទទួលបាន និងចែករំលែកពត៌មាននិងគំនិតយោបល់អំពីប្រវត្តិសាស្ត្ររបស់គាត់ អំពីសាលាក្តី និងអំពីមធ្យោបាយអភិវឌ្ឍន៍នានា ជាមួយមជ្ឈដ្ឋាននានាទាំងក្នុងនិងក្រៅប្រទេស) ។ យើងបានចែកចាយសំណួរនេះជូនគាត់នៅក្នុងការប្រជុំនៅតាមតំបន់ចំនួនបីលើកកាលពីខែតុលាថ្មីៗនេះ ។ នៅពេលនោះ យើងបានពិភាក្សាគ្នាយ៉ាងទូលំទូលាយ និងច្បាស់លាស់អំពីគម្រោងការនេះ ។

## ២) ដូនជី

បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ៧៥ ភាគរយនៃអ្នករស់ពីរបបនេះគឺជាស្ត្រី ហើយស្ត្រីទាំងនោះជាអ្នកជួយកសាងសង្គមកម្ពុជាឡើងវិញនៅក្នុងឆ្នាំ១៩៧៩ ។ បច្ចុប្បន្នដូនជីមួយភាគធំគឺជាស្ត្រីដែលរស់ពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូនជីជាច្រើនមានតួនាទីជាជនគំរូសម្រាប់សហគមន៍ ហើយគាត់ក៏ត្រូវបានប្រជាជនទូទៅចាត់ទុកជា"ម្តាយ"ដែរ ។ ដោយសារការពេញចិត្តចំពោះការគោរពមកលើគាត់ និងការពិតដែលថា ដូនជីទទួលឥទ្ធិពលនយោបាយតិចជាងព្រះសង្ឃ យើងគិតថា ដូនជីជាក្រុមល្អបំផុតក្នុងការអប់រំអំពីដំណើរការតុលាការនិងប្រវត្តិសាស្ត្រខ្មែរក្រហម ។

យើងបានជួបជាមួយអ្នកតំណាងសមាគមដូនជីចំនួនពីរក្រុម នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៤ ដើម្បីសាកសួរអំពីចំណាប់អារម្មណ៍របស់សមាគមទាំងពីរក្នុងការចូលរួមកម្មវិធីនេះ ។ ប្រសិនបើសមាគមទាំងពីរមានចំណាប់អារម្មណ៍ចូលរួមក្នុងកម្មវិធីរបស់យើង គាត់នឹងត្រូវស្នើឲ្យផ្ញើឯកសារអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់គាត់ ទទួលការហ្វឹកហ្វឺននិងព័ត៌មានផ្សេងៗដែលទាក់ទងនឹងការអប់រំជាសាធារណៈក្នុងពេលដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ក្នុងនោះដែរកិច្ចខិតខំប្រឹងប្រែងធ្វើឲ្យមានការទទួលស្គាល់ជាសាធារណៈអំពីបទរំលោភផ្លូវភេទដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ជាសកម្មភាពមួយរបស់កម្មវិធីនេះ


ក្រុមអ្នកដឹកនាំសហគមន៍ចាម


ក្រុមដូនជី

ដែរ ។ ក្នុងពេលថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ចប់ការផលិតខ្សែភាពយន្តឯកសារមួយស្តីអំពីស្ត្រីកម្ពុជាម្នាក់នៅខេត្តកំពង់ឆ្នាំងដែលត្រូវរំលោភដោយយុទ្ធជនខ្មែរក្រហមមួយក្រុម ហើយសព្វថ្ងៃបានបួសជាដូនជី ។ ខ្សែភាពយន្តឯកសារនេះទើបតែបញ្ចាំងនៅក្នុងពិធីបុណ្យខ្សែភាពយន្តមួយនៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី១០ ខែកញ្ញា កន្លងទៅនេះ ។ យើងក៏ទើបតែបានទទួលការអញ្ជើញឲ្យទៅចាក់ផ្សាយខ្សែភាពយន្តនេះនៅសារមន្ទីរសិល្បៈទំនើបនៅទីក្រុងញូវយ៉កនៅខែក្រោយនេះដែរ ។

នៅក្នុងដំណាក់កាលទីមួយនៃកម្មវិធីនេះ យើងនឹងបង្ហាញខ្សែភាពយន្តខាងលើនៅតាមទីកន្លែងផ្សេងៗទូទាំងប្រទេសកម្ពុជា និងនៅក្នុងបន្ទប់សាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរទួលស្លែង និងនៅតាមបណ្តាអង្គការនានាក្នុងទីក្រុងភ្នំពេញ ។ យើងក៏នឹងមានការពិភាក្សាជាសាធារណៈលើប្រធានបទការរំលោភផ្លូវភេទដែលកើតមាននៅក្នុងរបបខ្មែរក្រហមដើម្បីស្ទង់ពីប្រតិកម្មរបស់មហាជន ក៏ដូចជាបង្កើនការយល់ដឹងពីបញ្ហានេះចំពោះមហាជន ។

នៅក្នុងដំណាក់កាលទីពីរ ផាត រចនា អ្នកផលិតខ្សែភាពយន្តនេះ នឹងទៅចូលរួមកម្មវិធីមួយនៅប្រទេសអាហ្វ្រិកខាងត្បូងដើម្បីសិក្សាអំពីវិធីសាស្ត្ររបស់គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាជាតិជាមួយក្រុមស្ត្រីនិងមនុស្សដទៃទៀតដែលបានចូលរួមរិះរកដំណោះស្រាយចំពោះបទឧក្រិដ្ឋរំលោភផ្លូវភេទនេះ ។ បន្ទាប់មក ផាត រចនា នឹងធ្វើដំណើរទៅប្រទេសទីម័រខាងកើតដើម្បីរៀនសូត្រពីបទពិសោធន៍ក្នុងការទទួលប្រតិកម្មផ្សេងៗជាមួយនឹងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាជាតិ អំពីវិធីដោះស្រាយចំពោះឧក្រិដ្ឋកម្មប្រភេទនេះ ។ ក្នុងពេលជាមួយគ្នានោះក៏មានការបញ្ចាំងខ្សែភាពយន្តនេះដែរ ។ ផាត រចនា នឹងធ្វើការនៅទីនោះដើម្បីបង្កើតទំនាក់ទំនងអន្តរជាតិជាមួយក្រុមដែលធ្វើការលើប្រធានបទនេះ ។

នៅក្នុងដំណាក់កាលទីបី ផាត រចនា នឹងធ្វើការជាមួយអ្នកជំនាញការបរទេសដើម្បីរិះរកយុទ្ធសាស្ត្រក្នុងការស្វែងរកនូវ

ការទទួលខុសត្រូវចំពោះបទរំលោភផ្លូវភេទនៅក្នុងបរិបទកម្ពុជា ។ នៅចុងបញ្ចប់នៃគម្រោងនេះ យើងសង្ឃឹមថានឹងជួយឲ្យសង្គមកម្ពុជាទទួលស្គាល់ស្ត្រីដែលធ្លាប់រងគ្រោះដោយការរំលោភផ្លូវភេទក្នុងរបបខ្មែរក្រហម ព្រមទាំងទទួលថាបទឧក្រិដ្ឋនេះពិតជាបានកើតមាននៅក្នុងរបបនេះមែន និងលើកទឹកចិត្តស្ត្រីដែលជាជនរងគ្រោះដោយសារបទឧក្រិដ្ឋនេះមកបកស្រាយរឿងរ៉ាវផ្ទាល់ខ្លួនបង្កើតការពិភាក្សាលើប្រធានបទនេះនៅក្នុងដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បង្កើនការយល់ដឹងពីបញ្ហានេះដល់ប្រជាជនកម្ពុជាជំនាន់ក្រោយ និងជំរុញឲ្យរដ្ឋាភិបាលពង្រឹងច្បាប់លើបទរំលោភផ្លូវភេទនេះផង ។

ដោយហេតុនេះហើយ មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបប្រជុំជាច្រើនដងជាមួយតំណាងសមាគមនិស្សិតមកពីសមាគមចំនួន ២២ទូទាំងប្រទេស (សមាគមទាំងនេះគឺជាសមាគមឯករាជ្យដែលជាទូទៅត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជានិងបណ្តាមហាវិទ្យាល័យឯកជនមួយចំនួន) ។

ជាលទ្ធផលនៃកិច្ចប្រជុំ គ្រប់សមាគមទាំងអស់បានឯកភាពគ្នាបង្កើតនូវក្រុមប្រឹក្សានិស្សិតមួយសម្រាប់យុត្តិធម៌និងការទទួលខុសត្រូវ ដោយជ្រើសរើសចេញពីសមាជិកនៃក្រុមនីមួយៗ ។ មុខងាររបស់ក្រុមប្រឹក្សានេះនឹងធ្វើការប្រកាសឡើងនៅពេលដែលតំណាងអគ្គការសហប្រជាជាតិអញ្ជើញមកដល់ប្រទេសកម្ពុជា






## ៣) សមាគមនិស្សិត

សព្វថ្ងៃ យុវជនកម្ពុជាជាច្រើនហាក់បីដូចជាមិនជឿថា អំពើប្រល័យពូជសាសន៍បានកើតមានឡើងនៅលើប្រទេសរបស់ខ្លួនផងទេ ហើយផ្នែកមួយចំនួនដែលបញ្ជាក់អំពីកម្ពុជាប្រជាធិបតេយ្យនៅក្នុងសៀវភៅសិក្សាតាមសាលាចំណេះទូទៅត្រូវបានកាត់ចេញដោយសារបញ្ហានយោបាយ ។ ដូច្នេះ វាជារឿងដ៏ចាំបាច់បំផុតដែលយុវជនជំនាន់ក្រោយគួរយល់ដឹងពីប្រវត្តិសាស្ត្ររបស់ជាតិខ្លួន ហើយការរួមចំណែករបស់អ្នកទាំងនោះនឹងជួយជំរុញដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ព្រមទាំងជួយធ្វើឲ្យអនាគតសង្គមស៊ីវិលនៅក្នុងប្រទេសកាន់តែមានឥទ្ធិពលឡើង ។

ដើម្បីពិភាក្សាអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ គោលបំណងរបស់ក្រុមប្រឹក្សានិស្សិតនេះគឺដើម្បីអប់រំសាធារណជនអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គាំទ្រដំណើរការតុលាការ ឃ្លាំមើលដំណើរការតុលាការនិងជួយរៀបចំចែកចាយការស្ទាបស្ទង់មតិនៅក្នុងអំឡុងពេលនិងក្រោយពេលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ដើម្បីបង្កើនការចូលរួមចំណែករបស់និស្សិតនិងករណីយកិច្ចជាម្ចាស់គម្រោង មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្នើសុំឲ្យសមាគមទាំងអស់រៀបចំនិងដាក់សំណើគម្រោងផែនការដោយខ្លួនឯង ។ ផែនការនេះនឹងត្រូវលើកយកមកពិភាក្សានិងអនុម័តនៅចុងខែតុលា ។ **ឆាំង យុ**






ព្រះអង្គម្ចាស់រាជទាយាទ ហាកុន នៃប្រទេសន័រវេ៉ ធ្វើទស្សនកិច្ចនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៤

*(ប្រទេសន័រវេ៉គឺជាប្រទេសទីមួយដែលគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត)*

# បទអន្តរាគមន៍របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារ របស់រាជរដ្ឋាភិបាល សម្រាប់រៀបចំការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ជូនសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៣

## ថ្ងៃច័ន្ទទី៤ ខែតុលា ឆ្នាំ២០០៤

*សូមថ្វាយបង្គំសម្តេចក្រុមព្រះប្រធានរដ្ឋសភា! សូមគោរពសម្តេច អនុប្រធានទី១ រដ្ឋសភា! សូមគោរពសម្តេច នាយករដ្ឋមន្ត្រី សូមគោរព សម្តេច ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា អង្គសភាដ៏ឧត្តុង្គឧត្តម ឯកឧត្តម លោកជំទាវ តំណាងអង្គទូត ដែលមានវត្តមានក្នុងពេលនេះ!*

*ថ្ងៃនេះទូលបង្គំ ខ្ញុំបាទមានកិត្តិយស និងសេចក្តីរីករាយដាក់ជូនអង្គសភាអាណត្តិទី៣ ដ៏ឧត្តុង្គឧត្តម នូវសេចក្តីព្រាងច្បាប់ពីរក្នុងចំណោមសេចក្តីព្រាងច្បាប់ប្រកបដោយអាទិភាពខ្ពស់ជាងគេដែលត្រូវបានអនុម័តដោយសម័យប្រជុំគណៈរដ្ឋមន្ត្រីលើកដំបូងនៃរាជរដ្ឋាភិបាលកម្ពុជាថ្មី ។ យើងអាចឈានទៅបញ្ចប់លើទិដ្ឋភាពច្បាប់នៃបញ្ហាមួយដែលមានសារសំខាន់ដ៏ធំធេងចំពោះប្រជាជនកម្ពុជា គឺជាបញ្ហាមួយដែលនៅមិនទាន់បានដោះស្រាយរយៈពេលមួយភាគបួននៃសតវត្សរ៍មកហើយ ។*

*យើងដាក់ជូនអង្គសភាដ៏ឧត្តុង្គឧត្តម នូវសេចក្តីព្រាងច្បាប់ពីរ ដែលជាប់ពាក់ព័ន្ធគ្នាទៅវិញទៅមក ដែលយើងអាចនិយាយជាភាសាអង់គ្លេសថា “Two sides of the same coin” នោះគឺៈ*

*សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។*

*យើងទាំងអស់គ្នានៅចាំបានថាៈ ៣ឆ្នាំមុន គឺក្នុងឆ្នាំ២០០១ រដ្ឋសភាអាណត្តិទី២ បានអនុម័តសេចក្តីព្រាងច្បាប់ចុងក្រោយនេះ ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ក្នុងឆ្នាំដដែល ដោយព្រះមហាក្សត្រ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ។ គោលបំណងនៃសេចក្តីព្រាងច្បាប់ថ្ងៃនេះ ក៏ដូចជាខ្លឹមសារដែលទូលបង្គំ ខ្ញុំបាទបានទូលថ្វាយនិងជម្រាបជូនអង្គសភានៅពេលនោះដែរ ។ ដើម្បីឲ្យសមស្របទៅនឹងការដែលយើងបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិក្នុងខែមិថុនា ឆ្នាំ១៩៩៧ ហើយតាំងពីមុនពេលនោះទៀត រាជរដ្ឋាភិបាលយើងបានប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់ៗដូចតទៅៈ*

- ***គោលការណ៍ទីមួយៈ*** *គឺផ្តល់យុត្តិធម៌ដល់វិញ្ញាណក្ខន្ធរបស់ប្រជាជនកម្ពុជារាប់លាននាក់ដែលបានបាត់បង់ជីវិតទៅ និងដល់ជនរងគ្រោះដែលបានរស់រានមានជីវិតពីយុគសម័យខ្មៅងងឹតនៃប្រវត្តិសាស្ត្រកម្ពុជា ។*
- ***គោលការណ៍ទីពីរៈ*** *គឺថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងឯកភាពជាតិ ដែលកម្ពុជាទើបសម្រេចបានក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ។*
- ***គោលការណ៍ទីបីៈ*** *គឺការគោរពដល់អធិបតេយ្យភាពយើង ដែលជាគោលការណ៍គ្រឹះមួយក្នុងចំណោមគោលការណ៍គ្រឹះទាំងឡាយ នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ។ ការគោរពដល់គោលការណ៍អធិបតេយ្យជាតិត្រូវបានរំលេចឲ្យឃើញនៅក្នុងច្បាប់*

និងកិច្ចព្រមព្រៀងដូចខាងក្រោមនេះ ÷

**ការតែងតាំងចៅក្រមៈ** រាល់ចៅក្រមទាំងអស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សាអង្គចៅក្រមកម្ពុជា ។ សេចក្តីព្រាងច្បាប់បានចែងថា អគ្គលេខាធិការអង្គការសហប្រជាជាតិនឹងផ្តល់នូវបញ្ជីឈ្មោះបេក្ខជនចៅក្រមបរទេសដែលនឹងត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ។

**សមាសភាពរបស់សាលាជំនុំជម្រះក្តីៈ** ចៅក្រមកម្ពុជាមានភាគច្រើននៅគ្រប់សាលាជំនុំជម្រះក្តី ។ ប្រសិនបើមានចៅក្រមចំនួន៥រូប ៣រូបជាកម្ពុជា ហើយប្រសិនបើមាន៧រូប ៤រូបជាកម្ពុជា ។ ដើម្បីថ្លឹងថ្លែងជាមួយចំនួនភាគច្រើនរបស់កម្ពុជានេះ រាល់ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយសំឡេងភាគច្រើនលើសលប់ "Super majority" ដែលជាឧទាហរណ៍តម្រូវឲ្យមានសំឡេងបួនក្នុងចំណោមចៅក្រម៥រូប ដើម្បីធ្វើការសម្រេចសេចក្តី ។

**ការផ្តើមគំនិតពីខាងក្នុងៈ** ប្រវត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិបង្ហាញថា តុលាការទាំងនោះត្រូវបានរៀបចំដោយចៅក្រមបរទេស ហើយផ្តួចផ្តើមគំនិត និងដាក់កំហិតមកពីខាងក្រៅ ។ ក៏ប៉ុន្តែយន្តការរបស់យើងដែលហៅថា អង្គជំនុំជម្រះវិសាមញ្ញត្រូវរៀបចំឡើងនៅក្នុងរចនាសម្ព័ន្ធរបស់តុលាការកម្ពុជា ហើយយើងបានអញ្ជើញសហគមន៍អន្តរជាតិមកចូលរួមជាមួយយើង ។

**ការរួមបញ្ចូលគ្នានូវច្បាប់អន្តរជាតិ និងច្បាប់ជាតិៈ** អង្គជំនុំជម្រះវិសាមញ្ញមានបទឧក្រិដ្ឋចំនួន៣ នៅក្រោមច្បាប់ជាតិ (មនុស្សឃាត ទារុណកម្ម ការវាយប្រហារលើសាសនា) និងមានបទឧក្រិដ្ឋចំនួន៥ នៅក្រោមច្បាប់អន្តរជាតិ (ប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសម្បត្តិវប្បធម៌ និងឧក្រិដ្ឋកម្មប្រឆាំងទៅលើអ្នកទទួលបានការការពារជាអន្តរជាតិ) ។

គោលការណ៍ទាំង៣ខាងលើនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ដែលត្រូវបានអនុម័តកាលពីឆ្នាំ២០០១ និងក្នុងកិច្ចព្រមព្រៀងរវាងកម្ពុជា និងអង្គការសហប្រជាជាតិដែលបានចុះហត្ថលេខា នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ នៅសាលសន្និសីទចតុមុខ រវាងទូលបង្គំខ្ញុំបាទផ្ទាល់ និងឯកឧត្តម ហាន់ កូរ៉ែល នៅពេលនោះជាទីប្រឹក្សាច្បាប់ (Legal counsel) និងជាអគ្គលេខាធិការរងអង្គការសហប្រជាជាតិ ។

គណៈរដ្ឋមន្ត្រីបានអនុម័តកិច្ចព្រមព្រៀងនេះមួយសប្តាហ៍ក្រោយ និងបានបញ្ជូនទៅរដ្ឋសភាអាណត្តិមុនដើម្បីស្នើសុំសច្ចាប័ន ។ ដោយសារព្រឹត្តិការណ៍នយោបាយរយៈពេលមួយឆ្នាំកន្លងទៅនេះ យើងត្រូវរង់ចាំរហូតមកដល់ពេលនេះ ទើបរដ្ឋសភាអាចបើកសម័យប្រជុំរបស់ខ្លួន ហើយឈានទៅផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងដ៏មានសារសំខាន់នេះ ។

មុននឹងឈានចូលចំណុចលម្អិតនៃសំណើធ្វើវិសោធនកម្ម ទូលបង្គំ ខ្ញុំបាទសូមព្រះអនុញ្ញាត និងអនុញ្ញាតទូលថ្វាយ និងជម្រាបជូនសមាជិក សមាជិកាដ៏ឧត្តុង្គឧត្តមរបស់រដ្ឋសភា នូវដំណើរការវិវត្តន៍ ចាប់តាំងពីការចុះហត្ថលេខារវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជារយៈពេលជាងមួយឆ្នាំកន្លងទៅនេះ ។

## ការរៀបចំសម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ

ការរៀបចំសម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានបន្តដំណើរការជាមួយនឹងការជួបប្រជុំ និងពិភាក្សារវាងភាគីទាំង៣ៈ

◆ **អង្គការសហប្រជាជាតិ** តំណាងដោយក្រុមការងារពិសេសមួយដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០០៣ ដែលមានឈ្មោះថា ជំនួយរបស់អង្គការសហប្រជាជាតិ សម្រាប់ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម(UNAKRT) ដឹកនាំដោយលោក កាស្តែន ហែរ៉ែល (Karsten Herrel)

◆ **រាជរដ្ឋាភិបាលកម្ពុជា** តំណាងដោយក្រុមការងារសម្រាប់កិច្ចសហប្រតិបត្តិការជាមួយជំនាញការបរទេស និងការរៀបចំដំណើរការសម្រាប់ជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម និងលេខាធិការដ្ឋាន រួមជាមួយតំណាងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង

មហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

◆ **ក្រុមប្រទេសអ្នកផ្តល់ជំនួយ ឬ** ក្រុមប្រទេសដែលមានការចាប់អារម្មណ៍ចំពោះការជំនុំជម្រះក្តីនេះ

នៅក្នុងរយៈពេលកន្លងមកនេះ ក្រុមការងាររាជរដ្ឋាភិបាលបានទទួលនិងជួបពិភាក្សាជាមួយគណៈប្រតិភូជំនាញរបស់អង្គការសហប្រជាជាតិចំនួន២លើក ដឹកនាំដោយលោក កាស្តែន ហៃវ៉ែល នៅក្នុងខែធ្នូ ឆ្នាំ២០០៣ និងខែមីនា ឆ្នាំ២០០៤ ។

ឥឡូវនេះក្រុមការងារកំពុងត្រៀមរៀបចំពិភាក្សាលើកទី៣ ជាមួយគណៈប្រតិភូជំនាញរបស់អង្គការសហប្រជាជាតិដើម្បីពិភាក្សាបញ្ចប់លើបញ្ហាចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។

រាជរដ្ឋាភិបាលកម្ពុជាបានជ្រើសយកអគារសំខាន់ៗចំនួន២ សម្រាប់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺសាលសន្និសីទចតុមុខ សម្រាប់ធ្វើជាសាលាជំនុំជម្រះក្តី និងមជ្ឈមណ្ឌលវប្បធម៌ជាតិសម្រាប់ជាការិយាល័យផ្សេងៗឲ្យតុលាការនេះ ។

**ថវិកា**

រាជរដ្ឋាភិបាលបានព្រមព្រៀងថា ចំណែកថវិកាកម្ពុជា គឺចំណាយលើទីតាំងអគារ ប្រាក់បៀវត្សរ៍ជាតិ និងសោហ៊ុយ ឬចំណាយប្រយោលដទៃទៀត ។

ក្រៅពីផ្តល់ទីតាំងអគារ (សាលចតុមុខនិងមជ្ឈមណ្ឌលវប្បធម៌ជាតិ) រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្តល់ប្រាក់បៀវត្សរ៍ជាតិដល់បុគ្គលិកកម្ពុជា និងត្រូវទទួលរ៉ាប់រងបន្ទុកចំណាយប្រយោលផ្សេងៗទៀតដូចជា ពង្រឹងសន្តិសុខទូទាំងប្រទេស ចំណាយសម្រាប់ការឃុំឃាំង និងព្យាបាលជំងឺជនសង្ស័យ ឬអ្នកដែលត្រូវជាប់ពិរុទ្ធ ។ ការប៉ាន់ប្រមាណសម្រាប់ចំណាយទាំងនេះក្នុងរយៈពេល៣ឆ្នាំ មានប្រមាណ៦លានដុល្លាអាមេរិក ។ ការជជែកពិភាក្សាលើថវិកាសរុបកំពុងដំណើរការ ។ នៅខែមីនា ឆ្នាំ២០០៤ ក្រោយទស្សនកិច្ចលើកទី២របស់ក្រុមជំនាញអង្គការសហប្រជាជាតិ យើងបានឯកភាពគ្នាលើថវិកាមួយសម្រាប់រយៈពេល៣ឆ្នាំ ដែលមានចំនួន៥៣លានដុល្លាអាមេរិក ។ ចំនួននេះកើនឡើងដល់ចំនួន៦៤លានដុល្លាអាមេរិក ពេលដែលគណៈប្រតិភូអង្គការសហប្រជាជាតិត្រឡប់ទៅកាន់ទីក្រុងញូវយ៉កវិញ ហើយជួបជាមួយក្រុមប្រទេស GIS ។ ក្រោយការពិចារណាលើការជូនយោបល់ផ្សេងៗពីបណ្តាប្រទេសផ្តល់ជំនួយ ចំនួនថវិកាសរុបត្រូវបានកាត់បន្ថយមកនៅត្រឹម៥៧លានដុល្លាអាមេរិក ហើយគណៈប្រតិភូអង្គការសហប្រជាជាតិ និងជួបប្រជុំជាមួយក្រុមការងាររាជរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយដើម្បីរិះរកវិធីកាត់បន្ថយចំណាយថែមទៀត ។

ថវិកាសរុបត្រូវបានបែងចែកជាខ្ទង់ចំណាយជាពីរផ្សេងពីគ្នា ម្ខាងគឺជាចំណែករបស់អង្គការសហប្រជាជាតិ និងម្ខាងទៀតជាចំណែករបស់រាជរដ្ឋាភិបាលកម្ពុជា ។ ហេតុនេះប្រទេសអ្នកផ្តល់ជំនួយអាចនឹងជ្រើសរើសថា ផ្តល់ជំនួយតាមរយៈវិភាគទានដល់មូលនិធិស្ម័គ្រចិត្ត UN Trust Fund ឬមួយតាមរយៈវិភាគទានទ្វេភាគីដល់រាជរដ្ឋាភិបាលកម្ពុជា ។ តាំងពីពេលចាប់ផ្តើមការចរចាមក យើងបានបញ្ជាក់ហើយថា យើងនឹងស្វែងរកការគាំទ្រពីប្រទេសផ្តល់ជំនួយដើម្បីបំពេញចំណែកថវិកាចំណាយដែលជាកាតព្វកិច្ចរបស់យើង ។

នៅខែមីនា ឆ្នាំ២០០៤ ការប្រៀបធៀបខ្ទង់ចំណាយរវាងអង្គការសហប្រជាជាតិ និងខ្ទង់ចំណាយកម្ពុជាមានចំនួនប្រហាក់ប្រហែល ៧៥/២៥ ។ ប៉ុន្តែក្រោយមកបណ្តាប្រទេសផ្តល់ជំនួយមួយចំនួន ជាពិសេសជប៉ុនបានស្នើឲ្យមានការផ្ទេរចំណាយប្រមាណ១០លានដុល្លាអាមេរិក ពីខាងអង្គការសហប្រជាជាតិមកខាងកម្ពុជាវិញ ក្នុងគោលបំណងកាត់បន្ថយចំណាយនិងសន្សំសំចៃដែលធ្វើឲ្យការប្រៀបធៀបគ្នាមានចំនួនប្រហាក់ប្រហែល ៦០/៤០ ។

យើងបានប្រកាសរួចហើយថា ជំហររបស់យើងទន់ភ្លន់ចំពោះការដាក់មុខចំណាយណាមួយទៅក្នុងចំណាយរាជរដ្ឋាភិបាលកម្ពុជា ឬក៏នៅក្នុងខ្ទង់ចំណាយរបស់អង្គការសហប្រជាជាតិក្នុងលក្ខខណ្ឌដែលៈ ក) ការផ្លាស់ប្តូរបែបនេះស្ថិតនៅក្នុងស្មារតីនៃកិច្ចព្រមព្រៀងដែលត្រូវចុះហត្ថលេខារវាងភាគីទាំងពីរ ហើយមិនតម្រូវឲ្យមានការធ្វើវិសោធនកម្មអ្វីឡើយ ហើយ ខ) ដោយទទួលយកមុខចំណាយដែលត្រូវផ្ទេរទៅឲ្យចំណែករបស់ខ្លួននោះ រាជរដ្ឋាភិបាលកម្ពុជាមិនមែនបង្ហាញថា ខ្លួនសុខចិត្តទទួលរ៉ាប់រងលើចំណាយ

នោះដោយប្រើប្រាស់ថវិកាជាតិទេ ។

## សកម្មភាពផ្សេងៗទៀត

យើងសង្ឃឹមថា បញ្ហាថវិកានឹងត្រូវពិភាក្សាបញ្ចប់នៅក្នុងពេលខាងមុខនេះហើយ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងធ្វើរបាយការណ៍ និងអំពាវនាវរកវិភាគទានពីបណ្តារដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ។ កន្លងមកនេះមានប្រទេសមួយចំនួនហើយដែលបានបង្ហាញថា គេមានបំណងរួមវិភាគទានចំពោះការចំណាយរបស់អង្គជំនុំជម្រះវិសាមញ្ញ ឬមួយតាមរយៈមូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិ ឬមួយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា ។ រហូតមកទល់ពេលនេះមានប្រទេសអូស្ត្រាលីមួយដែលបានផ្តល់ទឹកប្រាក់ចំនួន៣លានដុល្លារអូស្ត្រាលី ចំណែកប្រទេសដទៃទៀតរង់ចាំរហូតដល់ចំនួនប្រាក់ចំណាយសរុបត្រូវបានកំណត់ទើបគេបង្ហាញការរួមវិភាគទានជាទឹកប្រាក់ ឬជាសម្ភារផ្សេងៗ ។

ក្រៅពីការគ្រោងរៀបចំផែនការលើថវិកា និងប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងរយៈពេលប៉ុន្មានខែកន្លងទៅនេះ ក្នុងការងាររាជរដ្ឋាភិបាលក៏បានដំណើរការរៀបចំសកម្មភាពផ្សេងៗទៀតរបស់អង្គជំនុំជម្រះវិសាមញ្ញផងដែរ ។ ជាមួយនឹងសាលាភូមិន្ទអង្គចៅក្រម និងដោយមានការឧបត្ថម្ភថវិកាដោយ UNDP យើងបានរៀបចំបើកវគ្គបណ្តុះបណ្តាលរយៈពេល ២សប្តាហ៍ ស្តីពីច្បាប់មនុស្សធម៌អន្តរជាតិ សម្រាប់ចៅក្រម និងព្រះរាជអាជ្ញាចំនួន៣០នាក់ និងមេធាវីចំនួន៣០នាក់ ។ លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលក៏បានរៀបចំ និងធ្វើការបោះពុម្ពផ្សាយនូវសៀវភៅព័ត៌មានណែនាំអំពីប្រវត្តិ គោលបំណងនិងរចនាសម្ព័ន្ធរបស់អង្គជំនុំជម្រះវិសាមញ្ញ ភាសាខ្មែរ និងអង់គ្លេស ហើយនិង CD អំពីកម្រងច្បាប់កម្ពុជា និងអន្តរជាតិដែលពាក់ព័ន្ធ និងអង្គជំនុំជម្រះវិសាមញ្ញ សម្រាប់ចែកផ្សាយ ។ គម្រោង២ ចុងក្រោយនេះផ្តល់ថវិកាដោយវិទ្យាស្ថានធនធានច្បាប់របស់អូស្ត្រាលី(ALRI) និងកម្មវិធីអភិវឌ្ឍអន្តរជាតិរបស់អូស្ត្រាលី(AUSAID) ។

## អំពីសំណើសុំធ្វើវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ឆ្នាំ២០០១

ការធ្វើវិសោធនកម្មនេះពុំមានផ្លាស់ប្តូរអ្វីដល់ស្មារតី ឬខ្លឹមសារជាសារវន្តនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានអនុម័តដោយរដ្ឋសភា ពិនិត្យឡើងវិញដោយព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញ ហើយប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ នោះទេ ។ ការធ្វើវិសោធនកម្មដូចតទៅនេះ គ្រាន់តែសម្រាប់ធ្វើឲ្យមានភាពរលូន និងស៊ីសង្វាក់គ្នា (harmony) រវាងច្បាប់និងកិច្ចព្រមព្រៀង ហើយងាយស្រួលដល់ការអនុវត្ត ។

**ក) ការកែសម្រួលរចនាសម្ព័ន្ធ:** សំណើវិសោធនកម្មសំខាន់ជាងគេលើច្បាប់ គឺការកែប្រែរចនាសម្ព័ន្ធអង្គជំនុំជម្រះវិសាមញ្ញពីបីទៅពីរថ្នាក់ ។ ការកែសម្រួលនេះត្រូវបានឯកភាពតាមរយៈលិខិតរបស់សម្តេចនាយករដ្ឋមន្ត្រី ផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០២ ដើម្បីកាត់បន្ថយចំណាយ និងសម្រួលបែបបទរដ្ឋបាល ។ អង្គជំនុំជម្រះវិសាមញ្ញឥឡូវនេះមានតែពីរថ្នាក់ប៉ុណ្ណោះ ។

◆ ដូចពីមុនដែរ គឺមានអង្គជំនុំជម្រះសាលាដំបូង (ដែលមានចៅក្រមខ្មែរ៣រូប និងចៅក្រមបរទេស២រូប)

◆ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ និងអង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវបញ្ចូលគ្នា ជាអង្គជំនុំជម្រះតុលាការកំពូលតែមួយ (ដែលមានចៅក្រមខ្មែរ៤រូប និងចៅក្រមបរទេស៣រូប) ។ អង្គជំនុំជម្រះតុលាការកំពូលនេះជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និងជាកន្លែងចេញសេចក្តីសម្រេចបិទផ្លូវតវ៉ាផង ។

ជាលទ្ធផលនៃការកែប្រែរចនាសម្ព័ន្ធ យើងត្រូវធ្វើវិសោធនកម្មលើមាត្រានៃច្បាប់ដែលពាក់ព័ន្ធទៅនឹងចំនួនថ្នាក់របស់តុលាការមុខងាររបស់ថ្នាក់នីមួយៗ ហើយនិងចំនួនចៅក្រមដែលត្រូវតែងតាំងសម្រាប់ថ្នាក់នីមួយៗផងដែរ មាត្រា២, ៩, ១១, ១៤, ១៨, ៣៦ និង៣៧) ។

**ខ) បញ្ជាក់ថាកិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តជាច្បាប់នៅក្នុងប្រទេសកម្ពុជា៖** នៅក្នុងការចរចាររវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ យើងបានព្រមព្រៀងគ្នាថា នៅពេលដែលកិច្ចព្រមព្រៀងនេះត្រូវបានផ្តល់សច្ចាប័នតាមនីតិវិធីនៃការផ្តល់សច្ចាប័នរបស់ព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តដូចច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា (មាត្រា៤៧ស្ទួន) ។

**គ) ធានាអះអាងនូវសិទ្ធិពេញលេញសម្រាប់ចុងចោទ និងភ័យឯកសិទ្ធិសម្រាប់មន្ត្រីតុលាការ និងមេធាវីចុងចោទ៖** ប្រការទាំងនេះត្រូវបានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញឆ្នាំ២០០១រួចហើយ ប៉ុន្តែកិច្ចព្រមព្រៀងបានបញ្ជាក់ឲ្យរឹតតែច្បាស់ថែមទៀត ជាពិសេសដាក់បញ្ចូលនូវខ្លឹមសារដែលបានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយឆ្នាំ១៩៦៦ (មាត្រា២៤, ៣៣, ៣៤,៣៥ និង៤២)

**ឃ) បកស្រាយបំភ្លឺថានៅពេលដែលនីតិវិធីអន្តរជាតិអាចយកមកប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ៖** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញឆ្នាំ២០០១ បានចែងថា នីតិវិធីដែលត្រូវអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ គឺនីតិវិធីដែលនៅជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានបន្ថែមថា «ប្រសិនបើចាំបាច់ហើយ នីតិវិធីនៅជាធរមានមានការខ្វះចន្លោះ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ» ។

កិច្ចព្រមព្រៀងបានបញ្ជាក់លើចំណុចនេះឲ្យបានកាន់តែច្បាស់ថែមទៀត នៅពេលណាដែលគេអាចស្វែងរកការណែនាំបែបនេះហើយ ដែលយើងស្នើឲ្យមានវិសោធនកម្មលើច្បាប់ដើម្បីឲ្យមានភាពរលូន ឬស៊ីសង្វាក់គ្នាដោយបន្ថែមពាក្យ «ប្រសិនបើនីតិវិធីឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ» (មាត្រា២០, ២៣ និង៣៣)

**ង) បកស្រាយបំភ្លឺអំពីការលើកលែងទោស និងការអនុគ្រោះទោស៖** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញឆ្នាំ២០០១ បានបញ្ជាក់ច្បាស់ថាៈ រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឲ្យមានការលើកលែងទោស ឬការអនុគ្រោះដល់ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេត ឬត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះវិសាមញ្ញ ។ កិច្ចព្រមព្រៀងបកស្រាយបំភ្លឺស្ថានការណ៍នេះដោយបានបន្ថែមពាក្យ «វិសាលភាពនៃការលើកលែងទោស ឬអនុគ្រោះទោស ដែលអាចត្រូវបានផ្តល់ឲ្យមុនការអនុម័តច្បាប់នេះគឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ» (មាត្រា៤០)

**ច) វិសោធនកម្មបន្ទាប់បន្សំផ្សេងៗទៀត៖**

◆ បន្ថែមសេចក្តីថា ចៅក្រមដែលត្រូវតែងតាំងឲ្យបម្រើការក្នុងអង្គជំនុំជម្រះវិសាមញ្ញ គប្បីមានបទពិសោធន៍រួមតាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង (មាត្រា១០) ។

◆ បកស្រាយបំភ្លឺលើការជ្រើសរើសចៅក្រមបរទេស សហចៅក្រមស៊ើបអង្កេតបរទេស និងសហព្រះរាជអាជ្ញាបរទេសឲ្យជំនួសកន្លែងទំនេរ (មាត្រា១១, ២១ និង២៧) ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ អាចផ្តល់បញ្ជីឈ្មោះបេក្ខជនថ្មីបន្ថែមសម្រាប់តួនាទីទាំងនេះ (មាត្រា៤៦)

◆ ចែងអំពីសហព្រះរាជអាជ្ញាបរទេសមានសិទ្ធិតែងតាំងសហព្រះរាជអាជ្ញារងរបស់ខ្លួន (មាត្រា២២)

◆ បកស្រាយបំភ្លឺមាត្រា ៣៣, ៣៤ និង៣៥ ត្រូវអនុវត្តដូចគ្នា (Mutatis mutandis) ត្រូវអនុវត្តដូចគ្នាចំពោះអង្គជំនុំជម្រះតុលាការកំពូល ក៏ដូចជាអង្គជំនុំជម្រះសាលាដំបូងដែរ (មាត្រា៣៧ស្ទួន) ។

◆ បកស្រាយនូវភាពមិនអាចរំលោភបំពានបាននៃបណ្ណសារដែលត្រូវប្រើប្រាស់ដោយផ្នែកណាមួយនៃអង្គជំនុំជម្រះវិសាមញ្ញ រួមមានចៅក្រមស៊ើបអង្កេត ដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះនិងការិយាល័យរដ្ឋបាល (មាត្រា៤២)

◆ លុបពាក្យមូលនិធិស្ម័គ្រចិត្ត ដើម្បីផ្តល់លទ្ធភាពបន្ថែមទៀតដល់អង្គការសហប្រជាជាតិ ក្នុងការផ្តល់ថវិកា តាមរយៈយន្តការ

ផ្សេងៗ (មាត្រា៤៨) និងលុបពាក្យប្រាក់បៀវត្សរ៍របស់មន្ត្រីរដ្ឋបាលបរទេស ចៅក្រមជម្រះក្តី សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាបរទេសជាបន្ទុករបស់ប្រទេសដែលបានបញ្ជូនមកតាមសំណើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ (មាត្រា៤៨ ចំណុច៣) ។

◆ បន្ថយភាសាប្រើប្រាស់ជាផ្លូវការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅត្រឹម៣ភាសាៈ ខ្មែរ អង់គ្លេស និងបារាំង (មាត្រា៤៥) ។

បន្ថែមទៅលើវិសោធនកម្មដែលបានរៀបរាប់ពីខាងលើដែលធ្វើឲ្យមានភាពរលូន និងស៊ីសង្វាក់គ្នារវាងច្បាប់ និងកិច្ចព្រមព្រៀងនេះ គណៈរដ្ឋមន្ត្រីក៏បានស្នើឲ្យមានការពន្យារអាជ្ញាយុកាលចំនួន១០ឆ្នាំ ។ នៅក្នុងច្បាប់២០០១ អាជ្ញាយុកាលនេះចាប់ផ្តើមផុតកំណត់ក្នុងឆ្នាំ២០០៩ ។ ប៉ុន្តែយើងប្រាថ្នាចង់ឲ្យអង្គជំនុំជម្រះវិសាមញ្ញមានសិទ្ធិធ្វើការចោទប្រកាន់សម្រាប់រយៈពេលនៃដំណើរការរបស់ខ្លួន ហេតុនេះហើយទើបយើងស្នើឲ្យមានការបន្តរយៈពេល១០ឆ្នាំទៀត ។

***សន្និដ្ឋានៈ***

ឥឡូវនេះ យើងបានមកដល់ទីបញ្ចប់នៃផ្លូវដ៏វែងឆ្ងាយមួយ ។ អស់រយៈពេលជាងមួយភាគបួននៃសតវត្សរ៍មកហើយ ដែលមេដឹកនាំខ្មែរក្រហមត្រូវបានទម្លាក់ចេញពីការត្រួតត្រាដ៏ឃោរឃៅលើប្រទេសរបស់យើង ។ ដូចសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងក្នុងរយៈពេលថ្មីៗនេះថា “គ្មានប្រជាជនយើងណាម្នាក់បានរួចផុតពីការបំផ្លិចបំផ្លាញដែលប្រព្រឹត្តមកលើមាតុភូមិរបស់យើងក្នុងកំឡុងពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលពួកខ្មែរក្រហម ប៉ុល ពត កាន់អំណាចនៅក្រោមរបបមួយដែលគេស្គាល់ឈ្មោះថា កម្ពុជាប្រជាធិបតេយ្យ” ។ ចំពោះអ្នកណាដែលកើតក្រោយឆ្នាំ១៩៧៩ ដែលមិនបានជួបប្រទះផ្ទាល់នូវឧក្រិដ្ឋកម្មទាំងនោះ ក៏ទទួលរងនូវបន្ទុកដ៏ធ្ងន់ធ្ងរដែរ ។ ពួកគេឃើញឪពុកម្តាយ បងប្រុស បងស្រីរបស់គេឈឺចាប់ខ្លោចផ្សា ។ ពួកគេបានរួមចំណែកក្នុងការលំបាកដើម្បីកសាងសង្គមជាតិយើងឡើងវិញ ពីបាតដៃទទេ ឬពីឆ្នាំសូន្យ ដោយមិនបានទទួលផលប្រយោជន៍ពីគតិបណ្ឌិត និងបទពិសោធន៍នៃញាតិមិត្តដែលបានស្លាប់បាត់បង់ទៅ ។ គឺជាការបន្ត ការតស៊ូដ៏យូរអង្វែង និងលំបាក ហើយយើងទាំងអស់គ្នាដឹងថា កម្ពុជាសព្វថ្ងៃមានលក្ខណៈអន់ថយ ឆ្ងាយពីបណ្តាប្រទេសជិតខាង លើវិស័យសុខាភិបាល អប់រំ និងប្រាក់ចំណូល ។

ឥឡូវនេះពេលវេលាបានមកដល់ហើយ សម្រាប់អ្នកទាំងឡាយណាដែលទទួលខុសត្រូវក្នុងការរៀបចំផែនការនិងបញ្ជាឲ្យមានអំពើឃោរឃៅព្រៃផ្សៃនេះមកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់គេ ។ បន្ទាប់ពីការចរចាអស់រយៈពេលជាច្រើនឆ្នាំមក យើងនឹងឈានទៅបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ឧក្រិដ្ឋកម្មទាំងនេះពុំមែនប្រព្រឹត្តឡើងប្រឆាំងចំពោះតែប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែប្រឆាំងចំពោះមនុស្សជាតិទាំងមូល ។ ហេតុនេះ គឺជាការសមស្របដែលមានចៅក្រម ព្រះរាជអាជ្ញា អ្នកច្បាប់កម្ពុជា និងចៅក្រម ព្រះរាជអាជ្ញា អ្នកច្បាប់អន្តរជាតិធ្វើការងារជាមួយគ្នាក្នុងភារកិច្ចជំនុំជម្រះក្តីអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ហើយតាមរយៈនេះនឹងជួយបង្កើតនូវវប្បធម៌មួយដែលទប់ស្កាត់កុំឲ្យកើតមានអំពើបែបនេះជាថ្មីទៀត នៅកន្លែងណាក៏ដោយក្នុងពិភពលោក ។

គំរូតុលាការដែលយើងបានគាក់តែងរួមគ្នាជាមួយអង្គការសហប្រជាជាតិ បានទទួលនូវការគាំទ្រពីសហគមន៍អន្តរជាតិ ។ ពុំមានប្រទេសណាមួយបាននិយាយប្រឆាំង និងរូបមន្តដែលយើងបានបង្កើតឡើងទេ ដែលជួនកាលគេបានលើកឡើងថាជា “គំរូកម្ពុជានោះ” ដែលអាចផ្តល់ជាឧទាហរណ៍សម្រាប់អ្នកដទៃទៀតនៅក្នុងពេលអនាគត ដោយយើងបានដាក់បញ្ចូលគ្នានូវសមាសភាពជាតិនិងអន្តរជាតិលើផ្នែកច្បាប់ ចៅក្រម ព្រះរាជអាជ្ញា បុគ្គលិក និងថវិកា ជាតុលាការជាតិ ដែលមានចរិតអន្តរជាតិ ដូចដែលបានព្រមព្រៀងរវាងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ។

អាស្រ័យហេតុដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ ទូលបង្គំខ្ញុំបាទសូមដាក់ថ្វាយ និងជូនសមាជិក អង្គសភាដ៏ឧត្តុង្គឧត្តមនូវសេចក្តីព្រាងច្បាប់ទាំងពីរ គឺការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងកម្ពុជា និងអង្គការសហប្រជាជាតិនិងការអនុម័តលើសេចក្តីព្រាងច្បាប់វិសោធនកម្មច្បាប់២០០១ ដើម្បីឲ្យមានភាពរលូន និងស៊ីសង្វាក់គ្នារវាងឯកសារទាំងពីរ ។ សូមថ្លែងអំណរព្រះគុណ និងសូមអរគុណ!

# ការពិភាក្សានិងអនុម័តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ នៅក្នុងសម័យប្រជុំលើកទី១ នីតិកាលទី៣ របស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤

*(កត់ត្រាដោយៈ ដាន់ សុដា)*

***សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ*** *សូមគោរពសម្តេចនាយករដ្ឋមន្ត្រី សូមក្រាបថ្វាយបង្គំសម្តេច អ្នកអង្គម្ចាស់ក្សត្រីយ៍ សូមជម្រាបសួរលោកជំទាវ ឯកឧត្តមតំណាងរាស្ត្រ ជាទីគោរពនិងជាទីស្រឡាញ់ ។ ទូលព្រះបង្គំខ្ញុំថ្ងៃនេះសូមថ្លែងអំណរព្រះគុណនិងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះវត្តមាននិងវត្តមានរបស់សម្តេចនាយករដ្ឋមន្ត្រី សម្តេច លោកជំទាវ ឯកឧត្តមតំណាងរាស្ត្រ សមាជិកនៃរដ្ឋាភិបាល ។ ខ្ញុំសូមលេខានៃអង្គប្រជុំដែលមានឯកឧត្តម លី ណារ៉ុង ឯកឧត្តម ពូ សុធីរៈ និងឯកឧត្តម ជា ប៉ូច មេត្តាពិនិត្យនូវកូរ៉ុម ។*

***លេខានៃអង្គប្រជុំៈ*** *ទូលបង្គំខ្ញុំបាទសូមក្រាបថ្វាយបង្គំសម្តេចព្រះប្រធានរដ្ឋសភា សូមគោរពសម្តេចអនុប្រធានទីមួយនៃរដ្ឋសភា សូមគោរពសម្តេចនាយករដ្ឋមន្ត្រី សូមគោរពនិងថ្វាយបង្គំសម្តេច ទ្រង់ ឯកឧត្តម និងលោកជំទាវ ។ ខ្ញុំបាទសូមក្រាបបង្គំទូលថ្វាយសម្តេចព្រះប្រធាន សមាជិកសមាជិការដ្ឋសភានៅពេលនេះមានចំនួន១០១រូប សូមព្រះមេត្តាជ្រាប ។ សូមអរគុណនិងសូមអរព្រះគុណ ។*

***សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ*** *សូមអរព្រះគុណ ខ្ញុំបាទប្រកាសបើកសម័យប្រជុំពេញអង្គនៃរដ្ឋសភាជាតិនៅព្រឹកនេះ ។ ខ្ញុំសូមក្រាបបង្គំទូលនិងថ្វាយជម្រាបជូនអង្គសភាថា យោងតាមការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានប្រជុំកាលពីថ្ងៃពុធ ទី២២ ខែកញ្ញា កន្លងទៅនេះ អង្គសភាមានរបៀបវារៈតាមលេខរៀងចំនួនបីដែលត្រូវយកមកពិនិត្យនិងអនុម័តដូចតទៅៈ របៀបវារៈទី៦ៈ ការបោះឆ្នោតជ្រើសតាំងបេក្ខភាពឯកឧត្តម ឃ្លោក ប៊ុតឌី ជាអនុប្រធាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជំនួសឯកឧត្តម ង៉ី ឆៃលាង ដែលបានសុំលាលែង ។ របៀបវារៈទី៧ៈ ការពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីៈ ក) ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ខ) វិសោធនកម្មមាត្រា២, មាត្រា៣, មាត្រា៩, មាត្រា១០, មាត្រា១១, មាត្រា១៤, មាត្រា១៧, មាត្រា១៨, មាត្រា២០, មាត្រា២១, មាត្រា២២, មាត្រា២៣, មាត្រា២៤, មាត្រា២៧, មាត្រា២៩, មាត្រា៣១, មាត្រា៣៣, មាត្រា៣៤, មាត្រា៣៥, មាត្រា៣៦, មាត្រា៣៧, មាត្រា៣៩, មាត្រា៤០, មាត្រា៤២, មាត្រា៤៣, មាត្រា៤៤, មាត្រា៤៥, មាត្រា៤៦, និងមាត្រា៤៧ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ របៀបវារៈទី៨ៈ ការពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៤ ។ ទូលព្រះបង្គំខ្ញុំសូមអង្គសភាមេត្តាអនុម័តរបៀបវារៈ ។*

***លេខានៃអង្គប្រជុំៈ*** *សូមក្រាបទូលថ្វាយសម្តេចព្រះប្រធាន សមាជិកសមាជិកាដែលបានគាំទ្រមានចំនួន១០១លើ១០៣ ។ សូមអរព្រះគុណ ។*

***សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ*** *សូមអរគុណ ។ អង្គសភាលោកបានអនុម័តរបៀបវារៈ ។ របៀបវារៈទី៦ៈ ការបោះឆ្នោតជ្រើសតាំងបេក្ខភាពឯកឧត្តម ឃ្លោក ប៊ុតឌី ជាអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជំនួសឯកឧត្តម ង៉ី ឆៃលាង*

ដែលបានសុំលាលែង ។ សូមអញ្ជើញឯកឧត្តម ឃ្លោក ប៊ុតឌី អញ្ជើញមកបង្ហាញខ្លួន ។ យោងសេចក្តីសម្រេចរបស់អង្គប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍នារសៀលថ្ងៃពុធ ទី២២ ខែកញ្ញា ឆ្នាំ២០០៤ យោងសេចក្តីស្នើរបស់រាជរដ្ឋាភិបាលសុំដាក់បេក្ខភាពឯកឧត្តម ឃ្លោក ប៊ុតឌី ជាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជំនួសឯកឧត្តម ង៉ែ ឆៃលាង ដែលបានលាលែង ទូលព្រះបង្គំខ្ញុំសូមស្តេចយាងសម្តេចឧបនាយករដ្ឋមន្ត្រីតំណាងរាជរដ្ឋាភិបាលឡើងមានព្រះបន្ទូលជម្រាបជូនអង្គសភាពីករណីខាងលើដែលទាក់ទងសេចក្តីស្នើសុំសេចក្តីទុកចិត្តពីរដ្ឋសភាចំពោះឯកឧត្តម ឃ្លោក ប៊ុតឌី ។ សូមសម្តេចស្តេចយាង ។

**ស្តេចក្រុមឃុន នរោត្តម សេរីវុឌ្ឍន៍**: សូមក្រាបថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធាននៃរដ្ឋសភាជាតិជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមគោរពសម្តេចអនុប្រធានទី១និងឯកឧត្តម និងសូមគោរពសម្តេចនាយករដ្ឋមន្ត្រី សូមថ្វាយបង្គំអ្នកអង្គម្ចាស់ និងគោរពលោកជំទាវ ឯកឧត្តម សមាជិកសមាជិកានៃអង្គសភាដ៏ឧត្តុង្គឧត្តម ។ ថ្ងៃនេះទូលព្រះបង្គំជាខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយបានឯកភាពពីឯកឧត្តម ឧបនាយករដ្ឋមន្ត្រីនិងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ធ្វើពិធីខ្ទេសនាមថ្វាយនិងជូនអង្គសភាជាតិជាទីគោរព ដើម្បីស្នើសុំការអនុម័តលើការជ្រើសតាំងឯកឧត្តម ឃ្លោក ប៊ុតឌី ជាអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមខ្លឹមសារចាំបាច់នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ព្រមទាំងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ដូចមានចែងក្នុងវាក្យខណ្ឌទី៥ ទី៦ និងទី៧ មាត្រា១៥ថ្មី ។ សូមទូលថ្វាយ ឯកឧត្តម ឃ្លោក ប៊ុតឌី ជាឥស្សរជនមួយរូបដែលមានចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់ មានសមត្ថភាពខាងនយោបាយ បទពិសោធន៍ក្នុងការងារជាតិនិងអន្តរជាតិ និងបានជាធនធានដ៏សំខាន់សម្រាប់ការដឹកនាំនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឆ្ពោះទៅរកភាពសុក្រឹត អព្យាក្រឹត និងតម្លាភាព ។ ទូលព្រះបង្គំជាខ្ញុំសូមព្រះអនុញ្ញាតនិងអនុញ្ញាតអំពីអង្គសភាដ៏ឧត្តុង្គឧត្តម អានទូលថ្វាយពីប្រវត្តិសង្ខេបរបស់ឯកឧត្តម ឃ្លោក ប៊ុតឌី ដូចតទៅៈ

ឯកឧត្តម ឃ្លោក ប៊ុតឌី លោកកើតនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៤៥ បានបញ្ជាក់ថា សញ្ជាតិខ្មែរ ។ ទីកន្លែងកំណើតឃុំផ្សារក្រោម ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ អាសយដ្ឋានបច្ចុប្បន្ននៅគីឡូម៉ែត្រលេខ១៨ ផ្លូវជាតិលេខ៥ ។ កម្រិតវិជ្ជា ឆ្នាំ១៩៦៣-៦៥ និស្សិតសាលាភូមិន្ទរដ្ឋបាល ភ្នំពេញ ។ ១៩៦៧-១៩៧១ សាកលមហាវិទ្យាល័យម៉ុងរ៉េអាល់ កាណាដា បរិញ្ញាបត្រឧក្រិដ្ឋវិទ្យា ។ ១៩៧៥-១៩៧៨ សាកលវិទ្យាល័យម៉ុងរ៉េអាល់ សាលាឧត្តមសិក្សាពាណិជ្ជកម្ម អនុបណ្ឌិតផ្នែកគ្រប់គ្រង ។ ១៩៨១-១៩៨៦ វិទ្យាស្ថានអន្តរជាតិសិទ្ធិមនុស្ស សាកលវិទ្យាល័យស្ត្រាសបួ ប្រទេសបារាំង សញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់អន្តរជាតិនិងសិទ្ធិមនុស្ស ។ ១៩៩៤ វិទ្យាស្ថានអន្តរជាតិសាធារណៈ ទីក្រុងប៉ារីស សញ្ញាបត្រឧត្តមសិក្សាឯកទេស ។ ១៩៩៧ មជ្ឈមណ្ឌលអន្តរជាតិ ហ៊ីរ៉ូស៊ីម៉ា ជប៉ុន ប្រកាសនីយបត្រផ្នែកប្រព័ន្ធបោះឆ្នោត ។ បទពិសោធន៍ការងារៈ ឆ្នាំ១៩៧៨-១៩៨១ គណៈកម្មាធិការសិទ្ធិមនុស្សរដ្ឋកេបិច កាណាដា ។ ១៩៨១-១៩៩២ មន្ទីរការពារភាសាបារាំង ទីស្តីការគណៈរដ្ឋមន្ត្រី កេបិច កាណាដា ប្រធានមជ្ឈមណ្ឌលឯកសារ និងឧបការីអនុរដ្ឋមន្ត្រី ។ ១៩៩២-៩៣ ឯកឧត្តម ឃ្លោក ប៊ុតឌី ធ្វើការឲ្យអាជ្ញាធរអន្តរជាតិបណ្តោះអាសន្ននៃកម្ពុជា (អ៊ុនតាក់) មន្ត្រីរដ្ឋបាលស៊ីវិលទទួលបន្ទុកក្នុងពង្រាងច្បាប់ព្រហ្មទណ្ឌអន្តរកាលក្នុងកម្ពុជា ក្រសួងមហាផ្ទៃ ។ ១៩៩៤-៩៨ ឯកឧត្តម ឃ្លោក ប៊ុតឌី អញ្ជើញទៅក្រសួងមហាផ្ទៃ ជាទីប្រឹក្សាសហរដ្ឋមន្ត្រី និងជានាយកខុទ្ទកាល័យក្រសួងមហាផ្ទៃ សាស្ត្រាចារ្យមហាវិទ្យាល័យច្បាប់និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ១៩៩៨-២០០៣ សមាជិករដ្ឋសភា និងជាលេខាធិការគណៈកម្មការនីតិកម្មនៃរដ្ឋសភាជាតិ ។ ហើយមានអ្នកទទួលដឹងឮ គឺមានលោក ម៉ែន ប៊ុនឡេង ស្ថានទូតកាណាដានៅភ្នំពេញ ដែលលោកអាចបញ្ជាក់ជូននូវសកម្មភាពនិងកម្រិតវិជ្ជារបស់ឯកឧត្តម ឃ្លោក ប៊ុតឌី ហើយបើនៅក្នុងព្រះរាជាណាចក្រកម្ពុជាវិញ ក្នុងអាណត្តិទី១មានឯកឧត្តម ស៊ីណា ថាន់ ជាសមាជិករដ្ឋសភាសព្វថ្ងៃនេះ ដែលជាអតីតអគ្គលេខានៃរដ្ឋសភាជាតិ លោកបានបញ្ជាក់ជូន ។ សូមអរព្រះគុណ ។ ក្រសួងមហាផ្ទៃមានកិត្តិយសដ៏ខ្ពង់ខ្ពស់

ស្នើសុំព្រះរាជអនុញ្ញាតនិងអនុញ្ញាត សម្តេចព្រះប្រធាន សម្តេចអនុប្រធានទី១ អ្នកអង្គម្ចាស់ក្សត្រីយ៍ លោកជំទាវ និងឯកឧត្តម ទ្រង់មេត្តានិងមេត្តាធ្វើការអនុម័តលើបេក្ខភាពឯកឧត្តម ឃ្លោក ប៊ុតឌី ដោយអនុគ្រោះតាមការគួរ ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** សូមអរគុណព្រះអង្គ ។ យោងមាត្រា៤០ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា វាក្យខណ្ឌទី១ ដែលចែងថាវិធីបោះឆ្នោតសម្ងាត់ត្រូវតែប្រើក្នុងការជ្រើសតាំងការសម្តែងការទុកចិត្តនិងការអនុម័តញត្តិបន្ទោស យោងមាត្រា១៣ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ វាក្យខណ្ឌទី៣ដែលចែងថា ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ យ៉ាងតិច៧ខែមុនថ្ងៃបោះឆ្នោត តាមសំណើរបស់គណៈរដ្ឋមន្ត្រី ក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។ ខ្ញុំសូមលេខាធិការអង្គប្រជុំមេត្តាចាប់ឆ្នោតជ្រើសរើសគណៈកម្មការបោះឆ្នោតចំនួន៥រូប សូមអញ្ជើញចាប់ ។ ឯកឧត្តម ម៉ៅ មុនីវណ្ណ, ឯកឧត្តម ស៊ិន ពិនសេន, លោកជំទាវ កែ សុវណ្ណារ័ត្ន, ឯកឧត្តម ប៊ូ ថង, ឯកឧត្តម យឹម សុវណ្ណ (អវត្តមាន) , ឯកឧត្តម អ៊ឹង ប៊ុនហួរ ។ គ្រប់ហើយ ។

ជាបឋមខ្ញុំសូមអញ្ជើញគណៈកម្មការបោះឆ្នោតទាំង៥រូបអញ្ជើញមកខាងមុខ ។ គណៈកម្មការបោះឆ្នោតនេះមានភារកិច្ចដូចតទៅ: ១) ពិនិត្យវត្តមានតំណាងរាស្ត្រសរុបឡើងវិញ ២) រាប់សន្លឹកឆ្នោតដែលត្រូវចែកជូនឲ្យបានគ្រប់តាមចំនួនវត្តមាន ៣) ចែកសន្លឹកឆ្នោតជូនអ្នកតំណាងរាស្ត្រ ៤) បញ្ជាក់ឡើងវិញពីចំនួនសន្លឹកឆ្នោតបានទទួលឬមិនបានទទួល ៥) បង្ហាញសន្លឹកឆ្នោតនិងណែនាំពីបែបបទនៃការគូសសន្លឹកឆ្នោត ៦) អញ្ជើញតំណាងរាស្ត្របោះឆ្នោត ៧) បញ្ជាក់ឡើងវិញថាតើតំណាងរាស្ត្រទាំងអស់បានអញ្ជើញមកបោះឆ្នោតហើយឬនៅ ៨) រាប់សន្លឹកឆ្នោតដែលបានបោះរួចហើយ ៩) រាយការណ៍ជូនប្រធានអង្គប្រជុំអំពីលទ្ធផលនៃការបោះឆ្នោត ។ ខ្ញុំសូមមេត្តាពិនិត្យឡើងវិញ ។

**គណៈកម្មការបោះឆ្នោត:** ទូលព្រះបង្គំសូមក្រាបថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមគោរពសម្តេចអនុប្រធានទី១ សូមគោរពសម្តេចនាយករដ្ឋមន្ត្រី សម្តេចក្រុមឃុន ឯកឧត្តមលោកជំទាវ និងថ្វាយបង្គំព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រីយ៍ ទូលព្រះបង្គំគណៈកម្មការបោះឆ្នោត សូមទូលថ្វាយចំពោះវត្តមានតំណាងរាស្ត្រដែលមានវត្តមាននៅពេលព្រឹកនេះគឺ១១០ នាក់លើ១២៣ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** សូមមេត្តារាប់សន្លឹកឆ្នោតឲ្យគ្រប់ ដើម្បីចែកឲ្យគ្រប់វត្តមាន១១០ ។

**គណៈកម្មការបោះឆ្នោត:** ក្រាបបង្គំទូលថ្វាយសន្លឹកឆ្នោតដែលមានគឺ១១០ តាមវត្តមានរបស់តំណាងរាស្ត្រ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** មេត្តាឯកឧត្តមធ្វើការណែនាំថ្វាយនិងជូនទៅតាមរបៀបនៃការបោះនិងគូស ។

**គណៈកម្មការបោះឆ្នោត:** សូមក្រាបបង្គំទូលថ្វាយនិងជម្រាបជូនពីរបៀបនៃការបោះឆ្នោត ។ នៅក្នុងសន្លឹកឆ្នោតជ្រើសតាំងនេះគឺមានបីចំណុចគឺ ព្រម មិនព្រម និងអនុបវាទ ។ តាមការសម្រេចព្រះទ័យ តាមការសម្រេចចិត្តរបស់ឯកឧត្តម សូមមេត្តាបោះឆ្នោតតាមព្រះទ័យសម្រេច ក្រាបទូល ។ បើសិនជាព្រមសូមគូសនៅកន្លែងនេះ នៅត្រគូចនេះគឺព្រម មិនព្រម និងអនុបវាទ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** អរគុណ ។ សូមអញ្ជើញ ស្តេចយាងព្រះអង្គ អញ្ជើញបោះឆ្នោត ។

**គណៈកម្មការបោះឆ្នោត:** បាទ ព្រះអង្គ សូមសម្តេចប្រធាន អនុប្រធាន មេត្តាយាងក្រាបទូល ។ សូមជួរទី១ សូមសម្តេចនាយកសម្តេចខប ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** ឯកឧត្តម សម រង្ស៊ី លោកលើកដៃ សុំធ្វើបទអន្តរាគមន៍ ។ ខ្ញុំសូមរំឭកថ្វាយនិងជូនថាក្រោយពីខ្ញុំសនាមបង្ហាញបេក្ខភាពឯកឧត្តម ឃ្លោក ប៊ុតឌី ខ្ញុំពុំបានទទួលនូវសំណើដើម្បីធ្វើបទអន្តរាគមន៍ពាក់ព័ន្ធទៅនឹងបេក្ខភាពនោះទេ ។ ឯកឧត្តម សម រង្ស៊ី លោកអញ្ជើញមកយឺត ហើយខ្ញុំចាប់អនុវត្តនូវដំណើរការនៃការបោះឆ្នោតរួចហើយ បានខ្ញុំបានទទួលនូវសំណើរបស់ឯកឧត្តម សម រង្ស៊ី ។ សូមអរព្រះគុណនិងអរគុណ ។

ការសម្រេចនូវវត្តមានអ្នកតំណាងរាស្ត្រនៅថ្ងៃនេះ សម័យប្រជុំលើកទី១ នីតិកាលទី៣ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ វត្តមានតាមគណបក្ស គណបក្សប្រជាជនកម្ពុជា៦៦រូប គណបក្សហ៊្វុនស៊ិនប៉ិច២២រូប គណបក្សសមរង្ស៊ី ចំនួន២២រូប សរុបចំនួន១១០ ។ អវត្តមានតាមគណបក្ស គណបក្សប្រជាជន៧ គណបក្សហ៊្វុនស៊ិនប៉ិច៤ គណបក្សសមរង្ស៊ី ២ សរុប១៣រូប ។ សូមអរព្រះគុណ សូមអរគុណ ។

**គណៈកម្មការបោះឆ្នោត៖** ទូលបង្គំយើងខ្ញុំសូមជម្រាបជូនដូចតទៅ គឺចំនួនដែលបានយល់ព្រមគឺ៩០សំឡេង ចំនួនមិនយល់ព្រម ១៦សំឡេង អនុបវាទ២សំឡេង មោឃៈ២សំឡេង ។ របាយការណ៍សូមក្រាបបង្គំទូលថ្វាយអស់ក្រាបទូល ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ៖** អរព្រះគុណ យោងតាមការប្រកាសលទ្ធផលអម្បាញ់មិញនេះ លទ្ធផលនៃការបោះឆ្នោត ឯកឧត្តម ឃ្យោក ប៊ុតឌី ទទួលបានសន្លឹកឆ្នោតព្រមចំនួន៩០សំឡេង មិនព្រមចំនួន១៦ ចំនួនអនុបវាទចំនួន២សំឡេង និងមោឃៈចំនួន២សំឡេង ។ ខ្ញុំសូមទូលថ្វាយនិងជម្រាបអង្គសភាថា ឯកឧត្តម ឃ្យោក ប៊ុតឌី ត្រូវបានរដ្ឋសភាជាតិបោះឆ្នោតជ្រើសតាំងជាអនុប្រធាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ នាសម័យប្រជុំសភាលើកទី១ នីតិកាលទី៣ សូមសម្តេចឯកឧត្តមទាំងអស់មេត្តាជ្រាបពត៌មាន ។ សូមអរព្រះគុណ ។

របៀបវារៈទី៧៖ ការពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងរបៀបវារៈទី៧-ក យើងនឹងពិនិត្យពិភាក្សានិងអនុម័តមុន ហើយរបៀបវារៈទី៧-ខ យើងធ្វើពេលក្រោយ ។ យោងសេចក្តីសម្រេចរបស់អង្គប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍នារសៀលថ្ងៃពុធ ទី២២ ខែកញ្ញា ឆ្នាំ២០០៤ ខ្ញុំសូមអញ្ជើញឯកឧត្តមប្រធាន ឯក សំអុល ប្រធានគណៈកម្មការនីតិកម្ម អញ្ជើញមករាយការណ៍ជូនអង្គសភាពីការពិនិត្យពិភាក្សាស្រាវជ្រាវលើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ សូមអញ្ជើញឯកឧត្តម ។

**ឯកឧត្តម ឯក សំអុល៖** សូមក្រាបថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមគោរពសម្តេចអនុប្រធានទី១ សូមគោរពសម្តេចនាយករដ្ឋមន្ត្រី សូមក្រាបបង្គំទូលថ្វាយនិងគោរពសម្តេច ឯកឧត្តម លោកជំទាវ អស់លោកលោកជំទាវ សមាជិកសមាជិកាដ៏ឧត្តុង្គឧត្តមនៃរដ្ឋសភាជាទីគោរព ។ តាងនាមគណៈកម្មការនីតិកម្មនិងគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិឃោសនាការនិងពត៌មាននៃរដ្ឋសភា ទូលព្រះបង្គំខ្ញុំបាទសូមទ្រង់ព្រះអនុញ្ញាតនិងអនុញ្ញាតនាំមកនូវយោបល់របស់គណៈកម្មការទាំង២មកទូលថ្វាយនិងជម្រាបជូនអង្គសភាក្នុងការពិនិត្យនិងសិក្សាសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២, មាត្រា៣, មាត្រា៩, មាត្រា១០, មាត្រា១១, មាត្រា១៤, មាត្រា១៧, មាត្រា១៨, មាត្រា២០, មាត្រា២១, មាត្រា២២, មាត្រា២៣, មាត្រា២៤, មាត្រា២៧, មាត្រា២៩, មាត្រា៣១, មាត្រា៣៣, មាត្រា៣៤, មាត្រា៣៥, មាត្រា៣៦, មាត្រា៣៧, មាត្រា៣៩, មាត្រា៤០, មាត្រា៤២, មាត្រា៤៣, មាត្រា៤៤, មាត្រា៤៥, មាត្រា៤៦, និងមាត្រា៤៧ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីនូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដូចតទៅ៖

១) អំពីទម្រង់ច្បាប់៖ សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជា-

ធិបតេយ្យ និងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២, មាត្រា៣, មាត្រា៩, មាត្រា១០, មាត្រា១១, មាត្រា១៤, មាត្រា១៧, មាត្រា១៨, មាត្រា២០, មាត្រា២១, មាត្រា២២, មាត្រា២៣, មាត្រា២៤, មាត្រា២៧, មាត្រា២៩, មាត្រា៣១, មាត្រា៣៣, មាត្រា៣៤, មាត្រា៣៥, មាត្រា៣៦, មាត្រា៣៧, មាត្រា៣៩, មាត្រា៤០, មាត្រា៤២, មាត្រា៤៣, មាត្រា៤៤, មាត្រា៤៥, មាត្រា៤៦, និងមាត្រា៤៧ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរាជរដ្ឋាភិបាលបញ្ជូនមករដ្ឋសភាតាមលិខិតលេខ ១១៩ ល.ស.ក.ច.ប. ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៤ ដោយមានភ្ជាប់សេចក្តីថ្លែងថែម លេខ ១២ ស.ជ.ណ.ក.ប.ច. ចុះថ្ងៃទី៩សីហា ឆ្នាំ២០០៤ មកជាមួយផង ព្រមទាំងសេចក្តីព្រាងច្បាប់ថតចម្លងចំនួន១២៣ច្បាប់ដែលបានចែកថ្វាយជូនសមាជិកសមាជិការដ្ឋសភារួចហើយ ។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ក្រោយពីបានពិនិត្យនិងពិភាក្សា នាពេលប្រជុំកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៤ បានឯកភាពបញ្ជូនសេចក្តីព្រាងច្បាប់ទាំង២នេះមកគណៈកម្មការនីតិកម្ម ដោយសហការជាមួយគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពត៌មាននៃរដ្ឋសភា ដើម្បីពិនិត្យនិងសិក្សាតាមលិខិតលេខ ១៣១ រ.ស. ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៤ ។ ឆ្លើយតបនឹងការទទួលយកភារកិច្ចខាងលើនេះ គណៈកម្មការនីតិកម្មបានប្រជុំគ្នាកាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៤ ដើម្បីសិក្សាស្រាវជ្រាវបឋម ។ បន្ទាប់មកនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៤ គណៈកម្មការនីតិកម្មបានសហការជាមួយគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពត៌មាននៃរដ្ឋសភា បានប្រជុំជាផ្លូវការជាមួយគណៈប្រតិភូតំណាងរាជរដ្ឋាភិបាលដឹកនាំដោយឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានឯកភាពគ្នាថា សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២, មាត្រា៣, មាត្រា៩, មាត្រា១០, មាត្រា១១, មាត្រា១៤, មាត្រា១៧, មាត្រា១៨, មាត្រា២០, មាត្រា២១, មាត្រា២២, មាត្រា២៣, មាត្រា២៤, មាត្រា២៧, មាត្រា២៩, មាត្រា៣១, មាត្រា៣៣, មាត្រា៣៤, មាត្រា៣៥, មាត្រា៣៦, មាត្រា៣៧, មាត្រា៣៩, មាត្រា៤០, មាត្រា៤២, មាត្រា៤៣, មាត្រា៤៤, មាត្រា៤៥, មាត្រា៤៦, និងមាត្រា៤៧ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានដាក់ថ្វាយជូនអង្គសភាពិភាក្សានិងអនុម័តនៅពេលនេះគឺបានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ដែលបានចែងក្នុងប្រការ២១នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។

២) អំពីគតិច្បាប់៖ តាមការសិក្សាស្រាវជ្រាវរបស់គណៈកម្មការនីតិកម្មនិងគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងពត៌មាននៃរដ្ឋសភា យើងខ្ញុំយល់ឃើញដូចតទៅ៖

ក) សេចក្តីព្រាង ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យគឺ កិច្ចព្រមព្រៀងនេះនិយាយជារួមគោរពបាននូវស្មារតីនៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ន.ស.រ.ត.ម. ០៨០១១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដោយគ្រាន់តែបានបញ្ជាក់នូវខ្លឹមសារមួយចំនួនដែលមានស្រាប់នៅក្នុងច្បាប់នេះ ព្រមទាំងសម្រួលរចនាសម្ព័ន្ធតុលាការ និងកែសម្រួលកិច្ចការរដ្ឋបាលខ្លះៗប៉ុណ្ណោះ ។ សេចក្តីបញ្ជាក់សំខាន់ៗមានដូចខាងក្រោមនេះ÷

ក១) កិច្ចព្រមព្រៀងនេះត្រូវអនុវត្តឲ្យដូចជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាក្រោយពីទទួលសច្ចាប័នសមស្របតាមច្បាប់ផ្ទៃក្នុងកម្ពុជាស្តីពីសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញា ។

ក-២) រាជរដ្ឋាភិបាលបញ្ជាក់ជាថ្មីនូវការដែលខ្លួននឹងពុំស្នើឲ្យមានការលើកលែងទោសឬការអនុគ្រោះជាថ្មីទៀតទេ ។ រាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិបានឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសដែលមានពីមុននោះនឹងត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ។

ក-៣) សមាសភាពអង្គជំនុំជម្រះមាន២ថ្នាក់គឺ អង្គជំនុំជម្រះសាលាដំបូងមានចៅក្រមខ្មែរ ៣រូប ចៅក្រមបរទេស២រូប និងអង្គជំនុំជម្រះតុលាការកំពូលដែលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផងនិងសម្រេចសេចក្តីបិទផ្លូវតវ៉ាផង គឺមានចៅក្រមខ្មែរ៤រូប ចៅក្រមអន្តរជាតិ៣រូប ។

ក-៤) នីតិវិធីត្រូវឲ្យសមស្របជាមួយច្បាប់កម្ពុជា ។ នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបាន គេនឹងស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតស្តង់ដារអន្តរជាតិ ។

ក-៥) អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងត្រូវអនុវត្តតាមយុត្តាធិការរបស់ខ្លួន និងដំណើរការសមស្របរបស់ច្បាប់ដូចចែងក្នុងមាត្រា១៤និងមាត្រា១៥នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលកម្ពុជាជាភាគីហត្ថលេខីដែរ ។

ខ) ដើម្បីឲ្យមានភាពរលូនរវាងច្បាប់និងកិច្ចព្រមព្រៀង និងដើម្បីងាយស្រួលក្នុងការអនុវត្តចាំបាច់ត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មចំនួន២៩មាត្រានៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានដាក់ជូនអង្គសភាពិភាក្សានិងអនុម័តនៅពេលនេះ ខ្លឹមសារទាំងឡាយសុទ្ធតែត្រូវបានដកស្រង់ចេញពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនូវក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលមានដូចតទៅៈ

ខ-១) ការកែប្រែអាជ្ញាយុកាលៈ ដើម្បីធានាឲ្យអង្គជំនុំជម្រះវិសាមញ្ញមានសិទ្ធិធ្វើការចោទប្រកាន់ក្នុងរយៈពេលនៃដំណើរការរបស់ខ្លួននោះ អាជ្ញាយុកាលត្រូវតែពន្យារពេលពី២០ឆ្នាំទៅ៣០ឆ្នាំ ពីព្រោះអាជ្ញាយុកាលនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញដែលបានពន្យារ២០ឆ្នាំនោះ ត្រូវផុតកំណត់នៅឆ្នាំ២០០៥ខាងមុខនេះ ។

ខ-២) ការកែសម្រួលរចនាសម្ព័ន្ធៈ រចនាសម្ព័ន្ធនៅអង្គជំនុំជម្រះវិសាមញ្ញដែលមាន៣ថ្នាក់ត្រូវបានកែសម្រួលមកត្រឹម២ថ្នាក់ដើម្បីចៀសវាងនូវភាពស្មុគស្មាញផ្នែករដ្ឋបាលនិងការចំណាយថវិកាច្រើន គឺអង្គជំនុំជម្រះសាលាដំបូងមានចៅក្រមខ្មែរ៣រូប ដែល១រូបធ្វើជាប្រធាន និងចៅក្រមអន្តរជាតិ២រូប អង្គជំនុំជម្រះតុលាការកំពូលមានចៅក្រមខ្មែរ៤រូបដែល១រូបធ្វើជាប្រធាន និងចៅក្រមអន្តរជាតិ៣រូប ជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផងនិងសម្រេចសេចក្តីបិទផ្លូវតវ៉ាផង ។

ខ-៣) ចែងបញ្ជាក់បន្ថែមអំពីសិទ្ធិពេញលេញរបស់ចុងចោទនិងអភ័យឯកសិទ្ធិសម្រាប់មន្ត្រីតុលាការ និងមេធាវីចុងចោទដោយផ្អែកលើអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឆ្នាំ១៩៦៦ ។

ខ-៤) ចែងបន្ថែមអំពីនីតិវិធីឲ្យបានច្បាស់លាស់ថែមទៀតថា ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពមិនសមស្របទៅនៃនីតិវិធីទាំងអស់នេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ខ-៥) អំពីការលើកលែងទោសនិងការអនុគ្រោះទោសៈ ដោយបានបញ្ជាក់បន្ថែមថា វិសាលភាពនៃការលើកលែងទោសនិង

ការអនុគ្រោះទោសដែលអាចផ្តល់ឲ្យមុនការអនុម័តច្បាប់នេះ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ។

ក្រៅពីវិសោធនកម្មលើខ្លឹមសារដូចបានទូលថ្វាយនិងជម្រាបខាងលើនេះ នៅមានវិសោធនកម្មបន្ទាប់បន្សំមួយចំនួនទៀតដូចជា បន្ថែមលក្ខខណ្ឌចៅក្រមដែលត្រូវតែងតាំងហើយបម្រើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវមានបទពិសោធន៍ រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់សិទ្ធិមនុស្សផង ។ ចំណុចទី២ គឺអំពីការជ្រើសរើសចៅក្រម សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតអន្តរជាតិឲ្យបំពេញកន្លែងទំនេរ និងលោកអគ្គលេខាអង្គការសហប្រជាជាតិអាចផ្តល់បញ្ជីឈ្មោះបេក្ខជនថ្មីបន្ថែម ។ ចំណុចទី៣ សហព្រះរាជអាជ្ញាអន្តរជាតិមានសិទ្ធិតែងតាំងសហព្រះរាជអាជ្ញារងអន្តរជាតិ ។ ចំណុចទី៤ ការបកស្រាយបំភ្លឺលើមាត្រា៣៣ថ្មី មាត្រា៣៨ថ្មី និងមាត្រា៣៥ថ្មី ត្រូវអនុវត្តដូចគ្នាចំពោះការជំនុំជម្រះក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល ។ ចំណុចទី៥ ចែងអំពីភាពមិនអាចរំលោភបាននៃបណ្ណសារដែលប្រើប្រាស់ផ្នែកណាមួយនៃអង្គជំនុំជម្រះវិសាមញ្ញ រួមមានសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ។ ចំណុចទី៦ ការបន្ថយភាសាប្រើប្រាស់ជាផ្លូវការមកនៅត្រឹម៣ភាសាគឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។ ចំណុចទី៧ លុបចោល មូលនិធិស្មគ្រចិត្តនិងមន្ត្រីរដ្ឋបាលបុគ្គលិក អន្តរជាតិ សហចៅក្រមជម្រះក្តី សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាអន្តរជាតិជាបន្ទុករបស់ប្រទេសដែលបានបញ្ជូនមកតាមសំណើរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ក្នុងការពិនិត្យនិងសិក្សាសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មនេះ គណៈកម្មការនីតិកម្មនិងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការនិងព័ត៌មាននៃរដ្ឋសភា បានឯកភាពជាមួយតំណាងរាជរដ្ឋាភិបាលធ្វើវិសោធនកម្មលើមាត្រា២ទៀតគឺ មាត្រា២៩និងមាត្រា៣៩ ពីព្រោះមាត្រាទាំងពីរនេះដែលបានចែងយោងលើមាត្រា៣នេះត្រូវបានធ្វើវិសោធនកម្មរួចហើយ ។ ដូច្នេះត្រូវកែសម្រួលទៅជាមាត្រា៣ថ្មីដូចមានអត្ថបទសេចក្តីព្រាងច្បាប់លើកទី២ ថ្វាយនិងជូនរួចហើយ ។

ក្រោយពីបានពិនិត្យនិងសិក្សាលើខ្លឹមសារលម្អិតនៃសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម២៩មាត្រាស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីនូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជារួចមក គណៈកម្មការនីតិកម្មនិងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការនិងព័ត៌មាននៃរដ្ឋសភាបានឯកភាពជាមួយតំណាងរាជរដ្ឋាភិបាល សូមដាក់សេចក្តីព្រាងច្បាប់ទាំងពីរនេះថ្វាយនិងជូនអង្គសភាពិភាក្សានិងអនុម័តក្នុងមួយពេលប្រជុំនាព្រឹកនេះ ដោយសំណូមពរដល់អង្គសភានូវអាទិភាពទី១ ឬ"ក" គឺការពិភាក្សានិងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងអាទិភាពទី២ ឬចំណុច"ខ" គឺពិភាក្សាអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២, មាត្រា៣, មាត្រា៩, មាត្រា១០, មាត្រា១១, មាត្រា១៤, មាត្រា១៧, មាត្រា១៨, មាត្រា២០, មាត្រា២១, មាត្រា២២, មាត្រា២៣, មាត្រា២៤, មាត្រា២៧, មាត្រា២៩, មាត្រា៣១, មាត្រា៣៣, មាត្រា៣៤, មាត្រា៣៥, មាត្រា៣៦, មាត្រា៣៧, មាត្រា៣៩, មាត្រា៤០, មាត្រា៤២, មាត្រា៤៣, មាត្រា៤៤, មាត្រា៤៥, មាត្រា៤៦, និងមាត្រា៤៧ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ តាមនីតិវិធីពិភាក្សានិងអនុម័តមួយមាត្រាម្តងៗ ដោយចាត់ទុកជាការប្រញាប់តាមការគួរ ។ សូមអរព្រះគុណនិងអរគុណ ។

***សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:*** អរគុណឯកឧត្តមប្រធាន ។ យោងតាមមាត្រា២៩ថ្មីនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដែលបានចែងថា ការពិភាក្សានៃសេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់ត្រូវធ្វើដូចតទៅៈ ១) អង្គសភាពិភាក្សានិងអនុម័តលើខ្លឹមសារទាំងមូល

គឺបញ្ចេញមតិតើគួរទទួលយកមកពិចារណាឬទេ? ខ្ញុំសូមអង្គសភាមេត្តាអនុម័តលើខ្លឹមសារទាំងមូលថា តើគួរយកមកពិចារណាឬទេ?

**លេខានៃអង្គប្រជុំៈ** សូមក្រាបថ្វាយបង្គំសម្តេចព្រះប្រធាន សំឡេងគាំទ្រមានចំនួន១១០លើ១១០ ។ សូមអរព្រះគុណនិងអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ** អរគុណណាស់ ។ មុននឹងអញ្ជើញឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងសហការី អញ្ជើញមកការពារច្បាប់ ខ្ញុំសូមជូនវេទិកាទៅឯកឧត្តម សម រង្ស៊ី ។

**ឯកឧត្តម សម រង្ស៊ីៈ** ទូលបង្គំសូមអរព្រះគុណសម្តេចប្រធាន ។ សូមគោរពអង្គសភាទាំងមូល ។ អ្វីដែលខ្ញុំមានបំណងនិយាយថ្ងៃនេះគឺចង់និយាយពីដើមទីកាលពីអង្គប្រជុំចាប់ផ្តើមក៏បាន ចង់និយាយពេលនេះក៏បាន ។ អ្វីដែលចង់និយាយគឺសុំកោតសសើរដំណើរការនៃរដ្ឋសភាថ្ងៃនេះ ដោយបានធ្វើទៅដោយបានគោរពបទបញ្ជាផ្ទៃក្នុងនិងគោរពស្មារតីនៃលទ្ធិប្រជាធិបតេយ្យ ។ យើងរៀបចំការបោះឆ្នោតរើសបុគ្គលឲ្យកាន់តំណែងណាមួយ ជាពិសេសថ្ងៃនេះគឺតំណែងអនុប្រធាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយនិងមានការបោះឆ្នោតអនុម័តយល់ព្រមគាំទ្រផ្តល់សច្ចាប័នចំពោះកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ កាលពីបោះឆ្នោតអម្បាញ់មិញមុននេះគឺយើងបានគោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យ គោរពបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដោយយើងបោះឆ្នោតដោយសម្ងាត់ដើម្បីជ្រើសរើសបុគ្គលម្នាក់ឲ្យកាន់តំណែងមួយ ។ ជាគោលការណ៍ជាទូទៅគឺយើងត្រូវតែគោរពច្បាប់គោលការណ៍ទម្លាប់បែបនេះ ពីព្រោះបុគ្គលណាក៏ដោយដើម្បីមានភាពថ្លៃថ្នូរក្នុងការកាន់តំណែងណាក៏ដោយកាន់ដោយភាពថ្លៃថ្នូរត្រូវឲ្យសភាជ្រើសរើសបោះឆ្នោតដោយសម្ងាត់ ។ បុគ្គលបែបនេះមានភាពថ្លៃថ្នូរ ពីព្រោះបុគ្គលបែបនេះចេះគោរពភាពថ្លៃថ្នូររបស់តំណាងរាស្ត្រ គោរពសិទ្ធិអ្នកតំណាងរាស្ត្រ គោរពមនសិការអ្នកតំណាងរាស្ត្រម្នាក់ៗដែលគេបោះឆ្នោតឲ្យខ្លួនតាមតែគម្រូវចិត្ត តាមតែមនសិការបោះឆ្នោតដោយសម្ងាត់ឲ្យខ្លួន ។ បើបុគ្គលណាក៏ដោយចង់កាន់តំណែងណាមួយ បង្ខំឲ្យគេលើកដៃឲ្យខ្លួនដើម្បីឲ្យខ្លួនបានជាប់ជាតំណែង បុគ្គលនោះខ្វះភាពថ្លៃថ្នូរ ហើយតំណែងរបស់ខ្លួនរបៀប ដែលខ្លួនកាន់កាប់ក៏ខ្វះភាពថ្លៃថ្នូរដែរ ពីព្រោះចាំតែកត់ឈ្មោះអ្នកណាដែលមិនបោះឆ្នោតឲ្យខ្លួនដើម្បីទៅរករឿងគេ គំរាមកំហែងគេ កុំកួនទៅថ្ងៃក្រោយ ធ្វើឲ្យអ្នកតំណាងរាស្ត្រមានការភ័យខ្លាច ។ តំណែងដែលខ្លួនមកកាន់តាមរបៀបនេះគឺមិនសមរម្យនិងខ្វះភាពថ្លៃថ្នូរ ។ វិលត្រឡប់មករឿងបោះឆ្នោតផ្តល់សច្ចាប័នឲ្យកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា គណបក្សសមរង្ស៊ី តំណាងរាស្ត្រគណបក្សសមរង្ស៊ីទាំងអស់ សូមគាំទ្រពេញទំហឹងថា ត្រូវយកសេចក្តីព្រាងច្បាប់ត្រូវយកកិច្ចព្រមព្រៀងនេះយកមកពិភាក្សាដើម្បីឲ្យរដ្ឋសភាអនុម័តឲ្យបានឆាប់រហ័ស ពីព្រោះរឿងនេះជារឿងបន្ទាន់ ។ តាំងពីឆ្នាំ១៩៩៧មកគឺរឿងនេះជារឿង៧ឆ្នាំមកហើយដែលរាជរដ្ឋាភិបាលបានស្នើឲ្យអង្គការសហប្រជាជាតិកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវក្នុងការសម្លាប់ប្រជារាស្ត្រខ្មែរស្លូតត្រង់រាប់លាននាក់ ។ ប្រជារាស្ត្រខ្មែររង់ចាំការផ្តល់យុត្តិធម៌ជូនលោក ជូនចំពោះវិញ្ញាណក្ខន្ធអ្នកដែលបានបាត់បង់ជីវិតទៅហើយ ហើយជូនចំពោះក្រុមគ្រួសារមិត្តភក្តិដែលមានជីវិតនៅឡើយ ដូច្នេះគ្មានអ្វីដែលមានសារសំខាន់ជាងការផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ។ ហើយការផ្តល់យុត្តិធម៌ជូនជនរងគ្រោះនេះ មិនមែនមានសារសំខាន់គ្រាន់តែជម្រះបញ្ជីរឿងចាស់ទេ គឺយើងកាត់ទោសអ្នកដែលបានសម្លាប់មនុស្សស្លូតត្រង់រាប់សែនរាប់លាននាក់នោះ ជាកាតព្វកិច្ចរបស់យើង ជាការចាំបាច់សម្រាប់ប្រទេសជាតិយើងឈានទៅរកនីតិរដ្ឋ ឈានទៅរកការបញ្ចប់នូវទម្លាប់អាក្រក់មួយដែលអ្នកមានអំណាច អ្នកមានហៅថាបុណ្យស័ក្តិតំណែងខ្ពង់ខ្ពស់កាប់សម្លាប់គេតាមចិត្ត ប្រព្រឹត្តបទឧក្រិដ្ឋគ្រប់បែបយ៉ាងតាមចិត្ត តែមិនដែលទទួលទោសម្តងណាទេ ពីព្រោះយកអំណាចរបស់ខ្លួនមកបិទបាំង ឬមករំលងជាន់ឈ្លីនូវច្បាប់ជាធរមាន ។ ទម្លាប់បែបនេះអាក្រក់ណាស់ ធ្វើឲ្យមានភាពអនាធិបតេយ្យ មានការជិះជាន់មានការរំលោភច្បាប់គ្រប់បែបយ៉ាង ធ្វើឲ្យប្រទេសយើងស្ថិតក្នុងភាពក្រីក្រ ភាពអន់ថយជានិច្ចកាលមិនអាចរីកចម្រើន មិនអាចឈានទៅមុខបានទេ ពីព្រោះកត្តាជាចាំបាច់ដើម្បីឲ្យប្រទេសនីមួយៗរីកចម្រើនទៅបានលុះត្រាតែមានការគោរពច្បាប់ តែទម្លាប់ដ៏អាក្រក់ដែលយើងហៅថានិទណ្ឌភាពនេះ គឺធ្វើឲ្យប្រទេសយើងស្ថិតនៅក្នុងភាពអន់ថយ និងភាពក្រីក្រ ធ្វើឲ្យប្រជារាស្ត្ររស់នៅក្នុង

ភាពភ័យខ្លាច ធ្វើឲ្យលទ្ធិប្រជាធិបតេយ្យស្ថិតនៅក្នុងភាពទន់ខ្សោយជានិច្ច ។ ដូច្នេះអាទិភាពធំជាងគេបង្អស់ដែលប្រទេសយើងត្រូវតែបំពេញគឺធានាឲ្យមានការគោរពច្បាប់ ។ ការគោរពច្បាប់ធំជាងគេបង្អស់ សំខាន់ជាងគេបង្អស់គឺនាំជនឧក្រិដ្ឋមកឆ្លើយចំពោះមុខតុលាការ ហើយត្រូវផ្តន្ទាទោសជនឧក្រិដ្ឋតាមច្បាប់ ។ បើអ្នកដែលសម្លាប់គេរាប់លាននាក់ ទោះជា១០ឆ្នាំមកហើយ ២០ឆ្នាំមកហើយ ២៥ឆ្នាំមកហើយក៏ដោយ បើយើងបណ្តោយឲ្យជនឧក្រិដ្ឋរួចខ្លួន តើជនឧក្រិដ្ឋសព្វថ្ងៃបើសម្លាប់គេហើយ បើមានអំណាចការពារខ្លួនផងទៀតនោះ គឺច្បាស់ជារួចខ្លួនដែរហើយ ។ បើអ្នកសម្លាប់គេរាប់លាននាក់រួចខ្លួន អ្នកដែលមកកាន់អំណាចពេលក្រោយសម្លាប់គេតែ១ពាន់នាក់ក៏រួចខ្លួន ១០នាក់ក៏រួចខ្លួន ម្នាក់ក៏រួចខ្លួន ។ បើអ៊ីចឹងទម្លាប់នេះយើងត្រូវតែបញ្ចប់ ហើយដើម្បីបញ្ចប់ត្រូវតែជំរុញឲ្យមានតុលាការមួយ តុលាការពិសេសដែលមានអង្គការសហប្រជាជាតិមានសហគមន៍អន្តរជាតិចូលរួមដើម្បីធានានូវភាពឯករាជ្យ ។ តុលាការពិសេសនោះត្រូវតែដំណើរការឲ្យបានឆាប់ មកកាត់ទោសមេដឹកនាំខ្មែរក្រហមជាបន្ទាន់ ។ ហើយក្នុងឱកាសនេះ ខ្ញុំសូមស្នើឲ្យរាជរដ្ឋាភិបាលមានចិត្តស្មោះត្រង់និយាយអ៊ីឲ្យច្បាស់លាស់ កុំរកលេសពីមួយទៅមួយ ម្តងថាអ៊ីចេះ ម្តងថាអ៊ីចុះ ដើម្បីពន្យារពេល ចំណេញពេល ដាក់ស្ពែងរារាំងមិនឲ្យតុលាការនេះចេញរួច៧ឆ្នាំហើយ ។ ឥឡូវល្មមបញ្ចប់ បញ្ឈប់នូវការរង់ចាំ គឺថាសុំឲ្យរាជរដ្ឋាភិបាលរៀបចំថវិកា ពីព្រោះរឿងថវិកានេះជាលេសចុងក្រោយដែលរដ្ឋាភិបាលយកមកដាក់ចំពោះមុខដើម្បីរារាំងពន្យារពេលដើម្បីកុំឲ្យតុលាការនេះចេញរួច ទោះជាថ្ងៃប៉ុន្មានក៏ដោយ ក៏រដ្ឋាភិបាលគួរណាស់ចូលរួម ចូលរួមលើសពីនិមិត្តរូបចូលរួមក្នុងកម្រិតមួយសមរម្យ ។ បើយើងចង់ឲ្យគេផ្តល់យុត្តិធម៌ឲ្យយើង យើងថា ទេ! រឿងនេះបើអន្តរជាតិចង់បង្កើតតុលាការឲ្យអន្តរជាតិចេញលុយទៅ ។ និយាយបែបនេះមិនសមរម្យទេ យើងពឹងអន្តរជាតិ តែយើងមុននឹងចង់ឲ្យគេជួយយើង យើងត្រូវចេះជួយខ្លួនយើងផងដែរ ។ យើងត្រូវតែចេះផ្តល់នូវការរួមចំណែកថាយើងក៏ចង់បាន យើងក៏ខិតខំអស់ពីសមត្ថភាពរបស់យើង ពីព្រោះយើងក៏យល់ថាជាអាទិភាពទីមួយក្នុងការដឹកនាំប្រទេសជាតិដែរ ។ ទោះជាមានការប៉ាន់ស្មានថវិកាប្រមាណ៥០លានដុល្លារ ៦០លានដុល្លារ បើយើងប្រៀបធៀបទៅនឹងចំណាយថវិកាជាតិមួយឆ្នាំៗ៧០០-៨០០លានដុល្លារ ជំនួយអន្តរជាតិមួយឆ្នាំៗ៥០០លាន ៦០០លានដុល្លារ យើងច្បាស់ជាមានលទ្ធភាពចូលរួមក្នុងកម្រិតមួយសមរម្យ ។ បើយើងពិនិត្យមើលទំហំនៃអំពើពុករលួយនៅប្រទេសកម្ពុជាតាមរបាយការណ៍ដែលធនាគារពិភពលោកបានវាយតម្លៃនៃអំពើពុករលួយចំពោះឧស្សាហកម្មតែពីរគត់ៈ ឧស្សាហកម្មកាត់ដេរនិងឧស្សាហកម្មទេសចរណ៍ ចំពោះក្រុមហ៊ុនធំៗ ធនាគារពិភពលោកដែលគេមានជំនាញក្នុងការធ្វើវិភាគបែបនេះ គេបានបង្ហាញថា អំពើពុករលួយធ្វើឲ្យរដ្ឋបាត់បង់ចំណូល១១០លានដុល្លារ គឺលើសអំពីអ៊ីដែលត្រូវការដើម្បីរៀបចំតុលាការពិសេសដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនោះពីរដង ។ នេះខ្ញុំនិយាយគ្រាន់តែឧស្សាហកម្មតែពីរនេះ តើមានឧស្សាហកម្មសកម្មភាពសេដ្ឋកិច្ចដទៃទៀតដែលមានអំពើពុករលួយ សូម្បីចំពោះអ្នករកស៊ីតូចតាច អ្នកលក់ដូរតូចតាច កសិករតូចតាច ក៏រងគ្រោះដោយអំពើពុករលួយ ។ បើយើងបូកសរុបទៅ អំពើពុករលួយមិនតិចជាងរាប់ពាន់លានដុល្លារ ចូលដល់១ពាន់លានដុល្លារ ។ ដូច្នេះយើងត្រូវតែខិតខំជំរុញឲ្យរដ្ឋាភិបាលប្រទេសកម្ពុជាគិតគូររឿងនេះឲ្យបានត្រឹមត្រូវ ។ បើរឿងណាអត់ប្រយោជន៍ឬមួយមានប្រយោជន៍តិចតួច ប្រយោជន៍សម្រាប់តែក្រុមអ្នកដឹកនាំបក្សពួកគេ គឺមិនដែលខ្វះទេ លុយរកបានជានិច្ច ។ រៀបចំកិច្ចប្រជុំអាយប៉ូ *AIPO* មិនដឹងជាបានប្រយោជន៍អីអស់រាប់លានដុល្លារ ។ សង់រដ្ឋសភា អ្នកជំនាញគេវាយតម្លៃតែ១៣លានដុល្លារ អស់២៦-២៧លានដុល្លារ ។ ការចាយវាយព្រោងព្រាតអត់ប្រយោជន៍គឺរដ្ឋាភិបាលរកលុយបានជានិច្ច តែដល់តុលាការមួយដែលជាការចាំបាច់សម្រាប់អនាគតប្រទេសជាតិ ឥឡូវថារកលុយមិនបានទេ ឲ្យអន្តរជាតិចេញឲ្យទាំងស្រុង ។ មិនសមរម្យទេ សូមឲ្យរដ្ឋសភាគ្រប់គណបក្សទាំងអស់ មានតំណាងឲ្យប្រជារាស្ត្រខ្មែរទាំងមូល ប្រជារាស្ត្រខ្មែរទាំងមូលត្រូវការយុត្តិធម៌ ស្រេកឃ្លានយុត្តិធម៌ រង់ចាំយុត្តិធម៌ យើងត្រូវតែជំរុញឲ្យរាជរដ្ឋាភិបាលផ្តល់ថវិកាគ្រប់គ្រាន់ដើម្បីឲ្យអង្គការសហប្រជាជាតិរៀបចំតុលាការពិសេសនេះជាបន្ទាន់ កុំឲ្យរដ្ឋាភិបាលនេះរកលេសកិកកុកពន្យារពេលក្នុងការបង្កើតតុលាការពិសេសដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ទោះជាហេតុផលណាក៏ដោយ ទោះជាមានអតីតខ្មែរក្រហមខ្លះនៅក្នុង

ផ្លូវរដ្ឋាភិបាលសព្វថ្ងៃក៏ដោយ ក៏មិនមែនជាហេតុផលមួយដើម្បីពន្យារពេលក្នុងការបង្កើតតុលាការពិសេសនេះទេ ។ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ** អរគុណឯកឧត្តម ។ សូមអញ្ជើញសម្តេចនាយករដ្ឋមន្ត្រី ។

**សម្តេច ហ៊ុន សែនៈ** សូមក្រាបថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា សម្តេចអនុប្រធានទីមួយ សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ។ ការពិតទៅតាមសុខភាពទូលបង្គំមិនសមបើនឹងនិយាយទេ ដោយសារ២៤ម៉ោងរហូតមកដល់ពេលនេះគឺប្រហែល ២០-៣០ម៉ោងហើយដែលទូលបង្គំមិនបានសម្រាកមួយស្រឡេតសោះ ប៉ុន្តែទូលបង្គំមានឆន្ទៈដើម្បីមកចូលរួមបោះឆ្នោតសម្រាប់ ឯកឧត្តម ឃ្លោក ប៉ុគឌី និងចូលរួមដើម្បីនឹងពិភាក្សាទាក់ទិនជាមួយនឹងច្បាប់នេះ ។ ដូច្នេះសុខភាពទូលបង្គំមិនអនុគ្រោះទេសម្រាប់ការ និយាយ ប៉ុន្តែអ្វីដែលទូលបង្គំចង់បញ្ជាក់នៅទីនេះគឺដំបូងបំផុត ការអំពាវនាវធំបំផុតនោះគឺនៅត្រង់ថា ការពិនិត្យនិងអនុម័តនូវសច្ចាប័ន កិច្ចព្រមព្រៀងក៏ដូចជាវិសោធនកម្មច្បាប់នេះឲ្យបានឆាប់ ។ បញ្ហាអ្វីដែលគួរតែឆ្ងល់គឺវានៅត្រង់ថា មនុស្សខ្លះ បើមិនបានទិតៀនគេ វាយប្រហារគេ តើវារន្ធុះបាញ់ឬក៏វាថី? មុខរបរហ្នឹងតើជាទំនាយមកវាត្រូវតែនិយាយដេរគេដេរឯង វាយប្រហារគេ វាយប្រហារឯង រាប់ទាំងអាយប៉ូ និងបើមិនបានវាយប្រហារគេ ចេញទៅវិញរន្ធុះបាញ់ឬស្អី? បានតែគ្រប់ទាំងប្រជុំពេលណា ក៏ដូចជាពេលណា ។ យើងត្រូវគោរពសិទ្ធិរបស់គេផង ស្នេហាជាតិអីតែឯង គណបក្សខ្លួនឯង? ចុះគេអ្នកដទៃទៀតវាយ៉ាងម៉េច? អម្បាញ់មិញប៉ះពាល់ ដល់អាយប៉ូ ប៉ះពាល់ដល់រដ្ឋាភិបាល ឥឡូវទូលបង្គំ រឿងបក្សប្រឆាំង ប្រឆាំងគឺរឿងមិនចម្លែកទេ វាអត់ចម្លែក ។ បក្សប្រឆាំងមិន ប្រឆាំងទើបវាចម្លែក ប៉ុន្តែអ្វីដែលគួរឆ្ងល់គឺបញ្ហាត្រង់ថា ឲ្យតែឡើងហួសក្បាល១០ម៉ាត់គឺត្រូវតែប្រទេចផ្តាសាគេ ទិតៀនគេ វាយ ប្រហារគេ ទោះបីជាមិនមែនជាប្រធានបទក៏វាត្រូវតែក្លាយទៅជាប្រធានបទដែរ ។ អីចឹងសួរថា ឥឡូវហ្នឹងពីនេះទៅមុខ បើមិនបានដេរគេ មិនបានទិតៀនគេ រន្ធុះបាញ់ឬអី? ឬក៏វាជាហ្សែនរបស់មនុស្សក្នុងមួយរបបត្រូវតែមានកូនមួយហ្នឹងដើម្បីប្រឆាំង ។ ឥឡូវអាហ្នឹងថា ហ្សែន ។ កាលពីដើមឆ្នាំ១៩៥៩ អាហ្នឹងវាប្រឆាំងជាមួយសង្គមរាស្ត្រនិយមដែរ ឥឡូវមកដល់ដំណាក់កាលនេះទៀត ។ ប៉ុន្តែអានេះ ជាបញ្ហាដែលទូលបង្គំដាក់ជាចម្ងល់ ព្រោះគេមានសិទ្ធិនឹងនិយាយ ទូលបង្គំក៏ត្រូវមានសិទ្ធិនិយាយដែរក្នុងឋានៈជាតំណាងរាស្ត្រម្នាក់ មិនមែនឋានៈរដ្ឋាភិបាល អាហ្នឹងរឿងផ្សេង ។ ក៏ប៉ុន្តែបើថាមកបើកវេទិកាក្តៅម៉ាស៊ីនប្រើប នាំគ្នាគិតសួរទៅវិញមើល សួរថារន្ធុះវាបាញ់ ឬស្អី ឬទៅវិញវាក្រឡាប់ឡានវាអី បានវាចេះតែមកដល់បន្តតែហេតុនៅពេញតែសភា ឬក៏ហ្សែន? អាហ្នឹងហើយដែលហៅថា សម្តីសជាតិមារយាទសព្វជនោះ ។ លើសតែពីហ្នឹងទៅ ១លានដុល្លារ ១ពាន់លានដុល្លារ ១០០លានដុល្លារ យូរៗអាយប៉ូពុករលួយ គ្មានបានការអីទៀត ។ កាលប្រជុំអាស៊ាន បាតុកម្មទៅដេកក្នុងវត្តប្រលោមឯណាឯណោះ ពេញទឹកពេញដីឯណាឯណោះថាប្រមុខ រដ្ឋាភិបាល ប្រមុខរដ្ឋអាស៊ាន អាស៊ានបូកបីមិនបានការ ឥឡូវវាទៅអាយប៉ូហ្នឹងអត់បានការទៅទៀត រឿងតែផ្តេសផ្តាស ។ នេះ ទូលបង្គំសូមអភ័យទោសទុកជាមុន បើសិនជាមានការប៉ះពាល់ស្អី ព្រោះថាបើនិយាយរួមឡើងមកប្រដៅតែម្តង និយាយឲ្យច្បាស់ តែម្តង ។ សូមអរព្រះគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ** លោកនាយករដ្ឋមន្ត្រី ចំពោះបញ្ហាអាយប៉ូនេះខ្ញុំសូមមិនឆ្លើយទេ ដូចសម្តេចនាយកមាន ប្រសាសន៍អីចឹង វាចាកប្រធាន ។ ដូច្នេះសូមឯកឧត្តមអនុប្រធានទីពីរទទួលការខុសត្រូវ ឯកឧត្តម ជាម យៀប មេត្តានៅពេលណា សមស្របដើម្បីនឹងផ្តល់ជាថ្មីម្តងទៀត មិនដឹងជាលើកទីប៉ុន្មានទេនូវការបំភ្លឺជូនដល់រដ្ឋសភាជាតិ រាជរដ្ឋាភិបាល ដែលសម្តេចនាយក រដ្ឋមន្ត្រីលោកបានអនុញ្ញាតឲ្យប្រើប្រាស់នូវវេទិកាជាតិជាការចាំបាច់ ពីព្រោះនេះជាកាតព្វកិច្ចពាក់ព័ន្ធនឹងកិត្តិយសកិត្យានុភាពរបស់ ស្ថាប័នកំពូលគឺរដ្ឋសភាជាតិ ដែលជាលើកដំបូង ហើយក្រោយពី២៤ឆ្នាំមានការបង្កើតនូវអាយប៉ូ ។ យើងទទួលនូវកិត្តិយសរៀបចំនូវ មហាសន្និបាតនេះ ប្រទេសណាក៏គេធ្វើគ្រប់តែគ្នាអីចឹង ។ ចំពោះឯកឧត្តមមានប្រសាសន៍ថាមិនដឹងជាបានការអី ហើយភ្ជាប់គ្នាតែម្តង រដ្ឋសភាថ្មីមួយទៀត ដូច្នេះឯកឧត្តម ជាម យៀប ក្នុងឋានៈខ្ញុំជាប្រធានរដ្ឋសភាអាណត្តិទីពីរ សុំឲ្យឯកឧត្តមបង្កើតនូវគណៈកម្មាធិការ មួយដើម្បីរៀបចំដេញថ្លៃ ក្នុងការសាងសង់រដ្ឋសភានេះ ហើយឆ្លៀតឱកាសនេះផងដែរ ឯកឧត្តមវាគ្មិនបានប្រសាសន៍ថា ចាយ

លើសថវិកាជាតិ ខ្ញុំបានសរសេរលិខិតពីរហើយជូនទៅសម្តេចនាយករដ្ឋមន្ត្រីថា សុំឲ្យលោកមេត្តាផ្តល់នូវថវិកាមួយចំនួនជូនដល់ក្រុមហ៊ុនសាងសង់ ។ និយាយដល់បញ្ហាពុករលួយនេះ តាមខ្ញុំមើលទៅ តាមខ្ញុំវាយតម្លៃទៅ ក្រុមហ៊ុនបានផ្តល់ថវិកាផ្ទាល់ប្រហែលជា៧លានដុល្លារហើយ ក៏ប៉ុន្តែរាជរដ្ឋាភិបាលដោយមានបញ្ហាខ្វះខាត លោកក៏មិនទាន់បានផ្តល់នូវថវិកាគឺ១លានជាង ប្រហែលប៉ុណ្ណឹង ។ ដូច្នេះនិយាយរឿងពុករលួយនេះ បានលុយអីមកសូក ខ្ញុំមិនទាន់បានទទួលថវិកានេះផង ចំណាយថវិការបស់ក្រុមហ៊ុនថែមទៀត ។ ដូច្នេះសូមជម្រាបបញ្ហានេះផងដែរ សូមជម្រាបអង្គប្រជុំឲ្យជ្រាបថា ច្រើនរបបមកហើយតាំងពីឆ្នាំ១៩៤៧ អគារនេះដែលជាអគារសាងសង់ដោយបារាំងនៅឆ្នាំ១៩១៧ ហើយបានចប់សព្វគ្រប់នៅឆ្នាំ១៩២២ ហើយដែលព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងពេលនោះកំពុងច្បាំងពិភពលោកទី១ ប្រោសព្រះរាជទាននូវរដ្ឋធម្មនុញ្ញទាន់សម័យមួយដែលមានលក្ខណៈប្រជាធិបតេយ្យនៅឆ្នាំ១៩៤៧ ។ ចាប់ពីពេលនោះរហូតមកដល់ពេលនេះ អគារនេះបានក្លាយខ្លួនទៅជាអគារនៃរដ្ឋសភាជាតិ ។ យើងខ្ញុំទាំងអស់គ្នាដោយមានការរួមចំណែកពីសម្តេចនាយករដ្ឋមន្ត្រី យល់ថាជាឱកាសដើម្បីសាងសង់នូវរដ្ឋសភាជាតិមួយថ្មីជូនដល់ប្រទេសជាតិ មាតុភូមិ ។ បើយើងនិយាយអំពីប្រជាធិបតេយ្យអគារថ្មីនេះ មានលក្ខណៈជាខ្មែរសុទ្ធសាធ ហើយត្រៀមនូវបន្ទប់ការិយាល័យជូនដល់សមាជិកសមាជិកានៃរដ្ឋសភាទាំងអស់ គ្រប់គ្នាទាំងអស់ ។ ត្រៀមកន្លែងប្រជុំជូនដល់គណបក្សទាំងអស់ដែលមានវត្តមាន ។ គណបក្សមួយត្រូវមានកន្លែងប្រជុំមួយជូន ។ ហើយគណៈកម្មាធិការទាំងអស់ក៏លោកនឹងមានកន្លែងធ្វើការសមរម្យ សមស្របទៅនឹងអ្វីមួយដែលគេហៅថាតំណាងឲ្យប្រទេសជាតិ តំណាងឲ្យរាស្ត្រទាំងមូល ។ នេះការវាយតម្លៃ ។ ខ្ញុំសូមឲ្យឯកឧត្តម ជាម យៀប កុំធ្វើនៅថ្ងៃនេះ ក៏ប៉ុន្តែថ្ងៃណាជម្រាបក្នុងការដេញថ្លៃនេះ ។ល ។និង ។ល ។ ហើយសូមបញ្ជាក់ថ្វាយជូនឲ្យច្បាស់ថា ពេលដែលខ្ញុំសម្រេចខ្ញុំបានជម្រាបជូនឯកឧត្តមប្រធាន ជាម យៀប ច្បាស់ណាស់ថា ដោយសារខ្ញុំមានឋានៈជាប្រធានរដ្ឋសភា ខ្ញុំសូមឯកឧត្តម ចៀសវាងឲ្យខ្ញុំមានការប៉ះពាល់ ឬក៏ពាក់ព័ន្ធទៅក្នុងបញ្ហាដេញថ្លៃនេះ មានគណៈកម្មាធិការរបស់គេ ប៉ុន្តែចុងក្រោយ ឯកឧត្តម ជាម យៀប ថាក្នុងឋានៈខ្ញុំជាគណបក្សដើមខ្សែ គេសុំឲ្យខ្ញុំចុះហត្ថលេខាលើកិច្ចព្រមព្រៀង ខ្ញុំក៏ត្រូវតែចុះ បើមិនធ្វើយ៉ាងដូច្នេះទេ យើងពុំមានលទ្ធភាពទៅបើកថវិកាជូនជាតិ ។ ខ្ញុំសូមចប់តែប៉ុណ្ណឹង ។ ហើយចំពោះបក្សប្រឆាំង ខ្ញុំសូមជម្រាបថា យោងទៅលើកិច្ចព្រមព្រៀងរវាងគណបក្សប្រជាជនកម្ពុជានិងគណបក្សហ្វ៊ុនស៊ិនប៉ិច យើងបានចរចាច្បាស់នៅក្នុងកម្មវិធីនយោបាយ៧៣ចំណុចថា យើងនឹងកែធ្វើវិសោធនកម្មលើច្បាប់ស្តីអំពីគណបក្សនយោបាយ ដើម្បីទទួលស្គាល់នូវបក្សប្រឆាំងមួយស្របច្បាប់ នឹងគង់តែមិនហៅថា La position de Sa Majesté ដូចនៅប្រទេសអង់គ្លេសក៏ដោយ ក៏ប៉ុន្តែគណបក្សទាំងពីរ គណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច បានសម្រេចថានឹងកែច្បាប់ថ្មីៗនេះ ច្បាប់ស្តីអំពីគណបក្សនយោបាយ ។ ថ្មីៗនេះខ្ញុំបានជួបឯកឧត្តមអគ្គលេខានៃអង្គការកំពូលសភាអាយភីយូ IPU ក៏ខ្ញុំបានស្នើសុំជំនួយគេក្នុងការរៀបចំធ្វើវិសោធនកម្មលើច្បាប់នេះផងដែរថែងស្តីអំពីបក្សប្រឆាំង ប៉ុន្តែខ្ញុំសុំគេដោយទទូចថាបក្សប្រឆាំងនេះសុំឲ្យធ្វើជាបក្សប្រឆាំងក្នុងន័យស្ថាបនាមិនមែនក្នុងន័យបរិហារ ។ អត់ភ័ស្តុតាង គេហៅបរិហារហើយ ។ ក្នុងន័យស្ថាបនាជួយជំរុញប្រទេសជាតិមាតុភូមិយើងក្នុងការអភិវឌ្ឍន៍ ដើរតួនាទីរបស់ខ្លួនជាបក្សប្រឆាំងមានការថ្លៃថ្នូរ មានកិត្តិយសកិត្យានុភាពថែមទៀតសមស្របទៅនឹងអ្វីមួយដែលប្រទេសជាតិយើងធ្លាប់តែមានពីអតីតកាលមក ។ សូមអរព្រះគុណ សូមអរគុណ ។ ខ្ញុំសូមអញ្ជើញឯកឧត្តម ជាម យៀប មេត្តាមានមតិលើច្បាប់ឬសច្ចាប័ននេះពីរឿងអាយប៉ូដែលមិនបានការ ហើយនិងរឿងរដ្ឋសភាប្រហែលក៏មិនបានការដែរនោះ សូមឯកឧត្តមទុកទៅថ្ងៃក្រោយ សូមអញ្ជើញមានប្រសាសន៍ស្តីអំពីអ្វីមួយដែលយើងកំពុងតែពិភាក្សាគ្នាថ្ងៃនេះ ។ សូមអរគុណ ។

**ឯកឧត្តម ជាម យៀបៈ** ទូលបង្គំសូមថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា សម្តេចអនុប្រធានទីមួយ សូមគោរពសម្តេចនាយករដ្ឋមន្ត្រី និងសូមថ្វាយបង្គំព្រមទាំងគោរពចំពោះអង្គសភាទាំងមូលជាទីស្នេហ ។ ជារួមក្រោយអំពីបានស្តាប់នូវព្រះតម្រិះរបស់សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា ហើយក៏ដូចអម្បាញ់មិញ គឺសម្តេចព្រះប្រធានបានធ្វើការណែនាំជាអនុសាសន៍សម្រាប់រដ្ឋសភាយើងរួចហើយ ទូលបង្គំគ្រាន់តែ...។ ក្នុងច្បាប់ស្តីអំពីការផ្តល់សច្ចាប័ននេះ ទូលបង្គំក្រោយពីបានទទួល...

ទូលបង្គំយល់ឃើញថា សព្វថ្ងៃនេះគឺដើមចោទកំពុងតែរង់ចាំនូវអ្វីដែលច្បាប់នេះត្រូវរដ្ឋសភាលោកអនុម័តយល់ព្រម ក៏ដូចជាធ្វើវិសោធនកម្ម ហើយបញ្ហាសំខាន់ណាស់យើងឃើញថា ថ្វីដ្បិតតែច្បាប់នេះមានការវែងអន្លាយបន្តិចក៏ដោយ ទូលបង្គំយល់ឃើញថាអ្នកខ្លះគេចោទថា៧ឆ្នាំរាជរដ្ឋាភិបាលគឺជាអ្នករារាំង អ្នកដែលថាទេដែលជាអ្នករារាំង។ រាជរដ្ឋាភិបាល លោកខិតខំគ្រប់បែបយ៉ាងទាំងអស់ ពីព្រោះថាដើម្បីឲ្យចេញរួច វាត្រូវមើលទិដ្ឋភាពទាំងឡាយដែលគួបផ្សំធ្វើម៉េចឲ្យការងារទាំងហ្នឹងចេញរួចដោយមូលហេតុស្អីខ្លះ? ទីមួយ ការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ត្រូវមានការពាក់ព័ន្ធទៅនឹងអង្គការសហប្រជាជាតិ វាចាំបាច់ត្រូវតែមាននិយាយគ្នាយ៉ាងម៉េចៗខ្លះនោះ ពីព្រោះជាកិច្ចការងារអន្តរជាតិមិនមែនជាការងារកម្ពុជាតែឯងទេ។ ហើយកម្ពុជាដែលជាប្រទេសក្រីក្រ លោក សម រង្ស៊ី ទទួលស្គាល់មិញដែរថាក្រីក្រ។ តែក្រីក្រដែលយើងថា គ្មានលុយ មិនមែនគ្មានលុយដោយសារតែយើងពន្យារអារឿងហ្នឹងទេ។ យើងពិនិត្យទិដ្ឋភាពតាំងពីដំបូងឡើង ពីព្រោះវេជ្ជបណ្ឌិតម្នាក់ដែលមើលជំងឺមានប្រសិទ្ធភាពខ្ពស់ត្រូវតែស្គាល់ជំងឺហ្នឹងឲ្យច្បាស់។ យើងក៏អ៊ីចឹងដែរ យើងពិនិត្យមើលថាតើគោលការណ៍កន្លងមកយ៉ាងម៉េចរវាងការរៀបចំនិងច្បាប់ទម្លាប់។ ខ្ញុំយល់ឃើញថាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលមានការណែនាំផ្ទាល់ពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺថាលោកខិតខំគ្រប់បែបយ៉ាង រហូតដល់អង្គការសហប្រជាជាតិដកថយមួយរយៈពេលទៅវិញ យើងមិនយកអាពេលអស់ហ្នុងមកពិនិត្យមើលឡើងវិញទេ ហើយប្រការជាប់គាំងនយោបាយរបស់យើងកន្លងមកនេះតទៅទៀត យើងឃើញថានេះជាគោលការណ៍សំខាន់ទូលបង្គំមិនលើកឡើងច្រើនទេ។ ហើយម្យ៉ាងទៀត ទូលបង្គំយល់ឃើញថា ការងារនេះពាក្យថាអន្តរជាតិមួយម៉ាត់វាត្រូវមានជាតិនិងអន្តរជាតិ។ ជាតិនិងអន្តរជាតិហ្នឹងវាចាំបាច់ត្រូវគេចូលរួម។ ហើយការចូលរួមហ្នឹងអ៊ីចឹងដែរ ពីព្រោះការចូលរួមដូចជាអំណោយ គឺថាយើងជាអ្នកតំណាងរាស្ត្រយើងដឹងទាំងអស់គ្នាហើយ អំណោយរបស់គេ ការជួយរបស់គេ គេមិនមែនឲ្យយើងទៅលីលុយ សម្តេច ហ៊ុន សែន លោកទៅលីលុយមកពីស្រុកគេមកទេ។ លុយគេមកឲ្យហ្នឹងគឺថាទោះបីមួយរៀលរបស់គេដែលឲ្យមក គេសម្លឹងទាល់តែចង់ខ្វាក់ភ្នែកបានមកដល់យើង ហើយគេឲ្យគ្នាគេនោះមកចាយលុយគេនៅក្នុងស្រុកយើងទៀត។ អ៊ីចឹងកន្លងទៅយើងឃើញថា លុយបដិភាគរបស់រដ្ឋគឺចាំបាច់ត្រូវមាន ក្នុងនាមទូលបង្គំជាប្រធានគណៈកម្មាធិការហិរញ្ញវត្ថុធនាគារទូលបង្គំបានយល់អំពីអ្វីដែលរាជរដ្ឋាភិបាលបានធ្វើរយៈកាលកន្លងមក។ ទូលបង្គំជារួមគឺសូមសម្តែងនូវការគាំទ្រយ៉ាងខ្លាំងចំពោះច្បាប់នេះ ហើយក៏ដូចជាឯកឧត្តម ឯក សំអុល លោកបានលើកសុំដល់រដ្ឋសភាយើង គឺឲ្យពិនិត្យពិចារណាឲ្យបានឆាប់រហ័ស ទូលបង្គំសូមឯកភាពទាំងស្រុង។ សូមអស់យោបល់ សូមអរព្រះគុណ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** សូមអរគុណឯកឧត្តម។ អញ្ជើញឯកឧត្តម លី ធុច។

**ឯកឧត្តម លី ធុច:** សូមក្រាបថ្វាយព្រះបង្គំសម្តេចព្រះប្រធានដ៏ខ្ពស់ខ្ពស់ សម្តេចអនុប្រធានទីមួយ សម្តេចនាយករដ្ឋមន្ត្រី សម្តេចឧប ឯកឧត្តមឧប អង្គសភាទាំងមូលជាទីគោរព។ ថ្ងៃនេះជាថ្ងៃប្រវត្តិសាស្ត្រដែលអង្គសភាយើងរៀបចំផ្តល់នូវការអនុម័តទាក់ទងទៅនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហមជាការបោះឆ្នោតស្វែងរកយុត្តិធម៌ជូនជាតិមាតុភូមិនិងប្រជាពលរដ្ឋ ជាការបោះឆ្នោតដើម្បីអនាគតបញ្ចប់នូវអតីតកាលដ៏ជូរចត់ដែលប្រជាពលរដ្ឋខ្មែរយើងបានទទួលរងគ្រោះ។ ថ្ងៃនេះឆ្នាំ២០០៤ បើគិតទៅប្រមាណ២៩ឆ្នាំ បន្ទាប់ពីរបបប្រល័យពូជសាសន៍បានបំផ្លិចបំផ្លាញ ប្រទេសកម្ពុជារបស់យើង របប៣ឆ្នាំ៨ខែ២០ថ្ងៃកន្លងមកនេះបានបន្សល់ទុកនូវកេរមរតកយ៉ាងធ្ងន់ធ្ងរ។ ប្រជាពលរដ្ឋយើងរាប់លាននាក់ស្លាប់ ស្ត្រីមេម៉ាយរាប់សែនរាប់ម៉ឺននាក់ កុមារកំព្រាបែកបាក់គ្រួសារ ពិការ អត្តសញ្ញាណជាតិ តម្លៃជាតិ ព្រលឹងជាតិ ក៏បានបាត់បង់ដោយសាររបបប្រល័យពូជសាសន៍។ សេដ្ឋកិច្ចហេដ្ឋារចនាសម្ព័ន្ធជាតិយើងក៏បានខ្ទេចខ្ទាំដោយសាររបបនោះដែរ។ ក្នុងនាមជាតំណាងរាស្ត្រផង ក៏ក្នុងនាមជាកុមារកំព្រាម្នាក់ដែលកំព្រាតាំងពី៩ឆ្នាំដែលប៉ុលពតសម្លាប់ឪពុកម្តាយទាំងអស់ ក្នុងនាមសភាថ្ងៃនេះ ទូលព្រះបង្គំខ្ញុំបាទសូមថ្លែងនូវអំណរអរគុណនូវកតញ្ញូតាធម៌ដឹងគុណដោយពុំអាចបំភ្លេចបានចំពោះព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះមហាក្សត្រដែលព្រះអង្គបាន

បញ្ចេញនូវព្រះមាគ៌ានយោបាយបង្រួបបង្រួមជាតិផ្សះផ្សាជាតិ បានញ៉ាំងឲ្យមានសន្តិភាពនៅប្រទេសកម្ពុជា ។ ថ្លែងអំណរគុណនិង អំណរព្រះគុណនិងដឹងគុណដល់ខ្ពង់ខ្ពស់ចំពោះសម្តេចក្រុមព្រះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលព្រះអង្គជាព្រះប្រមុខនិង ប្រមុខរដ្ឋាភិបាលអាណត្តិទីមួយនិងបន្តបន្ទាប់បានបញ្ចេញនូវគោលនយោបាយបង្រួបបង្រួមនិងផ្សះផ្សាជាតិ ការចរចាឈ្នះៗ គឺជា នយោបាយឈ្នះ ជាតិខ្មែរមានទឹកដីតែមួយ សញ្ជាតិតែមួយ និងរដ្ឋាភិបាលតែមួយ ។ ...ទូលបង្គំឃើញឯកឧត្តម សុខ អាន នឹងត្រៀមអន្តរាគមន៍ ក៏សូមជាចុងបញ្ចប់នេះ សូមឯកឧត្តមមេត្តាបំភ្លឺបកស្រាយបន្តិចនូវទំព័រទីមួយដែលនិយាយអំពីប្រយោគទីពីរ មាត្រា២ថ្មី ដែលលើកឡើងដើម្បីប្រជុំជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់ បំផុត ។ ចំណុចនេះ បងប្អូនប្រជាពលរដ្ឋយើងនិងសង្គមស៊ីវិលនិងមតិជាតិលោកមានសំណូមពរចង់បានឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាបកស្រាយ ដើម្បីឲ្យលោកបានជ្រាបនិងដឹងពុងផងដែរ តើមេដឹកនាំជាន់ខ្ពស់និងអ្នកពាក់ព័ន្ធខ្ពស់បំផុតនេះជាបុគ្គលឬក៏ជាប្រធាន អង្គភាពប្រភេទណាដែលអាចប៉ះពាល់ឬក៏ពាក់ព័ន្ធនឹងច្បាប់ដែលយើងនឹងអនុម័តកន្លងទៅនេះ សូមអរព្រះគុណនិងអរគុណ ។

***សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:*** *សូមអរគុណឯកឧត្តម ។ ខ្ញុំសូមអញ្ជើញឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ព្រមទាំងសហការី ដែលមានឯកឧត្តម អង្គ វង្ស វឌ្ឍនា, ឌិម យិនទៀង, អ៊ុក វិធន់, ហេង វង្ស ប៊ុនឆាត និង ស៊ាន វិសុទ្ធ សូមមេត្តាអញ្ជើញមកកាន់វេទិកា ។ សូមអញ្ជើញឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន សូមអញ្ជើញមកការពារច្បាប់នៅលើវេទិកាខាងមុខនេះ អរគុណច្រើន ។*

***ឯកឧត្តម សុខ អាន:*** *ទូលបង្គំសូមថ្វាយបង្គំព្រះអង្គសម្តេចព្រះប្រធាន សម្តេចអនុប្រធាន សូមគោរពសម្តេចនាយករដ្ឋមន្ត្រី សូមថ្វាយបង្គំសម្តេចព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ ជាសមាជិកនៃរដ្ឋសភាដ៏ខ្ពង់ខ្ពស់ឧត្តមរបស់យើង ។ ទូលបង្គំ សូមថ្លែងអំណរគុណចំពោះសម្តេចព្រះប្រធានដែលបានអនុញ្ញាតឲ្យទូលបង្គំឡើងមកទូលថ្វាយនិងជម្រាបជូនរដ្ឋសភាដ៏ខ្ពង់ខ្ពស់ឧត្តម របស់យើងអំពីចំណុចធំពីរគឺ: ទីមួយ ការផ្តល់នូវសច្ចាប័នទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ ទីពីរ គឺការធ្វើវិសោធនកម្មទៅលើច្បាប់ដែលយើងបានចូលជាធរមានរួចហើយ ប៉ុន្តែទាក់ទិនទៅនឹងកិច្ចព្រមព្រៀងដែលយើងបានចុះ ហត្ថលេខាជាមួយអង្គការសហប្រជាជាតិ ។ ថ្ងៃនេះទូលបង្គំខ្ញុំសូមព្រះរាជានុញ្ញាតនិងអនុញ្ញាតពីអង្គសភាដ៏ខ្ពង់ខ្ពស់ឧត្តមថ្វាយនិងដាក់ជូន អង្គសភានូវសេចក្តីព្រាងច្បាប់ពីរក្នុងចំណោមសេចក្តីព្រាងច្បាប់ប្រកបដោយអាទិភាពខ្ពស់ជាងគេ ដែលត្រូវបានអនុម័តដោយសម័យ ប្រជុំគណរដ្ឋមន្ត្រីលើកដំបូងនៃរាជរដ្ឋាភិបាលកម្ពុជាថ្មី ។ យើងអាចឈានទៅបញ្ចប់លើទិដ្ឋភាពច្បាប់នៃបញ្ហាមួយដែលមាន សារសំខាន់ដ៏ធំធេងចំពោះប្រជាជនកម្ពុជា និងចំពោះមនុស្សជាតិ គឺជាបញ្ហាមួយដែលនៅមិនទាន់បានដោះស្រាយរយៈពេល មួយភាគបួននៃសតវត្សរ៍មកហើយ ។ យើងខ្ញុំដាក់ជូនអង្គសភាដ៏ខ្ពង់ខ្ពស់ឧត្តមនូវសេចក្តីព្រាងច្បាប់ពីរដែលពាក់ព័ន្ធគ្នាទៅវិញទៅមក ដែលយើងអាចនិយាយជាភាសាអង់គ្លេសថា The two sides of the same coin ។ នោះគឺសេចក្តីព្រាងច្បាប់ស្តីពីការអនុម័ត យល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបង្កើត ឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជា- ធិបតេយ្យ ។ យើងទាំងអស់គ្នាចាំបានថា បីឆ្នាំមុន គឺក្នុងឆ្នាំ២០០១ រដ្ឋសភាអាណត្តិទីពីរបានអនុម័តសេចក្តីព្រាងច្បាប់ចុងក្រោយ នេះដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ក្នុងឆ្នាំដដែល ដោយព្រះមហាក្សត្រព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ។ គោលបំណងនៃសេចក្តីព្រាងច្បាប់ថ្ងៃនេះក៏ដូចជាខ្លឹមសារដែលទូលព្រះបង្គំខ្ញុំបាទបានទូលថ្វាយនិងជម្រាបជូនអង្គសភានៅ ពេលនោះដែរ ដើម្បីឲ្យសមស្របទៅនឹងការដែលយើងបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិក្នុងខែកក្កដា ឆ្នាំ១៩៩៧ ហើយតាំងពីមុនពេលនោះមក រាជរដ្ឋាភិបាលយើងបានប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់ៗដូចតទៅ: គោលការណ៍ទីមួយ គឺផ្តល់ យុត្តិធម៌ដល់វិញ្ញាណក្ខន្ធរបស់ប្រជាជនកម្ពុជារាប់លាននាក់ដែលបានបាត់បង់ជីវិតទៅ និងដល់ជនរងគ្រោះដែលបានរស់រានមានជីវិត*

ពីយុគសម័យខ្មៅងងឹតនៃប្រវត្តិសាស្ត្រកម្ពុជា ។ គោលការណ៍ទីពីរគឺការថែរក្សាសន្តិភាពស្ថិរភាពនយោបាយនិងបង្រួបបង្រួមជាតិដែលកម្ពុជាទើបសម្រេចបានក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ។ គោលការណ៍ទីបីគឺការគោរពដល់អធិបតេយ្យរបស់យើងដែលជាគោលការណ៍គ្រឹះមួយក្នុងចំណោមគោលការណ៍គ្រឹះទាំងឡាយនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ។ ការគោរពដល់គោលការណ៍អធិបតេយ្យជាតិត្រូវបានរំលេចឲ្យឃើញនៅក្នុងច្បាប់និងកិច្ចព្រមព្រៀងដូចខាងក្រោមនេះ ។ ចំណុចនេះទូលបង្គំខ្ញុំបាទសុំបញ្ជាក់ថា គឺគោលការណ៍ទាំងបីនេះហើយដែលធ្វើឲ្យយើងបានទទួលជោគជ័យដែលយើងឆ្លងកាត់ការចរចានិងការដែលជជែកគ្នាយ៉ាងតឹងតែងអស់រយៈពេល៧ឆ្នាំនេះ ដែលយើងផ្អែកទៅលើគោលការណ៍ទាំងបីដែលរឹងមាំរបស់យើងនេះ ហើយដែលទីបំផុតគឺធ្វើឲ្យអ្នកច្បាប់ធំៗណាស់ ឧទាហរណ៍ អង្គការសហប្រជាជាតិអ៊ីចឹង គឺអគ្គលេខាធិការរង ដែលជាអ្នកច្បាប់ទាំងអស់នៃអង្គការសហប្រជាជាតិគឺបានឯកភាពមកលើគោលជំហរមួយចំនួនធំដែលយើងបានលើកឡើង ។ អ៊ីចឹងគោលការណ៍ទាំងបីនេះហើយ ជាពិសេសគោលការណ៍ទីបីដែលយើងបានលើកឡើងថាត្រូវរំលេចឡើងនូវការគោរពអធិបតេយ្យភាពជាតិកម្ពុជា ព្រោះថានេះជាបញ្ហារបស់កម្ពុជា ហើយកាលដែលអ្នកម្ចាស់រឿងជាអ្នកដែលត្រូវតែមានជំហរច្បាស់លាស់ និងត្រូវតែមានការសម្រេចឬក៏ចែករំលែកការសម្រេចយ៉ាងណាឲ្យសមទៅតាមគោលការណ៍ដែលថា យើងជាម្ចាស់ផ្ទះ ប៉ុន្តែយើងពឹងពាក់អញ្ជើញអង្គការសហប្រជាជាតិមកចូលរួមជាមួយយើង ។ ដូច្នេះ ទោះបីដែលអង្គការសហប្រជាជាតិលោកអញ្ជើញមកជួយក៏ដោយ ក៏ត្រូវតែធ្វើម៉េចឲ្យឃើញថាកម្ពុជាជាម្ចាស់រឿង កម្ពុជាត្រូវមានសំឡេង កម្ពុជាត្រូវមានយោបល់ច្បាស់លាស់ក្នុងការសម្រេចបញ្ហាដ៏សំខាន់ដែលមានលក្ខណៈជាប្រវត្តិសាស្ត្រនេះ ។ ដូច្នេះសួរថា ដែលយើងលើកឡើងអំពីគោលការណ៍ទាំងបី ហើយគោលការណ៍ទីបីគឺគោលការណ៍អធិបតេយ្យភាពជាតិនេះ តើចំណុចអ្វីខ្លះដែលយើងបានលើកឡើងនៅក្នុងច្បាប់របស់យើង ហើយរំលេចឡើងនូវអធិបតេយ្យភាពជាតិបាន ។ អ៊ីចឹងចំណុចទាំងនេះទូលបង្គំជាខ្ញុំសូមទូលថ្វាយនិងជម្រាបជូនព្រះអង្គព្រះប្រធាននិងអង្គសភាដ៏ឧត្តុង្គឧត្តមដូចតទៅនេះ÷ គោលការណ៍នៅក្នុងការតែងតាំងចៅក្រមៈ រាល់ចៅក្រមទាំងអស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរបស់កម្ពុជា ទោះជាចៅក្រមនោះជាបរទេសក្តីឬជាជនជាតិកម្ពុជាក្តី គឺយើងត្រូវតែគោរពនីតិវិធីបែបបទច្បាប់ទម្លាប់របស់ប្រទេសជាតិ គឺចៅក្រមត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទើបមកកាត់សេចក្តីបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ សេចក្តីព្រាងច្បាប់បានចែងថា អគ្គលេខាធិការអង្គការសហប្រជាជាតិនឹងផ្តល់នូវបញ្ជីឈ្មោះបេក្ខជនចៅក្រមបរទេសដែលនឹងត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា ។ ចំណុចមួយទៀត សមាសភាពរបស់សាលាជំនុំជម្រះក្តី ។ នេះជាចំណុចសំខាន់ណាស់ដែលទូលបង្គំជាខ្ញុំខ្ញុំបាទអាចមានមោទកភាពនៅក្នុងការដែលយើងតស៊ូបាននៅក្នុងចំណុចដ៏ឧត្តុង្គឧត្តមនេះ គឺសមាសភាពត្រូវរំលេចឲ្យឃើញថា កម្ពុជាគឺជាអ្នកដែលមានសំឡេងភាគច្រើន ។ ចំនួនចៅក្រមកម្ពុជាត្រូវច្រើនជាងចំនួនចៅក្រមបរទេស ហើយចំណុចនេះគឺនៅក្នុងស្ថាប័នផ្សេងៗដែលបង្កើតឡើងមានលក្ខណៈចម្រុះរវាងអង្គការសហប្រជាជាតិនិងប្រទេសសមាជិកមួយនោះ គឺមិនដែលមានទេដែលអង្គការសហប្រជាជាតិសុខចិត្តឲ្យសាមីប្រទេសមានចំនួនភាគច្រើន ដូច្នេះនេះជាករណីដ៏កម្រមួយដែលយើងធ្វើការតស៊ូហើយបានសម្រេច ។ ចៅក្រមកម្ពុជាមានភាគច្រើននៅគ្រប់សាលាជំនុំជម្រះក្តី ។ ប្រសិនបើមានចៅក្រមចំនួន៥រូប បីរូបជាកម្ពុជា ហើយប្រសិនមាន៧រូបគឺបួនរូបជាកម្ពុជា ក៏ប៉ុន្តែបើយើងសម្រេចទាំងអស់អ៊ីចឹងក៏គេអត់ព្រមដែរ ។ អ៊ីចឹងកន្លែងនេះគឺត្រូវមានការផ្តើមគំនិតច្រើនណាស់ ជជែកគ្នាយូរណាស់ដើម្បីឈានទៅដល់តុល្យភាពមួយ គឺថាយោបល់របស់យើងគឺត្រូវទទួលនូវការគិតគូររបស់ចៅក្រមអន្តរជាតិ ហើយអន្តរជាតិក៏ត្រូវតែទទួលយកនូវយោបល់របស់កម្ពុជា ដូច្នេះគឺយើងបានបង្កើតឡើងនូវរូបមន្តដែលយើងហៅថា super majority គឺសំឡេងភាគច្រើនលើសលប់ ។ ឧទាហរណ៍ តម្រូវឲ្យមានសំឡេងបួននៅក្នុងចំណោមចៅក្រម៥រូបដើម្បីធ្វើការកាត់សេចក្តីនៅក្នុងតុលាការកម្រិតទីមួយ ហើយនៅក្នុងតុលាការ៧រូបនោះគឺយើងក៏ត្រូវមានដល់ទៅ៥រូប ទើបសម្រេចបាន ។ ការផ្តើមគំនិតពីខាងក្នុងប្រវត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិបង្ហាញថា

តុលាការទាំងនោះត្រូវបានរៀបចំដោយចៅក្រមបរទេស ហើយផ្តួចផ្តើមគំនិតនិងដាក់កំហិតមកពីខាងក្រៅ ក៏ប៉ុន្តែយន្តការរបស់យើងដែលហៅថាអង្គជំនុំជម្រះវិសាមញ្ញត្រូវរៀបចំឡើងក្នុងរចនាសម្ព័ន្ធរបស់តុលាការកម្ពុជា ហើយយើងបានអញ្ជើញសហគមន៍អន្តរជាតិមកចូលរួមជាមួយយើង ។ ការរួមបញ្ចូលគ្នានូវច្បាប់អន្តរជាតិនិងច្បាប់ជាតិ អង្គជំនុំជម្រះវិសមញ្ញមានបទឧក្រិដ្ឋចំនួន៣នៅក្រោមច្បាប់ជាតិ គឺច្បាប់ស្តីពីមនុស្សជាតិ ច្បាប់ស្តីពីការដាក់ទារុណកម្ម ទណ្ឌកម្ម ហើយនឹងការដាក់ទារុណកម្មលើការវាយប្រហារលើសាសនា និងមានបទឧក្រិដ្ឋចំនួន៩នៅក្រោមច្បាប់អន្តរជាតិ មានច្បាប់ស្តីពីការប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាមឧក្រិដ្ឋកម្មប្រឆាំងសម្បត្តិវប្បធម៌ និងឧក្រិដ្ឋកម្មប្រឆាំងទៅលើអ្នកទទួលបានការការពារជាអន្តរជាតិ ។ គោលការណ៍ទាំងបីខាងលើនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ដែលត្រូវបានអនុម័តកាលពីឆ្នាំ២០០១ និងក្នុងកិច្ចព្រមព្រៀងរវាងកម្ពុជានិងអង្គការសហប្រជាជាតិដែលបានចុះហត្ថលេខានៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ នៅសាលសន្និសីទចតុមុខ រវាងទូលបង្គំខ្ញុំបាទនិងឯកឧត្តម ហាន់ កូរ៉ែល ដែលពេលនោះជាអគ្គលេខាធិការរង ហើយនិងជាប្រធានក្រុមប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ ។ គណៈរដ្ឋមន្ត្រីបានអនុម័តកិច្ចព្រមព្រៀងនេះមួយសប្តាហ៍ក្រោយពេលចុះហត្ថលេខា ហើយបានបញ្ជូនមករដ្ឋសភាអាណត្តិមុនដើម្បីស្នើសុំសច្ចាប័ន ។ ដោយសារព្រឹត្តិការណ៍នយោបាយរយៈ១ឆ្នាំកន្លងទៅនេះ យើងត្រូវរង់ចាំរហូតមកដល់ពេលនេះទើបរដ្ឋសភាអាចបើកសម័យប្រជុំរបស់ខ្លួន ហើយឈានទៅផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងដែលមានសារសំខាន់នេះ ។ មុននឹងឈានចូលចំណុចលម្អិតនៃសំណើធ្វើវិសោធនកម្ម ទូលបង្គំខ្ញុំបាទសុំអនុញ្ញាតទូលថ្វាយនិងជម្រាបជូនសមាជិកនិងសមាជិកាដ៏ឧត្តុង្គឧត្តមរបស់រដ្ឋសភានូវដំណើរការវិវឌ្ឍន៍នៃការចុះហត្ថលេខារវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជារយៈពេលជាងមួយឆ្នាំកន្លងមកនេះ ។ ការរៀបចំសម្រាប់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានបន្តដំណើរការជាមួយការជួបប្រជុំនិងពិភាក្សារវាងភាគីទាំងបី ទាំងនៅទីក្រុងញូវយ៉ក ទាំងនៅទីក្រុងភ្នំពេញ ។ ទាំងបីនេះគឺមានអង្គការសហប្រជាជាតិ មានរាជរដ្ឋាភិបាល ហើយភាគីទី៣គឺប្រទេសដែលគេចាប់អារម្មណ៍ដែលគេ ហៅថាជីអាយអេស GIS (Group of Interested States) បានន័យថាប្រទេសដែលគេចាប់អារម្មណ៍ទៅលើបញ្ហានេះ គេចង់រួមចំណែកចង់ជួយឧបត្ថម្ភនៅក្នុងដំណើរការនៃការកាត់សេចក្តីនេះ ។ ប្រទេសនេះដែលគេហៅថា ជីអាយអេសនេះ ពីដើមទីមាន២៧ប្រទេស ហើយឥឡូវនេះប្រជុំលើកក្រោយនៅញូវយ៉កមានប្រហែល២០ប្រទេសចូលរួម ។ ហើយនៅកម្ពុជាយើងក៏មានប្រទេសមួយចំនួនដែរ មានជប៉ុន បារាំង អូស្ត្រាលី មានអង់គ្លេសមានស៊ុយអែដ មានឥណ្ឌា មានរុស្ស៊ី មានសហរដ្ឋអាមេរិក មានអាល្លឺម៉ង់ជាច្រើន ។ នៅក្នុងរយៈពេលកន្លងមកនេះ ក្រុមការងាររាជរដ្ឋាភិបាលបានទទួលនិងជួបពិភាក្សាជាមួយគណៈប្រតិភូជំនាញរបស់អង្គការសហប្រជាជាតិចំនួន២លើក ដឹកនាំដោយលោកខាស្តែន ហារ៉ែល នៅក្នុងខែធ្នូ ឆ្នាំ២០០៣ និងខែមីនា ឆ្នាំ២០០៤ ។ ចំណុចនេះគឺមិនដូចវាគ្មិនខាងដើមបានលើកឡើងទេ គឺថាគំនិតដែលគិតថាមានការអូសបន្លាយគំនិតដែលគិតថាយកលេសដើម្បីធ្វើឲ្យយឺតនេះគឺជាគំនិតខុសឆ្គង១០០ភាគរយ ។ យើងបានខិតខំធ្វើឲ្យដំណើរការនេះលឿនមកមុខ ។ ដូច្នេះ ទោះបីច្បាប់ទោះបីកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលហើយនិងអង្គការសហប្រជាជាតិមិនទាន់ត្រូវបានទទួលសច្ចាប័នក៏ដោយ បានន័យថាមិនទាន់ចូលជាធរមានក៏ដោយ ប៉ុន្តែយើងបានផ្តើមគំនិតពិភាក្សាជាមួយអង្គការហសប្រជាជាតិថាយើងកុំចាំ ព្រោះថាបើចាំយើងខាតពេលច្រើន ។ បើដូច្នេះ យើងចាប់ផ្តើមធ្វើការងារជំនាញ ធ្វើការងារបច្ចេកទេសគឺស្នើឲ្យអង្គការសហប្រជាជាតិគេបញ្ជូនគណៈប្រតិភូគេមក ។ បើអ៊ីចឹងគេបានបញ្ជូនមក គឺឯកឧត្តមដែលមកក្រោយនេះមិនមែនឯកឧត្តមដែលមកមុនទេ ។ លោកអគ្គលេខាធិការរងមុនគឺបានចូលនិវត្តន៍ គឺគេបានចាត់តាំងឯកឧត្តមមួយរូបទៀតមក គឺលោកទូតឈ្មោះ ខាស្តែន ហារ៉ែល គឺថាតួនាទីលោកគឺឧបការីអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ បានន័យថាលោកទាបជាងលោកហេន កូរ៉ែល មួយថ្នាក់ ប៉ុន្តែជាមន្ត្រីដឹកនាំជាន់ខ្ពស់របស់គេ ជាឧបការីរបស់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។ អ៊ីចឹងលោកខាស្តែន ហារ៉ែល បានមកកម្ពុជាកាលពីខែធ្នូ ឆ្នាំ២០០៣ ក្រោយពីចុះ ហត្ថលេខាខែមិថុនា ដល់ខែមីនាឆ្នាំ២០០៤ក៏បានមកទៀត

គឺមកពិភាក្សាពីបញ្ហាជំនាញមួយចំនួន ក្នុងនោះមានបញ្ហាថវិកានេះឯង គឺថាត្រូវកំណត់របៀបណា? អំពាវនាវរបៀបណា? យកថវិកាមកចាយរបៀបម៉េច? មានបញ្ហាសន្តិសុខត្រូវធ្វើយ៉ាងម៉េចដើម្បីការពារដំណើរការនៃការកាត់ទោសនេះ ហើយធ្វើឲ្យមានស្តង់ដារអន្តរជាតិ ។ នេះជាចំណុចមានសារសំខាន់ ព្រោះថាអ្វីៗទាំងការងារជំនាញនេះគឺត្រូវគោរពដោយស្តង់ដារអន្តរជាតិ ។ នៅក្នុងចំណុចនេះទូលបង្គំខ្ញុំបាទក៏សុំទាក់ទាញនូវពាក្យស្តង់ដារអន្តរជាតិនេះដែរ ព្រោះថានៅក្នុងការងារជាច្រើន យើងប្រើពាក្យស្តង់ដារអន្តរជាតិមិនសូវមានចំណុចជាក់ស្តែងច្បាស់លាស់ដើម្បីពិពណ៌នាទេ ប៉ុន្តែនៅក្នុងការងារកាត់ទោសនេះគឺពាក្យស្តង់ដារអន្តរជាតិមានន័យច្បាស់លាស់ ។ គឺថាចំណុចនេះបានត្រូវឆ្លងកាត់ការពិចារណាជាក់ស្តែង ច្រើនលើកច្រើនសា ជាពិសេសមានអនុសញ្ញាអន្តរជាតិដែលគេបានចែងពីបញ្ហានេះ ឧទាហរណ៍មានអនុសញ្ញាអន្តរជាតិមួយសំខាន់ណាស់ ដែលយើងហៅថាអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយឆ្នាំ១៩៦៦ដែលបានចុះហត្ថលេខានៅញូវយ៉ក ។ អ៊ីចឹងបានថានេះជាមូលដ្ឋានធំណាស់ស្តីពីការងារដែលពាក់ព័ន្ធទៅនឹងដំណើរការយុត្តាធិការ ដំណើរការនៃការកាត់ទោសនេះ ។ អ៊ីចឹង គេបានកំណត់ជាស្តង់ដារច្បាស់ណាស់ ដើម្បីចោទប្រកាន់មនុស្សម្នាក់គេត្រូវធ្វើយ៉ាងម៉េច ដើម្បីកាត់ទោសត្រូវធ្វើយ៉ាងម៉េច ត្រូវរៀបចំយុត្តាធិការនោះត្រូវរៀបចំស្ថាប័នយ៉ាងម៉េច ស្ថាប័នយ៉ាងម៉េចដែលអាចហៅថាតុលាការបាន ពេលណាមានសិទ្ធិកាត់ទោស ពេលណាមានសិទ្ធិចោទប្រកាន់ ហើយអ្នកដែលត្រូវចោទប្រកាន់ត្រូវមានសិទ្ធិការពារខ្លួនយ៉ាងណាខ្លះ នេះជាស្តង់ដារដែលមានចែងច្បាស់លាស់នៅក្នុងអត្ថបទដែលជាប្រភពច្បាប់អន្តរជាតិ ដែលយើងហៅថាអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ នៅឆ្នាំ១៩៦៦ ។ រាជរដ្ឋាភិបាលបានជជែកពិគ្រោះគ្នាពីបញ្ហាទីកន្លែង យើងយកកន្លែងណា ។ យើងបានសម្រេចយកសាលចតុមុខ ដែលជានិមិត្តរូបនៃរាជធានីភ្នំពេញ ហើយនិងសាលពិពណ៌នៅជិតនោះធ្វើជាការិយាល័យសម្រាប់មន្ត្រីរដ្ឋបាលនិងចៅក្រមធ្វើការ ។ យើងបានជជែកតាំងពីដំណើរការរៀបចំក្បាលម៉ាស៊ីនរដ្ឋបាល យើងត្រូវរៀបចំក្បាលម៉ាស៊ីនរដ្ឋបាលចម្រុះគ្នានោះយ៉ាងដូចម្តេច ចាត់តាំងមន្ត្រីជាក់ស្តែងខាងរដ្ឋបាលនោះរបៀបម៉េច ។ អំពីបញ្ហាថវិកា ទូលបង្គំខ្ញុំបាទសុំរាជានុញ្ញាតជម្រាបជូនជាក់ស្តែង ជជែកគ្នាពីបញ្ហាថវិកានេះ ។ រាជរដ្ឋាភិបាលបានព្រមព្រៀងគ្នាថា ចំណែកថវិកាកម្ពុជាចំណាយទៅលើទីតាំងអគារ ប្រាក់បៀវត្សរ៍ មន្ត្រីជាតិនិងសោហ៊ុយឬចំណាយជាក់ស្តែងផ្សេងៗមួយចំនួនទៀត ។ ក្រៅពីផ្តល់ទីតាំងអគារមានសាលចតុមុខនិងមជ្ឈមណ្ឌលវប្បធម៌ជាតិ រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកលើថ្លៃដំណើរការប្រចាំថ្ងៃខ្លះ ដូចជាទឹក ភ្លើង ការថែទាំ និងផ្តល់ប្រាក់បៀវត្សរ៍ជាតិដល់បុគ្គលិកកម្ពុជា ហើយត្រូវទទួលរ៉ាប់រងចំណាយប្រយោជន៍ផ្សេងៗទៀតដូចជាពង្រឹងសន្តិសុខទូទាំងប្រទេស ចំណាយក្នុងការឃុំឃាំងនិងព្យាបាលជំងឺជនសង្ស័យ ឬអ្នកដែលត្រូវជាប់ពិរុទ្ធ ។ ការប៉ាន់ប្រមាណចំណាយទាំងនេះក្នុងរយៈពេល៣ឆ្នាំមានប្រមាណ១លាន៤សែនដុល្លារអាមេរិកដែលត្រូវទទួលដោយថវិកាជាតិ និង៦លានដុល្លារអាមេរិកទៀតជាសោហ៊ុយប្រយោលដែលយើងហៅថា *Indirect Cost* នោះ ។ បូកសរុបទៅកម្ពុជារួមវិភាគទាន ទាំង៦លាននិង១លាន៤សែន វាត្រូវនឹង៧លាន៤សែនទៅលើថវិកាមួយប្រហាក់ប្រហែលនៅចន្លោះពី៥៥លានទៅ៦០លាន វាប្រហែលជា៥៧លាន ។ ដូច្នេះយើងបានរួមចំណែកបើគិត៧លាន៤សែនទៅ៥៧លាន ជាង១០ភាគរយនៃថវិកា ។ ប៉ុន្តែក៏ចង់បញ្ជាក់ទូលថ្វាយជម្រាបជូនម្តងទៀតដែរថា ក្នុង៧លាន៤សែនដុល្លានេះគឺយើងខ្ទីលុយពីថវិកាជាតិក្នុងវង្វង់ជុំវិញ១លាន៤សែនដុល្លារ ។ ការជជែកពិភាក្សាលើថវិកាសរុបកំពុងដំណើរការខែមីនា ឆ្នាំ២០០៤ ក្រោយទស្សនកិច្ចលើកទី២របស់ក្រុមជំនាញអង្គការសហប្រជាជាតិ យើងបានឯកភាពគ្នាលើថវិកាមួយសម្រាប់រយៈពេល៣ឆ្នាំមានចំនួន៥៣លានដុល្លាអាមេរិក ។ ចំនួននេះក្រោយពីគេយកទៅជែកគ្នាជាមួយ ក្រុមជីអាយអេសនៅញូវយ៉កទៅ ហើយនឹងការដែលជាយោបល់របស់អ្នកជំនាញការរបស់អង្គការសហប្រជាជាតិនោះ ចំនួននេះគឺឡើងដល់៦៨លានដុល្លារអាមេរិក ។ ពេលដែលគណៈប្រតិភូអង្គការសហប្រជាជាតិត្រឡប់ទៅកាន់ទីក្រុងញូវយ៉កវិញហើយជួបជាមួយក្រុមជីអាយអេស ក្រោយពីការពិចារណាទៅលើការជូនយោបល់ផ្សេងៗពីបណ្តាប្រទេសផ្តល់ជំនួយចំនួនថវិកាសរុបត្រូវបានកាត់បន្ថយមកវិញ ។ ចង់សួរថាប្រទេសជីអាយអេស

ជាពិសេសប្រទេសខ្លះដែលគ្រោងចេញលុយច្រើន អ៊ីចឹងលោកជជែក លោកតស៊ូមតិដើម្បីឲ្យថវិកានេះវាចុះឲ្យបានទាបជាកម្រិតអប្បបរមា ។ ចុងក្រោយនេះហាក់ដូចជាបានឯកភាពចុះមកត្រឹម៥៧លានដុល្លារអាមេរិក ។ ហើយគណៈប្រតិភូអង្គការសហប្រជាជាតិនឹងជួបប្រជុំជាមួយក្រុមការងាររបស់រដ្ឋាភិបាលនិងប្រទេសផ្តល់ជំនួយម្តងទៀត ដើម្បីរិះរកកាត់បន្ថយការចំណាយនេះបើសិនកាត់បាន ។ អ៊ីចឹងការប្រជុំតែងតែបានរៀបចំជាពភាគី គឺរវាងក្រុមការងារផ្ទាល់របស់រាជរដ្ឋាភិបាលផង រវាងគណៈប្រតិភូអង្គការសហប្រជាជាតិផង ហើយនិងរវាងប្រតិភូដែលជាតំណាងរបស់ក្រុមប្រទេសដែលយើងហៅថាជីអាយអេសបានន័យថាប្រទេសដែលចាប់អារម្មណ៍នេះផង ។ ថវិកាសរុបត្រូវបាននៅខាងមុខនេះក្រោយពេលដែលច្បាប់របស់យើង ការរៀបចំមូលដ្ឋានគតិយុត្តិនេះចប់នោះ គឺអង្គការសហប្រជាជាតិគេនឹងបញ្ជូនគណៈប្រតិភូជំនាញរបស់គេមកម្តងទៀតដើម្បីបន្តពិភាក្សាលើបញ្ហាជំនាញដូចទូលបង្គំខ្ញុំបាទបានលើកឡើងអម្បាញ់មិញ ។ ថវិកាសរុបត្រូវបានបែងចែកជាខ្ទង់ចំណាយ២ផ្សេងៗពីគ្នា នេះជាយោបល់របស់ប្រទេសជីអាយអេសភាគច្រើនដែរ ។ គេចង់ឲ្យការចំណាយហ្នឹងឲ្យឃើញខ្ទង់ជាពីរ ម្ខាងជាចំណែករបស់អង្គការសហប្រជាជាតិដែលត្រូវចំណាយតាមរយៈដែលគេហៅថា ទ្រុសហ្វាន់ Trust Fund ដែលគេរៀបចំជាទ្រុសហ្វាន់របស់អង្គកាសហប្រជាជាតិ ហើយមួយចំណែកទៀតជាថវិកាដែលគេជួយផ្ទាល់មកប្រទេសកម្ពុជា ។ ព្រោះប្រទេសខ្លះគេយល់ថា បើជួយផ្ទាល់ត្រង់អង្គការសហប្រជាជាតិច្រើនគេក៏ត្រូវបង់ប្រាក់ គេហៅឈ្មោះខុសៗគ្នា ជួនកាលគេ ហៅជាសឺវិសហ្វីច្រើនដែរ ។ នៅក្នុងបញ្ហានេះគេលើកឡើងពីដំបូងគឺអង្គការសហប្រជាជាតិថាកាត់យក១ភាគរយ បើពាក្យយើងសាមញ្ញយើងហៅថាកុំមីស្យុង ប៉ុន្តែនៅក្នុងនេះគេហៅថា សឺវិសហ្វីជាដើម១៣ភាគរយ ។ ហើយបើគេជួយមកយើងគេគិតថាមិនបាច់ charge servise fee ទេ គេជួយមកប៉ុន្មាន គេត្រូវបង់ចូលទៅកន្លែងចំណាយនោះវាច្រើន ។ ដូច្នេះប្រទេសមួយចំនួនគេចង់ឲ្យថវិកាមួយចំនួនណានោះគឺត្រូវជួយផ្ទាល់មកកម្ពុជាតែម្តង អ៊ីចឹងថវិកានឹងមានខ្ទង់ពីរ ខ្ទង់ដែលត្រូវចេញពីអង្គការសហប្រជាជាតិ និងខ្ទង់ដែលត្រូវចេញមកខាងកម្ពុជា ។ ហេតុនេះប្រទេសអ្នកផ្តល់ជំនួយអាចត្រូវជ្រើសរើសថាផ្តល់ជំនួយមកតាមរយៈវិភាគទានស្ម័គ្រចិត្ត UN trust fund ឬតាមរយៈវិភាគទានទ្វេភាគីដល់រាជរដ្ឋាភិបាលកម្ពុជា ។ តាំងពីពេលចាប់ផ្តើមការចរចាមក យើងបានបញ្ជាក់ហើយថា យើងបានស្វែងរកការគាំទ្រពីប្រទេសផ្តល់ជំនួយទៅបំពេញចំណែកថវិកាចំណាយដែលជាកាតព្វកិច្ចរបស់យើង ។ អ៊ីចឹងតាមគម្រោងរបស់ខាងស្ម័គ្រចិត្តនេះ នៅពេលយើងជជែកគ្នាដាច់ស្រេចរវាងអង្គការសហប្រជាជាតិថាត្រូវដាក់ទៅខាង Trust Fund ប៉ុន្មានភាគរយ ដាក់មកខាងកម្ពុជាប៉ុន្មានភាគរយនោះគឺយើងធ្វើការអំពាវនាវបានថវិកាមកពីប្រទេសជីអាយអេសនេះឲ្យបានច្រើនដែរដើម្បីដាក់មកថវិកាកម្ពុជា ។ ការជជែកគ្នាដែលហៅថា service fee នេះយើងជជែកបានច្រើនដែរ គឺថយពី១៣ភាគរយមកនៅត្រឹម១០ភាគរយឬ៦ភាគរយ ។ អ៊ីចឹងហើយខាងអង្គការសហប្រជាជាតិនៅខែមីនា ឆ្នាំ២០០៤ ការប្រៀបធៀបខ្ទង់ចំណាយរវាងអង្គការសហប្រជាជាតិនិងខ្ទង់ចំណាយរបស់កម្ពុជាប្រហាក់ប្រហែលនឹង៧៥និង២៥ ។ ប៉ុន្តែក្រោយមកបណ្តាប្រទេសផ្តល់ជំនួយមួយចំនួនបានស្នើឲ្យមានការផ្ទេរចំណាយប្រមាណ១០លានដុល្លារអាមេរិកពីអង្គការសហប្រជាជាតិមកខាងកម្ពុជាវិញ ក្នុងគោលបំណងបន្ថយចំណាយនិងសន្សំសំចៃ ដែលធ្វើឲ្យការប្រៀបធៀបគ្នាអាចនឹងមានរូបមន្តថ្មី ប្រហែលជាអាចប្រហាក់ប្រហែលនឹង៦០-៤០ ។ យើងបានប្រកាសរួចហើយថា ជំហររបស់យើងទន់ភ្លន់ចំពោះការដាក់មុខចំណាយណាមួយទៅក្នុងការចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជា ឬក៏នៅក្នុងខ្ទង់ចំណាយរបស់អង្គការសហប្រជាជាតិក្នុងលក្ខខណ្ឌដែល÷ ក) ការផ្លាស់ប្តូរបែបនេះស្ថិតនៅក្នុងស្មារតីនៃកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខារវាងភាគីទាំងពីរ ហើយមិនតម្រូវឲ្យធ្វើវិសោធនកម្មអ្វីដល់អត្ថបទដែលជាមូលដ្ឋានគតិយុត្តិ ។ ខ) ដោយទទួលយកមុខតំណែងដែលត្រូវផ្ទេរទៅឲ្យចំណែករបស់ខ្លួននោះ រាជរដ្ឋាភិបាលកម្ពុជាមិនមែនបង្ហាញថាខ្លួនសុខចិត្តទទួលរ៉ាប់រងលើចំណាយនោះដោយប្រើប្រាស់ថវិកាជាតិទេ ។ យើងសង្ឃឹមថាបញ្ហាថវិកានឹងត្រូវពិភាក្សាបញ្ចប់នៅពេលខាងមុខនេះ ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងធ្វើរបាយការណ៍ និងអំពាវនាវរកវិភាគទានពីបណ្តារដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ។ កន្លងមកនេះមាន

ប្រទេសមួយចំនួនបានបង្ហាញថាគេមានបំណងរួមវិភាគទានចំពោះអង្គជំនុំជម្រះវិសាមញ្ញឬមួយតាមរូបភាពមូលនិធិស្ម័គ្រចិត្តរបស់អង្គការសហប្រជាជាតិឬតាមរាជរដ្ឋាភិបាលកម្ពុជា ។ រហូតមកទល់ពេលនេះមានតែប្រទេសអូស្ត្រាលីមួយដែលបានសន្យាផ្តល់ទឹកប្រាក់៣លានដុល្លារអូស្ត្រាលី ចំណែកប្រទេសដទៃទៀតបញ្ជាក់ថារង់ចាំរហូតដល់ចំនួនចំណាយសរុបត្រូវបានកំណត់ទើបគេបង្ហាញការរួមវិភាគទានជាទឹកប្រាក់ឬជាសម្ភារផ្សេងៗ ។ ក្រៅពីការរៀបចំផែនការលើថវិកានិងប្រតិបត្តិការលើអង្គវិសាមញ្ញក្នុងរយៈពេលប៉ុន្មានខែកន្លងទៅនេះ ក្នុងការងាររាជរដ្ឋាភិបាលក៏បានរៀបចំលើបញ្ហាផ្សេងៗទៀតរបស់អង្គជំនុំជម្រះវិសាមញ្ញផងដែរជាមួយនឹងសាលាភូមិន្ទភ្នំពេញ ជាមួយនឹងសាលាភូមិន្ទចៅក្រម និងដោយមានឧបត្ថម្ភថវិកាពីអង្គការ *UNDP* ។ យើងបានរៀបចំបើកវគ្គបណ្តុះបណ្តាល២សប្តាហ៍ស្តីពីច្បាប់មនុស្សធម៌អន្តរជាតិសម្រាប់ចៅក្រមនិងព្រះរាជអាជ្ញាចំនួន៣០នាក់ និងមេធាវីចំនួន៣០នាក់ដែរ ។ លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលក៏បានរៀបចំនិងធ្វើការបោះពុម្ពផ្សាយអំពីសៀវភៅ ពត៌មានណែនាំអំពីសាវតារ គោលបំណង និងរចនាសម្ព័ន្ធរបស់អង្គជំនុំជម្រះវិសាមញ្ញ ជាភាសាខ្មែរនិងអង់គ្លេស ហើយរៀបចំជាCDអំពីកម្រងច្បាប់កម្ពុជានិងអន្តរជាតិដែលពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ចែក ។ គម្រោងពីរចុងក្រោយនេះផ្តល់ថវិកាដោយធនធានច្បាប់របស់អូស្ត្រាលីហៅកាត់ថា *ALRI* និងកម្មវិធីអភិវឌ្ឍន៍អន្តរជាតិរបស់អូស្ត្រាលី *AUSAID* ។

អំពីសំណើសុំធ្វើវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញឆ្នាំ២០០១ ។ ឥឡូវនេះទូលបង្គំខ្ញុំបាទសុំទូលថ្វាយអំពីសេចក្តីព្រាងច្បាប់ស្នើវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសមញ្ញត្រូវបានអនុម័តជាឯកច្ឆន្ទ ហើយត្រូវបានអនុម័តឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ។ ការធ្វើវិសោធនកម្មនេះពុំមានផ្លាស់ប្តូរអ្វីដល់ស្មារតីឬខ្លឹមសារជាសារវន្តស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានអនុម័តដោយរដ្ឋសភាពិនិត្យឡើងវិញដោយព្រឹទ្ធសភានិងក្រុមប្រឹក្សាធម្មនុញ្ញ ហើយប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ នោះទេ ។ ការធ្វើវិសោធនកម្មដូចតទៅនេះគ្រាន់តែសម្រាប់ធ្វើឲ្យមានភាពរលូនស៊ីសង្វាក់គ្នារវាងច្បាប់និងកិច្ចព្រមព្រៀង ហើយងាយស្រួលដល់ការអនុវត្ត ។ ក) ការកែសម្រួលរចនាសម្ព័ន្ធ ។ អម្បាញ់មិញឯកឧត្តមប្រធានគណៈកម្មការ ឯកឧត្តម ឯក សំអុល ក៏បានលើកសរុបអំពីចំណុចធំៗដែលពាក់ព័ន្ធដល់ការលើកឡើងស្នើសុំធ្វើវិសោធនកម្ម ។ ទូលបង្គំសុំថាមិនបាច់លើកឡើងពីបញ្ហានេះទៀតទេ ព្រោះថាឯកឧត្តម ឯក សំអុល បានលើកឡើងរួចហើយ គឺចំណុចមានដូចគ្នា ។ ជាការសន្និដ្ឋានទូលបង្គំយល់ឃើញថា ឥឡូវនេះរាជរដ្ឋាភិបាលនិងអង្គសភាដ៏ខ្ពង់ខ្ពស់ឧត្តមបានឈានមកដល់ទីបញ្ចប់នៃផ្លូវមួយដ៏វែងដែលយើងបានធ្វើដំណើរអស់រយៈពេលជាង១ភាគ៤នៃសតវត្សរ៍មកហើយដែលមេដឹកនាំខ្មែរក្រហមត្រូវបានទម្លាក់ចេញពីការគ្រប់គ្រងដ៏ឃោរឃៅលើប្រទេសរបស់យើង ។ ដូចសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងក្នុងរយៈពេលថ្មីៗនេះថា គ្មានប្រជាជនណាម្នាក់ដែលរួចផុតពីការបំផ្លិចបំផ្លាញដែលប្រព្រឹត្តមកលើមាតុភូមិរបស់យើងក្នុងអំឡុង៣ឆ្នាំ ៨ខែ និង២០ថ្ងៃដែលពួកខ្មែរក្រហម ប៉ុល ពត កាន់អំណាចនៅក្រោមរបបមួយដែលគេទទួលស្គាល់ថា "កម្ពុជាប្រជាធិបតេយ្យ" ។ ចំពោះអ្នកណាដែលកើតក្រោយឆ្នាំ១៩៧៩ ដែលមិនបានជួបប្រទះផ្ទាល់នូវឧក្រិដ្ឋកម្មនោះ ក៏ទទួលរងនូវបន្ទុកក៏ធ្ងន់ធ្ងរដែរ ។ ពួកគេឃើញឪពុកម្តាយ បងប្រុសបងស្រីរបស់គេ ឈឺចាប់ខ្លោចផ្សា ។ ពួកគេបានរួមចំណែកក្នុងការលំបាកដើម្បីកសាងសង្គមជាតិយើងឡើងវិញពីបាតដៃទទេ ពីឆ្នាំសូន្យ ដោយមិនបានទទួលបានផលប្រយោជន៍ពីគតិបណ្ឌិត និងផលប្រយោជន៍នៃញាតិមិត្តដែលបានស្លាប់បាត់បង់ទៅ ។ គឺជាការបន្តការតស៊ូដ៏យូរអង្វែងលំបាកដែលយើងទាំងអស់គ្នាដឹងថាកម្ពុជាសព្វថ្ងៃមានលក្ខណៈអន់ថយជាងបណ្តាប្រទេសជិតខាងលើវិស័យសុខាភិបាល អប់រំ និងប្រាក់ចំណូល ។ ឥឡូវនេះពេលវេលាបានមកដល់សម្រាប់អ្នកទាំងឡាយណាដែលទទួលខុសត្រូវក្នុងការរៀបចំផែនការនិងបញ្ជាឲ្យមានអំពើឃោរឃៅព្រៃផ្សៃនេះ មកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្លួន ។ បន្ទាប់ពីការចរចាអស់រយៈពេលជាច្រើនឆ្នាំមក យើងនឹងឈានទៅបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ឧក្រិដ្ឋកម្មទាំងនេះពុំមែនប្រព្រឹត្តឡើងប្រឆាំងចំពោះ

ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែចំពោះមនុស្សជាតិទាំងមូល ។ ហេតុនេះជាការសមស្របដែលមានចៅក្រម ព្រះរាជអាជ្ញា និងអ្នកច្បាប់កម្ពុជា និងចៅក្រម ព្រះរាជអាជ្ញា និងអ្នកច្បាប់អន្តរជាតិ ធ្វើការជាមួយគ្នាក្នុងភារកិច្ចជំនុំជម្រះក្តីអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ហើយតាមរយៈនេះនឹងជួយបង្កើតវប្បធម៌មួយដែលជួយទប់ស្កាត់កុំឲ្យកើតមានអំពើបែបនេះជាថ្មីម្តងទៀតនៅកន្លែងណាក៏ដោយនៅក្នុងពិភពលោក ។ គំរូតុលាការដែលយើងបានគាក់តែងជាមួយអង្គការសហប្រជាជាតិ បានទទួលគាំទ្រពីសហគមន៍អន្តរជាតិ ។ ពុំមានប្រទេសណាមួយបាននិយាយប្រឆាំងនឹងរូបមន្តដែលយើងបានបង្កើតឡើងទេ ដែលជួនកាលបានលើកឡើងថាគឺជាគំរូកម្ពុជា ដែលអាចផ្តល់ជាឧទាហរណ៍សម្រាប់អ្នកដទៃទៀតក្នុងពេលអនាគត ដែលយើងបានដាក់បញ្ចូលគ្នានូវសមាសភាពជាតិនិងអន្តរជាតិលើផ្នែកច្បាប់ ចៅក្រម ព្រះរាជអាជ្ញា បុគ្គលិកនិងថវិកា ។ ជាតុលាការជាតិដែលមានចរិតអន្តរជាតិ ។ អ្នកខ្លះក៏ហៅថាតុលាការជាតិ-អន្តរជាតិ តុលាការជាតិដែលមានលក្ខណៈអន្តរជាតិ ដូចដែលបានព្រមព្រៀងរវាងសម្តេច ហ៊ុន សែន និងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ។ អាស្រ័យដូចបានទូលថ្វាយនិងជម្រាបជូនខាងលើ ទូលបង្គំសូមដាក់ថ្វាយនិងជូនសមាជិកអង្គសភាដ៏ខ្ពង់ខ្ពស់នូវសេចក្តីព្រាងច្បាប់ទាំងពីរ គឺការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាងកម្ពុជានិងអង្គការសហប្រជាជាតិ និងការអនុម័តលើសេចក្តីព្រាងច្បាប់វិសោធនកម្មច្បាប់២០០១ ដើម្បីឲ្យមានភាពរលូននិងស៊ីសង្វាក់គ្នារវាងឯកសារទាំងពីរ ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** សូមអរគុណឯកឧត្តមខប ។ មុននឹងថ្វាយវេទិកាថ្វាយទៅព្រះអង្គសម្តេចក្រុមយុន ។ ... ចំពោះអ្វីមួយដែលយើងកំពុងតែពិនិត្យនេះបញ្ហាថវិកា ។ ចុះបើយើងមានលទ្ធភាពទទួលជំនួយជាថវិកាពីអង្គការសហប្រជាជាតិពីប្រទេសផ្តល់ជំនួយមួយចំនួនក្នុងការធ្វើឲ្យធូរស្រាលចំពោះថវិកាជាតិ ម៉េចក៏យើងមិនធ្វើ? យើងត្រូវថាជាដាច់ខាតត្រូវតែខ្មែរយើងចាយថវិកាជាតិឲ្យបានច្រើនដើម្បីបង្ហាញនូវឆន្ទៈរបស់យើង ។ ខ្ញុំសុំជម្រាបថា ខ្ញុំបានជួបតំណាងនៃប្រទេសមួយចំនួនដូចឯកឧត្តមខបនាយក សុខ អាន មានប្រសាសន៍អម្បាញ់មិញថា គេចាំតែរដ្ឋសភាយើងអនុម័តនិងផ្តល់នូវសច្ចាប័ននិងធ្វើវិសោធនកម្មលើច្បាប់ដែលមានរួចហើយនេះ ហើយគេចាំតែអង្គការសហប្រជាជាតិធ្វើការវាយតម្លៃអំពីថវិកាសរុបប្រទេសមួយចំនួនដែលគេមានលុយមានកាក់ គេនឹងផ្តល់នូវជំនួយឲ្យបាន ។ អ្នកខ្លះហ៊ានថាឲ្យគ្រប់ចំនួនដែលអង្គការសហប្រជាជាតិលោកនឹងអនុម័តជាគម្រប់ ។ ចំណុចចុងក្រោយ ខ្ញុំសប្បាយចិត្តណាស់ ប្រហែលជារដ្ឋសភាមិនមានបញ្ហាពិនិត្យនិងអនុម័តនូវសច្ចាប័ន និងវិសោធនកម្មលើច្បាប់ដែលមានហើយនោះទេ ។ ពីព្រោះខ្ញុំចាំបានកាលពីឆ្នាំ១៩៩៨ ពេលដែលយើងកំពុងពិនិត្យច្បាប់ស្តីពីការដាក់កម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ កាលនោះឯកឧត្តម សម រង្ស៊ី លោកជាសមាជិកនៃគណបក្សហ៊ុនស៊ីនប៉ិច លោកបានទៅចលនាសមាជិកសមាជិកាហ៊ុនស៊ីប៉ិចមួយចំនួនក្នុងនោះមានព្រះអង្គសម្តេចខប នរោត្តម សេរីវុឌ្ឍ ដែរ ថាកុំបោះច្បាប់ប្រឆាំងច្បាប់ដាក់ខ្មែរក្រហមក្រៅច្បាប់ម៉េច? បង្រួបបង្រួមផ្សះផ្សាជាតិតាំងពីមុននោះ ២០០១ ឥឡូវ២០០៣ ។ ដូច្នេះរដ្ឋសភាយើងរួបរួមគ្នាហើយយ៉ាងម៉េចក៏នៅក្នុងចំណុចនេះមួយដែរ ។ ដូច្នេះខ្ញុំសុំអញ្ជើញឯកឧត្តម ឯក សំអុល មេត្តាអានមាត្រា១ ។

**ឯកឧត្តម ឯក សំអុល:** សូមក្រាបបង្គំសម្តេចក្រុមព្រះ ព្រះប្រធាននៃរដ្ឋសភា សូមគោរពសម្តេចនាយករដ្ឋមន្ត្រី សូមក្រាបថ្វាយបង្គំសម្តេច អង្គម្ចាស់ក្សត្រី អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិកសមាជិការដ្ឋសភា ។ ទូលបង្គំខ្ញុំបាទសូមអាននូវសេចក្តីព្រាងច្បាប់ដែលមានខ្លឹមសារដូចតទៅ÷ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ មាត្រា១ អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ** អរព្រះគុណ ។ សូមអញ្ជើញឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង ។

**ឯកឧត្តម ហោ ណាំហុងៈ** សូមថ្វាយបង្គំសម្តេចព្រះប្រធានរដ្ឋសភា សូមគោរពសម្តេចនាយករដ្ឋមន្ត្រី សូមគោរពសម្តេចលោកជំទាវជាសមាជិកជាទីគោរព ។ ទូលបង្គំសូមមានមតិខ្លីខ្លះដើម្បីស្រាយបំភ្លឺជូនអង្គសភាដ៏ឧត្តុង្គឧត្តមរបស់យើងផង និងដើម្បីជាការឆ្លើយតបនូវមតិរបស់ឯកឧត្តម សម រង្ស៊ី ផង ដើម្បីកុំទុកយូរ ហើយទើបតែមានឱកាស ការពិតទៅទុកយូរក៏មិនបានដែរ ព្រោះយើងតំណាងរាស្ត្រ ជាតំណាងរបស់ប្រជាពលរដ្ឋ យើងទូទាំងប្រទេសទាំងអស់គ្នា យើងមានភារកិច្ចដើម្បីធ្វើការបម្រើជាតិជូនជាតិ ហើយនិយាយការពិត ។ ការជួបកន្លងមកផង ហើយបានជួបលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ថ្មីៗនេះ ដែលពេលបំពេញបេសកម្មទៅញូវយ៉កនិយាយពីបញ្ហានេះដែរ ទូលបង្គំខ្ញុំសូមជម្រាបជូនការបំភ្លឺខ្លះៗអំពីបញ្ហាថា យើងចង់រាំងស្ទះឬយើងចង់លើក ។ រដ្ឋាភិបាលចង់រាំងស្ទះការកាត់ទោសមេដឹកនាំខ្មែរក្រហមឬចង់កាត់ទោសឲ្យឆាប់? ទូលបង្គំចាំច្បាស់ នៅថ្ងៃទិវាសន្តិភាពសហជីព ទូលបង្គំបាននិយាយប្រាប់អ្នកយកព័ត៌មាន ទូលបង្គំជួបលោក កូហ្វី អាណាន់ នៅថ្ងៃព្រហស្បតិ៍កន្លងមកនេះបាននិយាយម្តងទៀត គឺបានបញ្ជាក់ច្បាស់ទៅលើរាជរដ្ឋាភិបាលទាំងមូល គឺថារាជរដ្ឋាភិបាលចង់កាត់ទោសមេដឹកនាំខ្មែរក្រហមប្រញាប់ឲ្យបានឆាប់បំផុត ហើយជូនសភាផ្តល់សច្ចាប័នលើច្បាប់រវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ គឺបានបញ្ជាក់ច្បាស់ បើឯកឧត្តមណាមិនជឿទៅមើលការកត់ហេតុរបស់ឯកឧត្តម កូហ្វី អាណាន់ ចុះថាយើងចង់កាត់ទោសឲ្យបានច្បាស់ ។ បញ្ហាទី២ បញ្ហាអំពីថវិកាគឺមិនមែនទាមទារឲ្យសហគមន៍អន្តរជាតិគេចេញលុយបានយើងកាត់ទោសទេ គឺសហគមន៍អន្តរជាតិផ្ទាល់ខ្លួនគេចាំចេញលុយ ដោយសារឧក្រិដ្ឋកម្មនេះជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ផងនិងប្រល័យជាតិផង ។ ហើយកន្លងមកយកឧទាហរណ៍ អន្តរជាតិមកនិយាយតុលាការនៅរ៉ាន់ដាដែលគេចោទថាមានប្រល័យពូជសាសន៍ តុលាការនៅសេរ៉ាឡេអូន តុលាការនៅយូហ្គោស្លាវី ។ តុលាការទាំងបីនេះ ប្រទេសទាំងបីនេះគ្មានចេញលុយមួយកាក់ទេ គឺសហគមន៍អន្តរជាតិគេចេញទាំងស្រុង ។ ហើយបើប្រៀបធៀបមកប៉ុលពតខ្មែរក្រហមនេះប្រល័យពូជសាសន៍បើតាមយើងដឹងទៅជុំវិញ៣លាននាក់ ។ មិនមែនប៉ុន្មានសែននាក់ដូចនៅរ៉ាន់ដាទេ មិនមែនប៉ុន្មានសែននាក់ដូចនៅប៊ូស្នៀ និងមិនមែនប៉ុន្មានសែននាក់ដូចនៅសេរ៉ាឡេអូនទេ ។ ដូច្នេះហើយបានជាសហគមន៍អន្តរជាតិ គេបានបង្កើតខ្លួនគេ គេហៅថាដូចឯកឧត្តម សុខ អាន បានជម្រាបអង្គសភាហើយ គេថា Group of Interested States ក្រុមប្រទេសដែលយកចិត្តទុកដាក់លើបញ្ហាហ្នឹងគេស្ម័គ្រចិត្តខ្លួនឯង គេបញ្ចេញសុឆន្ទៈរបស់គេ ហើយពេលដែលទូលបង្គំខ្ញុំជួបឯកឧត្តម កូហ្វី អាណាន់ ទៀត ព្រោះឯកឧត្តម កូហ្វី អាណាន់ បាននិយាយច្បាស់ថា សុំឲ្យរាជរដ្ឋាភិបាលផ្ញើលិខិតមួយទៅលោក ពេលសភាអនុម័តហើយលោកប្រជុំប្រមូលប្រទេសស្ម័គ្រចិត្តធ្វើអំណោយនេះដើម្បីយកថវិកានេះមកដំណើរការឲ្យបានឆាប់ ។ ការស្ម័គ្រចិត្តរបស់អង្គការទាំងនោះជាការស្ម័គ្រចិត្តរបស់សហគមន៍អន្តរជាតិដែលព្រះអង្គព្រះប្រធានរដ្ឋសភាមានព្រះបន្ទូលអម្បាញ់មិញថា សហគមន៍អន្តរជាតិគេសុខចិត្តយូរមកហើយ ។ ហេតុអីបានយើងសុខចិត្តយកថវិកាយើងទៅធ្វើ យើងមិនយកថវិកាហ្នឹងយកទៅកសាងជាតិទៅកសាងពេទ្យ សាលាឲ្យប្រជាជន ។ ខ្ញុំសូមមានការបញ្ជាក់តែប៉ុណ្ណឹង ដើម្បីបំភ្លឺអង្គសភាយើងឲ្យយល់ ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ** អរគុណ សូមអញ្ជើញឯកឧត្តម កែវ រ៉េមី ។

**ឯកឧត្តម កែវ រ៉េមីៈ** ជាបឋមនេះ ទូលបង្គំខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចព្រះប្រធានរដ្ឋសភាដែលបានអនុញ្ញាតឲ្យទូលបង្គំធ្វើបទអន្តរាគមន៍ ។ សូមក្រាបថ្វាយបង្គំសម្តេចនាយករដ្ឋមន្ត្រី សម្តេចឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ ។ ពាក់ព័ន្ធទៅនឹងសេចក្តីព្រាងច្បាប់អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្រោមរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។ ទូលបង្គំសូមធ្វើការចាប់អារម្មណ៍ដូចតទៅនេះ÷ ការរៀបចំសេចក្តីព្រាងច្បាប់ការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះគោលបំណងដើម្បីរកយុត្តិធម៌ដើម្បីជួយប្រជាពលរដ្ឋខ្មែរដែលបានស្លាប់ជាង២លាននាក់ ។ ដូច្នេះច្បាប់សំខាន់ណាស់ គឺត្រូវយើងកំណត់ឲ្យបានច្បាស់លាស់

ហើយផ្តល់យុត្តិធម៌ថាតើថ្នាក់ដឹកនាំកំពូលជាន់ខ្ពស់ត្រឹមកម្រិតណា? ទូលបង្គំខ្ញុំបាទនៅចាំថាកាលពីសម័យប៉ុលពត ដឹងថាសូម្បីតែមេភូមិក៏មានសិទ្ធិសម្លាប់មនុស្សដែរ ពេលនោះវិមជ្ឈការក្នុងការផ្តល់សិទ្ធិសម្លាប់ប្រជាពលរដ្ឋតាមភូមិវាមានហើយ ។ ចុះទម្រាំប្រធានគណៈតំបន់ ចែកជាតំបន់៤ តំបន់៥អី ។ល។និង ។ល។ តើគាត់ជាប់ទោសទេ? ឬមួយច្បាប់នេះសម្រាប់កាត់ទោសតែមនុស្ស៤-៥នាក់ តើថ្នាក់ដឹកនាំកម្រិតណាយើងចាប់ផ្តើមការចោទប្រកាន់តែទៅលើមនុស្ស៣-៤នាក់ខ្ញុំយល់ឃើញថាជារឿងអយុត្តិធម៌ទៅវិញ ពុំបានផ្តល់យុត្តិធម៌ដល់ជនរងគ្រោះដែលបានស្លាប់ទៅទេ ។ ចំពោះការចាប់អារម្មណ៍បន្ទាប់មកទៀតគឺទាក់ទងនឹងមាត្រាទី៣ថ្មីគឺអាជ្ញាយុកាល ។ អាជ្ញាយុកាលនៅក្នុងខ្លឹមសារនៃច្បាប់នេះគឺពន្យារមកត្រឹម៣០ឆ្នាំ ក៏ប៉ុន្តែយើងដឹងថារបបប្រល័យពូជសាសន៍ជាអំពើមនុស្សឃាតមួយដែលយើងមិនអាចកំណត់អាជ្ញាយុកាលត្រឹមតែ៣០ឆ្នាំបាននោះទេ ។ ៣០ឆ្នាំខ្លីណាស់ ។ ចុះបើសិនជាធ្វើការកាត់សេចក្តីទៅ យើងធ្វើការស៊ើបអង្កេតទៅឃើញថាមានពាក់ព័ន្ធទៅដល់ប្រទេសផ្សេងទៀតដែលមានពាក់ព័ន្ធដែលនៅពីក្រោយខ្នង យើងអត់ដឹងពីណាទេ ដែលនៅពីក្រោយខ្នងនៅសម័យប៉ុលពត ។ ដូច្នេះការទាមទារស្រាវជ្រាវក្នុងការស៊ើបអង្កេតនេះគឺអាជ្ញាយុកាលមិនអាចកំណត់បានទេ ពីព្រោះបើយោងតាមច្បាប់ដែលទូលបង្គំធ្វើការស្រាវជ្រាវហើយពិគ្រោះជាមួយរៀមច្បងមួយចំនួនគឺថា ដូចជាការកាត់ទោសអ៊ីទ្ធែក្ដីស្ដីក្ដី គឺថាក្នុងច្បាប់មីឡូសីវិកហ្នឹងគឺថា អាជ្ញាយុកាលគេអត់កំណត់ទេ គេចំហជាប់រហូត ។ នេះជាចំណុចវិជ្ជមានមួយដែលបង្ហាញថាព្រមានដល់អ្នកដឹកនាំ ។ អ្នកដឹកនាំគឺថា មិនអាចសម្លាប់មនុស្សបានទេ បើសិនជាអ្នកសម្លាប់មនុស្សគឺថាក្នុងមួយជីវិតនេះមិនអាចរួចផុតពីការផ្តន្ទាទោសបានឡើយ ។ បើសិនជាយើងកំណត់អាជ្ញាយុកាលត្រឹម៣០ឆ្នាំ ចុះបើសល់តែប្រមាណ៣-៤ឆ្នាំ១ឆ្នាំទៀតផុតបាត់ទៅហើយ តើកាត់ទោសនេះយើងអាចរកយុត្តិធម៌ជូនជនរងគ្រោះបានដែរឬទេ? ហើយយើងអាចដឹងពីហេតុផលអ្វីនៅពីក្រោយខ្នងដែលជាសម្ងាត់ដែលយើងមិនអាចកាត់ទុកជាមុនបានដែរឬទេ? នេះជាចំណុចមួយដែលទូលបង្គំខ្ញុំស្នើសុំកែប្រែដាក់អាជ្ញាយុកាលគ្មានកំណត់វិញ ។ ហើយពាក់ព័ន្ធទៅនឹងលិខិត សុំបើកវង់ក្រចកបន្តិច ទូលបង្គំបានឃើញលិខិតលេខ៩៩៨ ឆ្នាំ២០០៤ ចុះនៅថ្ងៃទី១៦កញ្ញា ឆ្នាំ២០០៤ របស់ក្រសួងមហាផ្ទៃ បានបញ្ជាក់ទៅក្រសួងយុត្តិធម៌ក្នុងភាពមិនប្រក្រតីពីតុលាការយើង តុលាការខេត្តក្រុង និងសាលាឧទ្ធរណ៍ ២៧៤ករណីក្នុងការលែងពិរុទ្ធជនទណ្ឌិតដោយមិនមានភាពប្រក្រតី ។ នេះជាការបង្ហាញមួយថា ចៅក្រម ព្រះរាជអាជ្ញារបស់យើង គឺថាមានបញ្ហានិយាយឲ្យចំទៅមានបញ្ហា ។ ប៉ុន្តែទាក់ទងទៅនឹងសមត្ថភាពចៅក្រម ព្រះរាជអាជ្ញា ទូលបង្គំខ្ញុំសុំលើកឆ្លៀតឱកាសក្នុងនេះដែរ ។ ទូលបង្គំបានទទួលឈ្មោះចៅក្រមមួយចំនួនធំលោកមានកម្រិតវប្បធម៌ទាបមែនទែន ហើយពុំបានរៀនសូត្រឆ្លងកាត់សាលាច្បាប់ត្រឹមត្រូវ ហើយភាគច្រើនពួកគាត់ទាំងនោះមានអាយុ៦០ឆ្នាំ ហួស៦០ឆ្នាំទៅទៀត ។ ប៉ុន្តែទូលបង្គំនៅចាំបានកម្មវិធីនយោបាយ៧៣ចំណុចដែលបានរៀបចំកន្លងមកនេះសម្រាប់អាណត្តិទី៣នេះថា ចៅក្រម ព្រះរាជអាជ្ញា ដែលមានអាយុលើសពី៦០ឆ្នាំឲ្យចូលនិវត្តន៍ ក៏ប៉ុន្តែមកទល់ពេលនេះពុំទាន់ឃើញអនុវត្តក្នុងការជំរុញឲ្យគាត់ចូលនិវត្តន៍នៅឡើយទេ ។ ហើយជាការបើកផ្លូវមួយឲ្យប្អូនៗក្មេងៗចៅក្រមដែលគេបានហាត់ហ្វឹកហ្វឺនពីសាលាត្រឹមត្រូវឲ្យគាត់ចូលដើម្បីបំពេញភារកិច្ចដែលជួយដល់ប្រទេសជាតិយើងផង ។ ម្យ៉ាងវិញទៀត ទោះបីមួយចំនួនធំមានកម្រិតវប្បធម៌ទាបថ្នាក់ទី២ ទី៣ ពីសង្គម ខ្លះទី៩ពីសង្គម ទូលបង្គំបានឃើញ ក៏ប៉ុន្តែក៏មានចៅក្រមខ្លះដែលមានសមត្ថភាព ដូចជាឯកឧត្តម ឱត មន្ទីរ, ឯកឧត្តម អ៊ុក វិធន ដែលមានវត្តមាននៅទីនេះ ដែលមានសញ្ញាប័ត្រខ្ពង់ខ្ពស់ ។ នេះជាចំណុចវិជ្ជមានផងអវិជ្ជមានផង ក៏ប៉ុន្តែរាជរដ្ឋាភិបាល ក្រសួងយុត្តិធម៌ អ្វីដែលគណៈកម្មការកំណែទម្រង់ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំឲ្យបានខ្ពស់ក្នុងសមត្ថភាពតុលាការ ។ ហើយក្នុងមាត្រាទី១១ថ្មីទូលបង្គំឃើញថាចៅក្រមបរទេស កូហ្វី អាណាន់ ជាអ្នកបញ្ជូនចៅក្រមបរទេសមកឧត្តមក្រុមប្រឹក្សាអង្គចៅក្រមដើម្បីពិនិត្យនិងសម្រេច ។ ចុះចៅក្រមខ្មែរយើងវិញ អ្នកណាអ្នកបញ្ជូន? តើឧត្តមក្រុមប្រឹក្សា គាត់រើសខ្លួនឯង គាត់បញ្ជូនខ្លួនឯង? តាមទូលបង្គំស៊ើបឮថានឹងមានសមាសភាពចៅក្រមដែលនឹងចូលរួមសហការជាមួយចៅក្រមបរទេសហ្នឹងជាសមាជិកនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រមផងដែរ ។ នេះបញ្ជាក់ឲ្យឃើញថាដូចជាធ្វើអាបឹតផង ទាត់បាល់ផង

ស៊ីខ្លួនឯងផង អាហ្នឹងវាដូចជាមិនត្រឹមត្រូវ ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ទូលបង្គំសុំសំណូមពរមួយថា ទោះបីជារៀបចំសមាសភាពចៅក្រមលើកនេះសូមឲ្យមានតម្លាភាពហើយប្រកាសជាសាធារណៈឲ្យបងប្អូនប្រជាពលរដ្ឋបានដឹង ជាពិសេសតំណាងរាស្ត្រក៏បានដឹងផងដែរពីសមាសភាពចៅក្រម ។ យើងមានការព្រួយបារម្ភចំពោះចៅក្រមដែលមានកេរ្តិ៍ឈ្មោះមិនល្អ ហើយមានប្រវត្តិបញ្ហាពុករលួយ ។ល ។និង ។ល ។ នេះជាការដែលយើងលើកកិត្តិយសសម្រាប់ប្រទេសជាតិយើងផងដែរ ។ ពាក់ព័ន្ធទៅនឹងរឿងអង្គបុរេវិនិច្ឆ័យ ។ ទាក់ទងទៅនឹងអង្គបុរេជំនុំជម្រះនេះទូលបង្គំឃើញថា កាលណាបើសិនជាព្រះរាជអាជ្ញាខ្មែរម្នាក់និងបរទេសម្នាក់មិនឯកភាពទេនោះ យើងនឹងជំរុញទៅអង្គបុរេវិនិច្ឆ័យ បើសិនជារកមតិភាគច្រើនមិនបានទេនឹងបន្តទៅទៀត ។ ក៏ប៉ុន្តែទូលបង្គំសុំឯកឧត្តមលោកឧបនាយករដ្ឋមន្ត្រីលោកមេត្តាឆ្លើយពីនីតិវិធី ថាតើបុរេវិនិច្ឆ័យអង្គជំនុំជម្រះហ្នឹងមានប៉ុន្មានដំណាក់កាល? ចុះបើសិនព្រះរាជអាជ្ញាមានមួយដំណាក់កាលបន្តទៅចៅក្រមស៊ើបអង្កេតមួយដំណាក់កាលទៀត ហើយចុះឡើងទៅជម្រះក្តីមួយដំណាក់កាលទៀត ដូច្នេះវិលទៅវិលមកវារាំងស្ទះមិនអាចចេញរួច នេះជាការជាប់គាំងមួយដែលទូលបង្គំខ្ញុំមានការព្រួយបារម្ភ ។ ហើយទាក់ទងទៅនឹងអ្វីដែលគណបក្សសមរង្ស៊ីសំណូមពរឲ្យមានកំណែវិសោធនកម្ម កាលនោះទូលបង្គំក៏បានដឹងដែរថា កាលនោះចៀសវាងកុំឲ្យមានការបោះឆ្នោតជាកញ្ចប់ ចៀសវាងដើម្បីឲ្យមានការជ្រើសរើសតាមនីតិវិធី ប្រធានរដ្ឋសភាមុន អនុប្រធាន បន្ទាប់មកគណៈរដ្ឋមន្ត្រី ដើម្បីយើងចៀសវាងកុំឲ្យមានការបំពារបំពានលើច្បាប់រដ្ឋធម្មនុញ្ញ យើងសុខចិត្តកែប្រែបទបញ្ញត្តិផ្ទៃក្នុងវិញ ។ នេះជាចំណុចដែលទូលបង្គំបានដឹងច្បាស់ ។ សូមអរព្រះគុណសម្តេចព្រះប្រធាន សូមអរគុណអង្គសភាទាំងមូល ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ៖** សូមអរគុណឯកឧត្តម ។ សូមអង្គសភាលោកមេត្តាអនុម័តមាត្រា១ ។

**លេខានៃអង្គប្រជុំ៖** សូមថ្វាយបង្គំទូលថ្វាយសម្តេចព្រះប្រធាន សំឡេងគាំទ្រមាន១០៥លើ១០៧ ។ សូមអរព្រះគុណ និងអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ៖** អរគុណណាស់ ។ អង្គសភាលោកបានអនុម័ត មាត្រា១នៃកិច្ចព្រមព្រៀង ។ ឯកឧត្តមប្រធានមេត្តាអានមាត្រា២ ។

**ឯកឧត្តម ឯក សំអុល៖** មាត្រា២៖ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ៖** សូមអរគុណ ។ សូមអង្គសភាលោកអនុម័ត ។

**លេខានៃអង្គប្រជុំ៖** សូមក្រាបបង្គំទូលថ្វាយសម្តេចរដ្ឋសភា សំឡេងយល់ព្រមមានចំនួន១០៥លើ១០៧ ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ៖** អរគុណ រដ្ឋសភាលោកបានអនុម័តមាត្រាទី២ ។ សូមមេត្តាអានមាត្រាទី៣ ។

**ឯកឧត្តម ឯក សំអុល៖** មាត្រា៣៖ ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ៖** សូមមេត្តាអនុម័ត ។

**លេខានៃអង្គប្រជុំ៖** សូមក្រាបបង្គំទូលថ្វាយសម្តេចប្រធាន ។ សំឡេងយល់ព្រមមានចំនួន១០៧លើ១០៧ ។ សូមអរព្រះគុណ និងអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ៖** អរគុណណាស់ ។ សូមអង្គសភាអនុម័តលើខ្លឹមសារទាំងមូលនៃច្បាប់ ។

**លេខានៃអង្គប្រជុំ៖** សូមក្រាបបង្គំទូលថ្វាយ សំឡេងយល់ស្របមាន១០៧លើ១០៧ ។ សូមអរព្រះគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ៖** សភាលោកបានអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីក្រមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំសុំប្រកាសបិទអង្គប្រជុំនៅពេលនេះ ។ អរគុណ ។

# ការពិភាក្សានិងអនុម័តច្បាប់វិសោធនកម្ម ២៩មាត្រានៃច្បាប់កាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នៅក្នុងសម័យប្រជុំលើកទី១ នីតិកាលទី៣ របស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៤

***សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ*** *សូមគោរពសម្តេច អនុប្រធានទី១ សូមថ្វាយបង្គំសម្តេច អ្នក អង្គម្ចាស់ក្សត្រី លោកជំទាវ ឯកឧត្តម សមាជិក សមាជិកាទាំងអស់នៃរដ្ឋសភាជាតិ ។ សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រីអញ្ជើញមកតំណាងរដ្ឋាភិបាល ព្រមទាំងសហការីទាំងអស់ ។ កាលពីម្សិលមិញ រដ្ឋសភាជាតិបានពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។ មុននឹងស្នើអង្គសភាមេត្តាចាប់ផ្តើមពិនិត្យនិងអនុម័តនូវរបៀបវារៈទី៧-ខ គឺការពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ សេចក្តីពីវិសោធនកម្មនូវមាត្រាមួយចំនួនស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។ កាលពីម្សិលមិញមានវាគ្មិនមួយចំនួនលោកបានដាក់ជាសំណួរដល់ឯកឧត្តមឧប សុខ អាន មានឯកឧត្តម លី ធុច ឯកឧត្តម កែវ រ៉េមី ។ ដូច្នេះ បើឯកឧត្តមឧបមិនយល់ទាស់ទេ ខ្ញុំសុំស្នើលោកមេត្តាផ្តល់នូវចម្លើយចំពោះសំណួរទាំងនោះ ។ សូមអរគុណ ឯកឧត្តមសូមអញ្ជើញ ។*

***ឯកឧត្តម សុខ អានៈ*** *សូមថ្វាយបង្គំសម្តេចព្រះប្រធានរដ្ឋសភា សម្តេចលោកប្រធាន សូមគោរពអង្គសភាទាំងមូល ។ ទូលបង្គំខ្ញុំបាទបានការអនុញ្ញាតពីសម្តេចព្រះប្រធានសូមធ្វើអត្ថាធិប្បាយលើចំណុចជាបន្តបន្ទាប់ដែលវាគ្មិនគាត់បានលើកឡើងនោះ ។ ចំណុចទី១ដែលពាក់ព័ន្ធទៅនឹងមាត្រា២ គឺមាត្រា២នៅក្នុងសេចក្តីព្រាងច្បាប់ គឺបានថែងអំពីមុខសញ្ញានៃការកាត់ទោស មុខសញ្ញាដែលជាកម្មវត្ថុនៃការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ។ អ៊ីចឹងក្នុងនេះគឺមានថែងពីរចំណុច មានជាចំណុច២ដែលជាសំខាន់គឺទី១បញ្ជាក់ថា "ជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" ហើយពាក្យទី២គឺ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធទៅនឹងអំពើឧក្រិដ្ឋកម្ម ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" ។ ចំពោះការបញ្ជាក់ដំបូងគឺបញ្ជាក់ថាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជា-ធិបតេយ្យ ចំណុចនេះគឺសំដៅទៅលើមានពាក្យនេះដូចជាច្បាស់លាស់គួរសមហើយថា "មេដឹកនាំជាន់ខ្ពស់" ។ ព្រោះថាជាការដែលជជែកវែកញែកជាមួយនឹងគណៈប្រតិភូផ្សេងៗដែលមកធ្វើការពិភាក្សាអំពីការរៀបចំអង្គជំនុំជម្រះវិសាមញ្ញនេះគឺយើងបានកំណត់ថា ការកាត់សេចក្តីអ្នកដែលមានបញ្ហាពាក់ព័ន្ធហើយជាប់ទៅនឹងការងារនេះប៉ុន្តែស្ថិតនៅក្នុងឋានៈតួនាទីធម្មតានោះគឺមិនមែនជាការលំបាកទេ គឺចាត់ទុកជាការងាររបស់តុលាការកម្ពុជាក៏បាន ក៏ប៉ុន្តែអ្វីដែលជាការយកចិត្តទុកដាក់សំខាន់ជាង គឺការកាត់ទោសទៅលើមេដឹកនាំជាន់ខ្ពស់ ។ ដូច្នេះហើយបានជានៅក្នុងមាត្រា២នេះយើងរៀបរៀងឡើងដោយយកចិត្តទុកដាក់ ដោយបញ្ជាក់មុខសញ្ញាឲ្យបានច្បាស់លាស់ គឺសំដៅទៅលើមេដឹកនាំជាន់ខ្ពស់ ។ ប៉ុន្តែក៏មានយោបល់ថា ចុះវានៅជាប់អ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែគឺការអនុវត្តនោះវាលេចធ្លោជាងគេ គឺចំពោះឧក្រិដ្ឋកម្មនិងការរំលោភធ្ងន់ធ្ងរផ្សេងៗដែលវាលេចធ្លោជាងគេ នោះវាក៏ជា*

មុខសញ្ញានៃការងាររបស់អង្គជំនុំជម្រះវិសាមញ្ញដែរ ។ ដូច្នេះនៅក្នុងចំណុចនេះ ទូលបង្គំខ្ញុំបាទក៏សូមបញ្ជាក់ជូនគឺឯកឧត្តម លី ធុច លោកបានលើកម្សិលមិញ មុខសញ្ញាគឺមាន២ប្រភេទនេះគឺ ទី១) មេដឹកនាំជាន់ខ្ពស់ដែលជាមុខសញ្ញាសំខាន់សម្រាប់អង្គជំនុំជម្រះ ហើយទន្ទឹមនឹងនេះក៏នៅមានអ្នកខ្លះដែលអាចថាមិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ ប៉ុន្តែសកម្មភាពរបស់ខ្លួននោះវាលេចធ្លោខ្លាំងពេក មានភ័ស្តុតាង មានការបញ្ជាក់ច្បាស់លាស់ថា បានប្រព្រឹត្តហ្នឹងខ្លាំងក្លាជាងគេ ។ ក៏ប៉ុន្តែចំនួននោះយើងក៏បានគិតគូរហើយថាមិនឲ្យច្រើនពេកទេ ឧទាហរណ៍ដូចជានៅសេរ៉ាឡេអូន ។ សេរ៉ាឡេអូន បើតាមព័ត៌មានគឺហាក់ដូចជា ធ្វើបាន៩នាក់ ចំពោះតុលាការសេរ៉ាឡេអូន ។ ចំពោះយើងនេះគឺករណីដែលទូលព្រះបង្គំបានលើកឡើងគឺមានការឯកភាពគ្នាជារួម ហើយកំណត់មុខសញ្ញាអ៊ីចឹងទើបសរសេរនៅក្នុងមាត្រាទី២នេះយ៉ាងដូច្នេះ ។ ចំពោះចំណុចមួយទៀតដែលពាក់ព័ន្ធទៅនឹងបញ្ហាអាជ្ញាយុកាលមាត្រា៣ ។ មាត្រា៣ដែលចែងពីអាជ្ញាយុកាល ដែលនៅក្នុងការធ្វើវិសោធនកម្មនេះសូមប្តូរពី២០ឆ្នាំទៅ៣០ឆ្នាំ ។ ឯកឧត្តមជាវ៉ាគ្និនម្សិញមិញក៏បានលើកឡើងថា ម៉េចក៏ចាំបាច់ដាក់អាជ្ញាយុកាល ព្រោះឧក្រិដ្ឋកម្មប្រភេទប្រល័យពូជសាសន៍ ប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺម៉េចបានយើងចាំបាច់ដាក់អាជ្ញាយុកាល បើនៅក្នុងតុលាការខ្លះគេកំណត់ថាគ្មានអាជ្ញាយុកាលទេ គឺត្រូវតែមានការអនុវត្តបានរហូត ។ ចំណុចនេះទូលបង្គំខ្ញុំបាទក៏សូមបញ្ជាក់ដែរថា ឧក្រិដ្ឋកម្មកម្រិតខ្ពស់ហើយនិងឧក្រិដ្ឋកម្មកម្រិតទាបជាងអ៊ីចឹងកម្រិតដែលគេហៅថាប្រល័យពូជសាសន៍ កម្រិតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះគឺជាធម្មតាអត់មានអាជ្ញាយុកាលទេ គឺយើងមិនបាច់សរសេរពាក្យអាជ្ញាយុកាលទេបើយើងប្រើប្រាស់តែច្បាប់នេះ ប៉ុន្តែដូចដែលទូលបង្គំបានទូលថ្វាយនិងជម្រាបជូនអង្គសភាដ៏ឧត្តុង្គឧត្តមពីម្សិលមិញហើយថា នៅក្នុងអង្គជំនុំជម្រះនេះគឺយើងមានទាំងចៅក្រមខ្មែរ ទាំងចៅក្រមបរទេស យើងប្រើប្រាស់ទាំងច្បាប់ខ្មែរទាំងច្បាប់បរទេស ។ ដូច្នេះនៅក្នុងច្បាប់របស់យើងនេះដែលទូលបង្គំបានលើកឡើងថាយើងនឹងត្រៀម ធ្វើជាCD ដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវមូលដ្ឋានគតិយុត្តិទាំងអស់ដែលយើងប្រើប្រាស់នៅក្នុងតុលាការនេះ គឺមានច្បាប់កម្ពុជាយើងផងនិងច្បាប់អន្តរជាតិផង ដែលបានរៀបរាប់ទូលថ្វាយនិងជម្រាបជូនពីម្សិលមិញនេះ ។ អ៊ីចឹងនៅក្នុងក្របខ័ណ្ឌនៃក្រមព្រហ្មទណ្ឌកម្ពុជាដែលយើងមកប្រើប្រាស់ដែរនោះ ជាពិសេសគឺអត្ថបទឆ្នាំ១៩៥៦ ខ្ញុំគិតថាមានចែងអំពីឧក្រិដ្ឋកម្មដែលយើងអាចយកប្រើប្រាស់ជាប្រភពច្បាប់នៅក្នុងអង្គជំនុំជម្រះ ដូច្នេះប្រភេទឧក្រិដ្ឋកម្មនោះគឺមានចែងអំពីអាជ្ញាយុកាល ។ ដូច្នេះមាត្រា៣នេះគឺមានគោលដៅគ្របដណ្តប់ឲ្យបានកញ្ចប់ច្បាប់ទាំងអស់ ប្រភពច្បាប់ទាំងអស់ដែលយើងយកមកប្រើប្រាស់ជាមូលដ្ឋានគតិយុត្តិនៅក្នុងអង្គជំនុំជម្រះ ។ នេះជាមូលហេតុដែលយើងសរសេរពីការបន្តអាជ្ញាយុកាល ។ ពីដំបូងយើងដាក់ថា២០ឆ្នាំ ដោយសារយើងគិតថាពី១៩៧៥ អ៊ីចឹងយើងធម្មតាគឺមានអាជ្ញាយុកាល១០ឆ្នាំ អ៊ីចឹង១៩៧៥បូកនឹង១០គឺ១៩៨៥ ហើយយើងបន្ត២០ឆ្នាំ អ៊ីចឹងវាអាចដល់២០០៥ ។ ប៉ុន្តែក្នុងករណីដែលយើងចង់បានឲ្យវាច្បាស់លាស់ កុំឲ្យវាប្រថុយប្រញ៉ូចនឹងពេលវេលាទើបសុំស្នើបន្តដាក់៣០ឆ្នាំ ព្រោះបើយើងសរុបមកវាត្រូវដល់២០១៥ រយៈពេលដែលយើងទៅធ្វើសកម្មភាពការងារនេះ ។ ហើយកាលដែលបន្តអាជ្ញាយុកាលសម្រាប់ច្បាប់ដែលនៅក្នុងក្របខណ្ឌនៃច្បាប់កម្ពុជានេះគឺទើបអ្នកច្បាប់យល់ថាយើងមិនចង់បន្តរហូតអ៊ីចឹងទេ គឺបន្តឲ្យមានក្របខ័ណ្ឌនិងពេលវេលា ដាក់៣០ឆ្នាំសម្រាប់រយៈពេលដល់ទៅ២០១៥ ។ ចំណុចមួយទៀតដែលមានចំណុចដែលលើកឡើងដែលពាក់ព័ន្ធទៅនឹងអង្គបុរេជំនុំជម្រះ ។ ជាធម្មតានៅក្នុងតុលាការរបស់យើងឬនៅក្នុងតុលាការប្រទេសផ្សេងៗ គឺមិនមានរូបមន្តអង្គបុរេជំនុំជម្រះនេះទេ ។ ប៉ុន្តែនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញរបស់យើង យើងបានបង្កើតរូបមន្តនេះ ដោយសារថាយើងមានសហព្រះរាជអាជ្ញា២សម្រាប់ធ្វើការចោទប្រកាន់ ។ នៅក្នុងករណីនេះ យើងបានយកមូលដ្ឋាននៃច្បាប់របស់យើងនេះដែលទូលបង្គំបានលើកឡើងជារូបមន្តដូចថា ដែលជាការសម្របសម្រួលគ្នារវាងយើងនឹងអង្គការសហប្រជាជាតិនោះ គឺចំនួនចៅក្រមយើងច្រើនជាង ប៉ុន្តែត្រូវសម្រេចតាមរូបមន្តដែលយើងហៅថា ភាគច្រើនលើសលុប ។ ដូច្នេះរូបមន្តសម្រេចនេះទាមទារឲ្យមានការឯកភាពគ្នា ការយល់ព្រមទាំងសងខាង ទាំងខាងចៅក្រមកម្ពុជា ទាំងខាងចៅក្រមបរទេស ទាំងព្រះរាជអាជ្ញាកម្ពុជា ទាំងព្រះរាជអាជ្ញាបរទេស ។ អ៊ីចឹងនៅក្នុងការចោទប្រកាន់

គឺសហព្រះរាជអាជ្ញាហ្នឹងទាល់តែមានការឯកភាពគ្នាដែរ ។ បើបរទេសថាត្រូវចោទប្រកាន់លោក “ក” ហើយព្រះរាជអាជ្ញាកម្ពុជាថាអត់ត្រូវចោទប្រកាន់លោក“ក”ទេ គឺមិនមានការឯកភាពគ្នាក្នុងការចោទប្រកាន់ទេ អ៊ីចឹងដំណើរការអត់កើតទេ ។ ក្នុងករណីដែលមានបញ្ហានេះគឺរូបមន្តដែលយើងយកមកដោះស្រាយនេះ គឺបង្កើតឡើងនូវអង្គបុរេវិនិច្ឆ័យដើម្បីយកការសម្រេចក្នុងករណីដែលសហព្រះរាជអាជ្ញាទាំង២មិនឯកភាពគ្នាក្នុងការចោទប្រកាន់ ។ អ៊ីចឹងហើយ អង្គបុរេវិនិច្ឆ័យនឹងត្រូវអញ្ជើញសហព្រះរាជអាជ្ញាមកដោយមានការសម្របសម្រួលពីការិយាល័យរដ្ឋបាល អង្គបុរេវិនិច្ឆ័យត្រូវធ្វើការសម្រេចថាត្រូវចោទប្រកាន់លោក“ក” ឬមិនចោទប្រកាន់លោក“ក” ។ នេះជារូបមន្តពិសេសសម្រាប់ដំណើរការពិសេសនៃអង្គជំនុំជម្រះវិសាមញ្ញរបស់យើងនេះ សួរថាតើមានបុន្មានថ្នាក់? អង្គបុរេវិនិច្ឆ័យអត់មានប៉ុន្មានថ្នាក់ទេ ព្រោះថាបើកាលណាចោទប្រកាន់ ឬមិនចោទប្រកាន់គឺចប់ការងាររបស់អង្គបុរេវិច្ឆ័យ ។ អ៊ីចឹងអង្គបុរេវិនិច្ឆ័យក៏ត្រូវសម្រេចតាមរូបភាពភាគច្រើនលើសលប់ដែរ ។ អ៊ីចឹងហើយដូចដែលទូលបង្គំបានទូលថ្វាយនិងជម្រាបជូនអង្គសភាពីថ្ងៃមុនអ៊ីចឹងពីខាងដើម គឺបើមិនមានការឯកភាពគ្នារវាងចៅក្រមកម្ពុជា រវាងព្រះរាជអាជ្ញាកម្ពុជាហើយនិងចៅក្រម និងព្រះរាជអាជ្ញាបរទេសនោះទេ គឺមិនអាចមានការចោទប្រកាន់មិនអាចមានការកាត់សេចក្តីទេ ។ នេះអាចនិយាយបានថាជាគោលការណ៍មូលដ្ឋាននៃដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញនេះ ។ ទូលបង្គំសុំមានយោបល់ប៉ុណ្ណេះ សុំអរព្រះគុណ ។

***សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិៈ*** *ខ្ញុំសូមអរគុណឯកឧត្តមឧបនាយករដ្ឋមន្ត្រី ។ ខ្ញុំសុំអញ្ជើញឯកឧត្តម ឯក សំអុល មេត្តាអាននូវមាត្រា១ថ្វាយនិងជូនអរគុណ ។*

***ឯកឧត្តម ឯក សំអុលៈ*** *សូមក្រាបថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា សូមគោរពសម្តេចអនុប្រធានទី១ សូមថ្វាយបង្គំសម្តេច ព្រះអង្គម្ចាស់ក្សត្រីយ៍ អ្នកអង្គម្ចាស់ សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ សមាជិកសមាជិការដ្ឋសភាដ៏ខុដុងឧត្តម ។ ទូលបង្គំខ្ញុំបាទសូមអានសេចក្តីព្រាងច្បាប់ដែលមានខ្លឹមសារដូចតទៅ÷*

*ច្បាប់ស្តីពីវិសោធនកម្មមាត្រា២, មាត្រា៣, មាត្រា៩, មាត្រា១០, មាត្រា១១, មាត្រា១៤, មាត្រា១៧, មាត្រា១៨, មាត្រា២០, មាត្រា២១, មាត្រា២២, មាត្រា២៣, មាត្រា២៤, មាត្រា២៧, មាត្រា២៩, មាត្រា៣១, មាត្រា៣៣, មាត្រា៣៤, មាត្រា៣៥, មាត្រា៣៦, មាត្រា៣៧, មាត្រា៣៩, មាត្រា៤០, មាត្រា៤២, មាត្រា៤៣, មាត្រា៤៤, មាត្រា៤៥, មាត្រា៤៦, និងមាត្រា៤៧ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។*

*មាត្រា១ៈ មាត្រា២, មាត្រា៣, មាត្រា៩, មាត្រា១០, មាត្រា១១, មាត្រា១៤, មាត្រា១៧, មាត្រា១៨, មាត្រា២១, មាត្រា២២, មាត្រា២៣, មាត្រា២៤, មាត្រា២៧, មាត្រា២៩, មាត្រា៣១, មាត្រា៣៣, មាត្រា៣៤, មាត្រា៣៥, មាត្រា៣៦, មាត្រា៣៧, មាត្រា៣៩, មាត្រា៤០, មាត្រា៤២, មាត្រា៤៣, មាត្រា៤៤, មាត្រា៤៥, មាត្រា៤៦, និងមាត្រា៤៧ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ន.ស.,រ.ក.ម. ០៨០១,១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ÷*

*មាត្រា២ថ្មីៈ ត្រូវបានបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺសាលាដំបូងនិងតុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធទៅនឹងអំពើឧក្រិដ្ឋការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់ ហើយដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ មេដឹកនាំជាន់ខ្ពស់កម្ពុជា*

ប្រជាធិបតេយ្យនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋខាងលើនេះហៅថាជនសង្ស័យ ។

មាត្រា៣ថ្មីៈ អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩÷

- មនុស្សឃាត មាត្រា៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨
- ទារុណកម្ម មាត្រា៥០០
- ការវាយប្រហារលើសាសនា មាត្រា២០៩ និងមាត្រា២១០ ។

អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាៈ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យារពេលបន្ថែម៣០ឆ្នាំទៀតទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មខាងលើដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ។ ទោសបញ្ញត្តិចែងក្នុងមាត្រា២០៩, ៥០០, ៥០៦ និងមាត្រា៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវកំណត់ជាអតិបរមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិតអនុលោមតាមមាត្រា៣២នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជាក់បន្ថែមដោយមាត្រា៣៨និងមាត្រា៣៩ថ្មីនៃច្បាប់នេះ ។

មាត្រា៩ថ្មីៈ សាលាដំបូងជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រមវិជ្ជាជីវៈ៥រូប ដែលរួមមានចៅក្រមខ្មែរ៣រូប ១រូបធ្វើជាប្រធាន និងមានចៅក្រមបរទេស២រូប និងមានក្រឡាបញ្ជី១រូបឬច្រើនរូបតាមការចាំបាច់របស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យបណ្តឹងនៅចំពោះមុខសាលាដំបូងនេះ ។ តុលាការកំពូលដែលជាកន្លែងសម្រាប់ទទួលពាក្យបណ្តឹងឧទ្ធរណ៍ផងនិងសម្រេចសេចក្តីចុងក្រោយផង ជាអង្គជំនុំជម្រះវិសាមញ្ញដោយចៅក្រម៧រូប ដែលរួមមានចៅក្រមខ្មែរ៤រូប ដែល១រូបធ្វើជាប្រធាន និងចៅក្រមបរទេស៣រូប និងមានក្រឡាបញ្ជី១រូប ឬច្រើនរូបតាមការចាំបាច់តាមការចាត់តាំងរបស់ប្រធានចូលរួម ព្រមទាំងមានសហព្រះរាជអាជ្ញាដែលត្រូវដាក់ពាក្យបណ្តឹងនៅចំពោះមុខតុលាការកំពូលនេះ ។

មាត្រា១០ថ្មីៈ ចៅក្រមជម្រះក្តីនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានជ្រើសតាំងនៅក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់មិនលម្អៀង និងសុចរិត មានបទពិសោធន៍ក្នុងការងារជំនាញ ជាពិសេសខាងច្បាប់ព្រហ្មទណ្ឌឬច្បាប់អន្តរជាតិ ក្នុងនោះរួមមានច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់សិទ្ធិមនុស្សផង ។ ចៅក្រមជម្រះក្តីត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួលឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។

មាត្រា១១ថ្មីៈ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមខ្មែរយ៉ាងតិច៧រូបឲ្យធ្វើជាចៅក្រមជម្រះក្តីសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ និងជ្រើសតាំងចៅក្រមជម្រះក្តីបម្រុងមួយចំនួនតាមតម្រូវការ ព្រមទាំងជ្រើសតាំងផងដែរនូវប្រធានអង្គជំនុំជម្រះវិសាមញ្ញក្នុងចំណោមចៅក្រមខ្មែរខាងលើតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ។ ចៅក្រមបម្រុងខ្មែរត្រូវជំនួសចៅក្រមជម្រះក្តីខ្មែរពេញសិទ្ធិនៅពេលចៅក្រមនេះអវត្តមានឬមានធុរៈ ។ ចៅក្រមជម្រះក្តីទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជម្រះក្តីដែលខ្លួនកំពុងបំពេញ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងយ៉ាងតិចបុគ្គល៥រូបដែលមានសញ្ជាតិបរទេស ឲ្យធ្វើជាចៅក្រមជម្រះក្តីបរទេសសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្រោយពីការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនជាចៅក្រមបរទេសដែលមានចំនួនយ៉ាងតិច៧រូបជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមពេញសិទ្ធិ៥រូប និងចៅក្រមបម្រុងយ៉ាងតិច២រូប ពីក្នុងបញ្ជីឈ្មោះបន្ថែមពីលើចៅក្រមបរទេសដែលចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងដែលមានវត្តមាននៅគ្រប់ដំណាក់កាលនៃដំណើរការជំនុំជម្រះ ។ ប្រធានអង្គជំនុំជម្រះវិសាមញ្ញអាចចាត់តាំងតាមករណី

នីមួយៗនូវចៅក្រមបរទេស១រូបឬច្រើនរូបដែលត្រូវបានជ្រើសរើសរួចហើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឲ្យមានវត្តមាននៅដំណាក់កាលជំនុំជម្រះនីមួយៗ ហើយឲ្យជំនួសចៅក្រមបរទេសប្រសិនបើចៅក្រមរូបនោះពុំមានលទ្ធភាពអាចបន្តការជំនុំជម្រះតទៅទៀតបាន ។

មាត្រា១៤ថ្មី: ១) ចៅក្រមទាំងអស់ត្រូវព្យាយាមសម្រេចឲ្យបានភាពឯកច្ឆន្ទក្នុងសេចក្តីសម្រេចរបស់ខ្លួន ។ ប្រសិនបើភាពឯកច្ឆន្ទនេះពុំអាចរកបានទេ ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោមៈ ក) ការសម្រេចសេចក្តីដែលអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ត្រូវឲ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ខ) ការជម្រះសេចក្តីដែលអង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកំពូលតម្រូវឲ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមប្រាំរូបយ៉ាងតិច ។ ២) នៅពេលដែលពុំមានឯកភាពឯកច្ឆន្ទនោះទេ សេចក្តីសម្រេចនៃអង្គជំនុំជម្រះត្រូវកត់ត្រាទុកនូវយោបល់របស់មតិភាគច្រើននិងមតិភាគតិច ។

មាត្រា១៧ថ្មី: សហព្រះរាជអាជ្ញានៃសាលាដំបូងមានសិទ្ធិបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ។

មាត្រា១៨ថ្មី: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញានិងព្រះរាជអាជ្ញាបម្រុងខ្មែរមួយចំនួនតាមតម្រូវការពីក្របខ័ណ្ឌនៃចៅក្រមវិជ្ជាជីវៈខ្មែរ ។ ព្រះរាជអាជ្ញាបម្រុងត្រូវជំនួសព្រះរាជអាជ្ញាពេញសិទ្ធិនៅពេលដែលព្រះរាជអាជ្ញានោះ អវត្តមានឬមានធុរៈ ។ ព្រះរាជអាជ្ញាទាំងនេះអាចបន្តបំពេញការងារប្រចាំថ្ងៃនៅក្នុងសាលាជំនុំជម្រះក្តីដែលខ្លួនកំពុងបំពេញ ។ ព្រះរាជអាជ្ញាបរទេសមួយរូបដែលមានសមត្ថកិច្ចបង្ហាញខ្លួនក្នុងគ្រប់លំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្រោយពីការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំបញ្ជីបេក្ខជនយ៉ាងតិចពីររូបជាសហព្រះរាជអាជ្ញាបរទេសជូនរាជរដ្ឋាភិបាលកម្ពុជា ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងព្រះរាជអាជ្ញាពេញសិទ្ធិមួយរូបនិងព្រះរាជអាជ្ញាបម្រុងមួយរូបចេញពីបញ្ជីបេក្ខជននេះ ។

មាត្រា២០ថ្មី: សហព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តន៍នីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហព្រះរាជអាជ្ញាអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាត្រូវអនុវត្តគោលការណ៍ដូចខាងក្រោមៈ ការចោទប្រកាន់ត្រូវបន្តដរាបណាសហព្រះរាជអាជ្ញាឬក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេល៣០ថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយដោយអនុលោមតាមបទបញ្ញត្តិដូចខាងក្រោមៈ សហព្រះរាជអាជ្ញាត្រូវដាក់ជូននូវកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុនិងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នារបស់គេដល់ប្រធានការិយាល័យរដ្ឋបាល ។ ភាពខ្វែងយោបល់គ្នាត្រូវតែដោះស្រាយភ្លាមបើអង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូប ចៅក្រមខ្មែរបីរូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានចៅក្រមមួយរូបជាប្រធានហើយនិងចៅក្រមបរទេសពីររូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបន្ទាប់ពីមានការជ្រើសរើសឲ្យឈរឈ្មោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការជ្រើសរើសចៅក្រមខាងលើនេះត្រូវអនុវត្តតាមបទបញ្ញត្តិនៃមាត្រា១០ថ្មីនៃច្បាប់នេះ ។ បន្ទាប់ពីទទួលបានកំណត់ហេតុដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌទីបី ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយត្រូវជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឲ្យមានបណ្តឹងឧទ្ធរណ៍តម្រូវឲ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាល ដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហព្រះរាជអាជ្ញា ។ សហ

ព្រះរាជអាជ្ញាត្រូវចាត់ការបន្តជាបន្ទាន់ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ ប្រសិនបើពុំមានមតិភាគច្រើនដូចតម្រូវឲ្យមានចំពោះការធ្វើសេចក្តីសម្រេចទេ ការចោទប្រកាន់ត្រូវធ្វើបន្តទៅទៀត ។ ក្នុងពេលធ្វើការចោទប្រកាន់សហព្រះរាជអាជ្ញាអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាល ប្រសិនបើការជួយឧបត្ថម្ភនេះពិតជាមានប្រយោជន៍ចំពោះការចោទប្រកាន់ ហើយការជួយឧបត្ថម្ភនេះត្រូវតែផ្តល់ជូន ។

មាត្រា២១ថ្មីៈ សហព្រះរាជអាជ្ញាទាំងអស់ដែលស្ថិតក្រោមច្បាប់នេះមានឋានៈនិងលក្ខខណ្ឌការងារស្មើៗគ្នាទៅតាមលំដាប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញនីមួយៗ ។ ព្រះរាជអាជ្ញាមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។ ក្នុងករណីដែលព្រះរាជអាជ្ញាបរទេសអវត្តមានឬមានធុរៈត្រូវជំនួសដោយព្រះរាជអាជ្ញាបម្រុងបរទេស ។

មាត្រា២២ថ្មីៈ សហព្រះរាជអាជ្ញាមួយរូបៗមានសិទ្ធិជ្រើសរើសព្រះរាជអាជ្ញារងមួយរូប ឬច្រើនរូបដើម្បីជួយខ្លួនក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះ ។ ព្រះរាជអាជ្ញារងបរទេសត្រូវតែងតាំងដោយសហព្រះរាជអាជ្ញាបរទេសពីបញ្ជីផ្តល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ សហព្រះរាជអាជ្ញាត្រូវមានបុគ្គលិកខ្មែរឬបុគ្គលិកអន្តរជាតិជាជំនួយការទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការងារនៅការិយាល័យរបស់ខ្លួន ។ ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការប្រធានការិយាល័យរដ្ឋបាលត្រូវធ្វើសម្ភាសន៍ក្នុងករណីចាំបាច់និងត្រូវមានការយល់ព្រមពីសហព្រះរាជអាជ្ញាខ្មែរក្នុងការជួលបុគ្គលិកដែលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិកបរទេសទាំងអស់ ។ ចំនួនបុគ្គលិកជំនួយការត្រូវជ្រើសរើសតាមសមាមាត្រ ព្រះរាជអាជ្ញាខ្មែរនិងព្រះរាជអាជ្ញាបរទេស ។ បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬជនជាតិខ្មែរដទៃទៀតដែលមានសមាសភាពក្នុងករណីចាំបាច់ ។

មាត្រា២៣ថ្មីៈ រាល់ការស៊ើបអង្កេតគឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រម២នាក់ ម្នាក់ជាកម្ពុជានិងម្នាក់ទៀតជាបរទេស ដែលហៅថាសហចៅក្រមស៊ើបអង្កេតដោយអនុវត្តន៍តាមនីតិវិធីដែលនៅជាធរមាន ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តន៍នីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ ក្នុងករណីដែលមានភាពមិនយល់ស្របគ្នារវាងសហចៅក្រមត្រូវអនុវត្តគោលការណ៍ដូចខាងក្រោមៈ ការស៊ើបអង្កេតត្រូវធ្វើបន្តដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬមួយរូបក្នុងចំណោមពួកគេពុំបានប្តឹងមិនសុខចិត្តក្នុងរយៈពេល៣០ថ្ងៃថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយ ដោយអនុវត្តតាមបទបញ្ញត្តិដូចខាងក្រោមៈ សហចៅក្រមស៊ើបអង្កេត ត្រូវជូនកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុនិងហេតុផលទាំងឡាយចំពោះគោលជំហរខុសគ្នាដល់ប្រធានការិយាល័យរដ្ឋបាល ។ ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយភ្លាមដោយអង្គបុរេជំនុំជម្រះដូចមានចែងក្នុងមាត្រា២០ថ្មីនៃច្បាប់នេះ ។ បន្ទាប់ពីទទួលបាននូវកំណត់ហេតុដូចមានចែងក្នុងកថាខ័ណ្ឌទី៣រួចមក ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ ។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឲ្យមានបណ្តឹងឧទ្ធរណ៍តម្រូវឲ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាលដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនេះ ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឲ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត ។ សហចៅក្រមស៊ើបអង្កេតអាចផ្អែកទៅលើមូលដ្ឋាននៃព័ត៌មានដែលទទួលបានពីស្ថាប័ននានា រួមមានរដ្ឋាភិបាល ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឬអង្គការក្រៅរដ្ឋាភិបាល

ជាដើម ។ សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ ឬស្តាប់ចម្លើយសាក្សី និងប្រមូលភ័ស្តុតាង ដោយអនុវត្តតាមនីតិវិធីជាធរមាន ។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតយល់ថាជាការចាំបាច់ខានមិនបានសហចៅក្រមស៊ើបអង្កេតអាចចេញដីកាសុំឲ្យសហព្រះរាជអាជ្ញាធ្វើការសាកសួរសាក្សីបន្ថែមបាន ។ ក្នុងការអនុវត្តន៍ភារកិច្ចនេះសហចៅក្រមស៊ើបអង្កេតអាចស្នើសុំការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលបានប្រសិនបើយល់ឃើញថាសមស្របនិងមានប្រយោជន៍ដល់ការស៊ើបអង្កេត ហើយការជួយឧបត្ថម្ភនេះត្រូវតែបានផ្តល់ជូន ។

មាត្រា២៤ថ្មី៖ ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវីដែលជ្រើសរើសដោយខ្លួនឯង ដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ដល់ពួកគេដោយឥតគិតថ្លៃប្រសិនបើខ្លួនពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវីព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយនិងយល់បាន ។

មាត្រា២៧ថ្មី៖ ចៅក្រមស៊ើបអង្កេតទាំងអស់ដែលស្ថិតក្រោមច្បាប់នេះមានឋានៈនិងលក្ខខណ្ឌការងារស្មើៗគ្នា ។ ចៅក្រមស៊ើបអង្កេតមួយរូបៗត្រូវបានជ្រើសតាំងសម្រាប់រយៈពេលនៃការស៊ើបអង្កេត ។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតបរទេសណាមួយអវត្តមានឬមានធុរៈ ត្រូវជំនួសដោយចៅក្រមស៊ើបអង្កេតបម្រុងបរទេស ។

មាត្រា២៩ថ្មី៖ ជនសង្ស័យណាមួយដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយ និងជំរុញក្នុងការរៀបចំផែនការឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា៣ថ្មី, ៤, ៥, ៦, ៧ និង៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ ។ តួនាទីឬឋានៈ របស់ជនសង្ស័យមិនអាចជួយជននេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋឬជួយបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ ។ ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា៣ថ្មី, ៤, ៥, ៦, ៧ និង៨ នៃច្បាប់នេះត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឲ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ។ ប្រសិនបើថ្នាក់លើមានបញ្ជានិងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាចនិងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹងនិងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់និងសមស្របដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឬរបស់ថ្នាក់លើណាមួយមិនអាចជួយជនសង្ស័យនេះឲ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ ។

មាត្រា៣១ថ្មី៖ ប្រធានការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាសម្រាប់រយៈពេលពីរឆ្នាំ ហើយអាចត្រូវបានតែងតាំងបន្តទៅទៀតបាន ។ ប្រធានការិយាល័យរដ្ឋបាលមានភារកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល លើកលែងតែការងារដែលស្ថិតនៅក្រោមបទបញ្ញត្តិនិងនីតិវិធីរបស់អង្គការសហប្រជាជាតិ ។ ប្រធានការិយាល័យរដ្ឋបាលត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាលតុលាការ មានភាពស្ទាត់ជំនាញលើភាសាណាមួយក្នុងចំណោមភាសាបរទេសដែលប្រើការក្នុងអង្គជំនុំជម្រះវិសាមញ្ញ ជាមនុស្សមានចរិតលក្ខណៈនិងស្មារតីខ្ពស់ និងសុចរិត ។ អនុប្រធានបរទេសនៃការិយាល័យរដ្ឋបាលត្រូវជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នឹងត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសនិងការគ្រប់គ្រងបុគ្គលិកអន្តរជាតិទាំងអស់ដូចដែលបានតម្រូវឲ្យមានដោយសមាសភាគបរទេសនៃអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេត ការិយាល័យនៃសហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល ។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវគ្រប់គ្រងប្រាក់ធនធានដែលផ្តល់ជូនតាមរយៈមូលនិធិស្ម័គ្រចិត្តនៃអង្គការសហប្រជាជាតិ ។ ការិយាល័យរដ្ឋបាលត្រូវមានបុគ្គលិកខ្មែរនិងបុគ្គលិកអន្តរជាតិជាជំនួយការតាមតម្រូវការជាក់ស្តែង ។ បុគ្គលិកខ្មែរទាំងអស់នៃការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាតាមសំណើរបស់ប្រធានការិយាល័យ ។ បុគ្គលិកបរទេសត្រូវ

តែងតាំងដោយអនុប្រធានការិយាល័យរដ្ឋបាល ។ បុគ្គលិកខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ឬជនជាតិខ្មែរដទៃទៀតដែលមានសមាសភាពក្នុងករណីចាំបាច់ ។

មាត្រា៣៣ថ្មីៈ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវនិងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់បកស្រាយ ឬអនុវត្តន៍នីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤និងមាត្រា១៥នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ។ ជនសង្ស័យដែលត្រូវបានចោទប្រកាន់ហើយត្រូវបានចាប់ខ្លួន ត្រូវបញ្ជូនខ្លួនមកសាលាដំបូងតាមនីតិវិធីជាធរមាន ។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខចំពោះការចូលខ្លួន ឬក្នុងការចាត់ការឲ្យចាប់ខ្លួនជនសង្ស័យដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ ។ នគរបាលយុត្តិធម៌ត្រូវបានជួយឧបត្ថម្ភដោយអង្គភាពអនុវត្តច្បាប់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដែលរួមមានកងកម្លាំងប្រដាប់អាវុធដើម្បីធានាឲ្យជនដែលត្រូវបានចោទប្រកាន់ត្រូវបាននាំខ្លួនមកក្នុងមន្ទីរឃុំឃាំងភ្លាមៗ ។ លក្ខខណ្ឌនៃការចាប់ខ្លួននិងឃុំខ្លួនត្រូវអនុវត្តតាមច្បាប់ជាធរមាន ។ តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់ និងការការពារនូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ ។

មាត្រា៣៤ថ្មីៈ អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈនិងបើកចំហសម្រាប់តំណាងរបស់រដ្ឋបរទេស តំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ តំណាងបណ្តាញពត៌មាននិងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិលើកលែងតែក្នុងកាលៈទេសៈពិសេស អង្គជំនុំជម្រះវិសាមញ្ញសម្រេចថាជំនុំជម្រះជាសម្ងាត់ដោយមានមូលហេតុត្រឹមត្រូវដោយយោងតាមនីតិវិធីជាធរមានដែលការផ្សព្វផ្សាយជាសាធារណៈត្រូវធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌ ។

មាត្រា៣៥ថ្មីៈ ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សអត់ទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។ នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបានការធានាជាអប្បបរមានិងស្មើៗគ្នាសមស្របតាមមាត្រា១៤នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦ៈ ក) ទទួលពត៌មានភ្លាមៗនិងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន ខ) មានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង គ) ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ ឃ) ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ និងការពារខ្លួនដោយខ្លួនឯងឬតាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់ឲ្យដឹងពីសិទ្ធិ និងទទួលបាននូវជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលដោយខ្លួនឯង ង) ពិនិត្យភ័ស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួមនិងការពិនិត្យភ័ស្តុតាងដោះបន្ទុកក្នុងលក្ខខណ្ឌដូចគ្នានឹងភ័ស្តុតាងដាក់បន្ទុកដែរ ច) មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសាប្រសិនបើជនជាប់ចោទមិនយល់ឬមិនអាចនិយាយបាននូវភាសាដែលប្រើនៅក្នុងតុលាការ ឆ) មិនត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុស ។

មាត្រា៣៦ថ្មីៈ អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូលជំនុំជម្រះលើបណ្តឹងសារទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះនិងរបស់សហព្រះរាជអាជ្ញា ពីសាលដីការបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ។ ក្នុងករណីនេះតុលាការកំពូលពិនិត្យសម្រេចជាចុងក្រោយទាំងអង្គហេតុ ទាំងអង្គច្បាប់ ដោយមិនបង្វិលសំណុំរឿងមកអង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងវិញទេ ។

មាត្រា៣៧ថ្មីៈ ប្រការដែលបានចែងនៅក្នុងមាត្រា៤៣ថ្មី, ៤៤ថ្មី និង៤៥ថ្មី ត្រូវអនុវត្តដូចគ្នាចំពោះការជំនុំជម្រះក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល ។

មាត្រា៣៩ថ្មីៈ ជនទាំងឡាយដែលប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា៣ថ្មី, ៤, ៥, ៦, ៧ និង៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសឧក្រិដ្ឋដាក់ពន្ធនាគារពីប្រាំឆ្នាំរហូតដល់មួយជីវិត ។ ក្រៅពីទោសដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងអាចសម្រេចរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុនិងអចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬក៏បានដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ។ ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ ។

មាត្រា៤០ថ្មីៈ រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឲ្យមានការលើកលែងទោសឬការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេតឬត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងមាត្រា៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា៨ នៃច្បាប់នេះបានឡើយ ។ វិសាលភាពនៃការលើកលែងទោសឬអនុគ្រោះទោសដែលអាចត្រូវបានផ្តល់ឲ្យមុនការអនុម័តច្បាប់នេះគឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ។

មាត្រា៤២ថ្មីៈ ១) ចៅក្រមខ្មែរ សហចៅក្រមស៊ើបអង្កេតខ្មែរ សហព្រះរាជអាជ្ញាខ្មែរ និងបុគ្គលិកខ្មែរត្រូវបានផ្តល់អភ័យឯកសិទ្ធិឲ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ដែលបាននិយាយឬសរសេរ និងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់គេ ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានបន្តក្រោយពីពួកគេបញ្ចប់ការងារជាមួយអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះនិងការិយាល័យរដ្ឋបាល ។

២) បុគ្គលិកអន្តរជាតិត្រូវបានផ្តល់បន្ថែមនូវៈ ក) អភ័យឯកសិទ្ធិឲ្យរួចផុតពីដំណើរក្តីតាមផ្លូវច្បាប់ចំពោះពាក្យពេចន៍ដែលបាននិយាយឬសរសេរនិងសកម្មភាពទាំងអស់ដែលបានបំពេញក្នុងតំណែងផ្លូវការរបស់ពួកគេ ។ អភ័យឯកសិទ្ធិបែបនេះនៅតែមានជាបន្តក្រោយពីពួកគេបញ្ចប់ការងារជាមួយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ។ ខ) អភ័យឯកសិទ្ធិឲ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្សរ៍ វិភាជន៍ និងបរិលាភ ដែលបើកជូនពួកគេដោយអង្គការសហប្រជាជាតិ ។ គ) អភ័យឯកសិទ្ធិឲ្យរួចផុតពីការដាក់កំហិតព្រំដែនអន្តោប្រវេសន៍ ឃ) សិទ្ធិនាំចូលដោយរួចពន្ធនូវគ្រឿងសង្ហារិមនិងសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេ លើកលែងតែការចំណាយសេវាកម្មនៅពេលដែលមកទទួលភារកិច្ចផ្លូវការជាលើកដំបូងនៅប្រទេសកម្ពុជា ។

៣) មេធាវីរបស់ជនសង្ស័យឬជនជាប់ចោទដែលត្រូវបានទទួលស្គាល់ថាជាមេធាវីដោយអង្គជំនុំជម្រះមិនត្រូវស្ថិតនៅក្រោមអំណាចរដ្ឋាភិបាលនូវវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញមុខងារដោយសេរីនិងឯករាជ្យរបស់ខ្លួននៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ជាពិសេសមេធាវីត្រូវបានផ្តល់នូវៈ ក) អភ័យឯកសិទ្ធិឲ្យរួចផុតពីការចាប់ឬឃុំខ្លួននិងការរឹបអូសរបស់របរផ្ទាល់ខ្លួនក្នុងក្របខ័ណ្ឌនៃការបំពេញភារកិច្ចរបស់ខ្លួនក្នុងរឿងក្តីនេះ ។ ខ) ភាពមិនអាចរំលោភបំពានបាននូវឯកសារទាំងអស់ដែលទាក់ទងដល់ការបំពេញមុខងាររបស់ខ្លួនជាមេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ ។ គ) អភ័យឯកសិទ្ធិឲ្យរួចផុតពីយុត្តាធិការរដ្ឋប្បវេណីនិងព្រហ្មទណ្ឌ ចំពោះពាក្យពេចន៍ដែលបាននិយាយ ឬសរសេរនិងសកម្មភាពដែលបានបំពេញក្នុងតំណែងជាផ្លូវការរបស់គេក្នុងនាមជាមេធាវី ។ អភ័យឯកសិទ្ធិបែបនេះនៅបន្តផ្តល់ចំពោះពួកគេ ក្រោយពួកគេបញ្ចប់មុខងារជាមេធាវីរបស់ជនសង្ស័យឬជនជាប់ចោទ ។

៤) បណ្ណសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និងជាទូទៅឯកសារនិងសម្ភារទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬប្រើប្រាស់ដោយអ្នកទាំងនោះ ទោះជាស្ថិតនៅកន្លែងណានៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងគ្រប់គ្រងដោយជនណាក៏ដោយគឺមិនអាចត្រូវបានរំលោភ

បំពានក្នុងរយៈពេលនៃកិច្ចដំណើរការជំនុំជម្រះនេះឡើយ ។

*មាត្រា៤៣ថ្មី:* អង្គជំនុំជម្រះវិសាមញ្ញដែលធ្វើឡើងនៅថ្នាក់សាលាដំបូងនិងតុលាការកំពូលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។

*មាត្រា៤៤ថ្មី:* ការចំណាយនិងប្រាក់បៀវត្សរ៍របស់អង្គជំនុំជម្រះវិសាមញ្ញមានៈ ១) ការចំណាយនិងប្រាក់បៀវត្សរ៍ចំពោះមន្ត្រីរដ្ឋបាល បុគ្គលិកខ្មែរចំពោះចៅក្រមជម្រះក្តីនិងចៅក្រមជម្រះក្តីបម្រុង ចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ ជាបន្ទុករបស់ថវិកាជាតិខ្មែរ ។ ២) ការចំណាយចំពោះមន្ត្រីរដ្ឋបាលនិងបុគ្គលិកបរទេស ចៅក្រមជម្រះក្តី សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបរទេស ដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់អង្គការសហប្រជាជាតិ ។ ៣) មេធាវីការពារក្តីអាចទទួលប្រាក់កម្រៃពីកិច្ចការពារក្តីរបស់ខ្លួន ។ ៤) ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀត ដូចជារដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនិងបុគ្គលដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ ។

*មាត្រា៤៥ថ្មី:* ភាសាដែលប្រើប្រាស់ជាផ្លូវការនៅក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ។

*មាត្រា៤៦ថ្មី:* ដើម្បីធានាការអនុវត្តច្បាប់នេះឲ្យបានទាន់ពេលវេលានិងមិនរអាក់រអួលក្នុងករណីដែលចៅក្រមជម្រះក្តីឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេសណាមួយមិនបានចូលរួម ឬបដិសេធមិនចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាផ្សេងទៀតឲ្យបំពេញកន្លែងទំនេរក្នុងចំណោមបញ្ជីបេក្ខជនបរទេសដែលមានចែងក្នុងមាត្រា១១ថ្មី មាត្រា១៨ថ្មី និងមាត្រា២៦នៃច្បាប់នេះ ។ ក្នុងករណីដែលឈ្មោះក្នុងបញ្ជីត្រូវបានប្រើអស់ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិពុំបានផ្តល់បញ្ជីឈ្មោះបេក្ខជនថ្មីបន្ថែម ឬក្នុងករណីដែលអង្គការសហប្រជាជាតិដកការគាំទ្រពីអង្គជំនុំជម្រះវិសាមញ្ញ កន្លែងទំនេរទាំងនេះត្រូវបំពេញបន្ថែមដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពីបណ្តាបេក្ខជនដែលបានស្នើឡើងដោយរដ្ឋាភិបាលនៃបណ្តារដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ឬពីក្នុងចំណោមឥស្សរជនច្បាប់បរទេសដទៃទៀត ។ បន្ទាប់ពីអនុវត្តនីតិវិធីនេះ ហើយបើនៅតែគ្មានចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេសចូលរួមក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយគ្មានបេក្ខជនបរទេសណាត្រូវបានជ្រើសរើសឲ្យបំពេញកន្លែងទំនេរនេះទេ នៅពេលនោះឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចជ្រើសតាំងចៅក្រមជម្រះក្តី ឬចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាខ្មែរជំនួស ។

*មាត្រា៤៧ស្ទួនៈ* ក្រោយពេលផ្តល់សច្ចាប័នសមស្របតាមបទបញ្ញត្តិនៃច្បាប់ព្រះរាជាណាចក្រកម្ពុជាទាក់ទងទៅនឹងសមត្ថកិច្ចនៃការចុះសន្ធិសញ្ញាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវធ្វើនៅភ្នំពេញថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ត្រូវបានអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ សូមអរព្រះគុណនិងអរគុណ ។

**សម្តេច ហេង សំរិនៈ** អ៊ីចឹងសូមបន្តការពិភាក្សាលើមាត្រាមួយនេះ ។ សូមអញ្ជើញ ឯកឧត្តម ប៉ែន បញ្ញា ។

**ឯកឧត្តម ប៉ែន បញ្ញាៈ** សូមគោរពសម្តេចប្រធាន សូមថ្វាយបង្គំ សូមគោរពសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ។ ថ្ងៃនេះយើងពិភាក្សាអនុម័តនូវចំណុច "ឃ" នៃសេចក្តីព្រាងច្បាប់ដែលពាក់ព័ន្ធទៅនឹងវិសោធនកម្មនូវមាត្រាចំនួន២៩ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ការអនុម័តសេចក្តីព្រាងច្បាប់ទាំងពីរដែលសភាយើងកំពុងតែពិភាក្សានិងប្រឹងប្រែងអនុម័តនៅក្នុងពេលនេះ គឺជាការអនុម័តនូវសេចក្តីព្រាងច្បាប់គោលដ៏សំខាន់បំផុតសំដៅដោះស្រាយដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុតឈានទៅបិទនូវទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតមួយរបស់ប្រជាជាតិ ។ ប៉ុន្តែការបិទនូវទំព័រប្រវត្តិសាស្ត្រនោះវាមិនអាចនឹងបិទដោយ

ឆាយស្រួលពេកទេ ធ្វើដោយឆាយៗពេកទេ ព្រោះវាពាក់ព័ន្ធដល់វិញ្ញាណក្ខ័ន្ធរបស់ប្រជាជនរាប់លាននាក់ ឧក្រិដ្ឋកម្មសោកនាដកម្មដ៏យង់ឃ្នង ។ ច្បាប់នេះវាមានការពាក់ព័ន្ធច្រើន ទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រឆាំងសង្គ្រាមឧក្រិដ្ឋកម្មប្រឆាំងនឹងគោលការណ៍នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ ។ ខ្ញុំសូមឆ្លៀតយកវេទិកាដ៏ខ្ពង់ខ្ពស់នេះដើម្បីសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល ចំពោះស្ថាប័នទាំងអស់របស់ជាតិ ចំពោះសហគមន៍អន្តរជាតិ ចំពោះអង្គការសហប្រជាជាតិ ចំពោះអង្គការដៃគូដែលពាក់ព័ន្ធចំពោះអ្នកទាំងអស់ដែលបានខិតខំធ្វើនូវអ្វីៗទាំងអស់ដើម្បីយើងអាចឈានទៅបិទនូវទំព័រប្រវត្តិសាស្ត្រជាតិខ្មែរយើងមួយនៅក្នុងសេចក្តីថ្លៃថ្នូរនិងយុត្តិធម៌ ដោយយើងដកយកមេរៀននូវអ្វីដែលយើងត្រូវចងចាំ និងអ្វីដែលយើងត្រូវបំភ្លេច ។ ទាំងអស់នេះវាបានចែងច្បាស់ណាស់នូវក្នុងបណ្តាមាត្រារបស់យើងក៏ដូចជាអនុសញ្ញាដែលរដ្ឋសភាយើងបានអនុម័តកាលពីម្សិលមិញ ។ យើងខ្ញុំសូមគាំទ្រទាំងស្រុងនូវមាត្រាទាំង២៩ដែលឯកឧត្តមប្រធានគណៈកម្មការនីតិកម្មបានអានអម្បាញ់មិញនេះ ហើយដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី លោកបានបកស្រាយរួចហើយព្រឹកមិញអំពីខ្លឹមសារសំខាន់ៗដែលត្រូវកែប្រែដើម្បីឲ្យច្បាប់នេះវារលូនទៅនឹងអនុសញ្ញាដែលសភាយើងទើបតែបានអនុម័តជាឯកច្ឆ័នកាលពីម្សិលមិញ ។ ដូច្នេះខ្លឹមសារទាំង៩ក៏មានបញ្ជាក់ច្បាស់លាស់ណាស់អំពីអាជ្ញាយុកាលអំពីការចាត់តាំងផ្សេងៗដែលមាននៅក្នុងរបាយការណ៍របស់ឯកឧត្តមប្រធានគណៈកម្មការនីតិកម្មរួចហើយ ។ យើងខ្ញុំសូមមិនរួមយោបល់ទៀតទេ គ្រាន់តែសុំគាំទ្រយ៉ាងពេញទំហឹងនូវការធ្វើវិសោធនកម្មទាំង២៩មាត្រានេះ ដើម្បីធ្វើឲ្យច្បាប់នេះ ដែលកន្លងមក មាន៤៨មាត្រានោះដែលយើងបានអនុម័តរួចហើយនោះ វាមានភាពរលូនទៅនឹងអនុសញ្ញាដែលយើងទើបតែបានអនុម័តកាលពីម្សិលមិញ ។ ដូច្នេះយើងជឿជាក់ថា អស់លោកឯកឧត្តម លោកជំទាវ ដែលជាអ្នកតំណាងរាស្ត្រភាគច្រើន លោកក៏មានសុភនិច្ឆ័យ លោកកំពុងតែគិតគូរនូវបញ្ហាដែលជាអាយុជីវិតជាប្រវត្តិសាស្ត្ររបស់ប្រទេសជាតិយើងផង ហើយដែលយើងត្រូវធ្វើយ៉ាងណាបង្ហាញឲ្យឃើញនូវស្នាដៃរបស់យើងនៅជំនាន់នេះ មិនមែនធ្វើប្រជាធិបតេយ្យរបៀបឲ្យប្អូនៗជំនាន់ក្រោយ របៀបឲ្យអ្នកដឹកនាំនយោបាយខ្លះមានការច្រឡំផ្លូវដោយវិលត្រឡប់ទៅរកភាពអនាធិបតេយ្យ ។ ហើយបើមានបញ្ហានិយាយ មានបញ្ហាចង់មានមតិស្រេចតែសិទ្ធិរបស់អស់លោក ប៉ុន្តែសុំកុំឲ្យប៉ះពាល់ដល់អ្វីដែលជារួម កុំបរិហារ កុំនិយាយអាក្រក់ កុំបន្តុច បើសិនជាយើងធ្វើរបៀបនេះ វាជាការប្រមាថមួយដល់អង្គការចាត់តាំងសង្គម ។ ហើយខ្ញុំគ្រាន់តែសុំលើកឡើងនូវគតិមួយរបស់ស្រីហិតោបទេសដែលបានចែងច្បាស់ថា "ក្តីប្រមាថគឺជាដើមហេតុនៃសេចក្តីវិនាស" ។ សូមអរគុណ ។

***សម្តេច ហេង សំរិនៈ*** សូមអរគុណឯកឧត្តម ។ សូមអញ្ជើញឯកឧត្តម ខៀវ សន ។

***ឯកឧត្តម ខៀវ សនៈ*** សូមគោរពសម្តេចអនុប្រធានទីមួយ សូមថ្វាយបង្គំសម្តេច ព្រះអង្គ ម្ចាស់ក្សត្រី អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវជាសមាជិកឧត្តុង្គឧត្តមនៃរដ្ឋសភាជាតិ ។ ថ្ងៃនេះទូលបង្គំខ្ញុំបាទសូមបង្ហាញខ្លួនថា ទូលបង្គំហ្នឹងជាអ្នកទោសមួយដែលខ្មែរក្រហមចាប់ដាក់គុកនៅតំបន់៣៣ ដែលគេហៅថាភ្នំម្លូ ហើយបានរស់រានមានជីវិតឡើងវិញ ។ ដើម្បីតបស្នងសងគុណចំពោះគាត់វិញ ថ្ងៃនេះលេងហើយត្រូវយកច្បាប់កាត់ទោសគាត់ម្តង ។ ហើយម៉េចបានអីចឹង? គឺថាបញ្ហាទាំងអស់នេះគឺអង្គជំនុំជម្រះវិសាមញ្ញនេះនាំមកនូវភាពយុត្តិធម៌ដល់អ្នករងគ្រោះដោយរបបខ្មែរក្រហមដែលអាចផ្តល់ការយល់ដឹងបន្ថែមទៀតអំពីគោលការណ៍យុត្តិធម៌របស់ប្រជាពលរដ្ឋកម្ពុជា ជាទុនដល់ការកែទម្រង់ប្រព័ន្ធច្បាប់កម្ពុជា ជាការព្រមានដល់ជនផ្តាច់ការទាំងឡាយលើពិភពលោក ។ ប្រជាពលរដ្ឋខ្មែរនិងមនុស្សលើពិភពលោកនឹងដឹងការពិត តើហេតុអ្វីអ្នកដឹកនាំសម្លាប់ប្រជាពលរដ្ឋឯងដូច្នេះ ។ វាខុសនឹងកាលជំនាន់ដែលគេហៅថា ណាហ្ស៊ីអ៊ីទ្លែរ គាត់អត់សម្លាប់ទេជាតិអាល្លឺម៉ង់របស់គាត់ ។ ខ្ញុំបាទសូមកោតសរសើរចំពោះរដ្ឋសភាម្សិលមិញ ហើយនិងអង្គការសហប្រជាជាតិផងដែលខិតខំប្រឹងប្រែង និងរាជរដ្ឋាភិបាលអាណត្តិទី៣នេះ ហើយផ្អែកទៅលើកម្មវិធីនយោបាយរបស់គណបក្សប្រជាជននិងគណបក្សហ៊្វុនស៊ិនប៉ិច ដែលកែទម្រង់ប្រព័ន្ធតុលាការនេះ ។ ហើយយើងធ្វើយ៉ាងម៉េចឲ្យច្បាប់ទាំងអស់នេះដែលបានតាក់តែងឡើង ខ្ញុំបាទឃើញមាន F3 គឺ ១) គេហៅថា *Fair* សមរម្យ ២) *Fast* ទាន់ពេលវេលា ៣) *Fund* ។ *Fund*

មាត្រា៤១ នេះបែងច្បាស់ស្រេចទៅហើយ មានថវិកាជាតិជួយអង្គការអី ថ្មីៗនេះក៏លោក កូហ៊ី អាណាន់ ក៏បានជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីក្រសួងការបរទេសថានឹងជួយ ម្ល៉ោះហើយយើងអត់មានភ័យទេ ។ រដ្ឋាភិបាលធ្វើម៉េចបន្តជំរុញសាលាក្តីនេះធ្វើម៉េចឲ្យលេចចេញជារូបរាងក្នុងពេលដ៏ឆាប់ខាងមុខ ហើយតុលាការយុត្តិធម៌គួរឲ្យទុកចិត្តបាន មានតម្លាភាព ឯករាជ្យ សម្រាប់ការកាត់ក្តី អាចនាំមកនូវក្តីសង្ឃឹមថ្មីសម្រាប់សង្គមកម្ពុជាយើង ដើម្បីរំដោះយើងឲ្យចេញពីអតីតកាលនិងធ្វើដំណើរទៅអនាគត និងការចូលរួមចំណែកដើម្បីធានាឲ្យមានយុត្តិធម៌និងបទដ្ឋានអន្តរជាតិសម្រាប់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ទូលបង្គំខ្ញុំជាសមាជិកនិងសង្គមស៊ីវិលមួយចំនួនទៀតដែលកំពុងតែសុំអំពាវនាវនូវយុត្តិធម៌ដូចតទៅនេះ÷ ច្បាប់នេះគឺត្រឹមត្រូវហើយ ទាំង២៩មាត្រាអរគុណណាស់ គណៈកម្មការនីតិកម្មបានពិភាក្សាយ៉ាងល្អិតល្អន់ យ៉ាងត្រឹមត្រូវ ខ្ញុំយល់ឃើញថាទៅតាមសុចរិតនិងទៅតាមគតិយុត្តិដូចខ្ញុំបាទជម្រាបហើយ ។ ក៏ប៉ុន្តែខ្ញុំបាទមានសំណួរមួយទៀត នៅក្នុងមាត្រា១១ថ្មី វាមានថា *English Version* បកប្រែខុសខ្លះ ។ ពីព្រោះអីចេះ នៅក្នុងអង្គការសហប្រជាជាតិគេនិយាយថា *Appointing* ឬចាត់តាំងចៅក្រម ។ រួចន័យនេះប្រឡំទៅជាការជ្រើសរើស ។ ការជ្រើសរើសនេះ យើងបោះឆ្នោតរើសដោយសារអ្នកណា ដោយសារអង្គប្រឹក្សាចៅក្រម ។ ខ្ញុំមានអនុសាសន៍ខ្លះ ពិសេសបំផុតសុំដាក់មុនឲ្យហើយ ដើម្បីឲ្យឯកឧត្តមចាំឆ្លើយនឹងខាងគណៈកម្មការខាងអង្គការប្រតិកម្មជាអង្គការស៊ីវិលសមាគមការពារសិទ្ធិមនុស្សចង់ដឹងច្បាស់ត្រង់នេះ គឺមាត្រា១២និងមាត្រា៣៣ សុំបំភ្លឺជូនគាត់ឡើងវិញ ។ មាត្រា១២ កិច្ចព្រមព្រៀងបានចែង នៅពេលណាដែលច្បាប់អគ្គពុំអាចឆ្លើយ នៅក្នុងករណីនេះគឺមានន័យថា បើសិនចៅក្រមណាមួយលើកឡើងនូវចំណុចមិនស្របគ្នារវាងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិនោះ តុលាការត្រូវស្វែងរកច្បាប់បទដ្ឋានអន្តរជាតិមកប្រើ ។ ក្នុងនេះប្រាកដជាមានការជជែកគ្នា តើយើងធ្វើយ៉ាងម៉េចដើម្បីចៀសវាងការជជែក ។ ឧទាហរណ៍មួយជាក់ស្តែង ថ្មីៗនេះរឿងនៅតុលាការវ៉ាន់ដា សេរ៉ាឡេអូន និងយូហ្គោស្លាវី យ៉ាងម៉េចបានជាខ្ញុំបាទលើករឿងនេះមកនិទាន? គុណភាពដែលធ្វើច្បាប់ទាំង៨នេះខ្ញុំបាទឃើញត្រឹមត្រូវណាស់ ទី១មាន៨យ៉ាងនៅក្នុងការធ្វើច្បាប់នេះដែលខ្ញុំថាល្អ ខ្ញុំបាទលើកឡើងសិន ទី១គឺតម្លាភាព ។ ស្តង់ដារទៅតាមន័យភាពឲ្យស្របតាមស្តង់ដារគោក់តែងច្បាប់អន្តរជាតិ ។ យើងយកតាំងពីសន្ធិសញ្ញាឆ្នាំ១៩៦៦ វីយែនទៀតក៏មាននៅក្នុងហ្នឹងទៀត គឺថាមានសព្វគ្រប់ហើយដូចជាមាត្រា៣១នៅ *JR* នៅក្រុងវីយែនហ្នឹងគឺថានិយាយអំពីបុព្វសិទ្ធិនៃតុលាការគឺត្រឹមត្រូវរបស់គាត់ ។ ហើយការពិចារណាលើហេតុផលនយោបាយក៏មាន ។ *public hearing* បានធ្វើសិក្ខាសិលាច្រើនដងណាស់ដែលខ្ញុំបាទបានចូលរួមជាមួយហ្នឹង ។ គឺថាបានត្រៀមជាស្រេចលើសេចក្តីព្រាងច្បាប់គឺត្រៀមខ្លួនទាំងអស់គ្នា ដែលធ្វើប៉ុន្មានហ្នឹងទាក់ទងតាំងពី *ONU* មករហូតដល់ប្រទេសកម្ពុជាទាំងអស់ ។ សូមអរគុណណាស់ *Task Force* នៃក្រុមការងារនេះ ។ ហើយត្រៀមខ្លួន ហើយងាយស្រួលធ្វើច្បាប់នេះងាយណាស់បើកាលណាយើងមិនប្រឡំច្បាប់ទាំងឡាយគឺយើងសរសេរល្អ គឺងាយស្រួលនឹងធ្វើវិសោធនកម្ម ។ នេះគឺថាសមាសភាពទាំង៨នៃច្បាប់ផង ។ ហើយទី២ ការបោះពុម្ពផ្សាយសេចក្តីព្រាងច្បាប់តាមទូរទស្សន៍ វិទ្យុ បានឃើញទាំងអស់បានលាតត្រដាងទាំងអស់នូវសេចក្តីស្មោះស្ម័គ្រនេះ ។ ខ្ញុំបាទអម្បាញ់មិញបានសុំឲ្យបំភ្លឺមាត្រាទី១២និង៣៣ ។ ខាងអង្គការសិទ្ធិមនុស្សកម្ពុជាដែលគាត់បានលើកឡើងនូវមាត្រា៣៣អីចឹងដែរ គឺគាត់ដឹងថាអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍គាត់ចង់លុបចោល គាត់ចង់ដាក់អីចេះទៅវិញ នៅក្នុងនេះគឺគាត់ចង់ដាក់ថាចៅក្រមអង្គជំនុំជម្រះវិសាមញ្ញទាំងមូលទៅរៀបចំអនុម័តសម្រេចនីតិវិធីសម្រាប់ជំនុំជម្រះវិសាមញ្ញ គឺវិធានស្តីពីវិធីនិងភ័ស្តុតាងសម្រាប់ដំណើរការមុនដំណាក់កាលជំនុះជម្រះ ដំណាក់កាលជំនុំជម្រះធ្វើឧទ្ធរណ៍ វិធានស្តីពីភ័ស្តុតាងការពារជនរងគ្រោះនិងសាក្សី និងបញ្ហាដទៃៗទៀតក្នុងការរៀបចំនិងអនុម័តនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមស្វែងរកការណែនាំនិងបទដ្ឋានវិធានស្តីពីនីតិវិធីដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ ទី៣គឺថា ចៅក្រមអង្គជំនុំជម្រះវិសាមញ្ញទាំងមូលអាចប្រែវិធានការខ្លួនបានអនុម័តនិងបទបញ្ញតិនៃមាត្រានេះ បើបទបញ្ញតិក្នុងមាត្រានេះមិនបានចែងឬមិនចែងគ្រប់គ្រាន់តាមស្ថានភាពជាក់ស្តែងណាមួយនោះ ។ ៤) គាត់មានគំនិតថា ការអនុម័តសម្រេចនីតិវិធីសម្រាប់អង្គជំនុំជម្រះវិសាមញ្ញត្រូវសម្រេចក្នុងការប្រជុំដោយសំឡេងជាឯកច្ឆន្ទ ។ ក្នុងករណីមិនអាច

រកសំឡេងឯកច្ឆន្ទត្រូវតាមសំឡេងភាគច្រើន២ភាគ៣នៃចៅក្រមជំនុំជម្រះវិសាមញ្ញទាំងមូល ។ គាត់បញ្ជាក់មកទៀតថា អង្គជំនុំជម្រះវិសាមញ្ញ គាត់លុបចោលសាលាដំបូង ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនិងដំណើរការសមស្របតាមច្បាប់ដូចបានចែងក្នុងមាត្រា១៤-១៥នៃអនុសញ្ញាឆ្នាំ១៩៦៦ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ។ ជនសង្ស័យត្រូវបានចោទប្រកាន់ហើយត្រូវចាប់ខ្លួនបញ្ជូនខ្លួនមកសាលាដំបូងតាម...។ អាហ្នឹងគឺដូចនឹងច្បាប់ដើម ឯកឧត្តមសូមមេត្តាត្រង់នេះមួយទៀត ។ ខ្ញុំសុំនេះជាអនុសាសន៍មួយ យើងចង់បង្កើតតុលាការមួយគំរូម្តងនេះ ។ គឺថាតុលាការយើងធ្លាប់ឮភាសាមួយគេហៅថា ស្អុយ ពុករលួយ ទិញយុត្តិធម៌ គឺឲ្យច្បាស់ ។ ដូច្នេះតាមអនុសាសន៍របស់ខ្ញុំ អំពីការដែលហៅថាលក្ខណៈ វិនិច្ឆ័យសម្រាប់ចៅក្រម បេក្ខជនដែលត្រូវជាបុគ្គលមានចរិតលក្ខណៈស្មារតីមិនលម្អៀង សុចរិត ទៀងត្រង់ និងការប៉ិនប្រសប់ ហើយឆ្លងកាត់ការបណ្តុះបណ្តាលមានសមត្ថភាពខាងផ្លូវច្បាប់ ចៀសវាងដូចជារ៉ាន់ដា ។ ទូលបង្គំខ្ញុំនិយាយរឿងរ៉ាន់ដា ខំធ្វើចុះធ្វើឡើងមនុស្ស៦នាក់នៅក្នុងអ្នកជំនុំជម្រះរ៉ាន់ដាហ្នឹងសុទ្ធតែអ្នកសម្លាប់គេបណ្តោយ អាហ្នឹងដល់គេរកទៅ ។ ធ្វើម៉េចក៏ដោយកុំឲ្យមាន ។ អនុសាសន៍របស់ខ្ញុំបាទដូចម្តេច? ទី១) ជាបុគ្គលដែលមានក្រមសីលធម៌ខ្ពស់ មានសេចក្តីសុចរិតទៀតត្រង់ អព្យាក្រឹត មានការប៉ិនប្រសប់ ហើយជាបុគ្គលដែលត្រូវបានគេគោរព ។ បន្តមកទៀតគឺថា បេក្ខជនប្តេជ្ញាប្រកាន់ឯករាជ្យភាពក្នុងពេលបំពេញមុខងាររបស់ខ្លួនមិនអាចទទួលនិងស្វែងរកការណែនាំពីរដ្ឋាភិបាលឬប្រភពណាមួយផ្សេងទៀតឡើយ ។ ទី៣) ចៅក្រមមិនត្រូវជ្រើសរើសក្នុងចំណោមបុគ្គលដែលមានវិសមតិរឿងក្តីដូចជាបញ្ហាថ្មីៗនេះ ករណីប៉ុន្មាន២៧៤ករណីដែលយើងមិនអាចដឹងឮកុំឲ្យគាត់ដាក់ចូលមកក្នុងរឿងហ្នឹង ។ ពីព្រោះថាក្នុងមាត្រា១ទីក្រុងវីយែនគេយល់ថាគាត់មានបុព្វសិទ្ធិគាត់ ហើយបុព្វសិទ្ធិហ្នឹងវែងទៅទៀតដល់គាត់ហ្នឹងគាត់លាក់ស្លាបទៅគាត់រួចខ្លួន ។ ដូច្នេះបេក្ខជនមិនត្រូវជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ ព្រោះឧត្តមអង្គចៅក្រមគាត់ជាអ្នកជ្រើសតាំងចៅក្រម ដល់គាត់មកត្រង់ហ្នឹងទៀត អាហ្នឹងជាបញ្ហាមួយគេហៅថាផ្ទុកពែងផង រួចទាត់បាល់ទៀតហើយ ។ បេក្ខជនត្រូវមានគុណសម្បត្តិដែលគាត់តែងតាំងឲ្យបម្រើការនៅក្នុងតុលាការ កុំយកអ្នកដែលមិនស្គាល់ច្បាប់ យកអីមកមិនដឹង ចាប់ដាក់ៗអាហ្នឹងជាបញ្ហាមួយដែលយើងថាជាបញ្ហាទើសសព្វថ្ងៃនេះ ដែលគេហៅថាជាជំងឺកង់សែរ (Cancer) ។ មួយទៀតគឺបេក្ខជនដែលមានគុណសម្បត្តិតម្រូវឲ្យប្រទេសរៀងៗខ្លួន សម្រាប់តែងតាំងបម្រើការនៅក្នុងតុលាការបេក្ខជនដែលជាបុគ្គលមានបទពិសោធន៍ចៅក្រមបច្ចុប្បន្ននេះ ជាអតីតចៅក្រមដែលមានបទពិសោធន៍ផ្នែកច្បាប់ព្រហ្មទណ្ឌ ច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌និងច្បាប់សិទ្ធិមនុស្សអន្តរជាតិទៀត ។ កុំយកអ្នកគណបក្សខ្លួនឬក៏ស្អី តាមស្គាល់ តាមបុគ្គលគឺចៀសវាងកន្លែងហ្នឹងបានយើងនៅក្នុងកម្មវិធីនយោបាយរដ្ឋាភិបាលអាណត្តិទី៣ និងរដ្ឋសភា គឺយើងជាពន្លឺហើយម្តងនេះ ។ បេក្ខជនសម្រាប់ការងារខាងតុលាការត្រូវតែបានបញ្ចប់វគ្គបណ្តុះបណ្តាលខាងផ្នែកច្បាប់ អានេះគេហៅថា កាំបិតកោរពុះខសមិនកើតទេ ។ បើអ្នកអត់ចេះច្បាប់កុំយកមកចាត់ចែងផ្នែកច្បាប់ ហើយត្រូវមានយ៉ាងហោចក៏មានបរិញ្ញាបត្រច្បាប់ឬសញ្ញាប័ត្រសមមូលដែលមានតម្លៃស្មើដែរ និងបេក្ខជនត្រូវមានបទពិសោធន៍ក្នុងវិស័យច្បាប់ ។ ទាំងអស់នេះគឺត្រូវមានបទពិសោធន៍យ៉ាងតិច៣ឆ្នាំទៅ៧ឆ្នាំចាំយក កុំយកអ្នកថ្មីមកគឺថាដូចម្សិលមិញទ្រីស្តីហ្នឹងវាហុយដូចគអ៊ីចឹង រួចដល់គោលជំហរទន់ដូចសំឡី អាហ្នឹងពិបាក ។ អាហ្នឹងពាក្យមួយគេហៅថាអីចេះទៀត "រស់តែពាក្យ ត្រគាកស្លាប់ស្អុក" ។ អាហ្នឹងប៉ុន្តែសុំកុំឲ្យចាកប្រធាន ។ ម្សិលមិញខ្ញុំបាទឈឺចាប់ណាស់ ដៀលដល់ទៅ AIPO ដល់អី ។ ហើយអន្តរជាតិគេសរសើរ មាត្រា៣១រដ្ឋធម្មនុញ្ញយើង ហើយយើងមាន regional របស់យើង គេផ្តើលគគ្រឹកគគ្រេងអំពីប្រទេសកម្ពុជា គេមកធ្វើគេមានតាំងពីច្បាប់រត់ពន្ធអាភៀនរត់ពន្ធ terrorism គេដឹងឮ គេយកមក ហើយយើងរៀនសូត្រនឹងគេ ។ល ។និង ។ល ។ នេះខ្ញុំសូមបិទវង់ក្រចកត្រង់ណោះ ហើយសុំបន្តទៅទៀត ។ បេក្ខជនត្រូវរើសតាមវិធីបើកចំហត្រឹមត្រូវនិងយុត្តិធម៌ ។ ពត៌មាននេះគឺថា ជ្រើសរើសនឹងត្រូវប្រកាសផ្សព្វផ្សាយជាសាធារណៈ កុំយកថាតាម channel បងប្អូននិយមហ្នឹងមកទៀត គឺថាអត់កើតទេ ។ license ឥឡូវខ្ញុំបានឃើញហើយ ស្រាប់តែដាក់ឲ្យធ្វើគ្រាន់តែវាយកុំព្យូទ័រម្រាមដៃ១ មួយយប់ទើសភ្លឺ មួយ page អត់ចប់ផង ។ អាហ្នឹងបញ្ហា អាហ្នឹង

សញ្ញាបត្រទិញហើយប្រយ័តអាហ្នឹងនោះ ។ ពាក្យសុំចូលធ្វើការត្រូវពិនិត្យពិច័យដោយម៉ត់ចត់ ពិគ្រោះយោបល់ជាមួយតំណាងសង្គមស៊ីវិល ។ សួរច្បាស់ តំណាងសង្គមស៊ីវិលម្តងនេះក៏មានដែរណា ខាងសង្គមស៊ីវិលសុទ្ធតែមេធាវីខាងស្អីឡូវ៉ាអី ។ល ។និង ។ល ។ ហើយគាត់សង្គមអន្តរជាតិចាំតាមដានយើង កុំថាយើងអញជិះសេះលែងដៃ អាហ្នឹងអាមួយ democracy អាមួយ autocracy ខុសគ្នា ។ autocracy ហ្នឹងពាក្យគេថា “អត្ត” ។ អត្តគឺស្រេចតែអញ អញអ្នកធ្វើ ចេញពីអញ មានតែអញ ជយោអញ ។ អាហ្នឹងមិនមែនប្រជាធិបតេយ្យទេ គេហៅ demo ហ្នឹងដូចថា cracy ពាក្យក្រិក ។ demo ជាធំ cracy ច្បាប់ ។ ដូច្នេះត្រូវយកប្រជាពលរដ្ឋជាធំ ព្រោះយើងកាន់របបប្រជាធិបតេយ្យ ។ ដូច្នេះខ្ញុំបាទសុំស្នើប៉ុណ្ណឹង ហើយរឿងបុគ្គលក្រសួងតុលាការត្រូវអនុវត្តតាមវិធីខាងលើដូចខ្ញុំបាទបានជម្រាប ហើយប្រុងប្រយ័ត្នកុំឲ្យមានការចាត់តាំងបុគ្គលដែលមានសមាសភាពមិនសមរម្យ ។ ខ្ញុំបាទសូមសួរត្រង់ណេះមួយទៀតជាអនុសាសន៍ ខ្ញុំបាទសុំសួរទៅឯកឧត្តមឧបនាយករដ្ឋមន្ត្រីដែលជាតំណាងរដ្ឋាភិបាលខាងណេះថា តើការចាត់តាំងឬក៏ជ្រើសតាំង? និយាយគ្នាឲ្យច្បាស់ ចាត់តាំងគឺ appointing ជ្រើសរើសតាំង selecting បោះឆ្នោត ។ ខ្ញុំបាទចង់សួរអ៊ីចេះទៀតថា តើការរើសហ្នឹងពីខាងគណបក្សនយោបាយដែរឬយ៉ាងម៉េច? ឬពីគណៈរដ្ឋមន្ត្រីក្រសួងខុត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬតែគ្នាឯងឬយ៉ាងម៉េច? សុំឲ្យឆ្លើយ ។ ទី២គឺថា ខ្ញុំបាទជម្រាបថា បើសិនលោកណាដែលជាប់ពាក់ព័ន្ធក្នុងរឿង... គឺថានៅក្នុងចំណុច៧/៣ចំណុចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលរវាងគណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សប្រជាជន ដែលមានហត្ថលេខីនិងពិធីសារស្រេចហើយ នៅក្នុងហ្នឹងរៀបហើយ ។ កុំ Blabla ច្រើនពេក ព្រោះនៅក្នុងនេះក៏មានគណបក្សប្រឆាំងចូលក្នុងហ្នឹងដែរ ។ ខ្ញុំបានតាមដានគ្រប់ពេលវេលា ដូច្នេះហើយជាការមួយតើបើសិនជាយកខាងធ្វើការទាំងអស់គ្នា រើសមកទាំងអស់គ្នា អ្នកដែលមកអង្គុយឲ្យស្មើគ្នា ។ ឧបមាថា ឥឡូវគណបក្សនេះប៉ុន្មាន អីប៉ុន្មាន ធ្វើឲ្យស្មើ រើសអ្នកមានសញ្ញាប័ត្រខ្ពង់ខ្ពស់ កុំឲ្យអន្តរជាតិមើលងាយថាយើងមិនដឹងជាស្អីមកពីណា ។

**សម្តេច ហេង សំរិនៈ** ជាបន្តទៅទៀតសុំអញ្ជើញឯកឧត្តម អេង ឆៃអ៊ាង ។

**ឯកឧត្តម អេង ឆៃអ៊ាងៈ** សូមអរគុណសម្តេចលោកប្រធានដែលបានឲ្យទូលព្រះបង្គំឡើងធ្វើបទអន្តរាគមន៍ ។ ជាបឋមសូមគោរពអង្គសភាទាំងមូល ទូលព្រះបង្គំខ្ញុំឡើងមកនេះគឺថាមានការចាប់អារម្មណ៍ទៅលើចំណុច៣មាត្រា៣នៅក្នុងច្បាប់ស្តីពីវិសោធនកម្មនេះ ។ ទី១ ខ្ញុំសុំឲ្យតំណាងរដ្ឋាភិបាលបញ្ជាក់ឲ្យបានច្បាស់នូវចំណុចនៅក្នុងមាត្រា២ថ្មី ហើយដូចឯកឧត្តមឧបលោកបានបញ្ជាក់ហើយប៉ុន្តែមិនដឹងច្បាស់ គឺដូចជាចំណុចដែលថាដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនោះ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋកម្ម ។ ខ្ញុំសូមបញ្ជាក់បន្តិចថា មេដឹកនាំជាន់ខ្ពស់គឺជាពាក្យមួយដែលទូលំទូលាយណាស់ ថាតើកម្រិតណា? បើយើងមើលទៅក្នុងរចនាសម្ព័ន្ធរបស់ខ្មែរក្រហម គឺមានគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្ស អាហ្នឹងក៏អាចចាត់ទុកថាជាន់ខ្ពស់ដែរ ហើយមានគណៈកម្មាធិការមជ្ឈិម អាហ្នឹងក៏ចាត់ទុកថាជាន់ខ្ពស់ដែរ ។ អ៊ីចឹងហើយសូមឲ្យឯកឧត្តមតំណាងបញ្ជាក់ថាតើថ្នាក់ណា? ថ្នាក់គណៈកម្មាធិការអចិន្ត្រៃយ៍ឬក៏រួមទាំងថ្នាក់គណៈកម្មាធិការមជ្ឈិមបក្ស? ព្រោះបើកាលណាយើងដាក់ថាពាក្យជាន់ខ្ពស់តែមួយម៉ាត់ហ្នឹងវាទូលំទូលាយ ។ ដូច្នេះសុំឲ្យបញ្ជាក់ ហើយបើអាចដាក់ចូលទៅក្នុងមាត្រាថ្មីនេះក៏បានដែរ ។ អានេះចំពោះមេដឹកនាំជាន់ខ្ពស់ប្រជាធិបតេយ្យ ។ ហើយមួយទៀតទាក់ទងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ។ តើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតហ្នឹងវាថ្នាក់ណា? ព្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងគឺយើងមានបែងចែកជាថ្នាក់មជ្ឈិម ថ្នាក់ភូមិភាគ ថ្នាក់តំបន់ ថ្នាក់ស្រុក ថ្នាក់ឃុំ និងថ្នាក់សហករណ៍ ហើយនៅក្នុងគ្រប់លំដាប់ថ្នាក់ទាំងអស់ហ្នឹងដែលយើងដឹងគឺមានសន្តិសុខគ្រប់ថ្នាក់ ដូចថ្នាក់ជាតិហ្នឹងមានសន្តិសុខថ្នាក់ជាតិដែលនៅក្នុងគុកទួលស្លែង អាហ្នឹងមានអ្នកទទួលខុសត្រូវខ្ពស់បំផុតមួយចំនួនហើយនៅថ្នាក់ភូមិភាគហ្នឹងក៏មានមន្ទីរសន្តិសុខដែលមានការសម្លាប់មនុស្សដូចគ្នាដែរ ហើយនៅក្នុងហ្នឹងក៏មានអ្នកទទួលខុសត្រូវដែរ ថ្នាក់តំបន់ក៏មាន ថ្នាក់ស្រុកក៏មាន ហើយថ្នាក់ឃុំនិងថ្នាក់សហករណ៍ក៏មាន ។ អ៊ីចឹងហើយបានជាខ្ញុំចង់ឲ្យតំណាងរដ្ឋាភិបាលបញ្ជាក់ថាតើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតហ្នឹងថ្នាក់ណាខ្លះ? បើយើងថាថ្នាក់ខ្ពស់បំផុតត្រឹមថ្នាក់ជាតិ ដូច្នេះយុត្តិធម៌មិនអាចមាន

ចំពោះជនរងគ្រោះទេ ព្រោះអ្នករងគ្រោះទាំងអស់ស្លាប់ក្រោមកណ្តាប់ដៃអ្នកណា គឺភាគច្រើនស្លាប់នៅក្រោមកណ្តាប់ដៃសន្តិសុខថ្នាក់ស្រុក គឺភាគច្រើនថ្នាក់ស្រុកជាអ្នកសម្រេចនូវការសម្លាប់ ។ ហើយថ្នាក់ខាងលើបើតាមខ្ញុំយល់គឺមិនខុសទេ គ្រាន់តែដាក់បទបញ្ជាថាឲ្យកម្ទេចខ្មាំងទេ ប៉ុន្តែអ្នកដែលកត់សម្គាល់ខ្មាំងគឺសន្តិសុខថ្នាក់ស្រុកឬថ្នាក់សហករណ៍ ។ ដូច្នេះហើយសូមឲ្យបញ្ជាក់កន្លែងហ្នឹងដើម្បីកុំឲ្យស្រពេចស្រពិល បើកាលណាបកស្រាយថាថ្នាក់លើខ្ពស់បំផុតមានតែប៉ុលពតមួយទេ ប៉ុន្តែឥឡូវប៉ុលពតស្លាប់បាត់ហើយ អាហ្នឹងថ្នាក់ខ្ពស់បំផុត ។

នៅក្នុងចំណុចមួយទៀតនៅក្នុងមាត្រា២៣ថ្មីដែលមានពាក្យមួយដែលដាក់ថា ម្នាក់ជាកម្ពុជា ។ គឺខ្ញុំសូមស្នើដាក់ថាម្នាក់ជាខ្មែរ ព្រោះយើងហៅថាកម្ពុជាជាជនជាតិខ្មែរ ។ ចំពោះមាត្រា៣៣ថ្មីហើយសមាជិករដ្ឋសភាពិតជាបានទទួលសំណើរបស់អង្គការសង្គមស៊ីវិលរួច ហើយដែលសង្គមស៊ីវិលស្នើសុំឲ្យអង្គសភាផ្តល់សិទ្ធិឲ្យចៅក្រមជំនុំជម្រះដើម្បីរៀបចំអនុម័តនីតិវិធីបញ្ហានេះគឺថាខ្ញុំយល់ឃើញថា វាចាំបាច់ដែរដោយសារនៅក្នុងមាត្រា៣៣នេះ គឺយើងបានបញ្ជាក់ច្បាស់ហើយគឺថា អង្គជំនុំជម្រះវិសាមញ្ញត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវនិងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ក៏ប៉ុន្តែនៅក្នុងហ្នឹងគឺបានបញ្ជាក់ថា ក្នុងករណីដែលមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តនីតិវិធីហ្នឹង គឺស្នើឲ្យមានការស្វែងរកការណែនាំនៅក្នុងបទដ្ឋាននីតិវិធីដែលបង្កើតឡើងក្នុងបទដ្ឋានអន្តរជាតិ ។ អាបញ្ហាហ្នឹងវាអត់ច្បាស់ អត់ច្បាស់ថាស្វែងរកកម្រិតណា? អាហ្នឹងគឺថាអាចធ្វើឲ្យអូសបន្លាយចំណាយពេលវេលាកាន់តែខ្លាំង ដូចថាយើងជជែកគ្នាអត់ត្រូវលើនីតិវិធីណាមួយ តើអ្នកណាជាអ្នកសម្រេច? ត្រូវលើកមកសភាវិញឬយ៉ាងម៉េច? បើលើកមកសភាវិញវាកាន់តែយឺតពេល ។ ដូច្នេះហើយបានជាគំនិតរបស់សង្គមស៊ីវិលដែលសុំឲ្យផ្តល់សិទ្ធិឲ្យក្រុមចៅក្រមទាំងអស់ហ្នឹងគឺថាធ្វើនីតិវិធីដោយឡែកមួយដើម្បីជជែកគ្នាឲ្យហើយថានីតិវិធីវិធានស្តីអំពីការរកភស្តុតាងសម្រាប់ដំណើរការមុនដំណាក់កាល ជំនុំជម្រះ ដំណាក់កាលជំនុំជម្រះឬការធ្វើឧទ្ធរណ៍អីចឹង ។ ដូច្នេះបានថា សុំឲ្យអង្គសភាពិនិត្យនិងពិចារណាចំពោះសំណើនេះ ។ ឥឡូវនេះគឺថា បើសិនជាយើងមានសុឆន្ទៈទាំងអស់គ្នា គឺខ្ញុំសូមជំរុញឲ្យអង្គសភាហ្នឹងឲ្យអនុម័តច្បាប់ស្តីពីការរៀបចំនៃការប្រព្រឹត្តទៅរបស់សមាជជាតិ ដើម្បីទុកឱកាសឲ្យប្រជារាស្ត្រ ឲ្យមហាជនដែលជាម្ចាស់ឆ្នោតហ្នឹងអាចមានយុត្តាធិការនៃការសួរដេញដោលជុំវិញបញ្ហាហ្នឹង ។ ឥឡូវវិលមករឿងច្បាប់នេះវិញ ជារួមគឺទូលព្រះបង្គំយើងខ្ញុំគាំទ្រខ្លឹមសារជារួមនៃច្បាប់ហ្នឹង ហើយនិងគាំទ្រឲ្យបានចេញឆាប់ ដើម្បីឲ្យដំណើរជំនុំជម្រះវិសាមញ្ញហ្នឹងគឺបានប្រព្រឹត្តទៅបានឆាប់ ដើម្បីផ្តល់យុត្តិធម៌ជូនប្រជារាស្ត្រខ្មែរ ។ ខ្ញុំសូមអរគុណ ។

***សម្តេច ហេង សំរិនៈ*** *សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ។*

***ឯកឧត្តម សុខ អានៈ*** *ខ្ញុំបាទសូមគោរពសម្តេចអនុប្រធានទី១ សុំថ្វាយបង្គំនិងគោរពអង្គសភាទាំងមូល ។ ខ្ញុំបាទទូលបង្គំសុំធ្វើអត្ថាធិប្បាយលើចំណុចខ្លះដែលបានលើកឡើងដោយឯកឧត្តម ខៀវ សន និងវាគ្មិនជាបន្តបន្ទាប់ ។ ឯកឧត្តម ខៀវ សន លោកបានលើកឡើងចំណុច២ ក្រោយពីបានវាយតម្លៃខ្ពស់និងគាំទ្រចំពោះដំណើរការនៃការកាត់ទោសនេះ ។ ចំណុចទី១ ឯកឧត្តម លោកបានបញ្ជាក់ពីនីតិវិធីដែលនឹងត្រូវអនុវត្តនៅក្នុងដំណើរការនៃអង្គជំនុំជម្រះ ហើយចំណុចទី២ការជ្រើសរើសចៅក្រម ។ ចំណុចទាំង២នេះគឺជាចំណុចដែលមានសារសំខាន់ដែលស្តីអំពីនីតិវិធីនេះ ។ ទូលបង្គំខ្ញុំបាទសូមទូលថ្វាយនិងជម្រាបជូនដែរថា ជាចំណុចដែលមានការពិភាក្សាគ្នាយូរណាស់ ហើយជ្រាលជ្រៅណាស់ជាមួយអង្គការសហប្រជាជាតិនោះ ។ ព្រោះថាក្នុងការអនុវត្តគឺគេចង់អនុវត្តយ៉ាងម៉េចឲ្យមាននីតិវិធីដូចយើងហៅថាស្តង់ដារឲ្យបានច្រើន រៀបទៅតាមអ្វីដែលសភាសន្មតថាជានីតិវិធីអន្តរជាតិ ។ ចំពោះយើងគឺយើងបានលើកឡើងថា គោលការណ៍ទាំង៣ដែលទូលបង្គំខ្ញុំបាទបានលើកឡើងគឺថាសំដៅបញ្ហាយុត្តិធម៌ ផ្តល់យុត្តិធម៌ផង សំដៅរក្សាការបង្រួបបង្រួមជាតិហើយនិងការគោរពអធិបតេយ្យភាពជាតិ ។ ដូច្នេះគឺតាំងពីដើមទីយើងបានលើកឡើងហើយថាជាអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ ដូច្នេះពាក្យថាតុលាការកម្ពុជា យើងបានឆ្លុះបញ្ចាំងច្បាស់ណាស់នូវធាតុពិតនូវសារជាតិនៃអង្គជំនុំជម្រះដែលត្រូវឆ្លុះបញ្ចាំងឲ្យឃើញថាជាតុលាការជាតិ ដូច្នេះនៅចុងបញ្ចប់នៃការពិភាក្សាយើងបានឯកភាពគ្នា យើងបានសម្របសម្រួល*

គ្នាថា ត្រូវប្រើប្រាស់នីតិវិធីជាតិ នីតិវិធីដែលមានជាធរមាននៅក្នុងតុលាការសព្វថ្ងៃនេះ ។ ប៉ុន្តែសួរថាអ្នកដែលបានព្រមព្រៀងជាមួយយើង អ្នកដែលបានលើកឡើងជាមួយយើង គឺថាគេមិនមែនអ្នកច្បាប់អត់ពិសោធន៍ទេ គេអ្នកច្បាប់មានបទពិសោធន៍ខ្ពង់ណាស់ កម្រិតគេខ្ពស់ណាស់ ។ ដូច្នេះយើងត្រូវតែមានការឲ្យទៅឲ្យមក យើងផ្តល់អីឲ្យគេគេផ្តល់អីឲ្យយើងលុះត្រាតែមានតុល្យភាពគ្នាទើបយើងបានធ្វើការសម្របសម្រួលចេញ ។ នេះទើបមានជារូបមន្តដែលអាចព្រមព្រៀងគ្នាបាន អ៊ីចឹងការសម្របសម្រួលនេះគឺថាយើងបញ្ជាក់ថា អង្គជំនុំជម្រះត្រូវប្រើប្រាស់នីតិវិធីដែលមានជាធរមាននៅកម្ពុជា គឺថាការដែលប្រើប្រាស់នីតិវិធីនេះគឺនឹងមានការល្អៀងគ្នា ព្រោះថាយើងនៅកម្ពុជាយើងប្រើតាមប្រព័ន្ធ រ៉ូម៉ាណូ ហ្សែរ ម៉ានិក គឺប្រព័ន្ធដែលយើងធ្លាប់ដកពិសោធន៍ពីបារាំង ហើយគេប្រើប្រព័ន្ធចេញពី ខមមិនឡ (common law) មាននៅអង់គ្លេស អាមេរិកជាដើម ។ អ៊ីចឹងហើយយើងបានសម្របសម្រួលគ្នាលើបញ្ហានេះ ដោយមានចែងច្បាស់លាស់នៅក្នុងមាត្រា៣៣នេះ វិធីដែលមានជាធរមាន ការមិនច្បាស់លាស់ឬមានការមិនប្រក្រតីជាមួយនឹងនីតិវិធីអន្តរជាតិ គឺអស់លោកចៅក្រមហ្នឹងពិភាក្សាគ្នាដើម្បីសម្របសម្រួលទៅនឹងនីតិវិធីអន្តរជាតិ ។ ដូច្នេះនីតិកាលធ្វើសំយោគបញ្ចូលគ្នាក្នុងការប្រើប្រាស់រវាងនីតិវិធីដែលកំពុងតែមាននៅកម្ពុជានិងនីតិវិធីដែលគេកំណត់ថាជានីតិវិធីសម្រាប់អន្តរជាតិដែលគេដកស្រង់ភាគច្រើនចេញពី common law នេះ ។ អ៊ីចឹងហើយបានជាយើងសរសេរនៅមាត្រាទី៣៣ដាក់ថា អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ ព្រោះនៅក្នុងជំពូកនីមួយៗ ជំពូកនេះជាជំពូកសាលាដំបូង ដូច្នេះគឺត្រូវតែបញ្ជាក់ពីសាលាដំបូងឲ្យបានត្រឹមត្រូវនិងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជននោះត្រូវចោទនិងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តន៍នីតិវិធីនោះ ឬប្រសិនបើទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនិងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤និង១៥នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយឆ្នាំ១៩៦៦ ។ នៅក្នុងអនុសញ្ញាអន្តរជាតិនេះគេបានចែងច្បាស់ណាស់ថាអ្វីដែលគេហៅថាស្តង់ដារអន្តរជាតិសម្រាប់ការកាត់ទោស ។ ដូច្នេះគឺយើងយកចំណុចទាំងពីរនេះ អ្វីដែលជាលក្ខណៈជាតិ អ្វីដែលជាលក្ខណៈអន្តរជាតិ មកបូកសរុបចូលគ្នានេះ ។ ទូលបង្គំខ្ញុំក៏បានទទួលព័ត៌មានដែរអំពីសំណើដែល NGO មួយចំនួនលោកបានពិចារណាហើយបានលើកឡើង ។ ដូចចំណុចនេះគឺមានសារសំខាន់ណាស់ គឺត្រង់ថាយើងជជែកគ្នាកម្រិតទីមួយនៅក្នុងពេលធ្វើច្បាប់ហ្នឹង គេចេញអស់ចិត្តហើយ បានឈានទៅដល់ការព្រមព្រៀងគ្នាលើកមុនដែលយើងសរសេរនៅក្នុងច្បាប់ឆ្នាំ២០០១របស់យើង ។ ដល់ពេលចុងក្រោយទៀតដែលត្រូវធ្វើកិច្ចព្រមព្រៀង គេបានយកបញ្ហានេះមកលើកទៀត ហើយមានការជជែកគ្នាយូរណាស់នៅទីក្រុងញូវយ៉ក អ៊ីចឹងចុងក្រោយគឺបានឈានដល់ការឯកភាពគ្នានៅក្នុងមាត្រា៣៣ថ្មីនេះ ។ ដូច្នេះបើយើងលើកតាមយោបល់ដែលបានលើកឡើងនៅក្នុងសំណើការជូនយោបល់របស់អង្គការ NGO នោះ ឬក៏ឯកឧត្តមវាគ្មិនបានយកមកលើកនៅទីនេះនោះ គឺយើងត្រូវធ្វើវិសោធនកម្មទៅលើច្បាប់នេះវិញទៀត ហើយត្រូវធ្វើវិសោធនកម្មត្រូវកែប្រែកិច្ចព្រមព្រៀងយើងជាមួយនឹងអង្គការសហប្រជាជាតិវិញទៀត ។ ដូច្នេះនេះជាប្រការដ៏ស្មុគស្មាញណាស់ អ៊ីចឹងបានយើងត្រូវផ្អាកដំណើរការ ហើយស្នើឲ្យ UN និងស្នើអង្គការសហប្រជាជាតិបញ្ជូនគណៈប្រតិភូចរចាគ្នាជាថ្មីទៀត ។ ដូច្នេះនេះជាប្រការដែលមិនគួរធ្វើទេ ព្រោះយើងបានចរចាស៊ីជម្រៅជាមួយគ្នាដល់ទៅពីរលើក ។ មួយលើកដំបូងហ្នឹងត្រូវប្រើពេលយូរណាស់បានឯកភាពគ្នាបាន ដោយឯកឧត្តមលោកជំទាវដែលជាចៅក្រមចាត់ទុកជាពិសោធន៍របស់យើងនេះត្រូវផ្លាស់ប្តូរយោបល់ជាមួយនឹងជំនាញការគេដែលគេអតីតចៅក្រមជាអ្នកច្បាប់ជាន់ខ្ពស់របស់គេនោះច្រើនដងច្រើនសាណាស់ទើបឈានមកដល់ការយល់ព្រមលើការរួមផ្សំនីតិវិធីទាំងពីរនេះ ។ មុននឹងគេឯកភាពលើការប្រើប្រាស់នីតិវិធីរបស់យើង ក៏គេមិនមែនចេះតែឯកភាពទេ គេបានស្វែងយល់

គេបានសិក្សានីតិវិធីដែលយើងកំពុងតែអនុវត្តនេះ នីតិវិធីដែលមានជាធរមាននេះ គេសិក្សាគេស្វែងយល់ចប់សព្វគ្រប់អស់ទើបគេឈានទៅធ្វើការសន្និដ្ឋាន ដូច្នេះទូលបង្គំខ្ញុំបាទយល់ថា ការដែលយើងឈានមកដល់ការព្រមព្រៀងគ្នាដូចមាននៅក្នុងអត្ថបទចុងក្រោយនេះវាជាលទ្ធផលនៃការចរចាយ៉ាងយូរ យ៉ាងស៊ីជម្រៅ ដោយមានការស្វែងយល់ពីប្រព័ន្ធតុលាការរបស់យើងច្បាស់លាស់ហើយ យើងក៏បានស្វែងយល់អំពីអ្វីដែលយើងហៅថាមាននៅកម្ពុជា ។ ប៉ុន្តែនៅចំណុចណាដែលមានស្តង់ដារអន្តរជាតិដែលគេដកស្រង់ចេញពីអនុសញ្ញាឆ្នាំ១៩៦៦ ស្តីពីសិទ្ធិស៊ីវិលសិទ្ធិនយោបាយនេះ បានស៊ីជម្រៅណាស់ទើបយើងឯកភាពគ្នាចេញជាមាត្រានេះបាន ។ ដូច្នេះទូលបង្គំខ្ញុំបាទសូមស្នើថា សូមរក្សាន័យមាត្រា១២ មាត្រា៣៣ ដូចដែលមាននៅក្នុងអត្ថបទដែលកំពុងដាក់ជូនអង្គសភាដ៏ឧត្តុង្គឧត្តមនេះ ។

ចំណុចមួយទៀតស្តីពីការជ្រើសរើសចៅក្រម ។ នេះជាការងារដែលយើងត្រូវធ្វើដ៏ធ្ងិតធ្ងន់ ហើយដែលយើងមានចែងជាលក្ខណៈសម្បត្តិសំខាន់ៗនៅក្នុងការធ្វើវិសោធនកម្ម ឬក៏សេចក្តីព្រាងច្បាប់របស់យើងនេះបានសព្វគ្រប់ដែរ គឺជាចៅក្រមដែលត្រូវទៅធ្វើការរួមជាមួយនឹងចៅក្រមអន្តរជាតិដែលយើងគិតថាសុទ្ធតែជាចៅក្រមចាស់ទុំមាន *conaissance* មានកម្រិតខ្ពស់របស់គេទើបគេជ្រើសរើសបញ្ជូនមក ។ អ៊ីចឹងក្នុងការដែលធ្វើការជាមួយគ្នានេះ ជាធម្មតាទេដែលអស់លោកចៅក្រមត្រូវធ្វើការក្នុងរូបភាពជាសហប្រតិបត្តិការនិងការតស៊ូមតិ វាបេះមិនដាច់ពីគ្នាទេ គឺជាធម្មតាទេ ត្រូវសហការសាមគ្គីឲ្យបានល្អ ហើយតស៊ូមតិឲ្យបានស៊ីជម្រៅ ។ ដូច្នេះអស់លោកចៅក្រមដែលយើងនឹងត្រូវជ្រើសរើសនោះគឺយើងបានគិតទុកច្បាស់ហើយថាលោកក៏ត្រូវតែមានកម្រិតយល់ដឹង មានបទពិសោធន៍ច្រើន ក្តាប់បានអំពីច្បាប់អំពីនីតិវិធីជាតិដែលធ្លាប់បានអនុវត្តមកច្បាស់លាស់ ហើយក្តាប់បានអំពីច្បាប់ដែលមានប្រភពជាច្បាប់អន្តរជាតិដែលយើងត្រូវយកមកប្រើប្រាស់នេះឲ្យបានច្បាស់លាស់ដែរ ។ ហើយចុងក្រោយគេថែមទៀត កាលធ្វើកិច្ចព្រមព្រៀង គេសុំថែមទៀតថាឲ្យបានច្បាស់លាស់ពីច្បាប់ស្តីពីសិទ្ធិមនុស្សច្បាប់នៃមនុស្សធម៌ថែមទៀត ។ ដូច្នេះការគិតគូរពីកម្រិតសមត្ថភាពនៃចៅក្រមគឺយើងក៏បានគិតគូរច្បាស់លាស់ណាស់ដែរ ហើយក៏នឹងមានវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ ។ យើងបានបើកវគ្គបណ្តុះបណ្តាលម្តងនៅសាលាភូមិន្ទរដ្ឋបាលរួចហើយ បើកបានពីរវគ្គហើយ ហើយយើងនឹងបន្តបើកវគ្គតទៅទៀតអំពីកម្រិតចៅក្រមនេះ ។ គឺថាដូចដែលទូលបង្គំខ្ញុំបាទបានបញ្ជាក់អ៊ីចឹង គឺយើងនឹងយកចិត្តទុកដាក់ធ្វើយ៉ាងណាដើម្បីជ្រើសរើសបាននូវចៅក្រមរបស់យើងដែលអាចជាទីមោទនៈរបស់យើង ។ ក្នុងការតែងតាំងការងារ តែងតាំងនេះក៏ជាការងារពិសេសលើសការតែងតាំងធម្មតាដែរ ព្រោះថាជាតុលាការដែលមានលក្ខណៈចម្រុះ បានន័យថាជាតិនិងអន្តរជាតិ អ៊ីចឹងការតែងតាំងក៏ត្រូវមានលក្ខណៈពិសេសលើសធម្មតា ។ មានការជ្រើសរើសពីអង្គការរដ្ឋផ្សេងទៀតផង បើតាមពិតគឺត្រូវច្រើនគន្លាក់ណាស់ ត្រូវជ្រើសរើសដំបូងអំពីប្រទេសដើមផងនិងសាមីប្រទេសដើម ឧបមាថាបើចៅក្រមហ្នឹងជនជាតិបារាំង ដំបូងត្រូវបារាំងគាត់ជ្រើសរើសសិន ហើយធម្មតាគឺតែងតែមានបេក្ខជនច្រើន ឧទាហរណ៍ថាមានបារាំង អាល្លឺម៉ង់ មានរុស្ស៊ី មានជប៉ុន មានឥណ្ឌា មានសញ្ជាតិអីច្រើនហូរហែអ៊ីចឹងទៅ មានបេក្ខជនច្រើន អង្គការសហប្រជាជាតិត្រូវធ្វើការជ្រើសរើសម្តង ជ្រើសរើសយកចំនួនដែលត្រូវការអ៊ីចឹងការជ្រើសរើសមួយគន្លាក់គឺពីប្រទេសគេមកហើយ អ៊ីចឹងមួយគន្លាក់ទៀតអង្គការសហប្រជាជាតិជ្រើសរើសទៀត ហើយគន្លាក់ទី៣ទើបយើងសម្រេច គឺភាគីកម្ពុជា គឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ឥឡូវរបៀបប្រើពាក្យនៅក្នុងអត្ថបទនេះ យើងបានប្រើពាក្យបីម៉ាត់ ។ នៅក្នុងការតែងតាំងនេះមានពាក្យ“ជ្រើសតាំង” ពាក្យ“តែងតាំង” ហើយបើជាភាសាអង់គ្លេសវិញមានបីម៉ាត់ គឺមានពាក្យ *Nominate* មានពាក្យ *Appoint* និងពាក្យ *Assign* ។ មានន័យថា ចៅក្រមគឺយើងប្រើពាក្យថា *Nominate by the UN General Secretary* ហើយយើងប្រែជាខ្មែរ យើងបានពិភាក្សាគ្នាទៅគឺប្រើពាក្យ“ជ្រើសតាំង” ។ ជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយបានយើងប្រើពាក្យ *Appointed by the Supreme Council of the Magistracy* យើងបកមកយើងប្រើពាក្យថា តាំងតែងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ មានពាក្យមួយទៀតដែលទូលបង្គំខ្ញុំបាទលើកឡើងមិញហ្នឹងថា ដែលពាក្យអង់គ្លេសថា *Assign* គឺពាក្យហ្នឹងជជែកគ្នាយូរណាស់ទើបរកឃើញ សូម្បីតែអង់គ្លេសគ្នាគាត់ សូម្បីតែអ្នកច្បាប់ស្ទាត់

ជំនាញខាងអង្គការសហប្រជាជាតិក៏ត្រូវចំណាយពេលយូរណាស់ដើម្បីរកពាក្យ Assign ហ្នឹងឃើញ ។ មានប្រភេទខ្លះមន្ត្រីខ្លះដែលបានលើកឡើងថា គឺភារកិច្ចអង្គការវិធានទេជាអ្នកតែងតាំង មិនជ្រើសតាំង អ៊ីចឹងគេអត់សុខចិត្តប្រើពាក្យ Nominate ទេ អ៊ីចឹងគេត្រូវប្រើពាក្យ Appoint ។ Appoint ហ្នឹងវាជាក់ត្រូវពាក្យយើងថា តែងតាំងជារដ្ឋមន្ត្រី មន្ត្រីអន្តរជាតិ ដែលគេហៅថា Functional International នេះគឺត្រូវ Appoint គឺត្រូវតែងតាំងដោយអង្គការសហប្រជាជាតិ ហើយដល់ពេលគេមកធ្វើការនៅកម្ពុជាដោយធ្វើការនៅក្នុងការងាររួម គឺវាត្រូវមានការចាត់ចែងពីភាគីកម្ពុជា ។ អ៊ីចឹងមុនដំបូងយើងប្រើពាក្យឲ្យគេ Nominate ហើយយើង Appoint អ៊ីចឹងគេមិនព្រមទេ គឺអត់ត្រូវគ្នាទេកន្លែងហ្នឹង ។ អ៊ីចឹងក្រោយពីពិចារណាយូរណាស់ គឺបានឈានទៅដល់ការឯកភាពគ្នា គេប្រើពាក្យគេ Appoint យើង Assign បានន័យថា គេតែងតាំង ហើយយើងយកមកចាត់ចែងប្រើប្រាស់ចាត់ចែងឲ្យធ្វើការងារជាក់ស្តែង ។ នេះជាចំណុចដែលទូលបង្គំខ្ញុំបាទចង់លើកឡើង គឺថាបើយើងឯកភាពគ្នាលើការប្រើពាក្យជ្រើសតាំងនិងពាក្យតែងតាំងអ៊ីចឹង ធ្វើឲ្យមានការជ្រើសរើស មានការតែងតាំង មានការជ្រើសតាំងហ្នឹងបន្តបន្ទាប់ ។ ដូច្នេះមុននឹងចៅក្រមនោះមុននឹងមន្ត្រីអន្តរជាតិនោះមកបំពេញការងារនៅក្នុងក្របខណ្ឌនៃអង្គជំនុំជម្រះវិសាមញ្ញនេះបាន ។ ចំណុចមួយទៀតដែលពាក់ព័ន្ធទៅនឹងមាត្រា២ គឺទូលបង្គំខ្ញុំបាទបានលើកឡើងអម្បាញ់មិញហ្នឹងហើយ គឺពាក្យថាមេដឹកនាំជាន់ខ្ពស់ ហើយនិងពាក្យថាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ។ អ៊ីចឹងបើយើងពិចារណាទៅមុខសញ្ញាគឺមានពីរប្រភេទ ប្រភេទទីមួយគឺថា ជាមេដឹកនាំ អ៊ីចឹងមេដឹកនាំគឺយើងអាចគិតគូរពីឋានៈ តួនាទី តាមស្មារតី តាមមូលដ្ឋាននៃគតិយុត្តិនេះ គឺអ្នកដែលមានសិទ្ធិជ្រើសរើសមុខសញ្ញាច្បាស់លាស់ដើម្បីយកមកចោទប្រកាន់និងកាត់ទោស គឺសហព្រះរាជអាជ្ញា ។ បានន័យថាចាប់ផ្តើមគឺសហព្រះរាជអាជ្ញា គឺព្រះរាជអាជ្ញាមួយរូបជាកម្ពុជាព្រះរាជអាជ្ញាមួយរូបជាអន្តរជាតិ ។ អ៊ីចឹងព្រះរាជអាជ្ញាពីររូបហ្នឹង គឺគាត់ត្រូវកំណត់មុខសញ្ញាថាត្រូវចោទប្រកាន់អ្នកណាមិនត្រូវចោទប្រកាន់អ្នកណា ប៉ុន្តែច្បាប់នេះ ក៏ផ្តល់នូវមូលដ្ឋានគតិយុត្តិឲ្យគាត់សម្រាប់ធ្វើការចោទប្រកាន់ អ៊ីចឹងឥឡូវនេះបើសួរក្រុមការងារ ឬក៏សួរអង្គការអន្តរជាតិខ្លួនឯងថា ឥឡូវត្រូវចោទប្រកាន់អ្នកណាខ្លះ គឺមិនអាចឆ្លើយបានទេ ព្រោះនេះជាការងាររបស់តុលាការ គឺជាការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ បើយើងដាក់ចំមុខសញ្ញាទៀតនោះ គឺបានន័យថាយើងរំលោភទៅលើការងាររបស់អង្គជំនុំជម្រះនោះហើយ ។ ដូច្នេះក្នុងនាមជាអ្នកដែលរៀបចំការងារនេះ ជាអ្នកដែលរៀបចំច្បាប់ហ្នឹង គឺយើងមិនមានសិទ្ធិទៅកំណត់មុខសញ្ញា ក ខ គ ឃ នោះទេ ។ អ៊ីចឹងយើងកំណត់ជាគោលការណ៍ដើម្បីសហព្រះរាជអាជ្ញាយកទៅធ្វើការ ។ អ៊ីចឹងគោលការណ៍យើងបានកំណត់ពីរប្រភេទ ប្រភេទទីមួយគឺ មេដឹកនាំជាន់ខ្ពស់ យើងចង់សំដៅតាមកម្រិតដែលយើងសរសេរនេះ គឺទាំងភាគីកម្ពុជាទាំងភាគីអង្គការសហប្រជាជាតិនេះ គឺយើងចង់សំដៅទៅលើមនុស្សមិនលើសពី១០នាក់ទេ ។ អ៊ីចឹងបើនិយាយឲ្យចំទៅគឺថាទៅលើវង្វង់អ្នកដឹកនាំដែលមានអាចថា នៅក្នុងរង្វង់ជុំវិញដប់នាក់ហ្នឹង មិនលើសពីប៉ុណ្ណឹងទេ ។ ហើយយើងមិននិយាយច្បាស់ថាគណៈអចិន្ត្រៃយ៍ ឬយើងមិននិយាយច្បាស់ថាគណៈកម្មការកណ្តាលអីទេ យើងកំណត់ពាក្យថាមេដឹកនាំជាន់ខ្ពស់ដើម្បីទុកលទ្ធភាពឲ្យសហព្រះរាជអាជ្ញាគេធ្វើការ ។ នេះជាប្រភេទទីមួយ ហើយមូលហេតុអីដែលយើងត្រូវព្រមព្រៀងគ្នាកំណត់ចំនួនតិចដូច្នេះ? ព្រោះអ្នកដែលមានពិសោធន៍នៅក្នុងការរៀបចំតុលាការអន្តរជាតិនេះក៏គេទទួលស្គាល់ដែរថា ការដែលកាត់ទោសទៅលើមុខសញ្ញារាប់ពាន់រាប់ម៉ឺននាក់នោះមិនមែនជាការងារដែលអាចនឹងទទួលលទ្ធផលល្អទេ ហើយគេទទួលស្គាល់ថាមិនមែនជាផលប្រយោជន៍នៃតុលាការអន្តរជាតិក្នុងការបំពេញលទ្ធផលឲ្យបានប្រសិទ្ធភាពនោះទេ ។ ការលំបាកដែលគេទទួលស្គាល់គឺការកាត់ទោសមេដឹកនាំ ។ បានន័យថាកាត់ទោសអ្នកធំ ព្រោះធម្មតាគឺមិនមានការលំបាកច្រើនដល់ចាំបាច់រៀបចំអង្គការអន្តរជាតិទេ អ៊ីចឹងគឺគេសំដៅទៅលើមេដឹកនាំធំ អ៊ីចឹងហើយបានជាមានការឯកភាពគ្នាកំណត់ប្រើពាក្យមេដឹកនាំនៅក្នុងស្មារតីយល់គ្នាថា ចំនួនហ្នឹងគឺមិនលើសពីដប់នាក់ទេ ហើយបើដាក់អ៊ីចឹង វានៅសល់ប្រភេទទីពីរដែលខ្លួនគេមិនមានឋានៈជាមេដឹកនាំជាន់ខ្ពស់នោះទេ ប៉ុន្តែគេបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មច្រើនហើយវាលេចធ្លោជាងគេ ។ អ៊ីចឹងបានយើងឯកភាពគ្នា ក្នុងការជ្រើសរើសពាក្យថា អ្នកទទួល

ខុសត្រូវខ្ពស់បំផុត ។ អ៊ីចឹងមិនដូចដែលវាគិតខាងដើមបានលើកឡើងទេថាអ្នកទទួលខុសត្រូវហ្នឹងថ្នាក់ណា ។ ប្រភេទទីពីរនេះអត់មានរើសថ្នាក់ទេ គេអត់កំណត់ពីថ្នាក់ពីតួនាទីដឹកនាំទេ គេកំណត់អំពីការទទួលខុសត្រូវផ្ទាល់ដែលវាលេចធ្លោ ហើយវាកាចសាហាវយង់ឃ្នងដែលគួរឲ្យចាប់អារម្មណ៍ជាងគេ ។ អ៊ីចឹងចំនួននេះវាអត់ច្រើនដែរ ចំនួននេះក៏មិនច្រើនដែរ គឺជាចំនួនដែលកំណត់បានថាមានអំពើឃោរឃៅមានឧក្រិដ្ឋកម្មកម្រិតខ្ពស់ជាងគេ ។ ចំណុចមួយទៀត អំពីពាក្យខ្មែរនិងពាក្យកម្ពុជា ទូលបង្គំខ្ញុំបាទក៏សូមបញ្ជាក់ដែរថាតាមទស្សនៈអ្នកច្បាប់គឺយើងមិនមានកំណត់លក្ខណៈខុសគ្នារវាងពាក្យថាខ្មែរនិងកម្ពុជាទេនៅក្នុងការសរសេរច្បាប់នេះ ។ ហើយជាទស្សនៈទូទៅនៅក្នុងអត្ថបទច្បាប់ក៏ប្រហែលជាមិនមានអ្វីខុសគ្នាជាទស្សនៈច្បាប់ដែរ ជាមូលដ្ឋានច្បាប់ដែរ ។ ដូច្នេះបានជានៅក្នុងអត្ថបទនេះកន្លែងខ្លះយើងសរសេរថាចៅក្រមខ្មែរ កន្លែងខ្លះក៏សរសេរថាចៅក្រមកម្ពុជា ។ អ៊ីចឹងចំណុចដែលទូលបង្គំខ្ញុំបាទសូមលើកឡើងគឺមាត្រា៣ដែលដាក់ថាចៅក្រមខ្មែរ ហើយប្រភេទខ្លះក៏អ្នកសរសេរដាក់ថាចៅក្រមកម្ពុជា ។ គឺក្នុងន័យនេះហើយដែលមានការសរសេរខុសប្លែកៗគ្នាដូច្នេះ ។ ចំណុចដែលបានលើកឡើងពីរដងនេះគឺបញ្ហានីតិវិធីផ្ទៃក្នុងពេលដែលទូលបង្គំខ្ញុំបាទបានលើកឡើងអ៊ីចឹងពីកម្មវត្ថុដែលធ្វើការពិភាក្សាគ្នាស៊ីជម្រៅណាស់ ទម្រាំនឹងឈានមកដល់ការព្រមព្រៀងគ្នានេះ ។ ហើយបើយើងដូរនីតិវិធី ឧទាហរណ៍មានគំនិតចង់ឲ្យច្បាប់ផ្តល់សិទ្ធិទៅដល់ចៅក្រមដើម្បីសរសេរជានីតិវិធីបទបញ្ជាផ្ទៃក្នុង ឬនីតិវិធីផ្ទៃក្នុងរបស់តុលាការរបស់អង្គជំនុំជម្រះ គឺទូលបង្គំខ្ញុំបាទយល់ថា វានឹងឈានទៅដល់ការធ្វើវិសោធនកម្មច្បាប់និងកិច្ចព្រមព្រៀងជាថ្មីម្តងទៀត ហើយអ្វីដែលយើងសរសេរនេះគឺជាលទ្ធផលនៃការជជែកគ្នាស៊ីជម្រៅណាស់ដែលធ្វើយ៉ាងម៉េចឆ្លុះបញ្ចាំងឲ្យឃើញថាយើងយកចិត្តទុកដាក់ពីអ្វីដែលជាស្តង់ដារអន្តរជាតិ ពីអ្វីជានីតិវិធីមានកម្រិតអន្តរជាតិ ហើយក៏ឆ្លុះបញ្ចាំងបានពីអ្វីដែលជានីតិវិធីជាតិ ហើយដែលកំពុងតែមានជាធរមាន ។ ទូលបង្គំខ្ញុំបាទសូមថ្លែងអំណរគុណ សូមមានយោបល់តែប៉ុណ្ណេះ ។

***សម្តេច ហេង សំរិនៈ*** *អ៊ីចឹងសូមអញ្ជើញប្រធានគណៈកម្មការ ។*

***ឯកឧត្តម ឯក សំអុលៈ*** ខ្ញុំបាទសូមគោរពសម្តេចប្រធាន សូមថ្វាយបង្គំសម្តេច ព្រះអង្គម្ចាស់ក្សត្រីយ៍ សូមគោរពឯកឧត្តម លោកជំទាវ សមាជិក សមាជិកាអង្គសភាដ៏ឧត្តុង្គឧត្តម ។ ទូលបង្គំខ្ញុំបាទសូមអនុញ្ញាតដើម្បីរាយការណ៍និងធ្វើការបកស្រាយនូវសំណួរខ្លះ បំពេញបន្ថែមទៅលើយោបល់ស្រាយបំភ្លឺរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ។ នៅពេលសម្រាកនេះ ទូលបង្គំខ្ញុំបាទយល់ថា សាធារណៈមតិ ពិសេសក្នុងមជ្ឈដ្ឋានអ្នកសារព័ត៌មាន ហាក់ដូចជាពុំបានទទួលដឹងឮអំពីខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលបានចុះហត្ថលេខាគឺថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ នៅឡើយទេ ។ បើសិនណាជាអត្ថបទកិច្ចព្រមព្រៀងនេះត្រូវបានរដ្ឋសភាថតចម្លងហើយដាក់លក់ទៅយកថ្លៃក្រដាស ពីព្រោះយើងវាក្រ ឬមួយក៏ចែក អាចចែកបានក៏ចែកទៅ ។ ពីព្រោះកិច្ចព្រមព្រៀងនេះមានទាំងអស់៣២មាត្រា ហើយពីម្សិលមិញអង្គសភាបានធ្វើការពិភាក្សានិងអនុម័តរួចហើយ ដូច្នេះអត់មានរឿងត្រឡប់ក្រោយដើម្បីសុំកែកិច្ចព្រមព្រៀងបានទេ ហើយកិច្ចព្រមព្រៀងដែលរដ្ឋសភាយើងបានអនុម័តនេះ ទូលបង្គំខ្ញុំបាទពីម្សិលមិញបានរាយការណ៍ជូនអង្គសភា ដែលនេះជាក្របខ័ណ្ឌជាមូលដ្ឋានបង្អែកក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញពីឆ្នាំ២០០១របស់យើង ។ ខ្លឹមសារគោលៗពីម្សិលមិញទូលបង្គំខ្ញុំបាទបានរាយការណ៍ជូនអង្គសភាហើយ គ្រាន់តែសុំលើកឧទាហរណ៍ខ្លះដែលកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាល ដែលយើងចាត់ទុកថាជាមូលដ្ឋានបន្ថែម ហើយធ្វើដូចជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។ កិច្ចព្រមព្រៀងដែលយើងអនុម័តពីម្សិលមិញនេះចាត់ទុកដូចជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ក្រោយពីយើងបានបំពេញតាមនីតិវិធីនៃការផ្តល់សច្ចាប័នហើយ ច្បាប់កិច្ចព្រមព្រៀងនឹងក្លាយជាច្បាប់មួយ ។ អ៊ីចឹងអ្វីដែលយើងជជែកគ្នានៅព្រឹកនេះ គឺយើងនឹងខិតខំកែសម្រួលធ្វើវិសោធនកម្មច្បាប់ឆ្នាំ២០០១យើងនេះឲ្យវារលូនទៅនឹងកិច្ចព្រមព្រៀងដែលអង្គសភាបានអនុម័តពីម្សិលមិញ ។ ឧទាហរណ៍គ្រាន់តែការកែសម្រួលរចនាសម្ព័ន្ធថ្នាក់តុលាការពីបីថ្នាក់ក្នុងច្បាប់ឆ្នាំ២០០១ គឺមានសាលាដំបូង មានសាលាឧទ្ធរណ៍ និងតុលាការកំពូល ឥឡូវយើងលុបសាលាឧទ្ធរណ៍ចោល

ឬរបរចនាសម្ព័ន្ធប៉ុណ្ណឹងវាញាំងទៅឲ្យយើងធ្វើវិសោធនកម្ម គ្រាន់តែកែសម្រួលរចនាសម្ព័ន្ធតុលាការប៉ុណ្ណឹងត្រូវធ្វើវិសោធនកម្មប្រាំពីរប្រាំបីមាត្រា គឺមាត្រា២, មាត្រា៩, ១១, ១៤, ១៧, ១៨, ៣៦ និង៣៧ និយាយតែរចនាសម្ព័ន្ធមួយ ។ និយាយពីអាជ្ញាយុកាល ។ តែអាជ្ញាយុកាលញាំងឲ្យកែរហូតដល់បីមាត្រា គឺមាត្រា៣ មាត្រា២៩ មាត្រា៣៦ ។ ដើម្បីទទួលស្គាល់និងអនុវត្តតាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល ឬក៏យើងហៅថាសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឆ្នាំ១៩៦៦ ក៏យើងទទួលស្គាល់ដែលចែងក្នុងកិច្ចព្រមព្រៀងហើយហ្នឹងត្រូវកែមាត្រា២៤, ៣៣, ៣៤, ៣៥, ៤៣ អស់មួយជន្លាសទៀត ។ ហើយនៅមានមាត្រាបន្ទាប់បន្សំជាច្រើនទៀត ឧទាហរណ៍ដូចជាការកំណត់ថា ចៅក្រមត្រូវមានបទពិសោធន៍រួមទាំងមានច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់សិទ្ធិមនុស្សផង ត្រូវធ្វើវិសោធនកម្មមាត្រា១០ ។ ការស្រាយបំភ្លឺលើការជ្រើសរើសចៅក្រម សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឬសហ-ព្រះរាជអាជ្ញាអន្តរជាតិឲ្យបំពេញកន្លែងទំនេរ គឺត្រូវធ្វើវិសោធនកម្មមាត្រា១១, ២១, និងមាត្រា២៧ ។ ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ លោកមានសិទ្ធិផ្តល់បញ្ជីបេក្ខជនបន្ថែម ត្រូវកែមួយមាត្រាទៀតគឺមាត្រា៤៦ ។ ហើយនិយាយអំពីសហព្រះរាជអាជ្ញាបរទេស សិទ្ធិតែងតាំងសហព្រះរាជអាជ្ញាបរទេសឬអន្តរជាតិ ពីរហ្នឹងយើងប្រើបានដូចគ្នាទេខ្លឹមសារ គាត់មានសិទ្ធិតែងតាំងសហព្រះរាជអាជ្ញារង រងរបស់គាត់គាត់មានសិទ្ធិតែងតាំង អាហ្នឹងត្រូវកែមាត្រា២២មួយ ហើយការបំភ្លឺមាត្រា៣៣, ៣៤, ៣៥ ដែលត្រូវអនុវត្តដូចគ្នានៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកំពូល យើងធ្វើមាត្រា៣៧ផ្សេង ។ មានចំណុចជាច្រើនទៀតដែលទូលបង្គំខ្ញុំបាទសូមលើកត្រង់ហ្នឹង ពីព្រោះបានរាយការណ៍លម្អិតពីម្សិលមិញហ្នឹងហើយ ដូច្នេះផ្អែកលើមូលដ្ឋានកិច្ចព្រមព្រៀងដែលអង្គសភាបានអនុម័តម្សិលមិញ សូម្បីតែពាក្យពេចន៍សឹងតែពិបាកដូរ ដូចជាវាគ្និនយើងបានលើកពិបាកដូរណាស់ ដូចថាសុំឲ្យដាក់ទទួលខុសត្រូវជាន់ខ្ពស់មួយកម្រិតមានឋានៈសមាជិកមជ្ឈិមឬថ្នាក់សមាជិកការិយាល័យនយោបាយ ឬមួយគណៈតំបន់ វាទៅអត់រួច ពីព្រោះកិច្ចព្រមព្រៀងចប់អស់ហើយ ។ នៅក្នុងកិច្ចព្រមព្រៀងនៅក្នុងមាត្រា១ ដែលគេនិយាយពីគោលបំណងនៃកិច្ចព្រមព្រៀងនៅក្នុងនោះគេចែងច្បាស់ ។ គេថា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ។ល ។និង ។ល ។ ដូច្នេះយើងអត់រកថែមអីបានទេ យើងកែពាក្យឯណាបាន? អត់បានទេ ។ យើងគ្រាន់តែដឹងថា ពីឆ្នាំ២០០១ ខែមករា រដ្ឋសភានីតិកាលទី២បានជជែកគ្នាច្រើនណាស់ អ្នកខ្លះគិតទៅដល់ប្រធានភូមិទៅទៀតនោះ ប្រធានសហករណ៍ទៅទៀតនោះ ។ បើនិយាយពីការឈឺចាប់ ពីព្រោះខ្ញុំគិតថា នៅក្នុងចំណោមសមាជិកសមាជិការដ្ឋសភា និងសមាជិកសមាជិការដ្ឋាភិបាលដែលបានអញ្ជើញមកទីនេះ ជិតឬឆ្ងាយសុទ្ធតែមានការបាត់បង់ឪពុកម្តាយ បងប្អូន ម្តាយធំ ឪពុកធំ មីងមាញាតិមិត្ត សុទ្ធតែយើងជាអ្នករងគ្រោះពីរបបប៉ុលពត ។ អ្នកខ្លះដឹងថាអ្នកនេះសម្លាប់គ្រួសារខ្ញុំ ប៉ុន្តែឥឡូវយើងធ្វើម៉េច? ព្រោះច្បាប់កំណត់ត្រឹមថា អ្នកទទួលខុសត្រូវខ្ពស់បំផុតនិងមេដឹកនាំជាន់ខ្ពស់ ហើយសុំឲ្យអង្គជំនុំជម្រះវិសាមញ្ញលោកធ្វើការចោទប្រកាន់ទៅព្រោះថាខ្ពស់បំផុតឬទទួលខុសត្រូវខ្ពស់បំផុតហ្នឹងគឺថា អាហ្នឹងគឺធ្ងន់ហើយ គឺបានប្រព្រឹត្តបទឧក្រិដ្ឋកម្មដែលមានចែងច្បាប់នេះគឺធ្ងន់ធ្ងរទទួលខុសត្រូវធំជាងគេ ទទួលខុសត្រូវច្រើនជាងគេហើយ ។ ដូច្នេះខ្ញុំគិតថាមតិដែលវាគ្និនខាងដើមបានលើកដូចជាមានទាក់ទងទៅនឹងមាត្រា២ដែលទាក់ទងទៅនឹងពាក្យ“ជាន់ខ្ពស់”នេះ កែអត់បានទេ ។ ហើយមាត្រា២ដែលកែតែបន្តិចទេ កែតែលុបពាក្យ“សាលាឧទ្ធរណ៍”ហ្នឹងមួយ ហើយនិងយើងបំពេញបន្ថែម “ប្រគល់សមត្ថកិច្ចឲ្យទៅតុលាការកំពូលជាអ្នកទទួលបណ្តឹងឧទ្ធរណ៍ផងនិងសម្រេចសេចក្តីបិទផ្លូវតវ៉ាផង ។” ...ដូចជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោយពីទទួលសច្ចាប័នសមស្របតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាស្តីពីសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញា ។ អីចឹងហើយគឺថាយើងរើអត់រួចទេ រកលុបពាក្យថាលុបអាស្លនហ្នឹងចេញលុបអត់បាន ពីព្រោះយើងដកស្រង់ចេញពីកិច្ចព្រមព្រៀង ។ ដូច្នេះទូលបង្គំខ្ញុំបាទយល់ថា ដោយសារយើងបានអនុម័តកិច្ចព្រមព្រៀងពីម្សិលមិញរួចហើយ ហើយកិច្ចព្រមព្រៀងនេះជាមូលដ្ឋានបង្អែក ឬក៏ជាក្របខណ្ឌក្នុងការដែលធ្វើវិសោធនកម្មច្បាប់ឆ្នាំ២០០១របស់យើងឲ្យរលូន ដូច្នេះហើយជាការចាំបាច់គឺមានការធ្វើវិសោធនកម្មរហូតទៅដល់២៩មាត្រាត្រូវបានជម្រាបជូននេះ

ហើយទូលបង្គំខ្ញុំបាទក៏មិនមែនគិតថាគណៈកម្មការជំនាញ សហការជាមួយនឹងគណៈកម្មការភាសាបរទេស សហប្រតិបត្តិការអន្តរជាតិ យោសនាការ ពត៌មានរួមជាមួយនឹងរាជរដ្ឋាភិបាលដែលបានប្រជុំគ្នាធ្វើការផ្សារទៅវាសុក្រឹតមួយរយភាគរយទេ ព្រោះថាវានៅសេសសល់បញ្ហាពាក្យពេចន៍ ជួនកាលខុះរបាទ ជួនកាលខុះទណ្ឌឃាត ជួនកាលខុះជើង ជួនកាលខុសស្រៈ ជួនកាលទៀតវាខុសចិត្តដោយសារសិល្បៈនៃការសរសេរមានរៀងៗខ្លួន រចនាបថក្នុងការសរសេរមានរៀងៗខ្លួនអាចមាននៅបញ្ហាសេសសល់ដែលសុំឲ្យអង្គសភាលោកមេត្តាយោគយល់ចំពោះកំហុសពាក្យពេចន៍ ខុះស្រៈខុះជើងទាំងនេះ គឺសុំស្នើដល់នាយកដ្ឋាននីតិវិធីនៃរដ្ឋសភាលោកមេត្តាជួយធ្វើការកែតម្រូវផ្អែកលើវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ធ្វើជាមូលដ្ឋាន ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិៈ** អរគុណឯកឧត្តម ។ ខ្ញុំសូមមានមតិដូចតទៅនេះ ទីមួយសមាជិក សមាជិកាដ៏ឧត្តុង្គឧត្តមនៃរដ្ឋសភាយើងទាំងមូលដែលអញ្ជើញមកពីគណបក្សទាំងបី មានការឯកភាពគ្នាជាឯកច្ឆន្ទក្នុងការពិនិត្យអនុម័តក្នុងការត្រូវការជាដាច់ខាតនូវកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ និងវិសោធនកម្មដែលយើងត្រូវតែធ្វើចំពោះច្បាប់ដែលយើងមានរួចមកហើយ ។ ចំណុចទីពីរ រដ្ឋសភាជាតិលោកបានអនុម័តជាឯកច្ឆន្ទ១០៧សំឡេងលើ១០៧ នូវសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងនេះ ។ ដូច្នេះហើយជាយោបល់របស់ខ្ញុំ ចំណុចទីបី ព្រឹទ្ធសភាពុំអាចនឹងស្នើកែនូវអត្ថបទនៃភាសាអក្ខរកម្មនៃច្បាប់នេះ ។ បើឯកឧត្តមលោកជំទាវមានសំណួរដើម្បីសុំស្នើឲ្យឯកឧត្តមប្រធាន ឯក សំអុល ឬក៏ឯកឧត្តមឧបនាយកឆ្លើយជម្រាប ប៉ុន្តែក្រៅពីនេះយើងមិនមានលទ្ធភាពអ្វីទេ ពីព្រោះយើងបានសម្រេចកិច្ចព្រមព្រៀងរួចហើយ ។ ធ្វើអ្វីគឺថាសមស្របវិសោធនកម្មនេះ សមស្របនឹងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិតែប៉ុណ្ណឹង ។ អ៊ីចឹងសំណួរ ពន្យល់ ប៉ុន្តែកែជាខ្លឹមសារនៃមាត្រាថ្មីទាំងប៉ុន្មាននេះខ្ញុំយល់ថាយើងពុំអាចនឹងកែបានទេ ពីព្រោះយើងបានអនុម័តកិច្ចព្រមព្រៀងពីម្សិលមិញរួចមកហើយ ។ សូមអរព្រះគុណ សូមអរគុណ ដូច្នេះខ្ញុំសុំឯកឧត្តម ម៉ោញ សាផាន ។

**ឯកឧត្តម ម៉ោញ សាផានៈ** ខ្ញុំបាទសូមគោរពអនុប្រធានទី១ សូមថ្វាយបង្គំសម្តេច អង្គម្ចាស់ក្សត្រី សូមគោរពឯកឧត្តម លោកជំទាវ សមាជិកសមាជិកានៃអង្គសភា ។ ទូលបង្គំបានស្តាប់ដោយយកចិត្តទុកដាក់ការពន្យល់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ព្រមទាំងការពន្យល់របស់ឯកឧត្តម ឯក សំអុល គឺថាសុទ្ធតែមានការខិតខំប្រឹងប្រែង ។ ...នេះគឺការតាមដានរបស់ជាតិទាំងផ្ទៃក្នុងនិងអន្តរជាតិ ប៉ុន្តែទូលបង្គំខ្ញុំបាទបានស្តាប់ការពន្យល់របស់ឯកឧត្តមឧបលោកថាការកាត់ទោសមិនឲ្យមានចំនួនច្រើនទេ អ៊ីចឹងហាក់ដូចជាដឹងមុន ។ នេះជាលក្ខណៈមួយដែលធ្វើឲ្យមានការសង្ស័យ បើឯកឧត្តមនៅតែយល់យ៉ាងដូច្នេះ ។ ទីពីរក្រោយមកទៀតលោកថា ការចោទប្រកាន់វាសម្រេចទៅលើតុលាការ អ៊ីចឹងវាដំណើរម្តងឆ្វេងម្តងស្តាំ ម្តងទៅមុខម្តងទៅក្រោយ ដូចដំណើរក្តាមអ៊ីចឹងពិបាកយល់ណាស់ ។ អ៊ីចឹងសូមឯកឧត្តមប្រកាន់ជំហរឲ្យច្បាស់ថាប៉ុន្មាន ឬក៏ជាភារកិច្ចរបស់តុលាការ ប៉ុន្តែតាមគោលការណ៍ច្បាប់ ការចោទប្រកាន់ទៅលើបុគ្គលណាមួយជាភារកិច្ចរបស់តុលាការ យើងមិនអាចកំណត់ថាតិចឬច្រើន ឬក៏ដប់នាក់យ៉ាងច្រើន កំណត់អ៊ីចឹងអត់បានទេ ខុសពេញទីតែម្តង ។ ហើយបញ្ហាមួយទៀត គឺបញ្ហាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ។ ឯកឧត្តមផ្តល់ទៀតថា ក៏មិនច្រើនដែរ ។ ប៉ុន្តែទូលបង្គំខ្ញុំបាទសូមលើកថា អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត គ្រាន់តែនៅតំបន់៥ ដែលទូលបង្គំខ្ញុំបាទបានរស់នៅទីនោះមានតាំងពីប្រធានតំបន់ អាហ្នឹងអ្នកទទួលខុសត្រូវនៅក្នុងតំបន់៥ ប្រធានសហករណ៍ដែលសម្លាប់គេច្រើន អាហ្នឹងអ្នកទទួលខុសត្រូវក្នុងសហករណ៍ ប្រធានឈ្លបដែលសម្លាប់គេច្រើន អាហ្នឹងអ្នកទទួលខុសត្រូវនៅកងឈ្លប អ៊ីចឹងមានបីនាក់ហើយគ្រាន់តែកន្លែងហ្នឹងបន្តិច ។ បន្តិចអ៊ីចឹងទូទាំងប្រទេសថាមិនច្រើនដែរ ។ អ៊ីចឹងហើយនៅពេលនេះ យើងក៏មិនអាចកំណត់បានដែរ ។ អ៊ីចឹងសូមឯកឧត្តមបញ្ជាក់ឲ្យច្បាស់មិនត្រូវបញ្ជាក់អង្គសភាថាមិនឲ្យហួសពី១០នាក់ឬតិចទេ មិនអាចថាបានទេ វានៅលើតុលាការ ចំណុចទីមួយ ។ ចំណុចទី២ ទូលបង្គំខ្ញុំបាទចង់លើកអនុសាសន៍មួយក្នុងការជ្រើសរើសចៅក្រមខ្មែរ ឲ្យចូលបម្រើការនៅអង្គជំនុំជម្រះវិសាមញ្ញនេះ ។ ចៅក្រមខ្មែរគឺចៅក្រមភាគច្រើនសុទ្ធតែពាក់ព័ន្ធនៅក្នុងការរស់នៅរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ អ៊ីចឹងតែពាក់ព័ន្ធហើយវា

ខុសនឹងគោលការណ៍យុត្តិធម៌ហើយ ។ នៅក្នុងតុលាការ ជាពិសេសឯកឧត្តម អ៊ុក វិធន់ នៅទីនេះ លោកជាអគ្គព្រះរាជអាជ្ញាតុលាការកំពូល លោកដឹងហើយ តែមានការពាក់ព័ន្ធហើយ ការជំនុំជម្រះក៏វាមិនអាចរកយុត្តិធម៌ដែរ អ៊ីចឹងនៅក្នុងពេលនេះ ច្បាប់នេះគឺយើងចង់រកយុត្តិធម៌ឲ្យប្រជាពលរដ្ឋដែលជាអ្នករងគ្រោះផង និងរកយុត្តិធម៌ឲ្យអ្នកដែលប្រព្រឹត្តផង ទាំងសងខាង ។ ប្រព្រឹត្ត១០ត្រូវតែទទួលទោស១០ អ៊ីចឹងអ្នកដែលធ្លាប់ប្រព្រឹត្តប៉ុន្មានគឺត្រូវទទួលទោសប៉ុណ្ណឹង ហើយគុណមិនអាចយកមកសងទោសបានទេ ទទួលទោសហើយបានមានគុណពីក្រោយ ។ ព្រះពុទ្ធសាសនាលោកក៏ចែងដែរថា ទោសមិនអាចសងដោយគុណបានទេ អ៊ីចឹងនៅក្នុងច្បាប់ក៏ដូចគ្នានៅក្នុងនេះនិយាយដូចគ្នា អ៊ីចឹងបញ្ហាទីពីរ ។ បញ្ហាទី៣ សូមកុំប្រើពាក្យចៅក្រមកម្ពុជា ព្រោះយើងសំអាងទៅលើរដ្ឋធម្មនុញ្ញ ។ រដ្ឋធម្មនុញ្ញនិយាយថាប្រជាពលរដ្ឋខ្មែរ អ៊ីចឹងសូមឯកឧត្តមដូរពាក្យចៅក្រមកម្ពុជាមកជាចៅក្រមខ្មែរវិញ ព្រោះអ្វីដែលរដ្ឋសភាអនុម័តវាជាច្បាប់ អ៊ីចឹងកាលណាជាច្បាប់ គេប្រើទូទាំងប្រទេស អ៊ីចឹងហើយរយៈកាលកន្លងមកស្អីដែលសភាអនុម័តហើយគឺទូទាំងប្រទេសគេប្រើយ៉ាងដូច្នេះ ហើយបើរដ្ឋធម្មនុញ្ញសរសេរថា ប្រជាពលរដ្ឋខ្មែរ ទៅជាដល់ច្បាប់នេះដាក់ថាប្រជាពលរដ្ឋកម្ពុជាមាត្រា៧៦ ។ ឯកឧត្តមសូមមើលមាត្រា៧៦ គេដាក់ថាប្រជាពលរដ្ឋខ្មែរ ។ អ៊ីចឹងសូមប្រែថាប្រជាពលរដ្ឋខ្មែរ កុំប្រែថាខ្មែរក៏បាន កម្ពុជាក៏បាន ។ វាអត់មានអីអាង យើងអាងតាមមាត់ដែលថាគឺវាមិនសមស្របទេ ។ អ៊ីចឹងសូមនិយាយដែលមានអ្វីជាអាង អាហ្នឹងចំណុចទីបី ។ ចំណុចមួយទៀតពាក់ព័ន្ធនឹងបញ្ហាខ្លឹមសារនៃវិសោធនកម្ម ។ ពិតមែនហើយគឺការផ្លាស់ប្តូរនូវរចនាសម្ព័ន្ធតុលាការ យើងត្រូវមានការផ្លាស់ប្តូរនិងវិសោធនកម្មនូវមាត្រាមួយចំនួនដែលពាក់ព័ន្ធ ។ ក្នុងនេះទូលបង្គំខ្ញុំបាទបានសង្កេតឃើញថា មាត្រា២៣ដែលមានដាក់ពាក្យ "ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា" ។ ហើយនៅឃ្លាចុងក្រោយដែលឯកឧត្តមប្រធានគណៈកម្មការនៅក្នុងខ្លឹមសារច្បាប់ដាក់ថា "ជនរងគ្រោះនិងស្តាប់ចម្លើយសាក្សី" ឯកឧត្តមអានថា "ជនរងគ្រោះឬស្តាប់ចម្លើយសាក្សី" ។ ឃ្លាពីរនេះបើយើងយកមកនិយាយវាដូចតែគ្នា ប៉ុន្តែតាមពិតន័យវាមិនដូចទេ ។ "សួរចម្លើយជនរងគ្រោះនិងស្តាប់ចម្លើយសាក្សី" បានន័យថាទាំងពីរហ្នឹង គឺទាំងពីរ ។ បើ "ស្តាប់ចម្លើយជនរងគ្រោះឬស្តាប់ចម្លើយសាក្សី" បានន័យថាធ្វើមួយណាក៏បានដែរ ។ នេះមិនមែនជាការគ្រាន់តែដូរពាក្យពេចន៍ ប៉ុន្តែជាការដូរខ្លឹមសារ ។ អ៊ីចឹងសូមឯកឧត្តមបញ្ជាក់ឲ្យបានច្បាស់ ឯកឧត្តមប្រធានគណៈកម្មការអានថា "ឬស្តាប់ចម្លើយសាក្សី" ប៉ុន្តែតាមខ្លឹមសារដែលដាក់នៅក្នុងសេចក្តីព្រាងគេថា សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះនិងស្តាប់ចម្លើយសាក្សី នៅក្នុងសេចក្តីព្រាងដាក់ "និង" រីឯឯកឧត្តមអានថា "ឬ" អ៊ីចឹងពីរហ្នឹង ខុសគ្នា តែ "និង" គឺត្រូវធ្វើទាំងអស់ តែដាក់ "ឬ" គេស្តាប់ចម្លើយសាក្សីក៏បាន មិនស្តាប់ក៏បាន ។ អ៊ីចឹងខ្លឹមសារនៅពេលនេះត្រូវឲ្យបានច្បាស់ ព្រោះជារឿងសំខាន់មិនមែនជារឿងលេងសើចដែលជាការកំណត់នៅក្នុងច្បាប់ ។ មាត្រា៣៣ នៅបន្ទាត់ទី៤រាប់ពីលើ បន្ទាត់ទី៥ នៅចន្លោះកណ្តាលគេថា ជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតក្នុងកម្រិតអន្តរជាតិ ។ នៅក្នុងនេះទូលបង្គំខ្ញុំបាទចង់សួរថា "គេ" គេហ្នឹង អ្នកណា"គេ"ហ្នឹង? "គេ"អាចបានន័យថា ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញហ្នឹងប្រជុំគ្នាដើម្បីរកនីតិវិធីតាមបទដ្ឋានអន្តរជាតិ ឬក៏ស្ថាប័នណាមួយទៀតដែលធ្វើការណែនាំ ។ អ៊ីចឹងនៅក្នុងនេះគេដាក់ថា គេអាចរកការណែនាំ អ៊ីចឹងបានន័យថាណែនាំយ៉ាងម៉េច? អ៊ីចឹងសូមឯកឧត្តមបញ្ជាក់ បើតាមទូលបង្គំខ្ញុំបាទយល់គឺថា គួរតែដាក់ថា "ចៅក្រមនៃអង្គជំនុំជម្រះក្តីប្រជុំអនុម័តរកនីតិវិធីណាមួយក្នុងបទដ្ឋានអន្តរជាតិ" ។ គួរតែដាក់យ៉ាងដូច្នេះទើបត្រឹមត្រូវ ។ បើដាក់ "គេអាចស្វែងរកការណែនាំ" វាមិនដឹងអ្នកណាអ្នកណែនាំ ។ អ៊ីចឹងសូមឯកឧត្តមបញ្ជាក់ ។ បន្តមកទៀតមាត្រា៣៨ថ្មី បន្ទាត់ទី៣ "លើកលែងតែក្នុងកាលៈទេសៈពិសេស" អាហ្នឹងគួរឯកឧត្តមបញ្ជាក់នៅពេលនេះដែរ ។ បើថាមិនអាចធ្វើការកែប្រែបានថាលក្ខណៈពិសេសអីខ្លះ តែដាក់ក្នុងកាលៈទេសៈពិសេសទទេអ៊ីចឹង កាលណាមិនចង់សម្ងាត់ ។ អាហ្នឹងលក្ខណៈពិសេសធ្វើសម្ងាត់អ៊ីចឹងសូមបញ្ជាក់ផង សូមបញ្ជាក់ថាវាប៉ះពាល់យ៉ាងម៉េច វាស្អីយ៉ាងម៉េច ក្នុងកាលៈទេសៈដែលយើងមិនអាចធ្វើការផ្សព្វផ្សាយ ដែលត្រូវប្រជុំជាសម្ងាត់ ។ សម្ងាត់ហ្នឹងក្នុងលក្ខណៈពិសេសពេលណាយ៉ាងម៉េចខ្លះ ដែលការផ្សព្វផ្សាយធ្វើឲ្យប៉ះពាល់ដល់ភាពយុត្តិធម៌? នៅបន្ទាត់ទី១ មាត្រា៣៨ដដែល អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជា

សាធារណៈនិងបើកចំហសម្រាប់តំណាងរបស់រដ្ឋបរទេស សម្រាប់តំណាងរបស់រដ្ឋបរទេស អាហ្នឹងសុំបញ្ជាក់ថាម៉េចរដ្ឋបរទេស? យ៉ាងម៉េចតំណាងរបស់ចៅក្រមបរទេស ឬក៏តំណាងរបស់រដ្ឋបរទេស? សុំបញ្ជាក់កន្លែងហ្នឹង បើថាយ៉ាងម៉េចសុំកែឲ្យហើយ រដ្ឋបរទេស តំណាងរបស់រដ្ឋបរទេសអាហ្នឹងយ៉ាងម៉េច? គឺអត់យល់កន្លែងហ្នឹង សូមឯកឧត្តមបញ្ជាក់ ។ តមកទៀត មាត្រា៣៦ បន្ទាត់ទី២ កណ្តាល ពីសាលដីការបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង អាហ្នឹងសាលដីកាអីចឹងឬក៏ហៅសាលក្រម? អីចឹងសូមនិយាយគ្នាឲ្យច្បាស់ឲ្យហើយ ។ ព្រោះយើងប្រើមកថាសាលាដំបូងវាសាលក្រម សាលាឧទ្ធរណ៍ឬតុលាការកំពូល យើងប្រើសាលដីកា ឥឡូវនៅក្នុងនេះសាលដីការបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ហើយយើងថាប្រើនីតិវិធីផ្ទៃក្នុង ហើយបើយើងដូរខ្លឹមសារ តើមានខ្លឹមសារយ៉ាងម៉េច សូមបញ្ជាក់ ។ បន្ទាប់មកទៀតមាត្រា៤០ វាពាក់ព័ន្ធនឹងបញ្ហាលើកលែងទោស ប៉ុន្តែទូលបង្គំខ្ញុំបាទបានមើលនៅក្នុងកិច្ចព្រមព្រៀងទៅឃើញថា កិច្ចព្រមព្រៀងគេបង្ខំឲ្យដាក់ឃ្លាចុងក្រោយ យើងថែមថាវិសាលភាពនៃការលើកលែងឬ អនុគ្រោះទោសដែលអាចត្រូវបានផ្តល់ ហើយមុនការអនុម័តច្បាប់នេះគឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ។ អីចឹងខ្ញុំសង្ឃឹមថាបន្ទាប់ពីបង្កើតតុលាការហ្នឹងនឹងមានអង្គជំនុំជម្រះវិសាមញ្ញគេអ្នកបើក ដើម្បីថាតើត្រូវលើកលែងទោសឲ្យឬក៏អត់ ។ ប៉ុន្តែការដែលសម្រេចពាក់ព័ន្ធបញ្ហានេះពាក់ព័ន្ធនឹងខ្លឹមសារនៃរដ្ឋធម្មនុញ្ញដែលបានចែងថា ព្រះមហាក្សត្រមានសិទ្ធិចេញព្រះរាជក្រឹត្យបន្ធូរបន្ថយ និងលើកលែងទោស អីចឹងវាប៉ះពាល់នឹងខ្លឹមសារនៃរដ្ឋធម្មនុញ្ញ ។ អត់មានពិបាកទេ បុគ្គល “ក” ដែលលើកលែងទោសហើយ ពេលណាអង្គជំនុំជម្រះវិសាមញ្ញកើតឡើងចង់ចោទប្រកាន់គឺត្រូវចោទករណីផ្សេងទៀត មិនខុះទេករណីដែលត្រូវចោទ ។ កាលពីលើកមុនចោទពីរករណី “ក, ខ” ឥឡូវយើងចោទ កុំឲ្យ “ក, ខ” យើងចោទ “គ, ឃ” តែម្តងឲ្យខុសពីករណីមុនទៅ យកមកកាត់ទោសបានដូចគ្នា ហើយវាមិនប៉ះពាល់នឹងខ្លឹមសារនៃរដ្ឋធម្មនុញ្ញដែលចែងថា ព្រះមហាក្សត្រទ្រង់មានព្រះរាជក្រឹត្យលើកលែងទោសនិងបន្ធូរបន្ថយទោសផង ។ អីចឹងពីបញ្ហាលើកលែងទោសនិងបន្ធូរបន្ថយទោសទូលបង្គំខ្ញុំបាទសូមលើកតែត្រឹមណេះ ។ ហើយមាត្រា៤៧ស្ទួន ឯកឧត្តម ឯក សំអុល បានពន្យល់មិញនោះ ប៉ុន្តែទូលបង្គំជារួមគ្រាន់តែថា យើងចង់និយាយថា ក្រោយពីការផ្តល់សច្ចាប័នហើយកិច្ចព្រមព្រៀងនឹងក្លាយជាច្បាប់ អាហ្នឹងយល់ហើយ ប៉ុន្តែនៅក្នុងនេះសរសេរដូចពិបាកថាក្រោយពេលផ្តល់សច្ចាប័នសមស្របតាមបទបញ្ញត្តិនៃច្បាប់ព្រះរាជាណាចក្រកម្ពុជាទាក់ទងទៅនឹងសមត្ថកិច្ចនៃការចុះសន្ធិសញ្ញា ហើយបានកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកាត់ទោសអី ហូរហែរអីចឹងទៅ ត្រូវអនុវត្តជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ទូលបង្គំថាសរសេរហ្នឹងដូចជាពិបាកស្តាប់ ។ យើងចង់បញ្ជាក់ថា កាលណាកិច្ចព្រមព្រៀងផ្តល់សច្ចាប័នហើយវាទៅជាច្បាប់ដែលប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយប៉ុន្តែវាមានទាក់ទងនឹងសមត្ថកិច្ចនៃការចុះសន្ធិសញ្ញាចុះអី អាហ្នឹងដូចអត់យល់ សូមឯកឧត្តមមេត្តាពន្យល់ ។ សូមអរព្រះគុណ អរគុណ ។

**សម្តេច ក្រុមព្រះ នរោត្តម រណឫទ្ធិៈ** អរគុណឯកឧត្តម ។ សូមអញ្ជើញឯកឧត្តម សុខ អាន ។

**ឯកឧត្តម សុខ អានៈ** សូមថ្វាយបង្គំសម្តេចព្រះប្រធាន សូមថ្វាយបង្គំនិងគោរពអង្គសភាទាំងមូល ។ ជាថ្មីម្តងទៀតដោយឯកឧត្តម ម៉ោញ សាផាន លោកបានលើកឡើងនូវចំណុចជាបន្តបន្ទាប់ ទូលបង្គំខ្ញុំបាទសូមធ្វើអត្ថាធិប្បាយចំណុចទាំងនេះដូចតទៅនេះ÷ ចំណុចទី១ ស្តីអំពីចំនួន ។ ការដែលសួរអំពីមុខសញ្ញានិងចំនួនដែលត្រូវទទួលការកាត់ទោសពីអង្គជំនុំជម្រះវិសាមញ្ញនេះ ចំណុចនេះគឺដូចទូលបង្គំខ្ញុំបាទបានអត្ថាធិប្បាយមុននេះដែរ យល់ថាហាក់ដូចជាច្បាស់លាស់ដែរ ប៉ុន្តែឯកឧត្តម ម៉ោញ សាផាន លោកនៅតែយល់ថាមិនច្បាស់លាស់ចំណុចនេះ ។ គឺច្បាប់គេបានចែងហើយថា គឺជាសមត្ថកិច្ចរបស់ចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញនេះដែលត្រូវជ្រើសរើសមុខសញ្ញាដែលថាត្រូវចោទប្រកាន់អ្នកណាត្រូវកាត់ទោសអ្នកណា ។ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញដែលលោកមានសមត្ថកិច្ចមានសិទ្ធិនៅក្នុងការងារនោះ គឺលោកត្រូវបំពេញភារកិច្ចទៅតាមច្បាប់ តាមកិច្ចព្រមព្រៀងនិងច្បាប់ដែលយើងកំពុងតែពិភាក្សានេះ ។ ដូច្នេះនៅក្នុងការជជែកធ្វើច្បាប់ហ្នឹង នៅក្នុងការរៀបចំច្បាប់ហ្នឹងដែលជាក្របខ័ណ្ឌសកម្មភាពរបស់ចៅក្រមរបស់ព្រះរាជអាជ្ញានោះ គឺជាធម្មតាអ្នកច្បាប់គាត់តែងតែពិចារណាយកគោលការណ៍ធំៗឯកភាពគ្នាទើបសរសេរច្បាប់បាន ។ អីចឹងវាមិន

យូរដល់ទៅប្រាំមួយប្រាំពីរឆ្នាំនោះទេ ដែលយូរដោយសារមានគោលការណ៍ធំៗច្រើនណាស់ដែលត្រូវពិភាក្សាគ្នា ។ ដូច្នេះដែលទូលបង្គំលើកឡើងអម្បាញ់មិញអំពីចំនួនអីនេះ គ្រាន់តែជាទស្សនៈអ្នកច្បាប់មុនហ្នឹងរៀបចំនូវមូលដ្ឋានគតិយុត្តិនេះ ហើយទូលបង្គំខ្ញុំក៏បានបញ្ជាក់ច្បាស់ហើយថា សិទ្ធិសម្រេចចុងក្រោយគឺជាសិទ្ធិរបស់សហព្រះរាជអាជ្ញា ជាសិទ្ធិរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ដូច្នេះចំណុចនេះខ្ញុំយល់ថាវាដូចជាច្បាស់លាស់ទៅហើយ គឺជជែកគ្នាក្នុងក្របខ័ណ្ឌច្បាប់ហ្នឹង អ្នកដែលគិតគូរពីរឿងច្បាប់ហ្នឹងនេះជាទស្សនៈហ្នឹង គឺគ្រាន់តែគិតគូរអីចឹង ប៉ុន្តែបានបញ្ជាក់ច្បាស់ណាស់ គឺជាសិទ្ធិរបស់សហព្រះរាជអាជ្ញា ជាសិទ្ធិរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ចំណុចទីពីរ ការជ្រើសរើសចៅក្រម ឯកឧត្តម ម៉ោញ សាផាន គាត់បានលើកឡើងដែរថា តាមមើលចៅក្រមរាល់ថ្ងៃសុទ្ធតែពាក់ព័ន្ធជាមួយហ្នឹងសម័យ៣ឆ្នាំ ៨ខែ ២០ថ្ងៃ អីចឹងគឺមិនអាចធ្វើបាន ។ ចំណុចនេះគឺរហូតមកដល់ពេលនេះគឺយើងក៏មិនទាន់សម្រេចមុខសញ្ញាឲ្យច្បាស់លាស់ថា ឯកឧត្តម "ក, ខ, គ" ទេ ប៉ុន្តែពាក្យថាដែលអ្នកឆ្លងកាត់របបប៉ុល ពត គឺមិនត្រូវធ្វើការងារនេះចំណុចនេះទូលបង្គំខ្ញុំបាទក៏យល់ដែរក្នុងក្របខ័ណ្ឌច្បាប់របស់យើង គឺយើងគិតថាបើចៅក្រមកាត់សេចក្ដីហ្នឹងមានពាក់ព័ន្ធទៅនឹងមុខសញ្ញាត្រូវកាត់សេចក្ដី នោះគឺមិនអាចទៅកាត់សេចក្ដីបានទេ សាមីខ្លួនគេអាចប្ដឹងមិនសុខចិត្តប្ដឹងអីហូរហែអីចឹង ឃើញថាចៅក្រមដែលអាចលម្អៀង ។ នេះហើយក្នុងស្ថានភាពច្បាប់ហ្នឹងក៏មិនគួរទៅធ្វើចៅក្រមកាត់រឿងហ្នឹង ប៉ុន្តែក្នុងករណីនេះដែលយើងលើកឡើងថាជាករណីពិសេស ហើយយើងឃើញខិតខំធ្វើច្បាប់ពិសេសនេះ យើងក៏ពិចារណាដែរបញ្ហាហ្នឹង គឺថាអ្នកដែលគេមកជជែកជាមួយយើងដើម្បីធ្វើច្បាប់នេះគឺគេមិនល្ងង់ទេ គេឆ្លាតណាស់ ហើយបើជំនុំគ្នានោះក៏គិតដែរថា ចៅក្រមដែលគេមកពីនាយជាចៅក្រមអន្តរជាតិមែន គឺគេអត់ដែលស្គាល់រឿងប៉ុលពតទេ គេអត់ដែលស្គាល់រឿងទោសឧក្រិដ្ឋកម្មនោះទេ គេមិនដែលស្គាល់របប៣ឆ្នាំ ៨ខែ ២០ថ្ងៃទេ ប៉ុន្តែចៅក្រមកម្ពុជាខ្លះស្គាល់ ។ អីចឹងយើងអាចគិតដែរ បើស្គាល់គាត់ធ្លាប់វេទនាពីរបបហ្នឹង ធ្លាប់ខឹងពីរបបហ្នឹង អីចឹងខ្លាចកាត់ទោសធ្ងន់ពេកលើរបបហ្នឹង យើងគិតតាមច្បាប់ទម្លាប់របស់យើងគឺយើងគិតថាមិនត្រូវចូលពាក់ព័ន្ធទេ ព្រោះមិនយុត្តិធម៌ ព្រោះខ្លាចមិនយុត្តិធម៌ ខ្លាចលម្អៀងកាត់ទោសទៅខ្មែរក្រហមធ្ងន់ពេក ។ ប៉ុន្តែក៏មានយោបល់ដែរថា អ្នកច្បាប់របស់គេអត់ដែលស្គាល់ទេរបបហ្នឹង គេមិនដែលស្គាល់៣ឆ្នាំ ៨ខែ ២០ថ្ងៃហ្នឹងតថភាពនោះវាយ៉ាងម៉េចខ្លះទេ អីចឹងបើមានចៅក្រមកម្ពុជាស្គាល់ខ្លះនោះគឺជាចំណុចវិជ្ជមានដែរ ព្រោះថាអ្នកដែលធ្លាប់រងគ្រោះដោយសាររបបហ្នឹង ធ្លាប់រស់នៅក្នុងរបបហ្នឹង ស្គាល់ទៅគឺអាចដឹងការពិតដែលលេចចេញពីឧក្រិដ្ឋកម្មដែលចេញអំពីទោសទាំងអស់ដែលកើតមានឡើង ។ អីចឹងវាមានវិជ្ជមានក៏វាមានផ្នែកអវិជ្ជមានដែរ ប៉ុន្តែមិនមែនទូលបង្គំលើកឡើងនេះថា យើងត្រូវតែចាត់តាំងចៅក្រមដែលធ្លាប់រស់នៅរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃនោះទេ ប៉ុន្តែជាការពិចារណាទៅ វាមានគេហៅថាមុំវិជ្ជមាននិងមុំអវិជ្ជមានអីចឹងដែរ ។ ពាក្យសរសេរនៅក្នុងចំណុចដែលលើកឡើងនៅក្នុងមាត្រាដែលលើកឡើងថា គេអាចរកការណែនាំដើម្បីរកនីតិវិធីពីប្រភពអន្តរជាតិនេះអីចឹង យើងលើកឡើងថាពាក្យថា"គេ"ហ្នឹងមិនដឹងអ្នកណា? ប៉ុន្តែអានេះបើយើងគិតទៅគឺនៅក្នុងការសរសេរនេះយើងក៏មានពាក់ព័ន្ធរវាងអត្ថបទអង់គ្លេសនិងអត្ថបទខ្មែរដែរ ព្រោះថាត្រូវជជែកគ្នាភាសាអង់គ្លេសហើយបានយកមកបកជាភាសាខ្មែរ ។ អីចឹងយើងគិតថា អ្ហូអីចឹងរបៀបធ្វើការយើងអន់ណាស់ យើងយកពីអង់គ្លេសបកខ្មែរ ។ គឺថានៅក្នុងស្ថានភាពរាល់ថ្ងៃ ន័យនគរូបនីយកម្ម ហើយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិហ្នឹង ពេលខ្លះយើងក៏ត្រូវបកពីអង់គ្លេសមកខ្មែរ ហើយពេលខ្លះយើងត្រូវបកពីខ្មែរទៅអង់គ្លេស គឺនៅក្នុងការងារមួយចំនួន ។ ហើយសព្វថ្ងៃក្រោយពីយើងធ្វើការងារនៅក្នុងរដ្ឋាភិបាលរយៈពេលវែងមកហើយនោះ មានអត្ថបទខ្លះយើងធ្វើជាខ្មែរ ហើយយើងបកជាអង់គ្លេសក្រោយ ដើម្បីឲ្យសហគមន៍អន្តរជាតិគេមានយោបល់តាមក្រោយ ។ ប៉ុន្តែអត្ថបទរបៀបនេះគឺក៏វានៅជាប់ពាក់ព័ន្ធរវាងអត្ថបទខ្មែរនិងអង់គ្លេសដែរអីចឹងហើយក៏ព្រោះថា អ្នកច្បាប់ទាំងអស់ហ្នឹងគាត់មកជជែកជាមួយយើងនិយាយអង់គ្លេស គាត់អត់មានជជែកជាខ្មែរផង អីចឹងហើយការសរសេរការរៀបចំអត្ថបទនោះក៏រៀបចំជាភាសាអង់គ្លេស ។ អីចឹងនៅក្នុងការសរសេរ"គេអាចរកការណែនាំ" នេះគឺមានន័យច្បាស់លាស់ ដោយអ្នកដែលធ្វើហ្នឹង អ្នកដែលអនុវត្តនីតិវិធីហ្នឹងគេយល់ថាបានអ្នកណាជាអ្នកអនុវត្តន៍នីតិវិធីហ្នឹង ។ នៅក្នុង

ក្របខ័ណ្ឌនៃអង្គជំនុំជម្រះវិសាមញ្ញនេះបើប្រព័ន្ធជាតិអនុវត្តទៅវាអត់ឯកភាពគ្នា  មានចំណុចដែលចៅក្រមឬក៏ព្រះរាជអាជ្ញាអន្តរជាតិ គេលើកឡើងថាវាពាក់ព័ន្ធឬវាជុយគ្នាទៅនឹងច្បាប់នីតិវិធីអន្តរជាតិ  គេអាចស្វែងរកការណែនាំអ្នកណាដែលដឹងរឿងច្បាស់លាស់មក អញ្ជើញជម្រាបអំពីនីតិវិធីអន្តរជាតិហ្នឹង ។  អ៊ីចឹងទូលបង្គំខ្ញុំបាទយល់ថា  កន្លែងហ្នឹងគេយល់បានច្បាស់លាស់របស់គេ  អ្នកធ្វើហ្នឹងគឺ គាត់យល់បានច្បាស់លាស់ ។  ហើយបើយើងមើលអត្ថបទហ្នឹងពីដើមមក  ក៏យើងអាចយល់បានបន្តិចដែរ  គឺអាចយល់បានដោយខ្លួនឯងកន្លែងហ្នឹង ។  ចំណុចទី៤  ក្នុងចំណុចដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយ  ហើយកន្លែងខ្លះមិនផ្សព្វផ្សាយ  ចាត់ទុកជាការប្រជុំសម្ងាត់ ។ ចំណុចហ្នឹងឥឡូវនេះយើងក៏មិនអាចកំណត់បានដែរ  គឺទាល់តែចៅក្រមខ្លួនឯងហ្នឹង  នៅពេលនោះបានគេសម្រេចថារឿងនេះត្រូវផ្សាយឬមិនផ្សាយទេ ដើម្បីការពារសាក្សី ឬមួយក៏ដើម្បីការពារបញ្ហាសុវត្ថិភាពរបស់អ្នកដែលជាប់ពាក់ព័ន្ធ ។ អ៊ីចឹងយើងឥឡូវម៉េចដឹងថារឿងនោះត្រូវការពារឬមិនការពារ?  នេះគឺជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញទៀត  នេះជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះវិសាមញ្ញ ។  បើយើងចង់សរសេរឲ្យច្បាស់លាស់ជាងហ្នឹងក៏យើងអត់សរសេរកើតទេ  យើងមិនអាចទៅកំណត់បញ្ជាមុនថា ន៉ែរឿងនេះត្រូវបើក រឿងនោះត្រូវបើក ។ ពីព្រោះនៅពេលដែលករណីមួយៗលើកឡើងមកដល់ទើបយើងសម្រេចបានគេសម្រេចទៅតាមនោះ  នេះជាចំណុចដែលពាក់ព័ន្ធនឹងមាត្រា៣៩ ។  មួយទៀតពាក្យដែលថា  រដ្ឋបរទេសនេះនៅក្នុងចំណុចហ្នឹងគេចង់បញ្ជាក់ថា នៅពេលបើកសវនាការហ្នឹង  តំណាងរបស់ប្រទេសផ្សេងៗ  តំណាងរបស់រដ្ឋបរទេស  គេអាចចូលស្តាប់ ។  បើអ៊ីចឹងគឺចង់រៀបរាប់អំពីប្រទេសអ្នកដែលអាចចូលទៅស្តាប់នៅក្នុងនោះ ។  រដ្ឋបរទេសហ្នឹងគឺចង់និយាយពីតំណាងប្រទេសផ្សេងៗដែលគេចូលទៅស្តាប់នៅក្នុងហ្នឹង  អ៊ីចឹងមិនមែនជាការសរសេរទេ  អាហ្នឹងខ្លឹមសារចង់បញ្ជាក់អ៊ីចឹង ។ ដែល Foreign States  រដ្ឋបរទេសហ្នឹង  គឺតំណាងគេអាចមានសិទ្ធិចូលទៅដោយប្រាប់ថាខ្លួនគេជាតំណាងរដ្ឋមួយអ៊ីចឹង ។  ពាក្យ“សាលដីកា”  និងពាក្យ“សាលក្រម”  ចំណុចនេះក៏វាមាននិន្នាការដែរ ។ អ្នកច្បាប់បានលើកឡើងថា  ឥឡូវនេះនៅក្នុងនិន្នាការសព្វថ្ងៃនៅលើមជ្ឈដ្ឋានអន្តរជាតិហ្នឹង  គេហាក់ដូចជាលែងចង់ឲ្យមានការខុសគ្នារវាងពាក្យសាលដីកានិងសាលក្រម  ហើយដែលភាសាបរទេសគេថា Judgement និងArrêt ។  ពេលខ្លះគេប្រើពាក្យ Judgement ពេលខ្លះគេប្រើពាក្យ Arrêt  អំពីសាលាកាត់ក្តីនោះជាសាលាដំបូងឬជាសាលាឧទ្ធរណ៍ ឬជាតុលាការកំពូល ។ ប៉ុន្តែជានិន្នាការរបស់យើងដែលយើងលើកឡើងថា តាមច្បាប់កម្ពុជាតាមនីតិវិធីកម្ពុជាគឺយើងនៅគិតស្មានថា បើចេញពីសាលាដំបូង យើងហៅថា សាលក្រម បើចេញពីសាលាឧទ្ធរណ៍យើងហៅសាលដីកា  ឬក៏តុលាការទៅលើទៀត ។  អាចំណុចនេះគឺមិនមែនជាការធំដុំទេ  គឺយើងអាចថាគិតគូរសម្របទៅនោះបាន  យើងសរសេរសាលដីកា  យើងសរសេរសាលក្រមហ្នឹង  ដោយមាននិន្នាការ ដល់ពេលហើយលែងគិត  សរសេរអត់ចេញគិតឃើញពាក្យសាលក្រម  ដាក់សាលក្រម  នឹកឃើញពាក្យសាលដីកា  សាលដីកាទៅ  ព្រោះចង់សម្របទៅតាមនិន្នាការអន្តរជាតិដែលគេលែងគិតពាក្យថា Arrêt  ឬលែងគិតថា  Judgement ។  ចំណុចដែលពាក់ព័ន្ធទៅនឹងការលើកលែងទោសចំណុចនេះគឺជាកម្មវត្ថុនៃការតស៊ូគ្នាតានតឹងណាស់  ជជែកគ្នានៅភ្នំពេញច្រើនដងណាស់ទើបឈានទៅដល់ការឯកភាពនៅក្នុងឆ្នាំ២០០១ ។  ប៉ុន្តែក្រោយមកទៀតនេះគឺនៅពេលដែលយើងទៅបន្តជជែកធ្វើកិច្ចព្រមព្រៀងនៅញូវយ៉កនេះ  គឺគេសង្កត់លើបញ្ហាហ្នឹងទៀត  ដោយគេនៅតែទទូច  គេខ្លាចមានការលើកលែងទោស ។  អ៊ីចឹងយើងបានបញ្ជាក់ប្រាប់គេថា  យើងមិនអាចធ្វើអ្វីឲ្យខុសពីរដ្ឋធម្មនុញ្ញរបស់យើងបានទេ ។  យើងមិនគួរទៅកែរដ្ឋធម្មនុញ្ញយើងដើម្បីតម្រូវទៅលើចំណុចដែលអាចសម្របសម្រួលគ្នាបានទេ ។   ជាចុងក្រោយគឺមានការឯកភាពគ្នាថា កម្ពុជាមិនបាច់កែរដ្ឋធម្មនុញ្ញទេ ប៉ុន្តែសរសេរយ៉ាងម៉េចឲ្យគេជឿបានថាយើងមិនលើកលែងទោសក្រោយពេលដែលកាត់ទោស ។ អ៊ីចឹងដំបូងឡើងគេពិភាក្សាថា  មិនឲ្យមានការលើកលែងទោស  យើងបានពន្យល់គេថាអ្នកឯងថាមិនឲ្យមានការលើកលែងទោសយ៉ាងម៉េច បើនៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្ញុំគឺព្រះករុណាយើងខ្ញុំ  លោកមានសិទ្ធិក្នុងការលើកលែងទោស  ហើយបើដាក់ថាមិនឲ្យមានការលើកលែងទោសគឺវាជុយពីរដ្ឋធម្មនុញ្ញហើយ  យើងមិនអាចសរសេរអ៊ីចឹងបានទេ ។  ប៉ុន្តែយើងអាចសរសេរបានឲ្យតែអ្នកឯងទុកចិត្តសរសេរថា រាជរដ្ឋាភិបាលមិនលើកសំណូមពរសុំឲ្យមានការលើកលែងទោសទេ  ព្រោះយើងចង់ឲ្យគេយល់ថា  ការលើកលែងទោសកន្លងមកគឺ

ដោយសាររាជរដ្ឋាភិបាលបានស្នើទូលសុំមានការគាំទ្រពីសមាជិករដ្ឋសភា ទើបព្រះករុណាលោកធ្វើការលើកលែងទោស ។ អ៊ីចឹងយើងបានពន្យល់គេថា ចុះបើរដ្ឋាភិបាលបើរដ្ឋសភាមិនសុំនឹងមិនមានការលើកលែងទោសទេ ។ អ៊ីចឹងចុងក្រោយទៀតគាត់នៅតែមិនអស់ចិត្ត យកបញ្ហាហ្នឹងទៅតាមទារទៀត ។ យើងត្រូវធ្វើការសម្របសម្រួលជាលើកទីពីរទៀត ។ ដំបូងឡើងគឺគេបានលើកឡើងនូវរូបមន្តថា ការលើកលែងទោសមិនអាចរារាំងមិនឲ្យមានការចោទប្រកាន់លើជនណាមួយបានទេ ។ ដូច្នេះយើងក៏មិនឯកភាពលើឃ្លានេះទេ ព្រោះថាបើសរសេរអ៊ីចឹងក៏មានន័យថា អត់មានការលើកលែងទោសដែរ ។ អ៊ីចឹងយើងបានស្នើឃ្លាចុងក្រោយដាក់ថា "ទុកឲ្យអង្គជំនុំជម្រះវិសាមញ្ញសម្រេច" ។ ពាក្យថា "ទុកឲ្យអង្គជំនុំជម្រះវិសាមញ្ញសម្រេច" នេះមិនមែនមានន័យថាត្រូវបើកអង្គជំនុំជម្រះមួយសម្រាប់រឿងហ្នឹងទេ នេះគឺជាតុលាការនេះហើយ ដែលយើងដាក់ឈ្មោះថាអង្គជំនុំជម្រះវិសាមញ្ញ គឺទុកជូនអង្គជំនុំជម្រះវិសាមញ្ញនេះធ្វើការសម្រេច ។ អ៊ីចឹងយើងយល់ថា មិនខុសពីរដ្ឋធម្មនុញ្ញមិនខុសពីស្មារតីរដ្ឋធម្មនុញ្ញយើង ហើយក៏អាចនិយាយបានថា ចៅក្រមរបស់យើងគឺគ្គាប់បានច្បាស់ស្មារតីរដ្ឋធម្មនុញ្ញរបស់យើង ហើយនិងមិនសម្រេចអ្វីឲ្យខុសពីរដ្ឋធម្មនុញ្ញទេ ។ អ៊ីចឹងនេះគឺជាដំណោះស្រាយចុងក្រោយដែលអាចធ្វើឲ្យមានការយល់គ្នាបាន ដែលអាចធ្វើឲ្យសម្របសម្រួលគ្នាបាន ។ ទូលបង្គំយើងខ្ញុំយល់ថាគួររក្សានូវរូបមន្តនេះជារូបមន្តដែលយើងអាចរក្សាចំណុចដែលថា យើងធ្វើមិនឲ្យមានការខុសពីច្បាប់នៃរដ្ឋធម្មនុញ្ញខ្លឹមសារដែលគេអាចទទួលយកបានហើយដែលយើងយល់ថា ចំណុចដែលយើងសរសេរវាស្របទៅនឹងអ្វីៗដែលយើងបានធ្វើកន្លងមក ។ ទូលបង្គំយើងខ្ញុំសូមមានយោបល់តែប៉ុណ្ណេះ សូមអរព្រះគុណ ។

***សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ៖*** អរគុណឯកឧត្តម ។ សូមអញ្ជើញឯកឧត្តម ឯក សំអុល ។

***ឯកឧត្តម ឯក សំអុល៖*** សូមថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធាននៃរដ្ឋសភាសាជាថ្មី សូមគោរពសម្តេចអនុប្រធាន សូមគោរពអង្គសភា ។ ទូលបង្គំខ្ញុំបាទក៏សុំរួមចំណែកជាមួយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ដើម្បីជួយបំភ្លឺនូវចំណុចខ្លះដែលលើកឡើងដោយឯកឧត្តម ម៉ោញ សាផាន ។ ចំពោះមាត្រា២៣ថ្មីឃ្លាដែលនៅក្នុងវាក្យខ័ណ្ឌពីក្រោមឡើងលើដែលឯកឧត្តម ម៉ោញ សាផាន លោកបានលើកគឺវាក្យខ័ណ្ឌទីពីរ សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះនិងស្តាប់ចម្លើយសាក្សីនិងប្រមូលភ័ស្តុតាង ។ ទូលបង្គំខ្ញុំបាទអាចអានខុស ឬក៏អានអត្ថបទវែង សរសេរត្រូវប៉ុន្តែអានខុស សូមអង្គសភាអធ្យាស្រ័យ គឺ "និង" មិនមែន "ឬ"ទេ ។ បន្ទាប់មកទៀតឯកឧត្តម ម៉ោញ សាផាន លើកមាត្រា៣៣ថ្មី គាត់ប្រើពាក្យ "គេ" ។ គេហ្នឹងសំដៅលើអ្នកណា? ពាក្យ "គេ" ហ្នឹងមិនមែនជាពាក្យធ្វើវិសោធនកម្មបញ្ចូលថ្មីទេ ។ ទូលបង្គំខ្ញុំបាទមើលច្បាប់ឆ្នាំ២០០១គឺរក្សាពាក្យ "គេ" ហ្នឹងដដែល ហើយពេលនោះ ឯកឧត្តម ម៉ោញ សាផាន ប្រធានគណៈកម្មការនីតិកម្ម អ៊ីចឹងវាអត់អីទេពាក្យ "គេ" ហ្នឹង ។ សុំត្រឡប់ទៅមាត្រា២៣ថ្មី ព្រោះគាត់មិនទាន់អស់ចិត្តចំពោះពាក្យ"ចៅក្រមកម្ពុជា" ។ អាហ្នឹងក៏អត់មានកែទេ អត់មាន កែពីខ្មែរមកកម្ពុជាទេព្រះអង្គ គឺមាត្រា២៣ចាស់គេចែងអ៊ីចេះថា រាល់ការស៊ើបអង្កេតគឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា ។ អ៊ីចឹងតាំងពី២០០១មកជាមួយគ្នា ហើយពេលហ្នឹងឯកឧត្តមជាប្រធានគណកម្មការនីតិកម្មដែរតើ ។ អ៊ីចឹងយើងប្រើជាមួយគ្នាទៅកម្ពុជាក៏បាន ខ្មែរក៏បានដែរ ពេលខ្លះវាច្រឡំគ្នា វាមិនជាអីទេណ៎ ។ មាត្រា៣៤ថ្មី ឯកឧត្តម ម៉ោញ សាផាន គាត់ឲ្យពន្យល់អំពីកាលៈទេសៈពិសេស ។ ពាក្យកាលៈទេសៈពិសេសហ្នឹងគឺនៅក្នុងច្បាប់២០០១ដែរ អត់មានសរសេរកែ ។ ក្នុងមាត្រា៣៤ថ្មីហ្នឹងថែមតែបន្តិចទេ កែត្រង់ថានឹងបើកចំហសម្រាប់តំណាងរដ្ឋបរទេស តំណាងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ តំណាងបណ្តាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ហើយនេះពាក្យដែលថែមថ្មី "លើកលែងតែក្នុងកាលៈទេសៈពិសេសអង្គជំនុំជម្រះសម្រេចថា" ។ ដូច្នេះកាលៈទេសៈពិសេសហ្នឹង បើថាអង្គជំនុំជម្រះលោកបកស្រាយថាកាលៈទេសៈណាដែលវាអាចប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌ណ៎ លោកប្រជុំសម្ងាត់ទៅ ។ មាត្រា៣៦ថ្មី ឯកឧត្តម ម៉ោញ សាផាន គាត់ចាប់អារម្មណ៍ដូចជាត្រឹមត្រូវដែរ ពីព្រោះយើងបានលុប យើងបានកែទាំងស្រុងមាត្រា៣៦ចាស់ ពីព្រោះមាត្រា៣៦ចាស់និយាយអំពីអង្គជំនុំជម្រះរបស់

សាលាឧទ្ធរណ៍ អ៊ីចឹងហើយវានៅសល់ពាក្យ "សាលដីកា" ។ ផ្អែកលើច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលនៅជាធរមាន សេចក្តីសម្រេចរបស់សាលាដំបូង ឬតុលាការខេត្តក្រុងគឺ"សាលក្រម" ។ ដូច្នេះសុំប្តូរពាក្យ "សាលក្រម" ព្រោះឯកឧត្តម សុខ អាន លោកទុកលទ្ធភាពឲ្យពីរ ។ ដូច្នេះទូលបង្គំ ខ្ញុំបាទសុំស្នើនាយកដ្ឋាននីតិវិធីជួយចាំពាក្យ "សាលដីកា" យើងកែដាក់ទៅជា "សាលក្រម" ទៅ ត្រូវទៅតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនៅជាធរមាន ។ អំពីមាត្រា៤៧ស្ទួន ទូលបង្គំខ្ញុំបាទយល់ថាជាខ្លឹមសារដូចជាគ្រប់គ្រាន់ហើយ ពីព្រោះជាការដកស្រង់ខ្លឹមសារចេញពីមាត្រា៣១នៃកិច្ចព្រមព្រៀង ។ ឯកឧត្តម ម៉ៅញ សាផាន លោកប្រាប់មិញថា លោកយល់ព្រមទៅតាមសំណេរ ទៅតាមសេចក្តីព្រាងច្បាប់នៃច្បាប់វិសោធនកម្ម ។ ដូច្នេះសូមអរព្រះគុណ សូមអរគុណ ។ សូមអង្គសភាមេត្តាអនុម័ត ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** សូមអរគុណឯកឧត្តមណាស់ ។ សូមអង្គសភាអនុម័តមាត្រា១ ។ អរគុណ ។

**លេខាធិការនៃអង្គប្រជុំ:** សូមថ្វាយបង្គំសម្តេចព្រះប្រធាន ទូលបង្គំទូលថ្វាយ សំឡេងគាំទ្រមានចំនួន៩៧/លើ៩៨ ។ សូមអរព្រះគុណនិងសូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** ៩៧/លើ៩៨ ។ អរគុណ ។ បើសភាអនុម័តមាត្រា១ សូមឯកឧត្តម ឯក សំអុល មេត្តាអាននូវមាត្រា២ ។

**ឯកឧត្តម ឯក សំអុល:** មាត្រា២: ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។ សូមអរព្រះគុណ និងអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** អង្គសភាអនុម័តមាត្រា២ ។

**លេខាធិការនៃអង្គប្រជុំ:** សូមបង្គំទូលថ្វាយ សំឡេងគាំទ្រមានចំនួន៩៧/លើ៩៨ ។ សូមអរព្រះគុណ និងសូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** សូមអង្គសភាអនុម័តលើខ្លឹមសារទាំងមូល ។

**លេខាធិការនៃអង្គប្រជុំ:** សូមថ្វាយបង្គំសម្តេចព្រះប្រធាន សំឡេងគាំទ្រមានចំនួន៩៦/លើ៩៨ ។ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** អង្គសភាលោកបានអនុម័តសេចក្តីព្រាងច្បាប់លើវិសោធនកម្មមាត្រា២ មាត្រា៣ មាត្រា៩ ។ល ។ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំសូមប្រកាសបិទការប្រជុំនៅថ្ងៃនេះ ។ សូមទោស ឯកឧត្តមឧបសុំមានមតិ ។ សូមអញ្ជើញ ឯកឧត្តមឧប ។

**ឯកឧត្តម សុខ អាន:** សូមក្រាបថ្វាយបង្គំសម្តេចព្រះប្រធាន និងសូមថ្វាយបង្គំ និងគោរពនូវអង្គសភាទាំងមូលជាថ្មីម្តងទៀត ។ ទូលបង្គំជាខ្ញុំសូមព្រះរាជានុញ្ញាតនេះគឺមានគោលដៅពីរ ។ ទីមួយគឺសុំថ្លែងព្រះរាជគុណនិងអំណរគុណដល់សម្តេចព្រះប្រធាននិងអង្គសភាដ៏ឧត្តុង្គឧត្តមទាំងមូលដែលបានអនុម័តយល់ព្រមបញ្ចប់នូវដំណើរការដ៏វែងមួយ នៅក្នុងការកសាងនូវមូលដ្ឋានគតិយុត្តិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនេះ ។ ហើយចំណុចមួយទៀត ទូលបង្គំខ្ញុំបាទក៏សូមយកឱកាសដ៏ឧត្តុង្គឧត្តមនេះដើម្បីទូលថ្វាយនិងជម្រាបជូនអង្គសភាអំពីកូនសៀវភៅពីរនេះ គឺដែលមានចំណងជើងថា "ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម" មួយជាភាសាខ្មែរ មួយជាភាសាអង់គ្លេស ដែលមានដាក់ចំណងជើងថា Introduction to The Khmer Rouge Trial ។ កូនសៀវភៅពីរនេះគឺបានរៀបចំឡើងដោយមានការឧបត្ថម្ភពីអង្គការពីរពីអូស្ត្រាលី ហើយមានគោលដៅបញ្ជាក់ថ្វាយជូនអំពីដំណើរការរៀបចំអង្គជំនុំជម្រះ រចនាសម្ព័ន្ធនិងរបៀបដំណើរការអង្គជំនុំជម្រះវិសាមញ្ញនេះ ។ មាននូវរូបភាពជាសំណួរចម្លើយគឺជិត៤០សំណួរ និងជិត៤០ចម្លើយ ។ ទូលបង្គំខ្ញុំបាទយល់ឃើញថា ការអានកូនសៀវភៅតូចនេះគឺនឹងនាំឲ្យមានការយល់ដឹងកាន់តែជ្រៅជ្រះអំពីដំណើរការអំពីការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ ហើយនិងគោលដៅធំនៃការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ ។ អ៊ីចឹងទូលបង្គំខ្ញុំបាទ សូមថ្លែងអំណរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ:** សូមអរគុណឯកឧត្តម ។ សូមប្រកាសលើកពេលប្រជុំត្រឹមម៉ោងនេះ ស្អែករដ្ឋសភានឹងចាប់ផ្តើមពិនិត្យពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៤ ជាវារៈទី៨ ។ សូមអរព្រះគុណ សូមអរគុណ ។

# ធ្វើនីតិកម្មនេះឱ្យទៅជាការពិត

*យើងទាំងអស់គ្នាជាសមាជិករដ្ឋសភានីតិកាលទី៣ ទើបតែបានបញ្ចប់ដំណើរការដ៏មានសារសំខាន់មួយ ដោយការធ្វើវិសោធនកម្មច្បាប់ឆ្នាំ២០០១ ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ហើយនិងបានផ្តល់សច្ចាប័នកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។*

*ទូលបង្គំ ខ្ញុំបាទ សូមអនុញ្ញាតថ្លែងអំណរព្រះគុណចំពោះសម្តេចក្រុមព្រះប្រធានរដ្ឋសភា សម្តេចអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ ព្រមទាំងសមាជិកទាំងអស់ដែលបានចូលរួមក្នុងការងាររបស់យើងនៅថ្ងៃនេះ ជាពិសេសចំពោះសម្តេច ឯកឧត្តម លោកជំទាវដែលបានផ្តល់មតិយោបល់ដ៏មានតម្លៃនៅក្នុងការពិភាក្សា និងចំពោះគណៈកម្មាធិការកិច្ចការបរទេសនិងគណៈកម្មការនីតិកម្មដែលបានពិនិត្យនិងផ្តល់យោបល់ទៅលើសេចក្តីព្រាងច្បាប់ទាំងពីរ ។*

*ទូលបង្គំ ខ្ញុំបាទ សូមឆ្លៀតយកឱកាសនេះដើម្បីថ្លែងអំណរគុណចំពោះសមាជិករាជរដ្ឋាភិបាល សហការីនៅក្នុងនិងក្រុមការងាររាជរដ្ឋាភិបាលដែលបានចូលរួមមតិនិងផ្លាស់ប្តូរយោបល់លើសេចក្តីព្រាងច្បាប់ ។ សូមថ្លែងអំណរគុណជាពិសេសចំពោះមន្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាពិសេសលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល ដែលបានជួយការងារនេះក្នុងការចរចានិងការរៀបចំអង្គជំនុំជម្រះវិសាមញ្ញនេះអស់រយៈពេលជាង៥ឆ្នាំ ។*

*ទូលបង្គំ ខ្ញុំបាទ សូមថ្វាយនិងផ្តល់ជូនចំពោះសមាជិករដ្ឋសភាដ៏ខ្ពង់ខ្ពស់នូវកូនសៀវភៅព័ត៌មានមួយដែលរៀបរៀងដោយលេខាធិការដ្ឋានក្រុមការងារ ដូចដែលទូលបង្គំខ្ញុំបាទបានបញ្ជាក់នៅក្នុងសុន្ទរកថារបស់ទូលបង្គំ ខ្ញុំបាទនាព្រឹកមិញនេះ ។ ពេលគឺយើងបានចងក្រងជាកូនសៀវភៅមួយដែលចំណងជើងថា ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ជាភាសាខ្មែរនិងអង់គ្លេសសម្រាប់ធ្វើការផ្សព្វផ្សាយទូទាំងប្រទេស ។ កូនសៀវភៅនេះត្រូវបានសរសេរជាពាក្យសាមញ្ញៗ ហើយអាចឆ្លើយនូវសំណួរនានាស្តីអំពីសារៈតារ គោលបំណង និងរចនាសម្ព័ន្ធរបស់អង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំងជួយលើកទឹកចិត្តឲ្យពលរដ្ឋជួយគាំទ្រនិងចូលរួមយ៉ាងសកម្មក្នុងដំណើរការជំនុំជម្រះក្តីដែលនឹងប្រព្រឹត្តទៅនៅឆ្នាំខាងមុខនេះ ។*

*នៅពេលដែលយើងរំឭកអំពីជំហានប្រវត្តិសាស្ត្រដែលយើងសម្រេចបានក្នុងការបញ្ចប់ដំណើរការផ្នែកច្បាប់នៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនាថ្ងៃនេះ ទូលបង្គំខ្ញុំបាទសូមស្នើសមាជិកសភាមេត្តាជ្រាបថា ឥឡូវនេះជារដូវបុណ្យភ្ជុំបិណ្ឌ គឺជាពេលវេលាដែលជនជាតិខ្មែរយើងទាំងអស់គ្នារំឭក និងធ្វើការគោរពបូជាចំពោះវិញ្ញាណក្ខន្ធក្រុមគ្រួសារនិងមិត្តភក្តិរបស់យើងដែលបានចាកលោកនេះទៅ ។ នៅពេលដែលយើងចាកចេញពីសម័យប្រជុំថ្ងៃនេះ យើងសូមឧទ្ទិសខ្លួនយើងដើម្បីបំពេញកិច្ចការចុងក្រោយដែលប្រវត្តិសាស្ត្របានបន្សល់ទុកឲ្យជំនាន់យើង គឺធ្វើនីតិកម្មនេះឲ្យទៅជាការពិត ។ ហេតុដូច្នោះយើងអាចផ្តល់យុត្តិធម៌ជូនអ្នកទាំងឡាយដែលបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សូមអរគុណ!* **ឯកឧត្តម សុខ អាន**

ទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៩



# ប្រជាជនកម្ពុជាត្រូវការសេចក្តីទុកចិត្ត

ការចាប់បដិសន្ធិនៃរាជរដ្ឋាភិបាលកម្ពុជាថ្មីបានធ្វើឲ្យប្រជាជនកម្ពុជាមានអារម្មណ៍ធូរស្រាលជាខ្លាំង ព្រោះថាកម្ពុជាពិតជាអាចផ្តើមកសាងជាតិឡើងវិញបន្ទាប់ពីរង់ចាំអស់រយៈពេលជិតមួយឆ្នាំកន្លងមកហើយ ។ រាជរដ្ឋាភិបាលកម្ពុជាថ្មីនេះបានផ្តល់សញ្ញាសង្ឃឹមថ្មីមួយដោយឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនភាគច្រើនតាមរយៈការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងបង្កើតតុលាការនិងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ ក៏ប៉ុន្តែ នៅថ្ងៃទី១៩ ខែតុលា សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ បានព្រលយព្រះបន្ទូលដែលអាចធ្វើឲ្យមានការពន្យារពេលបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបន្តទៀត ដោយលើកហេតុផលថា គួរតែយកទឹកប្រាក់ដែលត្រូវចំណាយលើការស្វែងរកយុត្តិធម៌នោះមកប្រើប្រាស់ជួយជនក្រីក្រវិញប្រសើរជាង ។



ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ជាទូទៅយើងដឹងយ៉ាងច្បាស់ថាការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាគឺជាអាទិភាពចម្បង ប៉ុន្តែតាមការពិតទៅ កម្ពុជាត្រូវការចំណាយច្រើនជាងប្រាក់សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចទៅទៀតក្នុងការដោះស្រាយមូលហេតុពិតប្រាកដដែលបណ្តាលឲ្យប្រជាជនកម្ពុជាមួយភាគធំកាន់តែក្រីក្រៗ ទៅពីមួយថ្ងៃទៅមួយថ្ងៃ។ ប្រសិនបើបញ្ហាថវិកាគឺជាឧបសគ្គរាំងស្ទះតែមួយគត់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាមែននោះ មន្ត្រីរាជរដ្ឋាភិបាលកម្ពុជាគួរតែសម្លឹងមើលមកលើខ្លួនឯងជាមុនសិន ។ ការបង្កើតរាជរដ្ឋាភិបាលកម្ពុជាថ្មីដែលមានសមាជិកគណៈរដ្ឋមន្ត្រីច្រើនជាងគេបង្អស់នៅលើពិភពលោក មិនមែនត្រូវចំណាយថវិកាបន្តិចបន្តួចនោះទេ ។ តើរាជរដ្ឋាភិបាលកម្ពុជាថ្មីគួរតែបង្វែរថវិការាប់លានដុល្លារដែលចំណាយលើប្រាក់បៀវត្សរ៍ ការិយាល័យបុគ្គលិក និងចំណាយប្រចាំខែផ្សេងៗ ទៀតរបស់គណៈរដ្ឋមន្ត្រីរបស់ខ្លួន មកជួយដល់ការអភិវឌ្ឍន៍វិស័យកសិកម្មវិញឬយ៉ាងដូចម្តេច?

អ្វីដែលប្រជាជនកម្ពុជាត្រូវការគ្រប់ដង្ហើមចេញចូលប្រហាក់ប្រហែលទៅនឹងប្រាក់ដែរនោះ គឺសេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលរបស់ខ្លួន។ ប្រជាជនកម្ពុជាត្រូវការនូវសេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលថ្មីក្នុងការធានាឲ្យមាននូវការរស់នៅស្មើភាពគ្នា ទទួលបានយុត្តិធម៌និងសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ។ ផលប្រយោជន៍នៃសេចក្តីទុកចិត្តនេះគឺមិនមែនជាអ្វីដែលអាចមើលឃើញនឹងភ្នែកនោះទេ ប៉ុន្តែវានៅតែមានឥទ្ធិពលសំខាន់យ៉ាងខ្លាំងក្នុងសង្គមកម្ពុជា ។ ទីមួយ សេចក្តីទុកចិត្តនោះនឹងអាចជួយឲ្យប្រជាជនកម្ពុជារួចផុតពីអារម្មណ៍ជាជនរងគ្រោះ ។ យើងមានភស្តុតាងគ្រប់គ្រាន់ដែលថាយើងបានរួចរស់ពីសង្គ្រាម យើងបានរួចរស់ពីរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែប្រសិនបើយើងចង់អភិវឌ្ឍសង្គម យើងត្រូវតែបញ្ឈប់ភាពក្លាយជាជនរងគ្រោះត្រឹមនេះ ហើយត្រឡប់មកចូលរួមយ៉ាងសកម្មក្នុងការស្វែងរកអនាគតសម្រាប់កម្ពុជា ។ តាមរយៈការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងការបង្ហាញថាគ្មានជនណាម្នាក់អាចរួចផុតពីអំណាចច្បាប់នោះ រាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់ទំនុកចិត្តដល់ប្រជាជនកម្ពុជាដែលអាចផ្ញើវាសនាលើអ្នកដឹកនាំកម្ពុជាថ្មី ហើយការធ្វើដូច្នេះគឺជាការអនុញ្ញាតឲ្យប្រជាជនចូលរួមក្នុងការអភិវឌ្ឍសង្គមកម្ពុជាទាំងមូល ។

**ឆាំង យុ**

# ទស្សនាវដ្តី ស្វែងរកការពិត




៤៦



៤៧



៤៨




៤៩




៥០




៥១



៥២




៥៣



៥៤




៥៥




៥៦



៥៧

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ពត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 58, October 2004.**
**Funded by Germany, Norway, Sweden, and USA.**